DBD ENGINEERING




# 2022

## របាយការណ៍ប្រចាំឆ្នាំ

# ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

# ទស្សនវិស័យ & បេសកកម្ម

## ទស្សនវិស័យ

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក មានគោលបំណងអភិវឌ្ឍសម្ថតភាពរបស់ថ្នាក់ដឹកនាំរបស់ខ្លួន ដើម្បីបម្រើអតិថិជន ទូទាំងប្រទេសកម្ពុជាក្នុងរយៈពេល ៣ (បី) ឆ្នាំ ខាងមុខនេះ ពិសេសខេត្តព្រះសីហនុ និងខេត្តសៀមរាប។

## បេសកកម្ម

បេសកកម្មរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីជីនារីង ម.ក គឺធ្វើឱ្យកេរ្តិ៍ឈ្មោះរបស់ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិននារីង ម.ក ពោពេញដោយគុណភាព ភាពឥតខ្ចោះ ទំនួលខុសត្រូវខ្ពស់ ភាពឆ្លាតវៃ និងសេវាកម្មបម្រើអតិថិជន ប្រកបដោយការប្រកួតប្រជែង ឱ្យនៅថិតថេរដូចដែលមានតាំងពីឆ្នាំ១៩៩៥ មកម្លេះ។

## តម្លៃស្នូល

យើងជឿជាក់លើក្រុមការងារបច្ចេកទេសរបស់យើង បុគ្គលិកគ្រប់កម្រិតរបស់យើង និងការបេជ្ញាចិត្តរបស់យើង ដើម្បីពង្រីកក្រុមហ៊ុនឱ្យក្លាយជាក្រុមហ៊ុនលំដាប់ពិភពលោក។ ពោលគឺ ក្រុមហ៊ុនរបស់យើងផ្តល់នូវសេវាកម្មជូនអតិថិជនដោយប្រកាន់ភ្ជាប់នូវ៖

- ជំនាញឯកទេសពិតប្រាកដ
- ប្រកបដោយវិជ្ជាជីវៈ
- គុណភាព និងសុវត្ថិភាព



# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

<table>
<tr><th colspan="2">បរិយាយ</th><th>២០២២</th><th>២០២១</th></tr>
<tr><td colspan="2">ស្ថានភាពហិរញ្ញវត្ថុ (ពាន់រៀល)</td><td></td><td></td></tr>
<tr><td colspan="2">ទ្រព្យសកម្មសរុប</td><td>៦០.៧៥១.៧៣១</td><td>៦៦.៥៤០.៧៤៨</td></tr>
<tr><td colspan="2">បំណុលសរុប</td><td>២៩.២៣៦.៣៩០</td><td>២៩.៦៤៩.៨៥១</td></tr>
<tr><td colspan="2">មូលធនសរុប</td><td>៣១.៥១៥.៣៤១</td><td>៣៦.៨៩០.៨៩៧</td></tr>
<tr><td colspan="2">លទ្ធផលហិរញ្ញវត្ថុ</td><td></td><td></td></tr>
<tr><td colspan="2">ចំណូលសរុប</td><td>៥៨.៥១២.៦៩២</td><td>៧៣.០៧៨.៤៨០</td></tr>
<tr><td colspan="2">ចំណេញ/(ខាត) មុនបង់ពន្ធ</td><td>(៤.៨៧២.៣០០)</td><td>២.៤១០.០៣០</td></tr>
<tr><td colspan="2">ចំណេញ/(ខាត) ក្រោយបង់ពន្ធ</td><td>(៤.៨៧២.៣០០)</td><td>១.៦៧៨.៧៩១</td></tr>
<tr><td colspan="2">លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ</td><td>(៤.៥២៤.៩៣៧)</td><td>១.៨៤៥.១០៩</td></tr>
<tr><td colspan="2">អនុបាតហិរញ្ញវត្ថុ</td><td></td><td></td></tr>
<tr><td colspan="2">អនុបាតបំណុលធៀបនឹងមូលធន</td><td>០,២០</td><td>០,៣៧</td></tr>
<tr><td rowspan="2">អនុបាតសន្ទនីយភាព</td><td>អនុបាតចរន្ត</td><td>១,៦៣</td><td>២,១០</td></tr>
<tr><td>អនុបាតចរន្តលឿន</td><td>១,៤៣</td><td>១,៧៧</td></tr>
</table>

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| បរិយាយ | | ២០២២ | ២០២១ |
|---|---|---|---|
| អនុបាតចំណេញភាព | អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម (%) | (៧,៤៥) | ២,៧៧ |
| | អនុបាតចំណេញធៀបនឹងមូលធន (%) | (១៤,៣៦) | ៥,០០ |
| | អនុបាតគម្លាតចំណេញដុល (%) | ៤,៩៨ | ១៤,២២ |
| | អនុបាតគម្លាតចំណេញភាព (%) | (៧,៧៣) | ២,៥២ |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | (២៤៥) រៀល | ១២២ រៀល |
| អនុបាតលទ្ធភាពបង់ការប្រាក់ | | (២,៣៦) | ២,១៧ |

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប

*រៀល






# សមាសភាពក្រុមប្រឹក្សាភិបាល



លោក នាង វិធី
ប្រធានក្រុមប្រឹក្សាភិបាល និងនាយកប្រតិបត្តិ



លោក ថៃ វ៉ាន់ថា
អភិបាលមិនប្រតិបត្តិ



លោកស្រី លឹម មុយលី
អភិបាលប្រតិបត្តិ និងនាយកហិរញ្ញវត្ថុ



លោក **RAMI Bashir Asad Sharaf**
អភិបាលមិនប្រតិបត្តិ



លោក ហ៊ុយ វ៉ាថារ៉ូ
អភិបាលឯករាជ្យ

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល និងនាយកប្រតិបត្តិ



តំណាងឱ្យក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក និងក្រុមប្រឹក្សាភិបាល ខ្ញុំបាទមានសេចក្តីសោមនស្សរីករាយក្នុងការបង្ហាញរបាយការណ៍ប្រចាំឆ្នាំ សម្រាប់ឆ្នាំហិរញ្ញវត្ថុបញ្ចប់ថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០២២ ជូនភាគីពាក់ព័ន្ធទាំងអស់។

សម្រាប់ឆ្នាំ២០២២ ក្រុមហ៊ុនមានប្រាក់ចំណូលសរុប ៥៨.៥១២.៦៩២ ពាន់រៀល ដែល ៥៨.២៨០.៥៥៩ ពាន់រៀលជាចំណូលពីគម្រោងសាងសង់ និងសេវាជួសជុល និង ២៣២.១៣៣ ពាន់រៀល ជាចំណូលពីលក់សម្ភារៈសំណង់។
បើធៀបនឹងឆ្នាំ២០២១ ក្រុមហ៊ុនមានប្រាក់ចំណេញថយចុះ ៣៤៥,២៤% ដែលការខាតស្មើនឹង ៦.៣៧០.០៤៦ ពាន់រៀល។ ទ្រព្យសកម្មសរុបមានការថយចុះចំនួន ៨,៧០ ភាគរយ ដែលថយចំនួនពី ៦៦.៥៤០.៧៤៨ ពាន់រៀល ទៅ ៦០.៧៥១.៧៣១ ពាន់រៀល បើធៀបនឹងឆ្នាំ២០២១ ។

ខ្ញុំសូមថ្លែងអំណរគុណចំពោះក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងបុគ្គលិក សម្រាប់ដំបូន្មានល្អៗ និងការខិតខំប្រឹងប្រែងរបស់អ្នកទាំងអស់គ្នា សម្រាប់ការរីកចម្រើនប្រកបដោយនិរន្តរភាពរបស់ក្រុមហ៊ុន។

ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះនិយ័តករមូលបត្រកម្ពុជា និងភាគហ៊ុន ដែលផ្តល់ទំនុកចិត្តនិងការគាំទ្រដល់ក្រុមហ៊ុន ឌី ប៊ី ឌី។

កាលបរិច្ឆេទ ៣១. មីនា. ២០២៣

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក DBD ENGINEERING Plc. KINGDOM OF CAMBODIA

ប្រធានក្រុមប្រឹក្សាភិបាល និងនាយកប្រតិបត្តិ
លោក នាង វីធី

# មាតិកា


**ទស្សនៈវិស័យ និងបេសកកម្ម** ... i

**ព័ត៌មានហិរញ្ញវត្ថុសង្ខេប** ... ii

**ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប** ... iv

**សមាសភាពក្រុមប្រឹក្សាភិបាល** ... v

**សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល** ... vi

**ផ្នែកទី ១៖ ព័ត៌មានទូទៅពាក់ព័ន្ធនឹងក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក** ... 1

ក-អត្តសញ្ញាណរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ... 1

ខ-លក្ខណៈនៃធុរកិច្ច ... 1

គ-សម្ព័ន្ធភាពក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ... 2

ឃ-ព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ ... 2

ង-ស្ថានភាពទីផ្សារ ... 3

ច-ស្ថានភាពប្រកួតប្រជែង ... 4

ឆ-ផែនការអនាគត ... 4

ជ-កត្តាហានិភ័យ និងវិធានការកាត់បន្ថយ ... 4

**ផ្នែកទី ២៖ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច** ... 10

ក-លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក ... 10

ខ-រចនាសម្ព័ន្ធចំណូល ... 12

**ផ្នែកទី ៣៖ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម** ... 13

**ផ្នែកទី ៤៖ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនិក** ... 16

**ផ្នែកទី ៥៖ របាយការណ៍ហិរញ្ញវត្ថុរបស់សវនកម្មផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង** ... 18

**ផ្នែកទី ៦៖ របាយការណ៍សវនកម្មដែលធ្វើសវនកម្មដោយសវនករឯករាជ្យ** ... 19

**ផ្នែកទី ៧៖ ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ និងទំនាស់ផលប្រយោជន៍** ... 20

**ផ្នែកទី ៨៖ ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង** ... 22

ក-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ... 22

ខ-កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ... 24

គ-ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ... 26

ឃ-ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ... 27

ង-ផលប៉ះពាល់នៃអតិផរណា ... 27

ច-គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល....................27
**ផ្នែកទី ៩៖ ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន** ....................29

**ហត្ថលេខាអភិបាលរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក**

ឧបសម្ព័ន្ធនៃរបាយការណ៍អភិបាលកិច្ចសាជីវកម្មប្រចាំឆ្នាំ

## ផ្នែកទី ១៖ ព័ត៌មានទូទៅពាក់ព័ន្ធនឹងក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក

## ក-អត្តសញ្ញាណរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | **ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក** ( ឌី ប៊ី ឌី ) |
| ជាអក្សរឡាតាំង | DBD Engineering Plc. |
| អក្សរកូដ | KH១០០០១៥០០០៨ |
| ទីស្នាក់ការ | ដីឡូតិ៍ ៦៨ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរសព្ទ | (+៨៥៥) ៧៨ ៧០០ ៥៩៨ |
| គេហទំព័រ | www.dbdengineering.com |
| អ៊ីម៉ែល | services@dbdengineering.com |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០៩០២៩ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៩៨ |
| សេចក្ដីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្ដល់ព័ត៌មាន | ១២៣/២១ ស.ស.រ/ន.ម.ក. ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ |
| ឈ្មោះបុគ្គលក្រុមហ៊ុន | លោក **នាង រីធី** |

## ខ-លក្ខណៈនៃធុរកិច្ច

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៥ ជាក្រុមហ៊ុនពហុមុខងារ ផ្នែកវិស្វកម្ម និងសំណង់ ដែលមានបទពិសោធន៍ជាច្រើនឆ្នាំក្នុងព្រះរាជាណាចក្រកម្ពុជា។ ឌី ប៊ី ឌី ផ្ដល់សេវាកម្មដូចជា សេវាគូសប្លង់ សាងសង់ ដំឡើង និងថែទាំ ដែលសេវាកម្មទាំងនេះធ្វើឱ្យក្រុមហ៊ុនទទួលកេរ្តិ៍ឈ្មោះលំដាប់ជាតិ និងអន្តរជាតិ។ ឌី ប៊ី ឌី ទទួលបានកំណត់ត្រាល្អក្នុងការផ្ដល់សេវាកម្ម និងផ្គត់ផ្គង់ផលិតផលប្រកបដោយគុណភាពខ្ពស់ដែលស្តែងបញ្ជាក់តាមរយៈការពេញចិត្ត និងការសរសើរពីសំណាក់អតិថិជនរបស់ខ្លួន។

អគ្គិសនី និងសំណង់



មេកានិច និងអគ្គិសនី



ការចុះត្រួតពិនិត្យ និងថែទាំអគារ



កម្តៅ ខ្យល់ចេញចូល និងប្រព័ន្ធម៉ាស៊ីនត្រជាក់



ក្រុមហ៊ុន ឌី ប៊ី ឌី មានបុគ្គលិកជំនាញផ្នែកសេវាកម្ម និងការថែទាំ ដើម្បីធានា និងរក្សាគុណភាពជាប់រឹងមាំរបស់សំណង់អគារ និងការបំពាក់ឧបករណ៍ថ្មី ហើយបច្ចុប្បន្ននេះ ក្រុមហ៊ុន ឌី ប៊ី ឌី បាននឹងកំពុងពង្រីកអាជីវកម្មផ្នែកផលិតកម្មលើប្រព័ន្ធបំពង់ គ្រឿងចក្រ ការថែរក្សារោងចក្រ និងឧបករណ៍។

**គ-សម្ព័ន្ធភាពរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក.**

គិតត្រឹមឆ្នាំ២០២២ នេះ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក. ពុំមានសម្ព័ន្ធភាពជាមួយក្រុមហ៊ុនបុត្រសម្ព័ន្ធ បុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនហូលឌីង ឬក្រុមហ៊ុនពាក់ព័ន្ធដទៃទៀតទេ។

**ឃ-ព្រឹត្តិការណ៍សំខាន់ៗរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក.**




ពិធីបញ្ចុះបឋមសិលា ស្នាក់ការកណ្តាលថ្មី ដែលមានគ្រោងទឹកប្រាក់ ២,៥ លានដុល្លារ កាលពីខែកុម្ភៈ ឆ្នាំ២០២២




ទទួលបានពានរង្វាន់ **"ផ្នែកមូលបត្រកម្មសិទ្ធិដែលលក់ដាច់បំផុត"** កាលពីខែមីនា ឆ្នាំ២០២២



ទទួលបានពានរង្វាន់ "**ភាគហ៊ុនពេញនិយមជាងគេនៅទីផ្សារកំណើន**" កាលពីខែឧសភា ឆ្នាំ២០២២




កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកលើកទី ១ កាលពីខែឧសភា ឆ្នាំ២០២២



វគ្គបណ្តុះបណ្តាលវិនិយោគិន កាលពីខែសីហា ឆ្នាំ ២០២២

**ង-ស្ថានភាពទីផ្សារ**

យោងតាមរបាយការណ៍ប្រចាំឆ្នាំ២០២២ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានបង្ហាញថាគម្រោងទូទាំងប្រទេសមានចំនួន ៤.២៧៦ គម្រោង ដែលមានផ្ទៃដីសាងសង់សរុបស្មើនឹង ៧.២៨៩.៧៦៥ ម៉ែត្រការ៉េ និងមានទុនវិនិយោគចំនួនប្រមាណ ២.៩៧២.២៦០.៩២៨ ដុល្លារអាមេរិក ដែលបានថយចុះចំនួន ៤៤,២៧ ភាគរយធៀបនឹងឆ្នាំ២០២១ ដែលមានគម្រោងចំនួន ៤.៣០៣ គម្រោង ស្មើនឹងផ្ទៃដីសាងសង់សរុបចំនួន ១២.៩៩៨.០៧២ ម៉ែត្រការ៉េ និងមានទុនវិនិយោគចំនួនប្រមាណ ៥.៣៣៣.៧៩៨.៥២៥ ដុល្លារអាមេរិក។

ក្រុមហ៊ុន ឌី ប៊ី ឌី គឺជាក្រុមហ៊ុនសំណង់ឈានមុខគេមួយនៅក្នុងប្រទេសកម្ពុជា ជាពិសេសការផ្តល់សេវាកម្ម MEP ដែលមានដូចជា (១)ផ្នែកមេកានិច និងអគ្គិសនី (២)ប្រព័ន្ធទឹក និងពន្លត់អគ្គិភ័យ, (៣) កំដៅ, ខ្យល់ចេញចូល និងប្រព័ន្ធម៉ាស៊ីនត្រជាក់ (៤) ការសាងសង់ និង (៥) ការថែទាំអគារ។ ទាំងនេះ គឺជាឱកាសសម្រាប់ក្រុមហ៊ុន ឌី ប៊ី ឌី នៅក្នុងទីផ្សារកំណើននេះ។

**ច-ស្ថានភាពប្រកួតប្រជែង**

ក្រុមហ៊ុន ឌី ប៊ី ឌី មានកេរ្តិ៍ឈ្មោះល្បីដ៏យូរអង្វែង និងបណ្តាញទំនាក់ទំនងអាជីវកម្មជាច្រើន ដែលជាហេតុធ្វើឱ្យក្រុមហ៊ុន ឌី ប៊ី ឌី ឈានមុខគេលើវិស័យសំណង់នាបច្ចុប្បន្ននេះ។ ក្រុមហ៊ុនមានចំណុចខ្លាំង និងគុណសម្បត្តិប្រកួតប្រជែងសំខាន់ៗមួយចំនួនដូច ខាងក្រោម ដើម្បីទ្រទ្រង់អាជីវកម្ម ក៏ដូចជាគាំទ្រដល់ការរីកចម្រើនរហូតមក៖

១.ការគ្រប់គ្រងកិច្ចសន្យាប្រកបដោយជំនាញ និងជំនាញក្នុងការដោះស្រាយបញ្ហាហិរញ្ញវត្ថុកិច្ចសន្យាសាងសង់រួមទាំងតម្លៃប្រកួតប្រជែង

២.ការបញ្ចប់គម្រោងទាន់ពេលវេលា ដោយក្រុមដឹកនាំជាន់ខ្ពស់ និងវិស្វករដែលមានបទពិសោធន៍យូរឆ្នាំ និងមានការយកចិត្តទុកដាក់ខ្ពស់

៣.រៀបចំឱ្យមានការត្រួតពិនិត្យគុណភាព សុវត្ថិភាព និងបរិស្ថានដ៏តឹងរ៉ឹង និង

៤.បង្កើនទំនាក់ទំនងជាមួយអតិថិជនជានិច្ច។

**ឆ-ផែនការអនាគត**

ក្រុមហ៊ុនមានគោលបំណងរក្សាឲ្យទីផ្សារឈានមុខគេផ្នែកការងារ MEP និងបង្កើនការលក់ និងការរួមចំណែកទីផ្សារដោយរក្សានូវកេរ្តិ៍ឈ្មោះដ៏ល្អរបស់ខ្លួនតាមរយៈយុទ្ធសាស្ត្រដូចខាងក្រោម៖

-បង្កើនការរួមចំណែកទីផ្សារដែលផ្តោតទៅលើ គម្រោងការងារ MEP នាបច្ចុប្បន្ន។

-ធ្វើការពង្រឹងសេវាកម្មស្នូលដែលមានស្រាប់របស់ក្រុមហ៊ុន MEP & Civil Engineering ជាបន្តបន្ទាប់ និងពង្រីកខ្សែសង្វាក់ផលិតកម្មផ្នែកប្រព័ន្ធ Ducting ដោយការប្រើប្រាស់ផ្ទាល់រហូតដល់រោងចក្រដែលនឹងអាចផ្គត់ផ្គង់ដល់អ្នកម៉ៅការផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា។

-ធ្វើឱ្យប្រសើរឡើងវិញនូវភាពមើលឃើញសេវាកម្ម និងភាពជឿជាក់របស់ក្រុមហ៊ុនក្នុងចំណោមសាធារណជនដោយធ្វើការបោះផ្សាយមូលបត្រកម្មសិទ្ធិជាលើកដំបូង (IPO) ព្រមទាំងបង្កើនការផ្សព្វផ្សាយបន្ថែមទៀតលើទីផ្សារសម្រាប់ការរីកចម្រើនរយៈពេលវែងរបស់ក្រុមហ៊ុន។

ជារួម ក្រុមហ៊ុន ឌី ប៊ី ឌី នឹងរក្សាកេរ្តិ៍ឈ្មោះរបស់ខ្លួនដែលអនុញ្ញាតឱ្យមានការរីកចម្រើនអាជីវកម្ម ដោយផ្តោតលើអ្វីដែលបានធ្វើឱ្យវាទទួលបានជោគជ័យរហូតមកដល់បច្ចុប្បន្ន បញ្ចប់គម្រោងជូនអតិថិជនទាន់ពេលវេលាប្រកបដោយគុណភាពខ្ពស់ក្នុងតម្លៃប្រកួតប្រជែង ជាមួយនឹងសេវាកម្មដ៏ល្អឥតខ្ចោះ។

**ជ-កត្តាហានិភ័យ**

**-ហានិភ័យនៃការប៉ាន់ស្មានតម្លៃទាប**

គម្រោងភាគច្រើនក្រុមហ៊ុន ឌី ប៊ី ឌី ដែលទទួល ត្រូវបានណែនាំតាមរយៈអតិថិជនរបស់ក្រុមហ៊ុន ឌី ប៊ី ឌី ឬតាមរយៈការចូលរួមដេញថ្លៃ។ ហានិភ័យដែលនឹងអាចកើតមាននៅពេលដែលក្រុមហ៊ុន ឌី ប៊ី ឌី ប៉ាន់ស្មានតម្លៃទាប នៅពេលដេញថ្លៃគម្រោង ដោយសារការប៉ាន់ស្មានតម្លៃទាបពេក លើតម្លៃសម្ភារៈ ឬកម្លាំងពលកម្ម។ មានកត្តាជាច្រើនដែល

អាចនាំឱ្យមានការប៉ាន់ប្រមាណតម្លៃទាប រួមមានកំហុសក្នុងគំនូសព្រាង ភាពខុសគ្នានៃលក្ខណៈបច្ចេកទេស ការប្រែប្រួលតម្លៃសម្ភារៈនៅលើទីផ្សារ។ ការប៉ាន់ស្មានតម្លៃទាបជាងតម្លៃជាក់ស្តែងនៃគម្រោងអាចមានផលប៉ះពាល់អវិជ្ជមានដល់ប្រាក់ចំណេញ។

**វិធានការកាត់បន្ថយ៖** ក្រុមហ៊ុនបានបង្កើតស្តង់ដារ និងគោលការណ៍ណែនាំយ៉ាងក្បោះក្បាយសម្រាប់រាល់ការដេញថ្លៃគម្រោងដែលរួមមាន ៣ ដំណាក់កាល៖ (១).ការស្ទង់មតិដែលដឹកនាំដោយក្រុមអ្នកស្ទង់មតិ (២).ការប៉ាន់ប្រមាណតម្លៃទៅលើគម្រោង និង (៣).សុពលភាពដែលត្រូវបានត្រួតពិនិត្យដោយអ្នកដេញថ្លៃដែលទទួលបានការអនុញ្ញាត។ ដំណើរការត្រួតពិនិត្យការដេញថ្លៃ ត្រូវបានធ្វើឡើងដោយអ្នកជំនាញរបស់ក្រុមហ៊ុនក្នុងនោះរួមមានក្រុមអ្នកជំនាញផ្នែកច្បាប់ និងអ្នកជំនាញបច្ចេកទេសដែលត្រួតពិនិត្យឡើងវិញនូវគំនូសព្រាង និងលក្ខណៈបច្ចេកទេសព្រមទាំងធ្វើការត្រួតពិនិត្យការអនុវត្តទៅនឹងការដ្ឋាននៃគម្រោងនីមួយៗ។

***-ហានិភ័យនៃកង្វះខាតសម្ភារៈ និងការប្រែប្រួលតម្លៃ***

ក្រុមហ៊ុន ឌី ប៊ី ឌី ពឹងផ្អែកយ៉ាងខ្លាំងលើការផ្គត់ផ្គង់ និងទំនិញដែលបញ្ជាទិញពីទីផ្សារក្រៅប្រទេស ដោយសារកង្វះខាត នៅក្នុងប្រទេសកម្ពុជា។ ជាធម្មតា តម្លៃទំនិញទាំងនោះ មានការប្រែប្រួលប្រហែលពី ៣ ភាគរយ និង ៥ ភាគរយក្នុងមួយឆ្នាំ។ តម្លៃ និងវត្តមានរបស់ទំនិញជារួម អាចរងផលប៉ះពាល់បណ្តាលមកពីកត្តាជាច្រើន ដូចជាតម្រូវការទីផ្សារ និងស្ថានភាពសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក ការប្រែប្រួលអាកាសធាតុ តម្លៃប្រេងឥន្ធនៈ និងស្ថានភាពនយោបាយជាដើម។ ដោយសារលក្ខណៈនៃអាជីវកម្មរបស់ខ្លួន ក្រុមហ៊ុន ឌី ប៊ី ឌី ត្រូវបានតម្រូវឱ្យដាក់ឯកសារដេញថ្លៃលើគម្រោងនានា និងចុះកិច្ចសន្យាលើតម្លៃដេញថ្លៃ។ ក្រុមហ៊ុន ឌី ប៊ី ឌី ដាក់តម្លៃដេញថ្លៃគម្រោងដោយផ្អែកលើការប៉ាន់ស្មានដ៏ល្អបំផុតរបស់ខ្លួន រួមបញ្ចូលទាំងការប៉ាន់ស្មានថ្លៃដើមនៃការផ្គត់ផ្គង់។ ប្រសិនបើ ថ្លៃដើមនៃការផ្គត់ផ្គង់កើន ឡើងបន្ទាប់ពីការដេញថ្លៃត្រូវបានទទួលយក ក្រុមហ៊ុន ឌី ប៊ី ឌី មិនអាចស្នើថ្លៃដើមបន្ថែមទៅអតិថិជនបានទេ ហើយក្រុមហ៊ុនអាចនឹងគ្មានជម្រើសណាមួយក្រៅពីទិញទំនិញនៅក្នុងតម្លៃថ្លៃ ដែលជាហេតុនាំឱ្យប្រាក់ចំណេញធ្លាក់ចុះ។ ហានិភ័យក៏អាចកើតមានផងដែរ នៅពេលដែលការផ្គត់ផ្គង់ចាំបាច់សម្រាប់គម្រោងត្រូវពន្យារពេល ឬមិនមានជាបណ្តោះអាសន្នដែលបណ្តាលឱ្យរយៈពេលបញ្ចប់គម្រោងត្រូវបានពន្យារពេល និងថ្លៃដើមគម្រោងកើនឡើង។ រាល់ការកើនឡើងនៃថ្លៃដើមផ្គត់ផ្គង់ ឬការពន្យារពេលក្នុងការទទួលការផ្គត់ផ្គង់ អាចជះឥទ្ធិពលអវិជ្ជមានដល់អាជីវកម្ម និងផលចំណេញរបស់ក្រុមហ៊ុន។

**វិធានការកាត់បន្ថយ៖** ក្រុមហ៊ុន ឌី ប៊ី ឌី រក្សាទំនាក់ទំនងយ៉ាងល្អជាមួយអ្នកផ្គត់ផ្គង់នានា និងមាននីតិវិធីដើម្បីកាត់បន្ថយហានិភ័យទាក់ទងនឹងការប្រែប្រួលនៃតម្លៃទំនិញ។ នីតិវិធីសំខាន់ គឺជាការចរចារតម្លៃជាមុននឹងអ្នកផ្គត់ផ្គង់ ដូច្នេះតម្លៃទំនិញត្រូវបានកំណត់ក្នុងអំឡុងពេលនៃគម្រោង។ ជាផ្នែកមួយនៃការចរចារ ក្រុមហ៊ុន ឌី ប៊ី ឌី បានរួមបញ្ចូលតម្រូវការផ្គត់ផ្គង់នៃគម្រោងដែលកំពុងដំណើការរបស់ខ្លួនភាគច្រើន ដើម្បីទទួលបានការបញ្ចុះតម្លៃយ៉ាងច្រើន និងបន្ថែមចំណុចខ្លាំងលើការចរចាររបស់ខ្លួន។ លើសពីនេះទៀត ក្រុមហ៊ុន ឌី ប៊ី ឌី ព្យាយាមរកការផ្គត់ផ្គង់ចាំបាច់បំផុតមុនពេលចាប់ផ្តើមគម្រោង ដើម្បីកាត់បន្ថយទាំងការប្រែប្រួលតម្លៃ និងហានិភ័យនៃការពន្យារពេលផ្គត់ផ្គង់។ ទោះបីជា ក្រុមហ៊ុន ឌី ប៊ី ឌី ត្រូវបានចុះកិច្ចសន្យាក្នុងតម្លៃជាមួយរយៈពេលសម្រាប់គម្រោងដែលបានដេញថ្លៃក៏ដោយ ក៏ក្រុមហ៊ុន ឌី ប៊ី ឌី អាចចរចារឡើងវិញជាមួយម្ចាស់គម្រោងទៅលើពេលវេលា និងតម្លៃថ្មី បើសិនមានព្រឹត្តិការណ៍ទីផ្សារណាមួយកើតមានឡើង ដែលហួសពីដែនគ្រប់គ្រងរបស់ក្រុមហ៊ុន ឌី ប៊ី ឌី។

***-ហានិភ័យនៃអវត្តមានការងារ***

យោងតាមក្រុមហ៊ុន ឌី ប៊ី ឌី អត្រាអវត្តមានការងារក្នុងវិស័យនេះ គឺប្រហែលពី ១០ ភាគរយ ទៅ ១៥ ភាគរយជារៀងរាល់ថ្ងៃ ហើយអត្រាលាឈប់ពីការងារក្នុងវិស័យគឺប្រហែល ១៥ ភាគរយ ទៅ ២០ ភាគរយ ជារៀងរាល់ឆ្នាំ។

កង្វះកម្លាំងពលកម្ម អាចបង្កឱ្យមានការពន្យារពេលនៃគម្រោង។ កង្វះកម្លាំងពលកម្ម អាចធ្វើឱ្យការចំណាយមិនមានប្រសិទ្ធិភាព នាំឱ្យថ្លៃដើមកើនឡើង និងប្រាក់ចំណេញថយចុះ។

**វិធានការកាត់បន្ថយ៖** ខណៈពេលដែលក្រុមហ៊ុន ឌី ប៊ី ឌី មិនអាចគ្រប់គ្រងអវត្តមានការងារមួយចំនួនបាន ក្រុមហ៊ុន ឌី ប៊ី ឌី ប្រើបច្ចេកទេសវិទ្យាស្កេនម្រាមដៃដើម្បីធានាថាក្រុមហ៊ុនចំណាយលើតែកម្មករនិយោជិកដែលមាន វត្តមានពិតប្រាកដ។ កត្តានេះក៏អនុញ្ញាតឱ្យក្រុមហ៊ុន ឌី ប៊ី ឌី អាចត្រួតពិនិត្យពេលវេលាជាក់ស្តែងនៅលើទីតាំងគម្រោងនៅមួយៗ។ ប្រសិនបើកម្មករអវត្តមាន ក្រុមហ៊ុន ឌី ប៊ី ឌី មានក្រុមការងារត្រួតពិនិត្យ ដើម្បីកំណត់ពីមូលហេតុ នៃអវត្តមាន និងកាលបរិច្ឆេទដែលត្រូវត្រលប់មកធ្វើការវិញ។ ក្រុមហ៊ុន ឌី ប៊ី ឌី ព្យាយាមរក្សាកម្មករ និយោជិក ដោយតែងតែបើកប្រាក់ខែឱ្យទាន់ពេលវេលា និងធានាថាកម្មករនយោជិក ពេញចិត្តនឹងលក្ខខណ្ឌការងារដើម្បីកាត់បន្ថយ អត្រាលាឈប់។ ទោះបីជា ក្រុមហ៊ុន ឌី ប៊ី ឌី ចាត់វិធានការសមស្រប ដើម្បីកាត់បន្ថយអវត្តមាន និងអត្រាលាឈប់ពីការងារ នៅតែជាការគម្រាមកំហែងតិចតួច ដែលអាចព្យាករណ៍បានចំពោះប្រតិបត្តិការ និងផលចំណេញរបស់ក្រុមហ៊ុន ឌី ប៊ី ឌី។

**-ហានិភ័យពីការប្រកួតប្រជែង**

ដោយសារវិស័យសំណង់រឹងមាំ និងមានការរីកចម្រើន ចំនួនក្រុមហ៊ុនសំណង់ទាំងបរទេស និងក្នុងស្រុកមានការកើនឡើងយ៉ាងឆាប់រហ័ស។ ក្រុមហ៊ុន ឌី ប៊ី ឌី កំពុងប្រឈមមុខនឹងការប្រកួតប្រជែងកាន់តែខ្លាំងឡើងនៅក្នុងដំណើរការដេញថ្លៃសម្រាប់គម្រោងរបស់ខ្លួន។ ដៃគូប្រកួតប្រជែងនានាមានដើមទុនច្រើន កំពុងបញ្ចុះតម្លៃក្នុងការដេញថ្លៃដើម្បីទទួលបានចំណែកទីផ្សារ។ កត្តានេះហើយធ្វើឱ្យ ក្រុមហ៊ុន ឌី ប៊ី ឌី ត្រូវបង្ខំចិត្តបញ្ចុះតម្លៃក្នុងការដេញថ្លៃដើម្បីទទួលបានគម្រោង។ បរិយាកាសប្រកួតប្រជែងនៅក្នុងវិស័យសំណង់កម្ពុជា អាចជះឥទ្ធិពលមិនល្អលើប្រាក់ចំណេញរបស់ក្រុមហ៊ុន ដោយសារហានិភ័យនៃការបាត់បង់ការដេញថ្លៃ ឬការកាត់បន្ថយប្រាក់ចំណេញលើគម្រោងដែលក្រុមហ៊ុន ឌី ប៊ី ឌី ត្រូវបញ្ចុះតម្លៃក្នុងការដេញថ្លៃ។

**វិធានការកាត់បន្ថយ៖** ដោយសារតែបទពិសោធន៍ដ៏ទូលំទូលាយក្នុងវិស័យសំណង់កម្ពុជា ក្រុមហ៊ុន ឌី ប៊ី ឌី អាចជ្រើសរើសគម្រោងដើម្បីដេញថ្លៃស្របតាមជំនាញរបស់ក្រុមហ៊ុន។ កត្តានេះ អនុញ្ញាតឱ្យក្រុមហ៊ុន ឌី ប៊ី ឌី គ្រប់គ្រងថ្លៃដើមគម្រោង និងដាក់តម្លៃដេញថ្លៃសមរម្យដើម្បីឱ្យក្រុមហ៊ុននៅតែទទួលបានផលចំណេញ។ លើសពីនេះទៅទៀត កេរ្តិ៍ឈ្មោះដ៏រឹងមាំ និងបទពិសោធន៍ជាង ២៥ ឆ្នាំ ជួយឱ្យក្រុមហ៊ុន ឌី ប៊ី ឌី ឈ្នះការដេញថ្លៃគម្រោង ទោះបីជាការដេញថ្លៃ មិនទាបពេកជាងក្រុមហ៊ុនដទៃក៏ដោយ។

**-ហានិភ័យទាក់ទងនឹងអាកាសធាតុ**

ប្រទេសកម្ពុជាស្ថិតក្នុងរដូវវស្សាចាប់ពីខែឧសភា រហូតដល់ខែតុលាជារៀងរាល់ឆ្នាំ។ ក្នុងអំឡុងពេលមានភ្លៀងខ្លាំង អាចបង្កជាទឹកជំនន់ ដែលភាគច្រើនជះឥទ្ធិពលដល់ការដឹកជញ្ជូនឧបករណ៍ និងសម្ភារៈផ្គត់ផ្គង់ ប៉ុន្តែក៏អាចបង្ករការជន់លិច និងពន្យារពេលនៅតាមគម្រោងនីមួយៗផងដែរ។ ទឹកជំនន់ប្រភេទណា ក៏អាចបង្កឱ្យមានការពន្យារពេលនៃការបញ្ចប់គម្រោងដែលនាំឱ្យការចំណាយកើនឡើង និងប្រាក់ចំណេញថយចុះ។

**វិធានការកាត់បន្ថយ៖** ក្រុមហ៊ុន ឌី ប៊ី ឌី ព្យាយាមសម្របពេលគម្រោងសាងសង់ ឱ្យទាន់រដូវប្រាំងនៅប្រទេសកម្ពុជា។ ផែនការគម្រោង ត្រូវបានគ្រោងទុកយ៉ាងល្អ ដើម្បីការពារទឹកជំនន់ដែលអាចកើតមានក្នុងរដូវវស្សា។ ទោះបីជាមានការរៀបចំផែនការជាក់លាក់ក៏ដោយរាល់សកម្មភាពទាំងអស់ មិនតែងតែអាចធ្វើឡើងស្របតាមអាកាសធាតុដែលបានរំពឹងទុកនោះទេ។ ដូច្នេះ ការពន្យាពេលខ្លះដោយសារកត្តាអាកាសធាតុ និងទឹកជំនន់ គឺមិនអាចជៀសវាងបានទាំងស្រុង ហើយអាចជះឥទ្ធិពលអវិជ្ជមានដល់ប្រសិទ្ធិភាពប្រតិបត្តិការ និងផលចំណេញ។

**-ហានិភ័យគ្រោះថ្នាក់**

ហានិភ័យគ្រោះថ្នាក់ គឺមានអត្រាខ្ពស់ក្នុងវិស័យសំណង់។ កម្មករនយោជិក តម្រូវឱ្យធ្វើការជាមួយឧបករណ៍ធុនធ្ងន់ កម្ពស់ខ្ពស់ លក្ខខណ្ឌទីតាំងពិបាក និងសម្ភារៈគ្រោះថ្នាក់។ កង្វះបទប្បញ្ញត្តិតឹងរឹងក្នុងប្រទេសកម្ពុជា មានន័យថា

ភាគច្រើននៃកម្មករនយោជិក នៅការដ្ឋាន មិនទទួលបានការអប់រំនៃហានិភ័យផ្សេងៗ និងវិធានការដើម្បីការពារឱ្យបានត្រឹមត្រូវ។ លើសពីនេះទៅទៀត កង្វះខាតកម្លាំងពលកម្មជំនាញ មានន័យថាកម្មករនយោជិកជារឿយៗ ខ្វះបទពិសោធន៍គ្រប់គ្រាន់ក្នុងការធ្វើការឱ្យបានត្រឹមត្រូវជាមួយគ្រឿងម៉ាស៊ីនធុនធ្ងន់ សម្ភារៈគ្រោះថ្នាក់ និងលក្ខខណ្ឌភូមិសាស្ត្រនៅការដ្ឋានមិនអំណោយផល។ សូម្បីតែនៅក្នុងលក្ខខណ្ឌល្អបំផុតយ៉ាងណាក៏ដោយ ក៏វិស័យសំណង់ នៅតែមានហានិភ័យគ្រោះថ្នាក់ខ្ពស់ បើធៀបនឹងវិស័យដទៃទៀត។ នៅប្រទេសកម្ពុជា គ្រោះថ្នាក់នៅនឹងកន្លែងសាងសង់ កើតមានឡើងជាប្រចាំ។ គ្រោះថ្នាក់អាចជះឥទ្ធិពលអវិជ្ជមានដល់ប្រតិបត្តិការរយៈពេលគម្រោង និងផលចំណេញរបស់ក្រុមហ៊ុន។

**វិធានការកាត់បន្ថយ៖** ក្រុមហ៊ុន ឌី ប៊ី ឌី ធ្វើការត្រួតពិនិត្យទីតាំង ដើម្បីធានាបាននូវលក្ខខណ្ឌល្អ ក្នុងការកាត់បន្ថយគ្រោះថ្នាក់។ ក្រុមហ៊ុនក៏បានបណ្តុះបណ្តាលបុគ្គលិករបស់ខ្លួន អំពីការអនុវត្តល្អ និងបទប្បញ្ញត្តិសុវត្ថិភាព។ម្យ៉ាងវិញទៀត ក្រុមហ៊ុន ឌី ប៊ី ឌី ព្យាយាមគោរពតាមស្តង់ដារអន្តរជាតិ ISO នៃសុខភាព និងសុវត្ថិភាព ហើយកំពុងស្ថិតក្នុងដំណើរការដាក់ពាក្យសុំវិញ្ញាបនបត្រ។ ក្រុមហ៊ុន ឌី ប៊ី ឌី បានទទួលវិញ្ញាបនបត្រសុវត្ថិភាពជាច្រើន ពីអតិថិជនបន្ទាប់ពីគម្រោងបានបញ្ចប់។

**-ហានិភ័យនៃកង្វះខាតណាមួយក្នុងគម្រោង**

នៅពេលដែលគម្រោងសាងសង់ត្រូវបានបញ្ចប់ ក្រុមហ៊ុន ឌី ប៊ី ឌី ទទួលខុសត្រូវក្នុងការកែតម្រូវកង្វះខាតណាមួយក្នុងគម្រោង ក្នុងរយៈពេល ១២ ខែ។ ទោះបីជាក្រុមហ៊ុន ប្រើជំនាញ និងបទពិសោធន៍របស់ខ្លួន ដើម្បីបញ្ចប់គម្រោងប្រកបដោយគុណភាពខ្ពស់ កង្វះខាត គឺជាផ្នែកមួយដែលអាចកើតមានក្នុងអាជីវកម្ម។ ទំនួលខុសត្រូវក្នុងការកែតម្រូវកង្វះខាតណាមួយ អាចនាំឱ្យមានការចំណាយដែលមិនបានគ្រោងទុកជាមុន និងអាចជះឥទ្ធិពលអវិជ្ជមានដល់លំហូរសាច់ប្រាក់ កេរ្តិ៍ឈ្មោះ និងប្រាក់ចំណេញរបស់ក្រុមហ៊ុន។

**វិធានការកាត់បន្ថយ៖**ក្រុមហ៊ុន ឌី ប៊ី ឌី រក្សាកម្លាំងពលកម្ម រួមទាំងវិស្វករដែលពោរពេញដោយបទពិសោធន៍ខ្ពស់ អ្នកសាងសង់ និងអ្នកគ្រប់គ្រងគម្រោង។ កម្លាំងពលកម្មប្រកបដោយជំនាញរបស់ក្រុមហ៊ុន ឌី ប៊ី ឌី មានន័យថាកង្វះខាតដែលនឹងកើតឡើង អាចនឹងមានភាគរយតិច។ ទោះជាកង្វះខាត មិនអាចត្រូវបានជៀសវាងទាំងស្រុងក៏ដោយ ក្រុមហ៊ុន ឌី ប៊ី ឌី ជឿជាក់ថាកង្វះខាតចម្បងៗដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់អាជីវកម្ម ឬទីតាំងហិរញ្ញវត្ថុ របស់ក្រុមហ៊ុន នៅមានកម្រិតទាប។

**-ហានិភ័យនៃការពន្យារពេលនៃគម្រោងសាងសង់**

ការពន្យារពេលនៃគម្រោង អាចកើតឡើងដោយសារតែបញ្ហាម្ចាស់គម្រោង ឬក្រុមហ៊ុន ឌី ប៊ី ឌី។ មូលហេតុនៃការពន្យារពេលពីម្ចាស់គម្រោង រួមមាន ការផ្លាស់ប្តូរផែនការសាងសង់ និងតម្លើង ឬកង្វះដើមទុនជាដើម។ ប្រសិនបើការពន្យាពេល បណ្តាលមកពីម្ចាស់គម្រោង ក្រុមហ៊ុន ឌី ប៊ី ឌី ប្រឈមនឹងហានិភ័យនៃការចំណាយបន្ថែម ដូចជាថ្លៃដើមពលកម្ម ថ្លៃដើមទឹកភ្លើងជាដើម។ ប្រសិនបលការពន្យារពេលបណ្តាលមកពី ក្រុមហ៊ុន ឌី ប៊ី ឌី នោះក្រុមហ៊ុនប្រឈមនឹងការផាកពិន័យពីម្ចាស់គម្រោង។

**វិធានការកាត់បន្ថយ៖** ផលប៉ះពាល់អវិជ្ជមាននៃការពន្យារពេលដែលបណ្តាលមកពីម្ចាស់គម្រោង អាចត្រូវបានបន្ថយតាមរយៈការកាត់បន្ថយថ្លៃពលកម្ម ដែលការកាត់បន្ថយនេះ មិនដល់ការងារបច្ចុប្បន្ន។ ចំណែកឬការពន្យារពេលដែលបណ្តាលមកពី ក្រុមហ៊ុន ឌី ប៊ី ឌី គឺមិនកើតមានញឹកញាប់នោះទេ ព្រោះក្រុមហ៊ុន ឌី ប៊ី ឌី ពឹងផ្អែកលើអ្នកគ្រប់គ្រងគម្រោងដែលមានបទពិសោធន៍ក្នុងការគ្រប់គ្រងបុគ្គលិក និងអ្នកម៉ៅការបន្ត ដើម្បីសម្រេចគម្រោងឱ្យបានទាន់ពេលវេលា។ អ្នកគ្រប់គ្រងគម្រោង ត្រួតពិនិត្យគម្រោងនីមួយៗ និងធ្វើរបាយការណ៍ប្រចាំខែដាក់ជូនថ្នាក់លើ ដោយកំណត់បញ្ហាចម្បង រួមនឹងការធ្វើផែនការ និងសកម្មភាពត្រឹមត្រូវ។

**-ហានិភ័យនៃការបាត់បង់បុគ្គលិកសំខាន់ៗ**

ដើម្បីរក្សាបាននូវគុណភាព ប្រសិទ្ធិភាព និងកេរ្តិ៍ឈ្មោះល្អ ក្រុមហ៊ុន ឌី ប៊ី ឌី ពឹងផ្អែកលើជំនាញរបស់បុគ្គលិក ជាពិសេស វិស្វករ អ្នកគ្រប់គ្រងគម្រោង និងអ្នកគ្រប់គ្រងការដ្ឋាន។ បុគ្គលិកជំនាញក្នុងមុខតំណែងទាំងនេះ នៅមានកម្រិតណាស់នៅក្នុងប្រទេសកម្ពុជា ដូច្នេះវាជាកត្តាសំខាន់ដែលក្រុមហ៊ុន ឌី ប៊ី ឌី អាចរក្សាបាននូវបុគ្គលិកទាំងនេះ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារលក្ខណៈប្រកួតប្រជែងនៃវិស័យសំណង់ក្នុងប្រទេសកម្ពុជា ហានិភ័យនៃការកង្វះខាត គឺជាការគម្រាមកំហែងឥតឈប់ឈរ។ ការបាត់បង់បុគ្គលិកសំខាន់ៗ អាចបណ្តាលឱ្យមានការពន្យាពេលនៃរយៈពេលគម្រោង ការកើនឡើងថ្លៃដើមគម្រោង ឬការថយចុះគុណភាពបុគ្គលិកសំខាន់ៗ អាចបណ្តាលឱ្យមានការពន្យារពេលគម្រោង ការកើនឡើងថ្លៃដើមគម្រោង ឬការថយចុះគុណភាពគម្រោងដែលកត្តាណាមួយក្នុងចំណោមកត្តាគម្រាមកំហែងទាំងនេះអាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់អាជីវកម្ម កេរ្តិ៍ឈ្មោះ ចំណូល និងប្រាក់ចំណេញរបស់ក្រុមហ៊ុន។

**វិធានការកាត់បន្ថយ៖** កង្វះខាតនៃកម្លាំងពលកម្មមួយចំនួន មិនអាចជៀសផុតបានទេ ប៉ុន្តែក្រុមហ៊ុន ឌី ប៊ី ឌី ព្យាយាមកាត់បន្ថយផលប៉ះពាល់នៃកង្វះខាត ដោយការបង្កើនសមត្ថភាពរបស់បុគ្គលិកខ្លួនជានិច្ច តាមរយៈកម្មវិធីបណ្តុះបណ្តាលនានា។ បុគ្គលិកមានជំនាញខ្ពស់ ចែករំលែកជំនាញរបស់ពួកគេ ជាមួយបុគ្គលិកដែលមានបទពិសោធន៍តិច។ ការអនុវត្តនេះ ជួយឱ្យក្រុមហ៊ុន ឌី ប៊ី ឌី មានភាពងាយស្រួលក្នុងការស្វែងរកបុគ្គលិកជំនួសផ្ទៃក្នុង ប្រសិនបើមានកង្វះខាតបុគ្គលិកជំនាញ។ ក្រុមហ៊ុន ឌី ប៊ី ឌី ក៏បានជ្រើសរើសបុគ្គលិកមានជំនាញ និងទេពកោសល្យ ពីសាកលវិទ្យាល័យ និងដៃគូប្រកួតប្រជែងផងដែរ។ ដើម្បីរក្សាបុគ្គលិកដែលមានស្រាប់ និងជ្រើសរើសបុគ្គលិកថ្មី ក្រុមហ៊ុន ឌី ប៊ី ឌី ផ្តល់នូវគុណប្រយោជន៍យ៉ាងច្រើនដល់បុគ្គលិក ក្នុងគោលបំណងបង្កើនការពេញចិត្តការងារ ដែលរួមមាន ផែនការអភិវឌ្ឍអាជីព ប្រាក់រង្វាន់ប្រចាំឆ្នាំ និងប្រាក់ខែដែលប្រកួតប្រជែងក្នុងទីផ្សារ។

**-ហានិភ័យនៃទុនបង្វិល**

នៅពេលដែលក្រុមហ៊ុន ឌី ប៊ី ឌី ចុះកិច្ចសន្យាលើគគម្រោងមួយ ជាទូទៅក្រុមហ៊ុនទទួលខុសត្រូវចំពោះរាល់ការចំណាយជាមុន ដែលចំណាយទាំងនេះអាចមានច្រើន។ ជាធម្មតា កិច្ចសន្យាមិនចែងពីការទូទាត់ជាមុននោះទេ ហើយការទូទាត់ជាបន្តបន្ទាប់ ត្រូវបានធ្វើឡើងជារៀងរាល់ខែ ដោយផ្អែកលើដំណើការនៃគម្រោង។ លើសពីនេះទៅទៀត ក្រុមហ៊ុន ឌី ប៊ី ឌី ត្រូវតែមានប្រាក់តម្កល់លើការអនុវត្តគម្រោងនីមួយៗដែលមានតម្លៃ ១០ ភាគរយ នៃចំនួនទឹកប្រាក់នៃកិច្ចសន្យា។ ប្រាក់តម្កល់លើការអនុវត្ត គឺជាទម្រង់នៃប្រាក់បញ្ញើនៅធនាគារ ដែលមិនអាចយកមកប្រើប្រាស់បានរហូតដល់ពេលដែលគ្រោងត្រូវបានបញ្ចប់។ គោលបំនងនៃប្រាក់តម្កល់នេះ គឺដើម្បីធានាដល់ម្ចាស់គម្រោងថា ក្រុមហ៊ុន ឌី ប៊ី ឌី មានសុវត្ថិភាពផ្នែកហិរញ្ញវត្ថុ និងសមត្ថភាពគ្រប់គ្រាន់ក្នុងការចំណាយលើគម្រោង។ កត្តាទាំងនេះ បានជះឥទ្ធិពលដល់ទុនបង្វិលរបស់ក្រុមហ៊ុន ឌី ប៊ី ឌី។ នៅក្នុងវិស័យសំណង់នេះ ទុនបង្វិលគ្រប់គ្រាន់ ត្រូវបានចាត់ទុកថា ក្នុងចន្លោះ ២៥ ភាគរយ និង ៣០ ភាគរយ នៃតម្លៃសរុបរបស់កិច្ចសន្យាដែលកំពុងដំណើរការទាំងអស់។ ជាធម្មតា ទុនបង្វិលត្រូវបានយកទៅប្រើប្រាស់ដើម្បីទូទាត់ថ្លៃវត្ថុធាតុដើម អ្នកផ្គត់ផ្គង់ និងថ្លៃពលកម្ម។ ទឹកប្រាក់ទាំងនោះ បានមកពីទុនបង្វិលរបស់ ក្រុមហ៊ុនដែលមានស្រាប់ រួមជាមួយនឹងឥណទានពីធនាគារ។ អាជីវកម្មរបស់ក្រុមហ៊ុន ឌី ប៊ី ឌី គឺចាំបាច់តម្រូវឱ្យមានទុនបង្វិលគ្រប់គ្រាន់ ដូច្នេះរាល់ការទូទាត់ប្រាក់ពីអតិថិជន ឬការពន្យារពេលទូទាត់ អាចមានផលប៉ះពាល់អវិជ្ជមានដល់ទុនបង្វិលរបស់ក្រុមហ៊ុន។

**វិធានការកាត់បន្ថយ៖**ដើម្បីកាត់បន្ថយផលប៉ះពាល់មួយចំនួននៃទុនបង្វិល ក្រុមហ៊ុន ឌី ប៊ី ឌី បន្តការចរចារ ដើម្បីទទួលបានទឹកប្រាក់ជាមុនលើគម្រោងដែលទទួលបាន។ ក្រុមហ៊ុន ឌី ប៊ី ឌី ក៏បានបម្រុងទុកសាច់ប្រាក់ក្នុងដៃមួយចំនួនធំសម្រាប់ផ្គត់ផ្គង់ប្រតិបត្តិការផងដែរ។ ដើម្បីជៀសវាងហានិភ័យនៃការមិនបង់ប្រាក់ ឬការទូទាត់យឺតយ៉ាវពីអតិថិជន ក្រុមហ៊ុន ឌី ប៊ី ឌី ពិនិត្យមើលស្ថានភាពហិរញ្ញវត្ថុរបស់អតិថិជន មុនពេលធ្វើការដេញថ្លៃ។ ជាចុងក្រោយ ក្រុមហ៊ុន ឌី ប៊ី ឌី មានក្រុមការងារសម្រាប់ប្រមូលសាច់ប្រាក់ និងទិញលក់ ដែលត្រួតពិនិត្យ និងតាមដានលើស្ថានភាពសាច់ប្រាក់ដែលត្រូវទទួលទាំងអស់។

**-ហានិភ័យអត្រាការប្រាក់**

ក្រុមហ៊ុន ឌី ប៊ី ឌី ពឹងផ្អែកលើប្រាក់កម្ចីធនាគារ និងបណ្ណាញឥណទាន ដើម្បីផ្តល់មូលនិធិដល់គម្រោងរបស់ក្រុមហ៊ុន។ ប្រសិនបើអត្រាការប្រាក់ក្នុងទីផ្សារកើនឡើង ក្រុមហ៊ុនអាចត្រូវបង់ការប្រាក់កាន់តែច្រើន ដែលនាំឱ្យជះឥទ្ធិពលអវិជ្ជមានដល់ប្រាក់ចំណេញ។

**វិធានការកាត់បន្ថយ៖** ក្រុមហ៊ុន ឌី ប៊ី ឌី មិនប្រឈមនឹងហានិភ័យអត្រាការប្រាក់នោះទេ ដោយសារក្រុមហ៊ុនមិនមានទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ដែលមានអត្រាការប្រាក់រយៈពេលខ្លីនោះទេ។

## ផ្នែកទី ២៖ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

### ក-លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

នាដើមឆ្នាំ២០២២ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ទទួលបានគម្រោងដំបូងគេ គឺការសាងសង់ និងដំឡើងប្រព័ន្ធ MEP របស់អាគារ "WING OFFICE TOWER" ដែលមានទីតាំងស្ថិតនៅមហាវិថីព្រះមុនីវង្ស និងមហាវិថីកម្ពុជាក្រោម ក្នុងសង្កាត់មនោរម្យខណ្ឌ ៧ មករា រាជធានីភ្នំពេញ។ គម្រោងនេះបានចាប់ផ្តើមធ្វើការសាងសង់ក្នុងឆ្នាំ ២០២២ និងបញ្ចប់គម្រោងក្នុងឆ្នាំ ២០២៣ នាពេលខាងមុខ។ បន្ថែមពីនេះក្រុមហ៊ុន ឌី ប៊ី ឌី ក៏សម្រេចទទួលយកគម្រោងធំមួយទៀតខាងផ្នែកសាងសង់ទាំងមូលទៅលើ គម្រោង "BIOMASS STEAM BOILER PLANT" ពីខាងក្រុមហ៊ុន BECIS ដែលនឹងផលិតថាមពលដោយចំហាយ និងផ្គត់ផ្គង់ទៅអោយ ក្រុមហ៊ុន HEINEKEN ។

ជាមួយគ្នានេះ ក្រុមហ៊ុន ឌី ប៊ី ឌី បានចូលរួមសាងសង់ និងបន្តសាងសង់គម្រោងធំៗមានដូចជា ផ្សារទំនើបអ៊ីអនទី១, ផ្សារទំនើបអ៊ីអនទី២, គម្រោងខុនដូ North Park, គម្រោង ជីប ម៉ុង សែនសុខ, គម្រោងផ្សារទំនើប ជីប ម៉ុង ៥៩៨, និងគម្រោងផ្សារទំនើប ជីប ម៉ុង ២៧១ ជាដើម។

បច្ចុប្បន្ន ក្រុមហ៊ុនកំពុងធ្វើការលើប្រព័ន្ធថ្មីសម្រាប់ការគ្រប់គ្រងធនធានមនុស្សដែលជួយឱ្យអ្នកគ្រប់គ្រងទទួលបានរបាយការណ៍ផ្ទាល់កាន់តែងាយស្រួលលើការរៀបចំ និងការត្រួតពិនិត្យកម្លាំងពលកម្ម ដើម្បីកាត់បន្ថយការខ្វះខាតកម្លាំងពលកម្ម។ បន្ថែមពីនេះ ក្រុមហ៊ុនក៏អនុវត្តមុខងារថ្មីនៅក្នុងប្រព័ន្ធគណនេយ្យបច្ចុប្បន្នផងដែរ ដើម្បីគ្រប់គ្រងការថ្លៃដើមសម្ភារៈ។

### គម្រោងថ្មី

| គម្រោង | កាលបរិច្ឆេទចាប់ផ្តើមគម្រោង | កាលបរិច្ឆេទរំពឹងទុកនៃការបញ្ចប់គម្រោង |
|---|---|---|
| Wing Tower – AV Work Package | តុលា ២០២២ | ២០ មិថុនា ២០២៣ |
| FTB Bank Tower | មីនា ២០២៣ | មិថុនា ២០២៥ |

### គម្រោងស្ថិតក្នុងដំណើរការ

| គម្រោង | កាលបរិច្ឆេទចាប់ផ្តើមគម្រោង | លទ្ធផលសម្រេចបាន |
|---|---|---|
| WING Tower | ៦ មករា ២០២២ | ២៧% |
| DBD New HQ | ៧ ធ្នូ ២០២១ | ៧៧% |
| WING Bank Branch | ១ កញ្ញា ២០២១ | ៩៨% |
| Chip Mong 271 Mega Mall | កក្កដា ២០២០ | ៩៥% |
| Tenant Market Place | ៧ មិថុនា ២០២២ | ៩៨% |
| Tenant Food Court | ៦ សីហា ២០២២ | ៩៨,០១% |
| Tenant Cinema | ៥ សីហា ២០២២ | ៧៥,៨៧% |

| | | |
|---|---|---|
| Tenant Paradise | ៣០ កញ្ញា ២០២២ | ៨០% |
| Decathlon Aeon 3 | ១០ តុលា ២០២២ | ៧៦,៨០% |
| Tenant CMG Office | | ៧៨% |
| Tenant CMRT Office | | ៧៩% |




❖ **គម្រោង BIOMASS STEAM BOILER PLANT**




**គម្រោងអាគារ WING OFFICE TOWER**



គម្រោង CHIP MONG MEGA MALL 271




គម្រោង CHIP MONG SENSOK MALL




គម្រោង CHIP MONG 598 MALL



គម្រោង TRIBE HOTEL Phnom Penh

## ខ-រចនាសម្ព័ន្ធចំណូល

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក មានប្រភពចំណូលពីរ ដែលចំណូលទី ១ គឺបានមកពីគម្រោងសាងសង់ ដែលជាប្រភពចម្បង ក្នុងនោះរួមបញ្ចូលនូវគម្រោងថ្មី និងការងារជួសជុល និងការថែទាំ។ ប្រភពចំណូលទី ២ គឺបានមកពីការលក់សម្ភារៈគម្រោង ដែលវាជាផ្នែកតូចមួយរបស់ចំណូលសរុប។ ទោះបីជាយ៉ាងណាក៏ដោយ ប្រាក់ចំណូលពីការលក់សម្ភារៈគម្រោង នឹងមានការកើនឡើងបន្ទាប់ពីក្រុមហ៊ុនពង្រីកនូវផលិតកម្មបំពង់របស់ខ្លួន។ ក្រុមហ៊ុន ឌី ប៊ី ឌី នឹងធ្វើការលក់ផលិតផលនេះ ដែលសព្វថ្ងៃនេះក្រុមហ៊ុនផលិតសម្រាប់តែផ្គត់ផ្គង់គម្រោងសាងសង់របស់ខ្លួនប៉ុណ្ណោះ។

| ល.រ | ប្រភពចំណូល | ឆ្នាំ២០២២ | | ឆ្នាំ២០២១ | |
|---|---|---|---|---|---|
| | | ចំនួនទឹកប្រាក់ (ពាន់រៀល) | ភាគរយ | ចំនួនទឹកប្រាក់ (ពាន់រៀល) | ភាគរយ |
| ១ | ចំណូលពីគម្រោងសាងសង់ | ៥៨.២៨០.៥៥៩ | ៩៩,៦០% | ៧១.៤៦១.៧០២ | ៩៧,៧៩% |
| ២ | ចំណូលពីការលក់ទំនិញ | ២៣២.១៣៣ | ០,៤០% | ១.៦១៦.៧៧៨ | ២,២១% |
| ចំណូលសរុប | | **៥៨.៥១២.៦៩២** | **១០០%** | **៧៣.០៧៨.៤៨០** | **១០០%** |

ក្នុងឆ្នាំ២០២២ ក្រុមហ៊ុន ឌី ប៊ី ឌី មានចំណូលចំនួន ៥៨.៥១២.៦៩២ ពាន់រៀល ដែលថយចុះចំនួន ១៤.៥៦៥.៧៨៨ ពាន់រៀល ស្មើនឹង ១៩,៩៣ ភាគរយ បើធៀបនឹងឆ្នាំ២០២១។ ការថយចុះនេះ បណ្តាលមកពីចំណូលពីគម្រោងសាងសង់ថយចុះចំនួន ១៨ ភាគរយ និងចំណូលពីការលក់ទំនិញថយចុះចំនួន ៨៦ ភាគរយ។

# ផ្នែកទី ៣៖ ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម

## ក-អង្គការលេខ



## ខ-ក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទក្លាយជាអភិបាល | កាលបរិច្ឆេទបញ្ចប់អាណត្តិ |
|---|---|---|---|---|
| ១ | លោក នាង វិធី | ប្រធានក្រុមប្រឹក្សាភិបាល និងនាយកប្រតិបត្តិ | ១០ មីនា ២០១៩ | ១០ មីនា ២០២២ |
| ២ | លោកស្រី លឹម មុយលី | អភិបាលប្រតិបត្តិ និងនាយកហិរញ្ញវត្ថុ | ១២ តុលា ២០២០ | ១២ តុលា ២០២៣ |
| ៣ | លោក ថៃ វ៉ាន់ថា | អភិបាលមិនប្រតិបត្តិ | ១២ តុលា ២០២០ | ១២ តុលា ២០២៣ |
| ៤ | លោក ហ៊ុយ វ៉ាថារ៉ូ | អភិបាលឯករាជ្យ | ១២ តុលា ២០២០ | ១២ តុលា ២០២៣ |
| ៥ | លោក Rami Bashir Asad sharaf | អភិបាលមិនប្រតិបត្តិ | ៣១ ឧសភា ២០២២ | ៣១ ឧសភា ២០២៥ |

ឈ្មោះលេខាធិការរបស់ក្រុមហ៊ុន ឌី ប៊ី ឌី គឺ**លោកស្រី លឹម មុយលី**។

## គ-បុគ្គលិកជាន់ខ្ពស់

### សមាសភាពបុគ្គលិកជាន់ខ្ពស់

| ល.រ | ឈ្មោះ | ភេទ | តំណែង |
|---|---|---|---|
| ១ | នាង វិធី | ប្រុស | នាយកគ្រប់គ្រង |
| ២ | លឹម មុយលី | ស្រី | នាយកហិរញ្ញវត្ថុ |
| ៣ | នង បំណង | ប្រុស | ប្រធានគ្រប់គ្រងទូទៅ |
| ៤ | គុយ កៅ | ប្រុស | ប្រធានគ្រប់គ្រងគម្រោងជាន់ខ្ពស់ |
| ៥ | Gerry P.Ardena | ប្រុស | ប្រធានគ្រប់គ្រងគម្រោងជាន់ខ្ពស់ |
| ៦ | ខន រតនៈ | ប្រុស | ប្រធានគ្រប់គ្រងគម្រោង |
| ៧ | ម៉ាយ រតនៈ | ប្រុស | ប្រធានគ្រប់គ្រងគម្រោង |
| ៨ | អ៊ុង គឹមហាន | ប្រុស | ប្រធានគ្រប់គ្រងគម្រោង |
| ៩ | ស្រ៊ិន ចាន់សារ៉ាង | ប្រុស | ប្រធានគ្រប់គ្រងគម្រោង |
| ១០ | សាន់ បញ្ញា | ប្រុស | ប្រធានគ្រប់គ្រងគម្រោង |
| ១១ | សៀក សុខន | ប្រុស | ប្រធានគ្រប់គ្រងគម្រោង |
| ១២ | ពា ធារ៉ា | ប្រុស | ប្រធានគ្រប់គ្រងការឌីហ្សាញ |
| ១៣ | អ៊ុក វល័ក្ខ | ប្រុស | ប្រធានគណនេយ្យ |

| | | | |
|---|---|---|---|
| ១៤ | វ៉េត វណ្ណី | ប្រុស | ប្រធានគ្រប់គ្រងផលិតកម្ម |
| ១៥ | យឹម តូយ៉ា | ប្រុស | ប្រធានគ្រប់គ្រងលទ្ធកម្ម |
| ១៦ | នូ ឧត្តម | ប្រុស | ប្រធានគ្រប់គ្រងផ្នែកថែទាំ |

សម្គាល់៖ ព័ត៌មានលម្អិតពាក់ព័ន្ធអភិបាលកិច្ចសាជីវកម្មមានភ្ជាប់ជាឧបសម្ព័ន្ធ។

## ផ្នែកទី ៤៖ ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនិករបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក

### ក-ព័ត៌មានអំពីមូលបត្រ

| | |
|---|---|
| ឈ្មោះមូលបត្រកម្មសិទ្ធិ | ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត |
| និមិត្តសញ្ញាមូលបត្រកម្មសិទ្ធិ | DBDE |
| ចំណាត់ថ្នាក់នៃមូលបត្រកម្មសិទ្ធិ | ភាគហ៊ុនប្រភេទ "ក" |
| តម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | ១.០០០ រៀល |
| ថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | ២.៣៨០ រៀល |
| បរិមាណមូលបត្រកម្មសិទ្ធិសរុបទាំងអស់ដែលកំពុងចរាចរលើទីផ្សារ | ៦.៤៦១.៥៣៨ ភាគហ៊ុន |
| មូលធនូបនីយកម្មទីផ្សារ | ៤៤.១២៣ លានរៀល |
| ឈ្មោះទីផ្សារមូលបត្រប្រតិស្រុត | ផ្សារមូលបត្រកម្ពុជា |
| កាលបរិច្ឆេទនៃការចុះបញ្ជីលក់មូលបត្រ | ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២១ |

### ខ-ថ្លៃ និងបរិមាណជួញដូរមូលបត្រ

| មូលបត្រកម្មសិទ្ធិ | | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា |
|---|---|---|---|---|---|---|---|
| ថ្លៃជួញដូរ | អតិបរមា | ២.៣២០ | ២.៤៨០ | ២.៦៣០ | ២.៥៩០ | ២.៦២០ | ២.៦២០ |
| | អប្បបរមា | ២.២៧០ | ២.៣០០ | ២.៤៤០ | ២.៤៣០ | ២.៥៦០ | ២.៤៤០ |
| | មធ្យម | ២.៣០១ | ២.៣៧៤ | ២.៥៥៩ | ២.៥៦២ | ២.៥៨៥ | ២.៥១២ |
| បរិមាណជួញដូរ | អតិបរមា | ៤៦.១៨៥ | ១៩៨.៥២៣ | ១១១.០៧០ | ៦៩.៧៩៩ | ៧៨.០៧៨ | ៨៩.០២៣ |
| | អប្បបរមា | ៦២០ | ៣៤៤ | ៦.៩០០ | ៤.៤៩៩ | ១.៧៩០ | ២.៣២៧ |
| | មធ្យម | ៧.២០៥ | ៤០.១០៦ | ៤២.៩៥០ | ១៧.៨១០ | ១១.៧៨២ | ២៤.១១៣ |

| មូលបត្រកម្មសិទ្ធិ | | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|
| ថ្លៃជួញដូរ | អតិបរមា | ២.៤៥០ | ២.៤០០ | ២.៤០០ | ២.៣៩០ | ២.៤០០ | ២.៣៩០ |
| | អប្បបរមា | ២.៣៨០ | ២.៣៦០ | ២.៣៦០ | ២.៣៧០ | ២.៣៥០ | ២.៣៧០ |
| | មធ្យម | ២.៤០៥ | ២.៣៨១ | ២.៣៨៥ | ២.៣៧៩ | ២.៣៨២ | ២.៣៧៥ |
| បរិមាណជួញដូរ | អតិបរមា | ១៨.៨៣៣ | ២២.៩៦២ | ១១.៦៧៥ | ៦.២២៦ | ២២.០៦៥ | ១៣.៧១៥ |
| | អប្បបរមា | ៣៣០ | ២៨០ | ១៦៨ | ៤១ | ៣២២ | ៨៦១ |
| | មធ្យម | ៥.៨២១ | ៣.០២៨ | ២.៦៧១ | ២.០៥០ | ៣.៦៨៣ | ៤.៤៧៤ |

## គ-ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនិកមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់

| ល.រ. | ឈ្មោះ | សញ្ជាតិ | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|
| ១ | លោក នាង វិធី | ខ្មែរ | ៨.៤០០.០០០ | ៤៥,៥០ |
| សរុប | | | ៨.៤០០.០០០ | ៤៥,៥០ |

## ឃ-ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនិកមានសិទ្ធិបោះឆ្នោតចំនួនច្រើន

| ល.រ. | ឈ្មោះ | សញ្ជាតិ | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|
| ១ | លោកស្រី លឹម មុយលី | ខ្មែរ | ៣.៦០០.០០០ | ១៩,៥០ |
| ២ | Royal Group Trustee co.ltd | ខ្មែរ | ៣.៤០០.០០០ | ១៨,៤២ |
| សរុប | | | ៧.០០០.០០០ | ៣៧,៩២ |

## ង-ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ (បី) ឆ្នាំចុងក្រោយ

| ពិពណ៌នាលម្អិតអំពីការបែងចែកភាគលាភ | ២០២១ | ២០២០ | ២០១៩ |
|---|---|---|---|
| ចំណេញសុទ្ធ | ១.៨៤៥.១០៩ រៀល | ១.០៦៩.៣២៤ រៀល | ៤.៦៨៤.៦០៣ រៀល |
| ភាគលាភជាសាច់ប្រាក់សុទ្ធ | ៨៤៦.៤៦១.៤៧៨ រៀល | មិនមាន | មិនមាន |
| ភាគលាភជាមូលបត្រកម្មសិទ្ធិ | មិនមាន | មិនមាន | មិនមាន |
| ភាគលាភផ្សេងទៀត | មិនមាន | មិនមាន | មិនមាន |
| អនុបាតនៃការបែងចែកភាគលាភ | ៤៥,៨៨ ភាគរយ | មិនមាន | មិនមាន |
| ទិន្នផលភាគលាភ (%) | ៥,៦៧ ភាគរយ | មិនមាន | មិនមាន |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | ១៣១ រៀល | មិនមាន | មិនមាន |

## ផ្នែកទី ៥៖ របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក បានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា កាលពីថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២១។ ដោយឡែក យោងតាមវិសាលភាពនៃការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលត្រូវបានធ្វើសវនកម្មចាប់តាំងពីឆ្នាំហិរញ្ញវត្ថុដែលបានបញ្ចប់ឆ្នាំ ២០២២។ សវនករឯករាជ្យបានត្រួតពិនិត្យឡើងវិញ និងលើកឡើងនូវបញ្ហាមួយចំនួនពាក់ព័ន្ធនឹងការធ្វើសវនកម្មផ្ទៃក្នុង ដែលបញ្ហាសំខាន់ៗមួយចំនួននោះ ត្រូវបានដាក់ឱ្យពិភាក្សារជាមួយគណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាល និងត្រូវបានសម្រេចអនុម័ត និងកែលម្អដោយក្រុមហ៊ុនទៅក្នុងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។ ក្រុមហ៊ុនបានបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងរៀបចំធនធានក្នុងការគាំទ្រប្រតិបត្តិការនៃការធ្វើសវនកម្មផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព។ សវនករផ្ទៃក្នុងនឹងរៀបចំរបាយការណ៍សវនកម្មផ្ទៃក្នុង ដែលនឹងបង្ហាញចាប់ពីរបាយការណ៍ប្រចាំឆ្នាំ២០២៣ ខាងមុខតទៅ។

## ផ្នែកទី ៦៖ របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ

- សូមពិនិត្យមើលឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ។

## ផ្នែកទី ៧.-ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ និងទំនាស់ផលប្រយោជន៍

ក្រុមហ៊ុន ឌី បី ឌី សូមបង្ហាញពីព័ត៌មានប្រតិបត្តិការសំខាន់ៗជាមួយភាគីជាប់ពាក់ព័ន្ធ នៅក្នុងរយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ ដោយបញ្ជាក់ពីឈ្មោះ ទំនាក់ទំនងរវាងក្រុមហ៊ុន ឌី បី ឌី និងភាគីជាប់ពាក់ព័ន្ធ ទំហំនៃប្រតិបត្តិការ និង ប្រភេទនៃផលប្រយោជន៍ដែលកើតចេញពីទំនាក់ទំនងនោះ ដូចខាងក្រោម៖

**ក-ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅនៃមូលបត្រកម្មសិទ្ធិកំពុងធ្វើចរាចរលើទីផ្សារ**

ក្នុងឆ្នាំ២០២២ ក្រុមហ៊ុន ឌី បី ឌី ក្រុមហ៊ុនមិនមានប្រតិបត្តិការជាមួយនឹងភាគហ៊ុនិកផ្សេងទៀតនោះទេ។

**ខ-ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់**

ក្នុងឆ្នាំ២០២២ ក្រុមហ៊ុន ឌី បី ឌី មិនមានប្រតិបត្តិការជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់នោះទេ។

**គ-ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ-លក់ទ្រព្យសកម្ម និងសេវាកម្ម**

ក្នុងឆ្នាំ២០២២ ក្រុមហ៊ុន ឌី បី ឌី មិនមានប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ-លក់ទ្រព្យសកម្ម និងសេវាកម្មនោះទេ។

**ឃ-ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅ**

ក្នុងឆ្នាំ២០២២ ក្រុមហ៊ុន ឌី បី ឌី មិនមានប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅ។

**ង-ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់ក្រុមហ៊ុន ឌី បី ឌី ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់ក្រុមហ៊ុន ឌី បី ឌី ដែលទំនាក់ទំនងរបស់បុគ្គលទាំងនោះកើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយដែលធ្វើឡើងដោយក្រុមហ៊ុន ឌី បី ឌី៖**

ក្នុងឆ្នាំ២០២២ ក្រុមហ៊ុន ឌី បី ឌី មិនមានប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធនោះទេ។

**ច-ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាល**

ក្នុងឆ្នាំ២០២២ ក្រុមហ៊ុន ឌី ប៊ី ឌី មិនមានប្រតិបត្តិការជាមួយបុគ្គលធ្លាប់ជាអភិបាលនោះទេ។

**ឆ-ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម អង្គភាពមិនស្វែងរកប្រាក់ ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពីក្រុមហ៊ុន ឌី ប៊ី ឌី**

ក្នុងឆ្នាំ២០២២ ក្រុមហ៊ុន ឌី ប៊ី ឌី មិនមានប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម អង្គភាពមិនស្វែងរកប្រាក់ ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពីក្រុមហ៊ុន ឌី ប៊ី ឌី។

**ជ-ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ពីបុគ្គលចុះបញ្ជីលក់មូលបត្រ ទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ**

ក្នុងឆ្នាំ២០២២ ក្រុមហ៊ុន ឌី ប៊ី ឌី មិនមានប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ពីបុគ្គលចុះបញ្ជីលក់មូលបត្រ ទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុនោះទេ។

## ផ្នែកទី ៨.- ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងការវិភាគខាងក្រោមនេះ គឺជាការពិភាក្សាលើលទ្ធផលនៃប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុដោយគណៈគ្រប់គ្រងរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។ គណៈគ្រប់គ្រងធ្វើការពិភាក្សា និងវិភាគលើសមាសធាតុសំខាន់ៗនៃរបាយការណ៍ហិរញ្ញវត្ថុ និងកត្តាសំខាន់ៗដែលបានជះឥទ្ធិពលទៅ លើប្រាក់ចំណេញរបស់ក្រុមហ៊ុន ឌី ប៊ី ឌី តែប៉ុណ្ណោះ។

**ក-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ**

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក បានបង្កើតឡើងនៅឆ្នាំ១៩៩៨ ក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុននេះ ជាក្រុមហ៊ុនម៉ៅការសាងសង់ឯកទេសផ្នែក MEP និងសំណង់ស៊ីវិល ដែលផ្តល់សេវាកម្មលើផ្នែកមេកានិច អគ្គិសនី ប្រព័ន្ធទឹក និងពន្លត់អគ្គីភ័យ ម៉ាស៊ីនត្រជាក់ បន្ទប់ត្រជាក់ HVAC និងថែទាំអគារ។

**១-ការវិភាគចំណូល**

ប្រភពចំណូលរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក គឺបានពីសេវាសាងសង់ និងសេវាថែទាំ រួមទាំងការងារ MEP និងការងារសំណង់ស៊ីវិល ហើយចំណូលសរុបត្រូវបានកត់ត្រាក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដោយធ្វើការបែងចែកជា ៣ (បី) ផ្នែកដូចជា៖ (១).ការសាងសង់ និងសេវាកម្មថែទាំ, (២).ការលក់ទំនិញ និង (៣).ចំណូលផ្សេងៗ។ ចំណូលត្រូវបានទទួលស្គាល់នៅពេលក្រុមហ៊ុន ឌី ប៊ី ឌី បានបំពេញការអនុវត្តកាតព្វកិច្ចដែលមានចែងក្នុងកិច្ចសន្យាអតិថិជនបានរួចរាល់។ ដើម្បីទទួលស្គាល់ចំណូល ក្រុមហ៊ុន ឌី ប៊ី ឌី បានអនុវត្ត ៥ ជំហាន គឺ៖

១.កំណត់កិច្ចសន្យាជាមួយអតិថិជន

២.កំណត់ពីការអនុវត្តកាតព្វកិច្ច

៣.កំណត់ពីថ្លៃប្រតិបត្តិការ

៤.ការបែងចែកថ្លៃប្រតិបត្តិការធៀបនឹងការអនុវត្តកាតព្វកិច្ច

៥.ទទួលស្គាល់ចំណូលនៅពេល/ការអនុវត្តកាតព្វកិច្ចត្រូវបានពេញចិត្ត។

**២-ការវិភាគចំណូលតាមផ្នែក**

ក្នុងឆ្នាំ២០២២ ក្រុមហ៊ុន ឌី ប៊ី ឌី មានចំណូលចំនួន ៥៨.៥១២.៦៩២ ពាន់រៀល ដែលថយចុះចំនួន ១៤.៥៦៥.៧៨៨ ពាន់រៀល ស្មើនឹង ១៩,៩៣ ភាគរយ បើធៀបនឹងឆ្នាំ២០២១។ ការថយចុះនេះ បណ្តាល មកពីចំណូលពីគម្រោងសាងសង់ថយចុះចំនួន ១៨ ភាគរយ និងចំណូលពីការលក់ទំនិញថយចុះចំនួន ៨៦ ភាគរយ។

### ៣-ការវិភាគគម្លាតចំណេញដុល

ក្នុងឆ្នាំ២០២២ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក មានចំណេញដុលចំនួន ២.៩១២.៩១១ ពាន់រៀល ដែលថយចុះចំនួន ៧.៤៨០.០៨៩ ពាន់រៀល ស្មើនឹង ៧១,៩៧ ភាគរយ បើធៀបនឹងឆ្នាំ២០២១។ ការខាតនេះបណ្តាលមកពីការថយចុះនៃចំណូល។

### ៤-ការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ

| តារាងសង្ខេប ប្រាក់ចំណេញ | ឆ្នាំ២០២២ (ពាន់រៀល) | ឆ្នាំ២០២១ (ពាន់រៀល) | បម្រែបម្រួល (ពាន់រៀល) | បម្រែបម្រួល % |
|---|---|---|---|---|
| ចំណេញដុល | ២.៩១២.៩១១ | ១០.៣៩៣.០០០ | (៧.៤៨០.០៨៩) | -៧១,៩៧% |
| ចំណូលផ្សេងៗ | ២៩.៩០៥ | ១១៤.១៦០ | (៨៤.២៥៥) | -៧៣,៨០% |
| ចំណាយប្រតិបត្តិការ | (៦.៣៦៥.៨៥៨) | (៦.០៣៥.១៨៣) | ៣៣០.៦៧៥ | ៥,៤៨% |
| ចំណាយហិរញ្ញវត្ថុ | (១.៤៤៩.២៥៨) | (២.០៦១.៩៤៧) | (៦១២.៦៨៩) | ២៩,៧១% |
| **ប្រាក់ចំណេញមុនបង់ពន្ធ** | **(៤.៨៧២.៣០០)** | **២.៤១០.០៣០** | **(៧.២៨២.៣៣០)** | **-៣០២,១៧%** |

ក្នុងឆ្នាំ២០២២ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ខាតមុនបង់ពន្ធចំនួន ៤.៨៧២.៣០០ ពាន់រៀល ដែលការខាតនេះបានកើនឡើងចំនួន ៧.២៨២.៣៣០ ពាន់រៀល ស្មើនឹង ៣០២,១៧ ភាគរយ បើធៀបនឹងឆ្នាំ២០២១។ មូលហេតុចម្បងនៃការកើនឡើងនៃការខាតនេះ ដោយសារតែមានការថយចុះនូវចំណូលចំនួន ១៩,៩៣ ភាគរយ និងចំណូលផ្សេងៗមានការថយចុះចំនួន ៧៣,៨០ ភាគរយ ។

### ៥-ការវិភាគចំណេញ/(ខាត) ក្នុងការិយបរិច្ឆេទ

| តារាងសង្ខេបប្រាក់ចំណេញ | ឆ្នាំ២០២២ (ពាន់រៀល) | ឆ្នាំ២០២១ (ពាន់រៀល) | បម្រែបម្រួល (ពាន់រៀល) | បម្រែបម្រួល % |
|---|---|---|---|---|
| ចំណេញមុនបង់ពន្ធ | (៤.៨៧២.៣០០) | ២.៤១០.០៣០ | (៧.២៨២.៣៣០) | -៣០២,១៧% |
| ចំណាយពន្ធលើប្រាក់ចំណូល | - | (៧៣១.២៣៩) | (៧៣១.២៣៩) | -១០០% |
| **ចំណេញក្នុងការិយបរិច្ឆេទ** | **(៤.៨៧២.៣០០)** | **១.៦៧៨.៧៩១** | **(៦.៥៥១.០៩១)** | **-៣៩០,២៣%** |

ចំពោះពន្ធលើប្រាក់ចំណូល ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ត្រូវបង់ចំនួន ២០ ភាគរយ នៃប្រាក់ចំណូលជាប់ពន្ធ ដោយកាត់កងជាមួយប្រាក់រំដោះពន្ធលើប្រាក់ចំណូលប្រចាំខែ ចំនួន ១ ភាគរយ នៃចំណូលប្រចាំឆ្នាំសរុប។

ក្នុងឆ្នាំ២០២២ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក បានខាតក្នុងការិយបរិច្ឆេទចំនួន ៤.៨៧២.៣០០ ពាន់រៀល ដែលការខាតនេះបានកើនឡើងចំនួន ៦.៥៥១.០៩១ ពាន់រៀល ស្មើនឹង ៣៩០,២៣ ភាគរយ បើធៀបនឹងឆ្នាំ២០២១។ មូលហេតុចម្បងនៃការខាតនេះ គឺដោយសារក្រុមហ៊ុនមានការកើនឡើងនៃខាតមុនបង់ពន្ធ។

### ៦-ការវិភាគលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

ក្នុងឆ្នាំ២០២២ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ទទួលបានលទ្ធផលខាតលម្អិតក្នុងការិយបរិច្ឆេទចំនួន ៤.៥២៤.៩៣៧ ពាន់រៀល ដែលការខាតនេះបានកើនឡើងចំនួន ៦.៣៧០.០៤៦ ពាន់រៀល ស្មើនឹង ៣៤៥,២៤ ភាគរយ បើធៀបនឹងឆ្នាំ២០២១។ មូលហេតុចម្បងនៃការខាតនេះ គឺដោយសារក្រុមហ៊ុនមានការកើនឡើងនៃខាតមុនបង់ពន្ធ។

### ៧-ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

ក្នុងឆ្នាំ២០២២ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក មិនមានកត្តា និងនិន្នាការដែលប៉ះពាល់ដល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលគួរឱ្យកត់សម្គាល់ឡើយ។

## ខ-កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក បានវិភាគកត្តាសំខាន់ៗដូចខាងក្រោម ដែលអាចមានផលប៉ះពាល់ដល់លទ្ធភាពរកប្រាក់ចំណេញដល់ក្រុមហ៊ុន។

### ១-ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

យោងតាមរបាយការណ៍ប្រចាំឆ្នាំ២០២២ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ទិន្នន័យសំណង់ទូទាំងប្រទេសមានចំនួន ៤.២៧៦ គម្រោង ដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបចំនួន ៧.២៨៩.៧៦៥ ម៉ែត្រការ៉េ ដែលមានតម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ ២.៩៧២.២៦០.៩២៨ ដុល្លារអាមេរិក មានការថយចុះចំនួន ៤៤,២៧ ភាគរយ បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២១ មានចំនួន ៤.៣០៣ គម្រោង មានផ្ទៃក្រឡាកម្រាលសំណង់ចំនួន ១២.៩៩៨.០៧២ ម៉ែត្រការ៉េ ដែលមានតម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ៥.៣៣៣.៧៩៨.៥២៥ ដុល្លារអាមេរិក។

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក គឺជាក្រុមហ៊ុនសំណង់ឈានមុខគេនៅក្នុងព្រះរាជាណាចក្រកម្ពុជា លើការផ្តល់សេវាកម្ម MEP ដែលមានដូចជា (១)ផ្នែកមេកានិច និងអគ្គិសនី (២)ប្រព័ន្ធទឹក និងពន្លត់អគ្គីភ័យ (៣)កម្តៅខ្យល់ចេញចូល និងប្រព័ន្ធម៉ាស៊ីនត្រជាក់ (៤) សំណង់ស៊ីវិល និង (៥) ការថែទាំអគារ។

**២-ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម**

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក បានរួមបញ្ចូលការឡើងអតិផរណាដែលបានរំពឹងទុកនៅក្នុងសំណើរដែលដាក់ដេញថ្លៃគម្រោង។ ប្រសិនបើតម្លៃនៃវត្ថុធាតុដើមប្រែប្រួលស្របតាមអត្រាអតិផរណា វានឹងមិនមានផលប៉ះពាល់ខ្លាំងដល់ប្រាក់ចំណេញរបស់ក្រុមហ៊ុននោះទេ។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើតម្លៃសម្ភារៈកើនឡើងខ្លាំង វានឹងធ្វើឱ្យក្រុមហ៊ុនខាតបង់។

**៣-ការវិភាគលើពន្ធ**

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក បានទទួលនូវការលើកទឹកចិត្តដោយបន្ថយពន្ធលើប្រាក់ចំណូល ៥០ ភាគរយសម្រាប់រយៈពេល៣ឆ្នាំ ដោយគិតចាប់ពីឆ្នាំ ២០២២ ដល់ ២០២៤។ ដោយអនុលោមតាមច្បាប់ពន្ធដារនៃព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ឌី ប៊ី ឌី មានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណូលក្នុងអត្រា ២០ ភាគរយ នៃប្រាក់ចំណូលជាប់ពន្ធ។ ក្រៅពីពន្ធលើប្រាក់ចំណេញ ក្រុមហ៊ុនក៏ត្រូវបង់ពន្ធអប្បបរមាផងដែរ។ ពន្ធអប្បបរមា ជាពន្ធប្រចាំឆ្នាំជាមួយនឹងអត្រា ១ ភាគរយ លើចំណូលប្រចាំឆ្នាំសរុប ដោយរួមបញ្ចូលពន្ធគ្រប់ប្រភេទទាំងអស់ លើកលែងតែអាករលើតម្លៃបន្ថែម និងដោយមិនគិតពីស្ថានភាពចំណេញ ឬខាតរបស់ក្រុមហ៊ុនឡើយ។ បន្ថែមពីនេះ ក្រុមហ៊ុនបានគណនាអាករលើតម្លៃបន្ថែមចំនួន ១០ ភាគរយ នៅលើវិក័យបត្រដែលចេញទៅឱ្យអតិថិជន។ អាករលើតម្លៃបន្ថែមត្រូវបានកាត់កងជាមួយអាករលើតម្លៃបន្ថែមលើធាតុចូល ១០ ភាគរយ ដែល ក្រុមហ៊ុនបានទូទាត់ទៅអ្នកផ្គត់ផ្គង់នូវរាល់ការទិញទំនិញ។ ក្រុមហ៊ុនមានកាតព្វកិច្ចបង់ពន្ធកាត់ទុកលើចំណូលការប្រាក់នៅអត្រា ៤ ភាគរយ នៃប្រាក់បញ្ញើចរន្ត ដែលត្រូវបានកាត់ទុកដោយធនាគារ, បង់ពន្ធកាត់ទុកលើប្រាក់បំណាច់ ឬលាភការ របស់ក្រុមប្រឹក្សាភិបាល នៅអត្រា ១៥ ភាគរយ, បង់ពន្ធកាត់ទុកលើការចំណាយពាក់ព័ន្ធនឹងសេវាប្រឹក្សាយោបល់នៅ អត្រា ១៤ ភាគរយ (អនិវាសនជន) និង អត្រា ១៥ ភាគរយ (និវាសនជន), និងបង់ពន្ធកាត់ទុកលើចំណូលពីការជួលនៅអត្រា ១០ ភាគរយ។ ជាមួយគ្នានេះ ក្រុមហ៊ុនក៏មានកាតព្វកិច្ចបង់ពន្ធលើការនាំចូលលើសម្ភារៈ និងវត្ថុធាតុដើមនូវអត្រា ៧ ភាគរយទៅ ៣៥ ភាគរយ ផ្អែកលើប្រភេទទំនិញ។

**៤-ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ**

ក្នុងឆ្នាំ២០២២ គណៈគ្រប់គ្រងយល់ថាក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ពុំមានធាតុដែលខុសពីធម្មតា និងវិសាមញ្ញនោះទេ។

### គ-ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ក្នុងឆ្នាំ២០២២ នេះ ប្រាក់ចំណូលរបស់ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក មានការធ្លាក់ចុះ គឺដោយសារការលក់សម្ភារៈមានការថយចុះយ៉ាងគួរឱ្យកត់សម្គាល់ ហើយប្រាក់ចំណូលពីការសាងសង់ក៏មានការថយចុះ។ គម្រោងធំដែលកំពុងសាងសង់មួយគឺ “Chip Mong Mega Mall 271” ដែលគ្រោងនឹងបញ្ចប់នាពេលឆាប់ៗ ហើយគម្រោងធំមួយទៀតគឺ “Wing Tower” ទើបតែចាប់ផ្តើម ដូចនេះប្រាក់ចំណូលដែលទទួលបានពីគម្រោងធំៗទាំងពីរនេះ គឺតិចតួចនៅឡើយ។ នៅក្នុងឆ្នាំ២០២២ នេះដែរ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ក៏បានសាងសង់អគារការិយាល័យកណ្តាល និងឃ្លាំងសម្រាប់ដាក់សម្ភារៈ ដែលការចំណាយនេះត្រូវបានកត់ត្រាចូលជាទ្រព្យសកម្មរយៈពេលវែងរបស់ក្រុមហ៊ុន ដូច្នេះទើបប្រាក់ចំណូលមានការថយចុះបើធៀបទៅនឹងឆ្នាំ២០២១។

លើសពីនេះទៀត ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក មានបញ្ហាប្រឈមចំនួន ២ (ពីរ) គឺ ការចំណាយលើកម្លាំងពលកម្ម និងការចំណាយលើសម្ភារៈ ។ ការចំណាយលើកម្លាំងពលកម្មបានកើនឡើងដោយសារតែការពន្យារពេលនៃគម្រោងធំៗ។ ឧទាហរណ៍ នៅពេលដែលក្រុមវិស្វកម្ម មកពីក្រុមហ៊ុនមួយផ្សេងទៀតបានពន្យារពេល ការងាររបស់ពួកគេ ក្រុម MEP នៃក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក នៅតែត្រូវប្រចាំការដោយសារតែក្រុមទាំងពីរនេះ គឺត្រូវ ធ្វើការជាមួយគ្នា។ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក មិនអាចកាត់បន្ថយបុគ្គលិកបានទេ ខណៈដែលរង់ចាំក្រុមវិស្វកម្មប្រតិបត្តិការងាររបស់ពួកគេ។ ដូច្នេះចំណាយលើកម្លាំងពលកម្ម គឺនៅតែដដែល ទោះបីជាការងារមិនត្រូវបានអនុវត្តក៏ដោយ។ ទោះបីបុគ្គលិកមួយចំនួនត្រូវបានកាត់បន្ថយ ក្នុងគោលបំណងកាត់បន្ថយការចំណាយ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក អាចមានបញ្ហាមួយផ្សេងទៀតលើតម្រូវការកម្លាំងពលកម្ម នៅពេលគម្រោង នេះត្រូវបានបន្ត ដែលនេះមិនមែនជារឿងងាយស្រួលទេក្នុងការហៅបុគ្គលិកនិយោជិតដែលត្រូវបានកាត់បន្ថយនោះ ឱ្យត្រឡប់មកធ្វើការវិញ។ លើសពីនេះទៀត ការចំណាយលើកម្លាំងពលកម្ម អាចនឹងកើនឡើង ឬក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ត្រូវចំណាយពេលសម្រាប់ហ្វឹកហាត់បុគ្គលិកថ្មីទាំងនោះ។ ក្រៅពីនេះ នៅពេលក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ចាប់ផ្តើមការងារទាំងនោះឡើងវិញ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ត្រូវអនុវត្តឱ្យបានលឿនដើម្បីឱ្យសម្រេចតាមកាលបរិច្ឆេទគម្រោងដែលបានកំណត់ ដែលជាអាចបណ្តាលឱ្យមានការអនុវត្តការងារលើសម៉ោង។ ក្នុងគោលបំណងដោះស្រាយលើបន្ទុកនៃការចំណាយលើកម្លាំងពលកម្មនេះ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក បាន ព្យាយាមត្រួតពិនិត្យយ៉ាងតឹងរឹងលើការគ្រប់គ្រងបុគ្គលិក តាមរយៈប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស ដែលផ្តល់របាយការណ៍ផ្ទាល់អំពីការត្រួតពិនិត្យ និងរៀបចំធនធានមនុស្ស។ បញ្ហាលើការចំណាយតម្លៃសម្ភារៈ បានកើនឡើងនៅពេលតម្លៃសម្ភារៈមានការកើនឡើង រួមទាំងបញ្ហាដឹកជញ្ជូនផងដែរ ដែលកើតឡើងពី កត្តាផ្សេងៗ ជាច្រើន ដូចជាការបិទផែសមុទ្រនៅក្នុងអំឡុងពេលបិទខ្ទប់។ ម្យ៉ាងវិញទៀត បញ្ហាទាំងនេះកើតឡើងគឺបណ្តាលមកពីគម្រោងបន្ទាន់ៗ ដែល

មានរយៈពេលខ្លីផងដែរ។ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ត្រូវបង្ខំចិត្ត ទិញសម្ភារនៅក្នុងស្រុកដែលមានតម្លៃខ្ពស់ជាង ដោយសារតែមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីនាំចូល សម្ភារ និងប្រៀបធៀបតម្លៃរវាងអ្នកផ្គត់ផ្គង់។

ហេតុនេះហើយ ក្នុងឆ្នាំ២០២២ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក បានខាតក្នុងការិយបរិច្ឆេទចំនួន ៤.៨៧២.៣០០ ពាន់រៀល បើធៀបទៅនឹងឆ្នាំ២០២២ ក្រុមហ៊ុនមានទទួលបានចំណេញក្នុងការិយបរិច្ឆេទចំនួន ១.៦៧៨.៧៩១ ពាន់រៀល។

**ឃ-ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ**

**១-ផលប៉ះពាល់នៃអត្រាប្តូរប្រាក់**

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក មិនមានទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុជារូបិយប័ណ្ណបរទេសផ្សេងទៀតទេ លើកលែងតែមានទឹកប្រាក់តូចមួយចំនួនសម្រាប់គណនីអ្នកផ្គត់ផ្គង់ ដែលត្រូវបង់ជារូបិយប័ណ្ណថៃបាត (THB) និង អឺរ៉ូ (EUR) ហើយរាល់កម្ចីទាំងអស់របស់ក្រុមហ៊ុនមានអត្រាថេរ ដូច្នេះក្រុមហ៊ុនមិនមានផលប៉ះពាល់ខ្លាំងពីការប្រែប្រួលនៃការប្តូររូបិយប័ណ្ណបរទេស និងអត្រាការប្រាក់ទេ។

**២-ផលប៉ះពាល់នៃអត្រាការប្រាក់**

ក្នុងឆ្នាំ២០២២ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក មិនទទួលរងហានិភ័យពាក់ព័ន្ធនឹងអត្រាការប្រាក់នោះទេ។

**៣-ផលប៉ះពាល់នៃថ្លៃទំនិញ**

ក្នុងឆ្នាំ២០២២ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក មិនមានផលប៉ះពាល់ជាសារវន្តលើថ្លៃទំនិញនោះទេ។

**ង-ផលប៉ះពាល់នៃអតិផរណា**

ក្នុងឆ្នាំ២០២២ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក បានរួមបញ្ចូលការកើនឡើងនៃអតិផរណាដែលបានរំពឹងទុកនៅក្នុងសំណើរដែលដាក់ដេញថ្លៃគម្រោង។ ប្រសិនបើតម្លៃនៃវត្ថុធាតុដើមប្រែប្រួលស្របតាមអត្រាអតិផរណា វានឹងមិនមានផលប៉ះពាល់ខ្លាំងដល់ប្រាក់ចំណេញរបស់ក្រុមហ៊ុននោះទេ។

**ច-គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល**

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ វិស័យអចលនទ្រព្យ និងសំណង់គឺជាកត្តាចម្បងមួយជំរុញកំណើនសេដ្ឋកិច្ច។ យោងតាមរបាយការណ៍របស់ CBRE ទស្សនវិស័យទីផ្សារអចលនទ្រព្យកម្ពុជាឆ្នាំ ២០១៩ ឧស្សាហកម្មសំណង់បានកើនឡើង ១៨,១ ភាគរយ រីឯនៅក្នុងឆ្នាំ ២០១៨ ចំនួនខុនដូកើនឡើងប្រហែល ១២០ ភាគរយ។ ខណៈពេលដែលកត្តាកំណើនសេដ្ឋកិច្ចចម្រុះចូលទៅក្នុងដំណើរការដ៏រឹងមាំនៃឧស្សាហកម្មសំណង់ ការវិនិយោគផ្ទាល់ពីបរទេស (FDI) គឺជាកត្តាជំរុញដ៏សំខាន់មួយនៃឧស្សាហកម្មនេះ។ ក្នុងឆ្នាំ២០១៩ FDI នៅកម្ពុជាមានចំនួន ១០,៦ ភាគរយ

នៃទិន្នផលក្នុងស្រុកសរុប (GDP) សរុប។ ក្នុងឆ្នាំ២០១៨ ការវិនិយោគផ្ទាល់ពីបរទេសបានឈានដល់កម្រិតខ្ពស់បំផុតដោយកើនឡើង ១០,៧ ភាគរយ ឬ ៣០០ លានដុល្លារអាមេរិក ពី ២,៨ ពាន់លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៧ ដល់ ៣,១ ពាន់លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៨ (ធនាគារពិភពលោក)។ ការផ្ទុះឡើងនៃជំងឺកូវីដ-១៩ ក្នុងស្រុក ការកែតម្រូវទីផ្សារអចលនទ្រព្យបន្ទាប់ពីការសាងសង់អូសបន្លាយពេលយូរ និងការរីកដុះដាលនៃអចលនទ្រព្យ ការផ្តល់ឥណទានកើនឡើងដល់វិស័យសំណង់/អចលនទ្រព្យ/កម្ចីទិញផ្ទះ (ដែលថ្មីៗនេះពឹងផ្អែកខ្លាំងលើការវិនិយោគរបស់ចិន) និងឥណទាន គឺជាចំណុចខ្សោយនៃឧស្សាហកម្មបច្ចុប្បន្ន។

## ផ្នែកទី ៩.-ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន

- ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក មិនមានព័ត៌មានគួរឱ្យកត់សម្គាល់ផ្សេងទៀតក្រៅពីព័ត៌មានដែលបានបង្ហាញក្នុងរបាយការណ៍នេះទេ។

## ហត្ថលេខាអភិបាលរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង

កាលបរិច្ឆេទៈ ថ្ងៃទី៣១ខែ មីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

-------------------
លោក នាង វិធី
ប្រធានក្រុមប្រឹក្សាភិបាល និងនាយកប្រតិបត្តិ

កាលបរិច្ឆេទៈ ថ្ងៃទី៣១ខែ មីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

-------------------
លោក ថៃ វ៉ាន់ថា
អភិបាលមិនប្រតិបត្តិ

កាលបរិច្ឆេទៈ ថ្ងៃទី៣១ខែ មីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

-------------------
លោកស្រី លឹម មុយលី
អភិបាលប្រតិបត្តិ និងនាយកហិរញ្ញវត្ថុ

កាលបរិច្ឆេទៈ ថ្ងៃទី៣១ខែ មីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

-------------------
លោក ហ៊ុយ វ៉ាថារ៉ូ
អភិបាលឯករាជ្យ

កាលបរិច្ឆេទៈ ថ្ងៃទី៣១ខែ មីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

-------------------
លោក RAMI Bashir Asad Sharaf
អភិបាលមិនប្រតិបត្តិ

## ឧបសម្ព័ន្ធនៃរបាយការណ៍ប្រចាំឆ្នាំ២០២២

## របាយការណ៍អភិបាលកិច្ចសាជីវកម្មប្រចាំឆ្នាំ

## ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង

ផ្នែកទី១៖ ភាគហ៊ុនិក

ក. រចនាសម្ព័ន្ធភាគហ៊ុនិក គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

១. ព័ត៌មានភាគហ៊ុនិក

| បរិយាយ | សញ្ជាតិ | ប្រភេទភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|---|
| តិចជាង ៥% | ខ្មែរ | រូបវន្តបុគ្គល | ១.៧០២ | ២.៧៤៣.៦៨១ | ១៤,៨៦% |
| | | នីតិបុគ្គល | ២ | ៦៦.៤០០ | ០,៣៦% |
| | មិនមានសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ៨៣ | ២៥១.៤៥៧ | ១,៣៦% |
| | | នីតិបុគ្គល | - | - | - |
| ពី ៥% ទៅ ៣០% | ខ្មែរ | រូបវន្តបុគ្គល | ១ | ៣.៦០០.០០០ | ១៩,៥% |
| | | នីតិបុគ្គល | ១ | ៣.៤០០.០០០ | ១៨,៤២% |
| ចាប់ពី ៣០% | ខ្មែរ | រូបវន្តបុគ្គល | ១ | ៨.៤០០.០០០ | ៤៥,៥% |

២. ភាគហ៊ុនិកដែលជាអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិករបស់ក្រុមហ៊ុន

| ភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|
| អភិបាល | ២ | ១២.០០០.០០០ | ៦៥% |
| បុគ្គលិកជាន់ខ្ពស់ | ២១ | ៤៣៩.៥៦៩ | ២,៣៨% |
| និយោជិក | ១៨ | ៦០.៩០៥ | ០,៣៣% |
| សរុប | ៤១ | ១២.៥០០.៤៧៤ | ៦៧.៧១% |

ខ. សិទ្ធិ និងកាតព្វកិច្ចរបស់ភាគហ៊ុនិក

១. សិទ្ធិរបស់ភាគហ៊ុនិក

លើកលែងតែមានការចែងផ្សេងពីនេះក្នុងលក្ខន្តិកៈនេះ ឬសេចក្តីសម្រេចពិសេសរបស់ភាគហ៊ុនិក អ្នកកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុនត្រូវមាន៖

- សិទ្ធិចូលរួមក្នុងមហាសន្និបាតភាគហ៊ុនិក រួមទាំងសិទ្ធិបោះឆ្នោតដោយផ្ទាល់ ឬតាមរយៈអ្នកតំណាងក្នុងកិច្ចប្រជុំណាមួយរបស់ភាគហ៊ុនិក។ ភាគហ៊ុននីមួយៗរបស់ក្រុមហ៊ុនផ្តល់ឱ្យអ្នកកាន់កាប់នូវសិទ្ធិបោះឆ្នោត ០១ (មួយ) សំឡេងក្នុងមហាសន្និបាតភាគហ៊ុនិក។
- សិទ្ធិទទួលបានភាគលាភ ឬផលប្រយោជន៍ដែលបានប្រកាសដោយក្រុមហ៊ុន។
- សិទ្ធិទទួលបានទ្រព្យសម្បត្តិ ដែលនៅសេសសល់បន្ទាប់ពីការរំលាយ និងការជម្រះបញ្ជីក្រុមហ៊ុន។
- សិទ្ធិទទួលបានព័ត៌មានគ្រប់ប្រភេទ រួមទាំង ព័ត៌មានអំពីអាជីវកម្មរបស់ក្រុមហ៊ុន ព្រមទាំងសៀវភៅ និងកំណត់ត្រាគណនេយ្យរបស់ក្រុមហ៊ុន ព្រមទាំងអាចពិនិត្យបញ្ជីឈ្មោះភាគហ៊ុនិកបាននៅទីស្នាក់ការចុះបញ្ជីរបស់ក្រុម-ហ៊ុននៅក្នុងម៉ោងធ្វើការ ឬនៅពេលប្រជុំមហាសន្និបាតភាគហ៊ុនិក។
- សិទ្ធិបុព្វក្រ័យ៖ ភាគហ៊ុនិកនីមួយៗមានសិទ្ធិបុព្វក្រ័យក្នុងការជាវបានមុននូវភាគហ៊ុនថ្មីដែលបោះចេញ ដោយក្រុមហ៊ុនស្របតាមអនុបាតនៃការកាន់កាប់ភាគហ៊ុនរបស់ខ្លួន ហើយដែលភាគហ៊ុនថ្មីទាំងនោះស្ថិតក្នុងប្រភេទតែមួយនឹងមូលបត្រកម្មសិទ្ធិដែលខ្លួនកំពុងកាន់កាប់។

### ២. ការការពារសិទ្ធិរបស់ភាគហ៊ុនិក និងការអនុវត្ត

ការទទួលខុសត្រូវរបស់ភាគហ៊ុនិកនីមួយៗត្រូវបានកម្រិតត្រឹមចំនួនភាគហ៊ុនដែលបានទិញ។

នៅក្នុងឆ្នាំ ២០២២ ក្រុមហ៊ុនបានធានាដល់ការពារសិទ្ធិភាគហ៊ុនិកទាំងអស់របស់ ឌី ប៊ី ឌី តាមរយៈការរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនលើកដំបូង ដោយអនុញ្ញាតឱ្យភាគហ៊ុនិកបានបោះឆ្នោតសម្រេចជ្រើសរើសអភិបាល បែងចែកភាគលាភ និងកែប្រែលក្ខន្តិកៈ។ ភាគហ៊ុនិកបានចូលរួមយ៉ាងសកម្មនៅក្នុងមហាសន្និបាតភាគហ៊ុនិករបស់ ឌី ប៊ី ឌី ដែលកត្តានេះបង្ហាញយ៉ាងច្បាស់ថាភាគហ៊ុនិករបស់ ឌី ប៊ី ឌី បានយល់ច្បាស់អំពីការអនុវត្តសិទ្ធិរបស់ខ្លួន និងបានអនុវត្តសិទ្ធិបោះឆ្នោត ប្រកបដោយប្រសិទ្ធភាព តាមរយៈយន្តការ និងនីតិវិធីរៀបចំមហាសន្និបាតភាគហ៊ុនិក និងបោះឆ្នោត ប្រកបដោយតម្លាភាព ឯករាជ្យភាព និងភាពត្រឹមត្រូវជូនដល់ភាគហ៊ុនិករបស់ ឌី ប៊ី ឌី។

### ៣. ការការពារសិទ្ធិរបស់ភាគហ៊ុនិកភាគតិច និងការអនុវត្ត

ភាគហ៊ុនិកទាំងអស់របស់ក្រុមហ៊ុន ឌី ប៊ី ឌី ទទួលបានការការពារ និងមានសិទ្ធិស្មើគ្នាទៅតាមប្រភេទ និងស៊េរីភាគហ៊ុនដែលខ្លួនកាន់កាប់។

នៅក្នុងឆ្នាំ២០២២ ក្រុមហ៊ុនបានរៀបចំយន្តការស្តីពីការបង្ហាញព័ត៌មានរបស់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនភាគច្រើន និងច្រើនលើសលប់ និងគោលការណ៍គ្រប់គ្រងប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ ដែលកិច្ចការទាំងពីរនេះកំពុងពិភាក្សានៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។ ក្រុមហ៊ុនជឿជាក់យ៉ាងមុតមាំថា យន្តការ និងគោលការណ៍ទាំងនេះអាចការពារដល់សិទ្ធិភាគហ៊ុនិកភាគតិចយ៉ាងមានប្រសិទ្ធភាព និងស្របតាមបទប្បញ្ញត្តិជាធរមាន។ យើងយល់យ៉ាងច្បាស់អំពីកាតព្វកិច្ចក្នុងការការពារផលប្រយោជន៍ជូនដល់ភាគហ៊ុនិក និងជាពិសេសគឺការការពារសិទ្ធិរបស់ភាគហ៊ុនិកភាគតិច និងប្តេជ្ញាអនុវត្តស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## គ. មហាសន្និបាតភាគហ៊ុនិកប្រចាំឆ្នាំ និងមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ

### ១. នីតិវិធីនៃការរៀបចំមហាសន្និបាតភាគហ៊ុនិកប្រចាំឆ្នាំ និងមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ

ក្រុមហ៊ុនត្រូវរៀបចំមហាសន្និបាតភាគហ៊ុនិកប្រចាំឆ្នាំ យ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ តែមិនឱ្យលើសពី ០៦ (ប្រាំមួយ)ខែបន្ទាប់ពីបញ្ចប់ឆ្នាំសារពើពន្ធនីមួយៗ។ មហាសន្និបាតភាគហ៊ុនិកវិសាមញ្ញអាចធ្វើឡើងគ្រប់ពេល ករណីមានការស្នើសុំរបស់ក្រុមប្រឹក្សាភិបាលដោយសំឡេងភាគច្រើន នៃចំនួនសមាជិកនៃក្រុមប្រឹក្សាភិបាល ឬដោយសំណើជាលាយក្ខណ៍អកក្សររបស់ភាគហ៊ុនិកដែលកាន់កាប់យ៉ាងតិច ៥១% (ហាសិបមួយភាគរយ) នៃភាគហ៊ុនមានសិទ្ធិបោះឆ្នោត។

ក្រុមប្រឹក្សាភិបាលត្រូវកំណត់កាលបរិច្ឆេទ និងពេលវេលានៃមហាសន្និបាតភាគហ៊ុនិក។ មហាសន្និបាតភាគហ៊ុនិកត្រូវធ្វើឡើងនៅអាសយដ្ឋានចុះបញ្ជីក្រុមហ៊ុន ឬនៅកន្លែងដទៃទៀតដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ឬភាគហ៊ុនិកដែលជាអ្នកកោះប្រជុំ។ សម្រាប់គោលបំណងកំណត់ចំនួនភាគហ៊ុនិកដែលមានសិទ្ធិទទួលបានសេចក្តីជូនដំណឹង ឬមានសិទ្ធិបោះឆ្នោតនៅក្នុងកិច្ចប្រជុំណាមួយរបស់ភាគហ៊ុនិក ឬនៅក្នុងកិច្ចប្រជុំលើកពេលណាមួយ ក្រុមប្រឹក្សាភិបាលអាចកំណត់កាលបរិច្ឆេទកំណត់ទុកមុន សម្រាប់ការកំណត់ចំនួនភាគហ៊ុនិកនោះ ដោយមិនត្រូវលើសពី ៥០ (ហាសិប)ថ្ងៃ ឬមិនត្រូវតិចជាង ២០ (ម្ភៃ)ថ្ងៃ មុនកាលបរិច្ឆេទធ្វើមហាសន្និបាតភាគហ៊ុនិកដែលចំណាត់ការពិសេសតម្រូវឱ្យមានការកំណត់ចំនួនភាគហ៊ុនិកនោះត្រូវធ្វើឡើង។

ប្រសិនបើក្រុមប្រឹក្សាភិបាលមិនបានកំណត់កាលបរិច្ឆេទកំណត់ទុកមុន នោះកាលបរិច្ឆេទកំណត់ទុកត្រូវកំណត់នៅថ្ងៃធ្វើការចុងក្រោយ មុនពេលជូនដំណឹងអំពីកិច្ចប្រជុំ ឬប្រសិនបើគ្មានការជូនដំណឹងទេ ត្រូវយកថ្ងៃបើកកិច្ចប្រជុំ។

ចំពោះកាលបរិច្ឆេទកំណត់ទុក ដើម្បីកំណត់ចំនួនភាគហ៊ុនិកសម្រាប់បញ្ហាណាមួយ ក្រៅពីសិទ្ធិទទួលបានសេចក្តីជូនដំណឹងអំពីកិច្ចប្រជុំ ឬសិទ្ធិបោះឆ្នោត ត្រូវកំណត់យកថ្ងៃធ្វើការចុងក្រោយ ដែលក្រុមប្រឹក្សាភិបាលអនុម័តសេចក្តីសម្រេចដែលទាក់ទងនឹងបញ្ហានេះ។

នៅពេលការកំណត់ចំនួនភាគហ៊ុនិកដែលមានសិទ្ធិបោះឆ្នោតនៅក្នុងមហាសន្និបាតភាគហ៊ុនិកត្រូវធ្វើឡើង ការកំណត់នេះត្រូវអនុវត្តចំពោះការលើកពេលកិច្ចប្រជុំផងដែរ លើកលែងតែក្រុមប្រឹក្សាភិបាលកំណត់កាលបរិច្ឆេទកំណត់ទុកមុនថ្មី។

ប្រធានក្រុមប្រឹក្សាភិបាល ឬក្រុមប្រឹក្សាភិបាល ត្រូវជូនដំណឹងអំពីមហាសន្និបាតភាគហ៊ុនិក តាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ឬតាមមធ្យោបាយអេឡេចត្រូនិចដល់ភាគហ៊ុនិកទាំងអស់ ដែលមានសិទ្ធិចូលរួមមហាសន្និបាតភាគហ៊ុនិក ឱ្យបានយ៉ាងតិច ២០ (ម្ភៃ) ថ្ងៃ ប៉ុន្តែមិនឱ្យលើសពី ៥០ (ហាសិប)ថ្ងៃ មុនកាលបរិច្ឆេទមហាសន្និបាតឡើយ។ ការជូនដំណឹងនោះត្រូវបញ្ជាក់កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃមហាសន្និបាត ព្រមទាំងរបៀបវារៈដែលត្រូវពិភាក្សា និងសម្រេចផងដែរ។

មហាសន្និបាតភាគហ៊ុនិកត្រូវកោះប្រជុំដោយប្រធានក្រុមប្រឹក្សាភិបាល ឬក្រុមប្រឹក្សាភិបាល។ ប្រសិនបើ ប្រធានក្រុមប្រឹក្សាភិបាល ឬក្រុមប្រឹក្សាភិបាលពុំធ្វើការកោះប្រជុំក្នុងរយៈពេល ២១ (ម្ភៃមួយ) ថ្ងៃ បន្ទាប់ពីទទួលបានសំណើនោះភាគហ៊ុនិកទាំងអស់ដែលបានចុះហត្ថលេខាលើសំណើ អាចកោះប្រជុំបាន។

ប្រសិនបើមិនអាចកោះប្រជុំ ឬរៀបចំមហាសន្និបាតភាគហ៊ុនិកបានទៅតាមបែបបទដូចមានបញ្ជាក់ក្នុងលក្ខន្តិកៈនេះ ឬច្បាប់ អភិបាល ឬភាគហ៊ុនិកដែលមានសិទ្ធិបោះឆ្នោតក្នុងកិច្ចប្រជុំអាចស្នើសុំតុលាការឱ្យចេញសេចក្តីសម្រេច

ណែនាំឱ្យមានការរៀបចំកិច្ចប្រជុំ តាមរបៀបណាមួយដែលតុលាការយល់ថាសមស្រប។ តុលាការអាចសម្រេចកែប្រែ ឬលើកលែងចោលនូវចំនួនកូរ៉ុមដែលតម្រូវដោយលក្ខន្តិកៈនេះ ចំពោះមហាសន្និបាតភាគហ៊ុនិកដែលត្រូវកោះហៅ និង រៀបចំឡើង។

ភាគហ៊ុនិកចូលរួមមហាសន្និបាតដោយផ្ទាល់ ឬដោយសិទ្ធិប្រទាន ដែលកាន់កាប់ភាគហ៊ុនយ៉ាងហោចណាស់ ៧៥% (ចិតសិបប្រាំភាគរយ) នៃភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត ទើបអាចកែប្រែរបៀបវារៈ នៃមហាសន្និបាត ភាគហ៊ុនិកបាន ទោះបីជាមុនពេលមហាសន្និបាត ឬក្នុងពេលមហាសន្និបាតក៏ដោយ។

កូរ៉ុមនៃមហាសន្និបាតភាគហ៊ុនិក ត្រូវតែជាភាគហ៊ុនិកចូលរួមមហាសន្និបាតដោយផ្ទាល់ ឬដោយសិទ្ធិប្រទាន ដែលកាន់កាប់ភាគហ៊ុនចំនួនលើសពី ៥១% (ហាសិបមួយភាគរយ) នៃភាគហ៊ុនមានសិទ្ធិបោះឆ្នោត។ ភាគហ៊ុនដែល តំណាងសិទ្ធិប្រទាន នឹងត្រូវរាប់បញ្ចូលដើម្បីកំណត់កូរ៉ុមនៃមហាសន្និបាតភាគហ៊ុនិក។ ប្រសិនបើកូរ៉ុមមិនគ្រប់ចំនួន សម្រាប់ធ្វើមហាសន្និបាតភាគហ៊ុនិកណាមួយ នោះមហាសន្និបាតនោះនឹងត្រូវផ្អាករយៈពេល ៣០ (សាមសិប)ថ្ងៃ។ ការជូនដំណឹងអំពីការផ្អាកមហាសន្និបាត ត្រូវធ្វើជូនគ្រប់ភាគហ៊ុនិកទាំងអស់។ នៅពេលចាប់បន្តមហាសន្និបាតដែល បានផ្អាកនោះ ភាគហ៊ុនិកទាំងអស់ដែលមានវត្តមានក្នុងមហាសន្និបាតដែលផ្អាកនោះ ជាកូរ៉ុមដែលអាចធ្វើមហាសន្និ បាតបាន។

ភាគហ៊ុនិកអាចផ្តល់សិទ្ធិប្រទានជាលាយលក្ខណ៍អក្សរទៅអ្នកតំណាងណាម្នាក់ឱ្យចូលរួម និងបោះឆ្នោតនៅ ក្នុងមហាសន្និបាតភាគហ៊ុនិក។ សិទ្ធិប្រទាននោះមានសុពលភាពសម្រាប់តែមហាសន្និបាតភាគហ៊ុនិកមួយលើកប៉ុណ្ណោះ (ចំពោះមហាសន្និបាតភាគហ៊ុនិកដែលបានផ្អាកនោះ ក៏ចាត់ទុកយកថាជាផ្នែកដូចគ្នាមួយនៃមហាសន្និបាតភាគហ៊ុនិក នោះផងដែរ)។ សិទ្ធិប្រទានអាចដកហូតមកវិញបានគ្រប់ពេល ហើយត្រូវបានដកដោយស្វ័យប្រវត្តិ ប្រសិនបើភាគហ៊ុនិក ដែលបានផ្តល់សិទ្ធិប្រទាននោះបានចូលរួមមហាសន្និបាតភាគហ៊ុនិកដោយផ្ទាល់។ ករណីអ្នកតំណាងចូលរួមបោះឆ្នោត នៅក្នុងមហាសន្និបាតភាគហ៊ុនិក លិខិតតែងតាំងអ្នកតំណាងរូបនោះត្រូវដាក់ជូនប្រធានក្រុមប្រឹក្សាភិបាលនៅក្នុងអំឡុង ឬមុនពេលចាប់ផ្តើមកិច្ចប្រជុំ។

លិខិតផ្តល់សិទ្ធិប្រទានដល់អ្នកតំណាង ត្រូវចុះកាលបរិច្ឆេទ និងមានហត្ថលេខារបស់ភាគហ៊ុនិក ព្រមទាំងត្រូវ បញ្ជាក់នូវៈ

- ចំនួនភាគហ៊ុនិកដែលកាន់កាប់ដោយភាគហ៊ុនិកដែលផ្តល់សិទ្ធិប្រទាន
- ឈ្មោះ និងអាសយដ្ឋានពេញលេញរបស់អ្នកតំណាងនោះ និង
- កិច្ចប្រជុំដែលអ្នកតំណាងនោះត្រូវតែងតាំងឱ្យចូលរួម។

មហាសន្និបាតភាគហ៊ុនិកនីមួយៗត្រូវដឹកនាំដោយប្រធានក្រុមប្រឹក្សាភិបាល។ ក្នុងករណីប្រធានក្រុមប្រឹក្សា- ភិបាលអវត្តមាន ភាគហ៊ុនិកដែលមានវត្តមានក្នុងកិច្ចប្រជុំត្រូវបោះឆ្នោតជ្រើសរើសតាំងប្រធានស្តីទី ដើម្បីដឹកនាំមហា សន្និបាតភាគហ៊ុនិកដោយមានសំឡេងឆ្នោតគាំទ្រភាគច្រើន។ ការបោះឆ្នោតក្នុងមហាសន្និបាតភាគហ៊ុនិកត្រូវធ្វើឡើង ដោយការលើកដៃ ឬដោយសន្លឹកឆ្នោត ទៅតាមការសម្រេចរបស់ប្រធាននៃមហាសន្និបាត។

លើកលែងតែមានចែងផ្សេងក្នុងលក្ខន្តិកៈនេះ ដោយច្បាប់ ឬដោយបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន រាល់សេចក្តី សម្រេចក្នុងមហាសន្និបាតភាគហ៊ុនិក តម្រូវឱ្យមានសន្លឹកឆ្នោតវិជ្ជមានយ៉ាងហោចណាស់ចំនួន៥១% (ហាសិបមួយ

ភាគរយ) នៃភាគហ៊ុនមានសិទ្ធិបោះឆ្នោតកាន់កាប់ដោយភាគហ៊ុនិក និងអ្នកតំណាង ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំ។ គ្មានសេចក្តីសម្រេចភាគហ៊ុនិកណាមួយត្រូវចងកាតព្វកិច្ចលើក្រុមហ៊ុនឡើយ លុះត្រាសេចក្តីសម្រេចនោះត្រូវបានអនុម័ត តាមរបៀប និងនីតិវិធីដូចមានចែងក្នុងលក្ខន្តិកៈនេះ។

សេចក្តីសម្រេចរបស់កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកដែលមានចែងដូចខាងក្រោម ត្រូវអនុម័តដោយសំឡេងយ៉ាងតិច ៧៥% (ចិតសិបប្រាំភាគរយ) នៃសំឡេងឆ្នោតសរុបរបស់ភាគហ៊ុនិក និងអ្នកតំណាងដែលមានវត្តមានក្នុងកិច្ចប្រជុំ និងមានសិទ្ធិបោះឆ្នោត ("សេចក្តីសម្រេចពិសេស")៖

- ការផ្លាស់ប្តូរនាមករណ៍ ឬទម្រង់របស់ក្រុមហ៊ុន
- ការបង្កើន ឬបន្ថយដើមទុនចុះបញ្ជីក្រុមហ៊ុន
- ការបញ្ចូល ឬការរំលាយក្រុមហ៊ុន
- ការបង្កើត ការបន្ថយ ឬការកែប្រែទាក់ទងនឹងកម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុន
- ការបោះផ្សាយមូលបត្រ
- ការកែប្រែចិរវេលាអត្ថិភាពរបស់ក្រុមហ៊ុន
- ការកែប្រែលក្ខខណ្ឌកូរ៉ុមសម្រាប់កិច្ចប្រជុំភាគហ៊ុនិក ឬកិច្ចប្រជុំក្រុមប្រឹក្សាភិបាល
- ការកែប្រែប្រការទាំងឡាយនៃលក្ខន្តិកៈនេះ
- ការទិញភាគហ៊ុនត្រលប់
- តាមការតម្រូវផ្សេងទៀតដោយលក្ខន្តិកៈនេះ។

ដំណើរការ និងលទ្ធផលនៃមហាសន្និបាតភាគហ៊ុនិក ត្រូវកត់ត្រានៅក្នុងកំណត់ហេតុនៃមហាសន្និបាតភាគហ៊ុនិក ដោយត្រូវមានភ្ជាប់ឈ្មោះ និងហត្ថលេខារបស់អ្នកចូលរួម និងប្រធាននៃមហាសន្និបាតភាគហ៊ុនិក។ កំណត់ហេតុនៃមហាសន្និបាតភាគហ៊ុនិកនីមួយៗ ត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល ឬប្រធាននៃមហាសន្និបាត និងលេខាធិការក្រុមហ៊ុន ព្រមទាំងត្រូវរក្សាទុកនៅទីស្នាក់ការចុះបញ្ជី។

ច្បាប់ចម្លង ឬសម្រង់នៃកំណត់ហេតុកិច្ចប្រជុំត្រូវធ្វើឡើងឱ្យបានត្រឹមត្រូវ និងពិតប្រាកដដោយលេខាធិការក្រុមហ៊ុន និងត្រូវបញ្ជាក់ដោយប្រធានក្រុមប្រឹក្សាភិបាល ឬប្រធាននៃមហាសន្និបាតភាគហ៊ុនិក។

ដំណើរការបោះឆ្នោតរបស់ឌី ប៊ី ឌី ត្រូវបានកំណត់នៅក្នុងនីតិវិធីនៃការបោះឆ្នោត ដែលរៀបចំឡើងស្របតាមច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន និងឈរលើគោលការណ៍ "មួយភាគហ៊ុនផ្តល់ឱ្យនូវសិទ្ធិបោះឆ្នោតមួយសម្លេង"។ ក្រុមហ៊ុនបានរៀបចំរួចជាស្រេចនូវបទបញ្ជាផ្ទៃក្នុងសម្រាប់ការបោះឆ្នោត ការរាប់សន្លឹក ការកត់ត្រាសន្លឹកឆ្នោត និងការប្រកាសលទ្ធផលបោះឆ្នោតរបស់ភាគហ៊ុនិកនៅក្នុងកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក។

## ២. ព័ត៌មានមហាសន្និបាតភាគហ៊ុនិក

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | កូរ៉ុម | របៀបវារៈ | សេចក្តីសម្រេច |
|---|---|---|---|---|---|
| ១ | ៣១ ឧសភា ២០២២ | មហាសន្និបាតភាគហ៊ុនិកសាមញ្ញ | ១៨.៤៦១.៥៣៨ ភាគហ៊ុន ៨៥,៣៨% | ក. ការបែងចែកភាគលាភប្រចាំឆ្នាំ២០២១ជូនភាគហ៊ុនិក<br>ខ. ការជ្រើសរើសអភិ- | បានបោះឆ្នោតអនុម័តលើ៖<br>ក. ការបែងចែកភាគលាភប្រចាំឆ្នាំ២០២១ ជូន |

| | | | | | |
|---|---|---|---|---|---|
| | | | | បាលតំណាងពីក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុប<br>គ. វិសោធនកម្មនៃលក្ខ-ន្តិកៈក្រុមហ៊ុន | ភាគហ៊ុនិក<br>ខ. ការជ្រើសរើសអភិ-បាលតំណាងពីក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុប<br>គ. វិសោធនកម្មនៃលក្ខ-ន្តិកៈក្រុមហ៊ុន |

## ឃ. ការបែងចែកភាគលាភ

### ១. គោលនយោបាយភាគលាភ

ក្រុមហ៊ុន ឌី ប៊ី ឌី មានបំណងអនុញ្ញាតឱ្យភាគហ៊ុនិកចូលរួមក្នុងប្រាក់ចំណេញរបស់ក្រុមហ៊ុនតាមរយៈការបែងចែកភាគលាភឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាព ខណៈពេលនៃការលៃបម្រុងឱ្យបានគ្រប់គ្រាន់សម្រាប់ការរីចម្រើនរបស់ក្រុមហ៊ុននាពេលអនាគត។ ភាគលាភដែលត្រូវបានប្រកាសដោយក្រុមប្រឹក្សាភិបាលរបស់ ឌី ប៊ី ឌី ស្របតាមការអនុម័តរបស់ភាគហ៊ុនិកក្នុងឆ្នាំសារពើពន្ធ ត្រូវបែងចែកក្នុងចំណោមភាគហ៊ុនិកប្រភេទ "ខ" និងប្រភេទ "ក"។

លទ្ធភាពក្នុងការទូទាត់ភាគលាភនាពេលអនាគតជូនភាគហ៊ុនិក គឺស្ថិតនៅលើកត្តាជាច្រើន រួមមាន ប្រតិបត្តិការហិរញ្ញវត្ថុ តម្រូវការលំហូរសាច់ប្រាក់ ទុនបម្រុងរក្សាទុក តម្រូវការចំណាយមូលធន និងកត្តាផ្សេងៗទៀតដែលត្រូវពិចារណាដោយក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន។

### ១.១ ភាគលាភអប្បបរមាដែលត្រូវបានធានា

ដើម្បីជាការលើកទឹកចិត្តដល់វិនិយោគិនសាធារណៈ និងដោយមានការយល់ព្រមពីភាគហ៊ុនិក ក្រុមប្រឹក្សាភិបាលរបស់ ឌី ប៊ី ឌី បានអនុម័តគោលនយោបាយភាគលាភ ដែលមានការធានាទិន្នផលភាគលាភអប្បរមាប្រចាំឆ្នាំស្មើនឹង ៥,៥% សម្រាប់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតប្រភេទ"ក"។ ភាគហ៊ុនិកប្រភេទ "ខ" មិនមានសិទ្ធិទទួលបានភាគលាភអប្បរមាដែលត្រូវបានធានាចំពោះភាគហ៊ុនប្រភេទ"ក" ឡើយ ក្នុងរយៈពេលធានាភាគលាភអប្បរមាដែលកំណត់ក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ប៉ុន្តែអាចទទួលបានភាគលាភដែលត្រូវបានបែងចែកលើសពីភាគលាភអប្បរមា (ប្រសិនមាន)។

ភាគហ៊ុនិកប្រភេទ"ក" ត្រូវបានធានាផ្តល់ជូនទិន្នផលភាគលាភប្រចាំឆ្នាំក្នុងអត្រា ៥,៥% (អាចជាភាគលាភជាសាច់ប្រាក់ ឬភាគលាភជាភាគហ៊ុន) នៃចំនួនភាគហ៊ុនសរុប ដែលកាន់កាប់ មុនថ្ងៃអិចឌីវីឌិនដ៍ (Ex-Dividend Day) គុណនឹងតម្លៃបោះផ្សាយលក់ភាគហ៊ុនប្រភេទ"ក" លើកដំបូង (IPO) ក្នុងរយៈពេល ៣ (បី)ឆ្នាំ ដែលភាគលាភអប្បរមាត្រូវបានធានា អាចត្រូវបានប្រកាស និងបែងចែក។ ក្នុងករណីដែលមានមូលនិធិដែលអាចត្រូវបានប្រកាស និងបែងចែកជាភាគលាភ ក្រុមប្រឹក្សាភិបាលរបស់ ឌី ប៊ី ឌី ត្រូវធ្វើការសម្រេចប្រកាស និងបែងចែកភាគលាភទៅភាគហ៊ុនិកនៅពេលដែលការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងមានរយៈពេល ១២ខែ ឬតិចជាងរយៈពេល ១២ខែ តាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាលរបស់ ឌី ប៊ី ឌី។

ឌី ប៊ី ឌី អាចបែងចែកភាគលាភ ក្នុងទម្រង់ភាគលាភជាភាគហ៊ុន ដោយផ្អែកលើថ្លៃបិទ នៅថ្ងៃជួញដូរមុនថ្ងៃអិចឌីវិឌិនដ៍។ ឌី ប៊ី ឌីត្រូវប្រកាសភាគលាភដែលអាចជាសាច់ប្រាក់ ឬជាភាគហ៊ុន ដើម្បីចែកជូនភាគហ៊ុនិកប្រភេទ"ក" ទៅតាមកម្រិតនៃភាគលាភអប្បរមាដែលត្រូវបានធានា លើកលែងតែករណីមានការហាមឃាត់ដោយច្បាប់។ ក្នុងករណីមូលនិធិដែលអាចត្រូវបានប្រកាស និងបែងចែកជាភាគលាភធំជាងភាគលាភអប្បរមាដែលត្រូវបានធានា ប៉ុន្តែ ឌី ប៊ី ឌី ពុំមានសាច់ប្រាក់គ្រប់គ្រាន់ ឬមិនមានគោលបំណងក្នុងការទូទាត់ជាភាគហ៊ុន ទំហំភាគលាភអប្បរមាដែលមិនត្រូវបានបែងចែកពេញលេញ នឹងត្រូវបង្គរទៅឆ្នាំបន្ទាប់រហូតដល់ការបែងចែកអាចធ្វើទៅបាន។ ក្នុងករណីមូលនិធិដែលអាចត្រូវបានប្រកាស និងបែងចែកជាភាគលាភតូចជាងភាគលាភអប្បរមាដែលត្រូវបានធានា ចំនួនរយៈពេលនៃការធានាភាគលាភអប្បរមាដែលនៅសល់ នឹងត្រូវពន្យារទៅមុខដោយរាប់ចាប់ពីឆ្នាំបន្ទាប់។

**១.២.ការប្រកាសភាគលាភ**

ការជូនដំណឹងស្តីពីការបែងចែកភាគលាភ នឹងត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ភាគហ៊ុនិក។

**១.៣. ការទូទាត់ភាគលាភ**

ក្រុមប្រឹក្សាភិបាលមានសិទ្ធិកំណត់ប្រាក់ចំណេញសុទ្ធមួយផ្នែក ដែលសមស្របសម្រាប់ទុកជាទុនបម្រុងដើម្បីប្រើប្រាស់ក្នុងប្រតិបត្តិការអាជីវកម្ម ស្របតាមច្បាប់ និងបទបញ្ញត្តិដែលមានជាធរមាន។

ករណីក្រុមហ៊ុនបានទទួលរងនូវការខាត ភាគលាភនឹងមិនត្រូវបានបែងចែកឡើយ រហូតដល់ការខាតបង់នោះត្រូវបានដោះស្រាយឡើងវិញ។

**២.ព័ត៌មាននៃការបែងចែកភាគលាភសម្រាប់រយៈពេល ៣ឆ្នាំ ចុងក្រោយ**

| ល.រ | ពិពណ៌នាលម្អិតអំពីការបែងចែងភាគលាភ | ២០២២ | ២០២១ | ២០២០ |
|---|---|---|---|---|
| ១ | កាលបរិច្ឆេទប្រកាសបែងចែកភាគលាភ (ការអនុម័តរបស់ភាគហ៊ុនិក) | ៣១ ឧសភា ២០២២ | គ្មាន | គ្មាន |
| ២ | កាលបរិច្ឆេទកំណត់ទុក | ១៤ មិថុនា ២០២២ | គ្មាន | គ្មាន |
| ៣ | កាលបរិច្ឆេទទូទាត់ភាគលាភ | ២៣ មិថុនា ២០២២ | គ្មាន | គ្មាន |

## ផ្នែកទី២៖ ក្រុមប្រឹក្សាភិបាល

### ក. ក្រុមប្រឹក្សាភិបាល

#### ១. សមាសភាពក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទក្លាយជាអភិបាល | កាលបរិច្ឆេទបញ្ចប់អាណត្តិបច្ចុប្បន្ន |
|---|---|---|---|---|
| ១ | លោក នាង វិធី | ប្រធានក្រុមប្រឹក្សាភិបាល និងនាយកគ្រប់គ្រង | ១០ មីនា ២០១៩ | ១០ មីនា ២០២២ |
| ២ | លោកស្រី លឹម មុយលី | អភិបាលប្រតិបត្តិ និងនាយកហិរញ្ញវត្ថុ | ១២ តុលា ២០២០ | ១២ តុលា ២០២៣ |
| ៣ | លោក ហ៊ុយ វ៉ាថារ៉ូ | អភិបាលឯករាជ្យ | ១២ តុលា ២០២០ | ១២ តុលា ២០២៣ |
| ៤ | លោក ថៃ វ៉ាន់ថា | អភិបាលមិនប្រតិបត្តិ | ១២ តុលា ២០២០ | ១២ តុលា ២០២៣ |
| ៥ | លោក RAMI Bashir Asad Sharaf | អភិបាលមិនប្រតិបត្តិ | ៣១ ឧសភា ២០២២ | ៣១ ឧសភា ២០២៥ |

#### ២. ប្រវត្តិរូបសង្ខេបរបស់អភិបាល

| ល.រ | ឈ្មោះ | តួនាទី | បទពិសោធន៍ |
|---|---|---|---|
| ១ | លោក នាង វិធី | ប្រធានក្រុមប្រឹក្សាភិបាល និងនាយកគ្រប់គ្រង | លោក នាង វិធី ជាស្ថាបនិករបស់ឌី ប៊ី ឌី។ ឌី ប៊ី ឌី គឺជាក្រុមហ៊ុនជំនាញវិស្វកម្ម និងសំណង់ ដែលធ្វើប្រតិបត្តិការជាង ២០ឆ្នាំ កន្លងមកហើយ។ លោកគឺជានាយកគ្រប់គ្រង ដែលមានចំណេះដឹង និងបទពិសោធន៍ជាច្រើនពាក់ព័ន្ធនឹងផ្នែកវិស្វកម្ម និងសំណង់។ លោកមានជំនាញតម្លើងប្រអប់បញ្ជា និងធ្លាប់ជាវិស្វករអគ្គិសនី និងគម្រោងនៅប្រទេសបារាំង និងប្រទេសកម្ពុជា មុនពេលលោកបង្កើត ឌី ប៊ី ឌី។ ជាមួយនឹងបទពិសោធន៍របស់លោករយៈពេល ១២ឆ្នាំ នៅប្រទេសបារាំង និង២៣ឆ្នាំ នៅប្រទេសកម្ពុជា លោកនាង វិធី បានដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រេចចិត្ត និងការទទួលខុសត្រូវក្នុងការដឹកនាំបេសកកម្ម ការគ្រប់គ្រងផែនការ និងយុទ្ធសាស្ត្ររបស់ក្រុមហ៊ុនប្រកបដោយប្រសិទ្ធភាព។ លោកទទួលបានបរិញ្ញាបត្រផ្នែកវិស្វកម្ម ប្រព័ន្ធអគ្គិសនី នៅទីក្រុងលីយ៉ុង ប្រទេសបារាំង។ |
| ២ | លោកស្រី លឹម មុយលី | អភិបាលប្រតិបត្តិ និងនាយកហិរញ្ញវត្ថុ | លោកស្រីលឹម មុយលី គឺជានាយកហិរញ្ញវត្ថុរបស់ ឌី ប៊ី ឌី។ លោកស្រីមានបទពិសោធន៍ជាច្រើនឆ្នាំពាក់ព័ន្ធនឹងការងារឡូជីស្ទីក គណនេយ្យ និងហិរញ្ញវត្ថុ។ លោកស្រីទទួលខុសត្រូវក្នុងការងារ ស្វែងរកមូលធនសម្រាប់ចំណាយរបស់គម្រោង ធានានូវលំហូរសាច់ប្រាក់ |

| | | | |
|---|---|---|---|
| | | | និងអនុវត្តនូវស្តង់ដារគណនេយ្យប្រកបដោយប្រសិទ្ធភាព។ លោកស្រីមានសញ្ញាបត្របរិញ្ញាបត្រផ្នែកគណនេយ្យពីវិទ្យាស្ថានវ៉ាន់ដា។ |
| ៣ | លោក ហ៊ុយ វ៉ាំថារ៉ូ | អភិបាល ឯករាជ្យ | លោក ហ៊ុយ វ៉ាំថារ៉ូ គឺជាអភិបាលឯករាជ្យរបស់ ឌី ប៊ី ឌី។ លោកគឺជានាយកគ្រប់គ្រង និងជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ក្រុម-ហ៊ុនធានារ៉ាប់រងបន្ត កម្ពុជា រី និងជាប្រធានក្រុមប្រឹក្សាភិបាលនៃសមាគមធានារ៉ាប់រងកម្ពុជាតាំងពីឆ្នាំ២០១៤ មក។ លោកមានបទពិសោធន៍ក្នុងវិស័យហរិញ្ញវត្ថុជាង ២០ឆ្នាំ មកហើយ។ លោកមានសញ្ញាបត្រអនុបណ្ឌិតផ្នែកអភិវឌ្ឍអន្តរជាតិ ពីសាកលវិទ្យាល័យអន្តរជាតិប្រទេសជប៉ុន (ទីក្រុង Nigata ប្រទេសជប៉ុន) សញ្ញាបត្របរិញ្ញាបត្រសេដ្ឋកិច្ចពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសញ្ញាបត្រផ្នែកបច្ចេកទេសអគ្គិសនី នៅវិទ្យា-ស្ថានបច្ចេកវិទ្យាប្រទេសកម្ពុជា។ |
| ៤ | លោក ថៃ វ៉ាន់ថា | អភិបាល មិនប្រតិបត្តិ | លោក ថៃ វ៉ាន់ថា គឺជាអភិបាលមិនប្រតិបត្តិ របស់ ឌី ប៊ី ឌី។ លោកជាអគ្គនាយករង ក្រុមហ៊ុន អ៊ីរ៉ូទិច អាហ័រណេ នីហ័រណេ ខូអិលធីឌី តាំងពីឆ្នាំ២០០០ និងជាស្ថានិក Home Photography តាំងពីឆ្នាំ២០១៩។ លោកមានសញ្ញាបត្របរិញ្ញាបត្រ និងអនុបណ្ឌិតផ្នែករដ្ឋបាលធុរកិច្ច ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង។ |
| ៥ | លោក RAMI Bashir Asad Sharaf | អភិបាល មិនប្រតិបត្តិ | លោក RAMI គឺជាអភិបាលមិនប្រតិបត្តិរបស់ ឌី ប៊ី ឌី តំណាងឱ្យរ៉ូយ៉ាល់ គ្រុប។ បច្ចុប្បន្ន លោកកាន់តំណែងជាន់ខ្ពស់សំខាន់ រួមមាន អគ្គនាយករងជាន់ខ្ពស់ប្រចាំនៅក្រុមហ៊ុនជាច្រើនដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រ៉ូយ៉ាល់ គ្រុប និងធ្លាប់ ជានាយកប្រតិបត្តិនៅក្នុងក្រុមហ៊ុនជាច្រើននៅកម្ពុជា ផងដែរ។ ជាមួយរ៉ូយ៉ាល់ គ្រុប លោកបានក្លាយជាអភិបាលនៃធនាគារ វីង (ខេមបូឌា) ម.ក និងក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតខ្នាតតូចកម្ពុជា "ខេមឡៃហ្វ" ម.ក ។ នៅក្នុងមុខតំណែងជាច្រើនរបស់លោក លោក RAMI បានចែករំលែកដល់កំនើន និងភាពជោគជ័យរបស់ក្រុមហ៊ុនតាមរយៈជំនាញរៀបចំផែនការយុទ្ធសាស្ត្រ ការគ្រប់គ្រងការលក់ និងជំនាញចរចារដ៏ប៉ិនប្រសព្វរបស់លោក។ |

### ៣. ករណីអភិបាលណាមួយជាអភិបាល ភាគហ៊ុនិក ឬសហកម្មសិទ្ធិរបស់ក្រុមហ៊ុនផ្សេងទៀត

| ល.រ. | ឈ្មោះអភិបាល | ឈ្មោះក្រុមហ៊ុនពាក់ព័ន្ធ | អភិបាល ឬភាគហ៊ុនិក ឬសហកម្មសិទ្ធិករ |
|---|---|---|---|
| ១ | លោក ហ៊ុយ វ៉ាំថារ៉ូ | ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជារី | នាយកគ្រប់គ្រង និងជាសមាជិកក្រុមប្រឹក្សាភិបាល |
| | | | ប្រធានក្រុមប្រឹក្សាភិបាល |
| | | សមាគមធានារ៉ាប់រងកម្ពុជា | |

| | | | |
|---|---|---|---|
| | | | |
| ២ | លោក ថៃ វ៉ាន់ថា | ក្រុមហ៊ុន Home Photography | ម្ចាស់ក្រុមហ៊ុន |
| ៣ | លោក RAMI Bashir Asad Sharaf | ធនាគារ វីង (ខេមបូឌា) ម.ក<br>ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតខ្នាតតូចកម្ពុជា "ខេមឡៃហ្វ" ម.ក | អភិបាល |

## ៤. សិទ្ធិអំណាច និងភារកិច្ចរបស់ក្រុមប្រឹក្សាភិបាល និងការអនុវត្ត

ឌី បី ឌី ស្ថិតនៅក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាភិបាល។ យោលតាមលក្ខន្តិកៈរបស់ ឌី បី ឌី ក្រុមប្រឹក្សាភិបាលមានសិទ្ធិអំណាចជាទូទៅក្នុងការគ្រប់គ្រងក្រុមហ៊ុនដែលរួមមានដូចខាងក្រោមៈ

- ធានាថាក្រុមហ៊ុនធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពជាមួយភាគហ៊ុនិក និងភាគីពាក់ព័ន្ធ
- បង្កើត តាមដាន និងវាយតម្លៃផែនការយុទ្ធសាស្ត្រ និងផែនការធុរកិច្ចរបស់ក្រុមហ៊ុន និងធានាថាធនធានត្រូវបានរៀបចំជាស្រេច ដើម្បីឆ្លើយតបគោលដៅដែលបានកំណត់
- បង្កើត តាមដាន និងវាយតម្លៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង
- បង្កើត តាមដាន និងវាយតម្លៃប្រសិទ្ធភាពសវនកម្ម
- បង្កើត និងតាមដានគោលនយោបាយគ្រប់គ្រងហានិភ័យ
- រៀបចំគោលនយោយបាយស្តីពីប្រាក់បំណាច់
- កំណត់លក្ខណៈវិនិច្ឆ័យ និងនីតិវិធីជ្រើសតាំងអភិបាល
- តែងតាំង និងដកហូតពីមុខតំណែង ជាលេខាធិការក្រុមហ៊ុន ប្រធានសវនកម្មផ្ទៃក្នុង និងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពការងាររបស់ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាល
- ធានាសាធនភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដោយបំពេញតួនាទី និងភារកិច្ចឲ្យអស់ពីលទ្ធភាព
- បង្កើតយន្តការ និងនីតិវិធីនៃការការពារសិទ្ធិរបស់ភាគហ៊ុនិក ដោយធានាថាភាគហ៊ុនិកដែលបានកាន់កាប់ភាគហ៊ុនភាគតិចក៏មានសិទ្ធិចូលរួមឈរឈ្មោះជាអភិបាល ឬស្នើបេក្ខភាពអភិបាល
- បង្កើតយន្តការ និងនីតិវិធីនៃការបោះឆ្នោតក្នុងមហាសន្និបាតភាគហ៊ុនិក ជាអាទិ៍ ការដាក់ឲ្យអនុវត្តប្រព័ន្ធបោះឆ្នោតត្រួត ដើម្បីធានាបាននូវការការពារផលប្រយោជន៍របស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិច
- បង្កើតយន្តការអនុញ្ញាតឲ្យភាគហ៊ុនិកដែលមានសិទ្ធិកាន់កាប់ភាគហ៊ុនចំនួនច្រើន និងភាគហ៊ុនិកដែលមានសិទ្ធិកាន់កាប់លើភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនលើសលប់ បង្ហាញព័ត៌មានដល់សាធារណៈជនតាមរយៈក្រុមហ៊ុនពាក់ព័ន្ធនឹងការប្រែប្រួលការកាន់កាប់ភាគហ៊ុន
- បង្កើតយន្តការ និងនីតិវិធីពាក់ព័ន្ធនឹងប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ
- បង្កើតគោលនយោបាយផ្សេងៗទៀតរបស់ក្រុមហ៊ុន
- ត្រូវអនុវត្តតាមច្បាប់ និងបទបញ្ញត្តិដែលមានជាធរមាន
- តួនាទីនានាដែលតម្រូវដោយច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនានាជាធរមាន។

នៅក្នុងឆ្នាំ២០២២ ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន ឌី បី ឌី បានយកចិត្តទុកដាក់ខ្ពស់ចំពោះការអនុវត្តតួនាទី និងការទទួលខុសត្រូវចំពោះភាគហ៊ុនិក និងក្រុមហ៊ុនទាំងមូល ដើម្បីសម្រេចតាមផែនការអាជីវកម្ម និងជានាឱ្យបាននូវការលូតលាស់នៃអាជីវកម្មរបស់ឌី បី ឌី។ ដោយលក្ខណៈនៃអាជីវកម្មរបស់ ឌី បី ឌី ពឹងផ្អែកយ៉ាងសំខាន់ទៅលើគម្រោងសាងសង់ និងសេវាជុសជុលថែទាំ យើងបានខំខិតស្វែងរកឱកាសទីផ្សារ និងគម្រោងថ្មីៗ ដើម្បីរក្សាឱ្យបាននូវកំនើននៃប្រាក់ចំណូលរបស់យើង។ ទន្ទឹមគ្នានេះដែរ យើងក៏បានប្រឹងប្រែងអនុវត្តនូវលក្ខខណ្ឌអភិបាលកិច្ចសាជីវកម្មតួយ៉ាងគឺការរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក គោលនយោបាល គោលការណ៍ និងយន្តការនានា ដើម្បីជានានូវអភិបាលកិច្ចរឹងមាំសម្រាប់ក្រុមហ៊ុន។ យើងក៏មិនធ្វេសប្រហែសចំពោះការកាតព្វកិច្ចបង្ហាញព័ត៌មានទាន់ពេល និងតាមគ្រា។ ក្រុមប្រឹក្សាភិបាលនៃ ឌី បី ឌី បានរៀបចំយ៉ាងទៀតទាត់ប្រចាំត្រីមាស ដើម្បីពិភាក្សាលើហានិភ័យ យុទ្ធសាស្ត្រអាជីវកម្ម ផែនការអាជីវកម្ម ការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង ។ល។ នៅរាល់កិច្ចប្រជុំនីមួយៗ លេខាធិការក្រុមហ៊ុនបានចាត់ចែងរៀបចំឯកសារប្រជុំ និងរក្សាទុកនូវកំណត់ហេតុកិច្ចប្រជុំយ៉ាងត្រឹមត្រូវ ព្រមទាំងផ្តល់ជូននូវកំណត់ហេតុកិច្ចប្រជុំប្រចាំឆ្នាំ២០២២ ជូន**ន.ម.ក.** ស្របតាមការកំណត់ដោយបញ្ញត្តិជាធរមានផងដែរ។

### ៥. ការប្រជុំក្រុមប្រឹក្សាភិបាល

| ល.រ | កាលបរិច្ឆេទ | ប្រភេទនៃកិច្ចប្រជុំ | ឈ្មោះអភិបាលដែលបានចូលរួម |
|---|---|---|---|
| ១ | ៣០ មិនា ២០២២ | កិច្ចប្រជុំសាមញ្ញ | ៤ |
| ២ | ០២ ឧសភា ២០២២ | កិច្ចប្រជុំវិសាមញ្ញ | ៥ |
| ៣ | ០៥ កក្កដា ២០២២ | កិច្ចប្រជុំសាមញ្ញ | ៥ |
| ៤ | ១០ តុលា ២០២២ | កិច្ចប្រជុំសាមញ្ញ | ៥ |

## ខ.គណៈកម្មាធិការក្រុមប្រឹក្សាភិបាល

### ១. រចនាសម្ព័ន្ធគណៈកម្មាធិការក្រុមប្រឹក្សាភិបាល

#### ១.១ គណៈកម្មាធិការសវនកម្ម

| ល.រ | ឈ្មោះ | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | ហ៊ុយ វ៉ាថារ៉ូ | ប្រធានគណៈកម្មាធិការសវនកម្ម | ១២ តុលា ២០២០ | ១ | ១ |
| ២ | ថៃ វ៉ាន់ថា | សមាជិក | ១២ តុលា ២០២០ | ១ | ១ |
| ៣ | លឹម មុយលី | សមាជិក | ១២ តុលា ២០២០ | ១ | ១ |

- គណៈកម្មាធិការសវនកម្មមានតួនាទី និងភារៈកិច្ចដូចខាងក្រោមៈ

    ១. ពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុទាំងអស់

    ២. ពិនិត្យលើការត្រួតពិនិត្យផ្ទៃក្នុង

៣. ពិនិត្យលើការធ្វើសវនកម្មផ្ទៃក្នុង

៤. ពិនិត្យលើការធ្វើសវនកម្មដោយសវនករឯករាជ្យ

៥. រាយការណ៍ និងផ្តល់របាយការណ៍ជូនក្រុមប្រឹក្សាភិបាល និង

៦. អនុវត្តកិច្ចការផ្សេងទៀតដែលកំណត់ដោយក្រុមប្រឹក្សាភិបាល។

- លទ្ធផលការងាររបស់គណៈកម្មាធិការសវនកម្ម
  គណៈកម្មាធិការសវនកម្មបានប្រជុំក្រៅផ្លូវការជាច្រើនលើកច្រើនសារជាមួយសមាជិកដែលជាអភិបាល និងបុគ្គលិកជាន់ខ្ពស់ ព្រមទាំងសវនករផ្ទៃក្នុង ដើម្បីពិនិត្យរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស ប្រចាំឆ្នាំ និងកិច្ចការសវនកម្មផ្ទៃក្នុង។ គណៈកម្មាធិការបានផ្តល់ការណែនាំឱ្យក្រុមហ៊ុនខិតខំពន្លឿនកិច្ចការសវនកម្មផ្ទៃក្នុង និងបានពិនិត្យលើគោលការណ៍ស្តីពីសវនកម្មផ្ទៃក្នុងថែមទៀតផងដែរ។

**១.២. ការប្រែប្រួលសមាជិកនៅក្នុងគណៈកម្មាធិការ**

ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក មិនមានការប្រែប្រួលសមាជិកនៅក្នុងគណៈកម្មាធិការនោះទេ។

**គ. ប្រាក់បំណាច់ ឬលាភការ**

**១. គោលការណ៍ប្រាក់បំណាច់ ឬលាភការសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់**

ឌី ប៊ី ឌី បានរៀបចំនូវគោលនយោបាយស្តីពីប្រាក់បំណាច ឬលាភការសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់រួចរាល់ និងកំពុងពិភាក្សានៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ដើម្បីពិនិត្យលើកត្តា និងលក្ខខណ្ឌនៃការទទួលបានការលើកទឹកចិត្តរបស់អភិបាល លទ្ធផលការងាររបស់បុគ្គលិកនីមួយៗ លទ្ធផលប្រតិបត្តិការរបស់ក្រុមហ៊ុន និងស្ថានភាពម៉ាក្រូសេដ្ឋកិច្ចរបស់ប្រទេស មុនពេលដាក់សម្រាប់ការអនុវត្តក្នុងពេលឆាប់ៗនេះ។

**២. បុគ្គលទទួលបានលាភការ ឬប្រាក់បំណាច់**

| ល.រ. | បុគ្គលទទួលបានលាភការ ឬប្រាក់បំណាច់ | ចំនួនសរុបលាភការ ឬប្រាក់បំណាច់ (ដុល្លាអាមេរិក) |
|---|---|---|
| ១. | អភិបាល | ៣៦,៣០០ |
| ២. | អភិបាលប្រតិបត្តិ | ១៤៨.៧៦៤ |
| ៣. | បុគ្គលិកជាន់ខ្ពស់ | ៥០៣.៩១៣,០៦ |
| ៤. | បុគ្គលិកទទួលបានលាភការ ឬប្រាក់បំណាច់ខ្ពស់បំផុត ៥រូប | ៦៨.៤៣៩,៧៤ |

**ឃ. ការវាយតម្លៃលទ្ធផលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល អភិបាលនីមួយៗ គណៈកម្មាធិការ និងនាយកប្រតិបត្តិ**

នៅក្នុងឆ្នាំ ២០២២ ក្រុមហ៊ុនកំពុងសិក្សាអំពីនីតិវិធី និងលក្ខណៈវិនិច្ឆ័យ សម្រាប់ការវាយតម្លៃលទ្ធផលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល អភិបាលនីមួយៗ គណៈកម្មាធិការ និងនាយកប្រតិបត្តិ និងគ្រោងអនុវត្តនៅក្នុងឆ្នាំ២០២៣។

### ង. ការបណ្តុះបណ្តាលសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

ឌី ប៊ី ឌី បានរៀបចំវគ្គបណ្តុះបណ្តាល និងអញ្ជើញក្រុមការងារ ន.ម.ក. ដើម្បីផ្តល់ជាចំណេះដឹងដល់ អភិបាល បុគ្គលិកជាន់ខ្ពស់ និងបុគ្គលិករបស់ក្រុមហ៊ុន ពាក់ព័ន្ធនឹងការបង្ហាញព័ត៌មាន អភិបាលកិច្ចសាជីវកម្ម ទីផ្សារមូលបត្រ ជាដើម។

ក្រៅពីការបណ្តុះបណ្តាលក្នុងវិស័យមូលបត្រ ឌី ប៊ី ឌីក៏បានរៀបចំការបណ្តុះបណ្តាលក្នុងស្រុកផងដែរ។

| ល.រ. | ឈ្មោះ | វគ្គ/ជំនាញ | កាលបរិច្ឆេទ |
|---|---|---|---|
| ១ | លោកស្រី លឹម មុយលី<br>លោក នង បំណាង | យុទ្ធសាស្រ្តរៀបចំប្រព័ន្ធគ្រប់គ្រងធនធានមនុស្សនិងKPI | ២១ មករា ដល់ ២១ ឧសភា ២០២២ |

## ផ្នែកទី៣៖ ការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច

## ក. ការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច

### គោលបំណង និងតម្លៃស្នូល

បេសកកម្មរបស់ ឌី ប៊ី ឌី គឺបង្កើតឈ្មោះក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង និងសំណង់ដោយរក្សាគុណភាពល្អប្រសើរ និងការទទួលខុសត្រូវ ភាពឆ្លាតវៃ និងសេវាកម្មបម្រើអតិថិជនប្រកបដោយការប្រកួតប្រជែងឱ្យនៅដដែលដូចដែលធ្លាប់បានផ្តល់អោយតាំងពីឆ្នាំ ១៩៩៨ មកម្លេះ។

តម្លៃស្នូលរបស់យើងត្រូវបានទទួលស្គាល់ថា ធុរកិច្ចជោគជ័យត្រូវបានរកឃើញអាស្រ័យលើការប្តេជ្ញាចិត្តចំពោះគោលការណ៍ពិតប្រាកដ។

### បុគ្គលិក

ជំនាញ ចំណង់ចំណូលចិត្ត និងតាមរយៈការដឹកនាំរបស់បុគ្គលិកដែលមានទេព្យកោសល្យ ធ្វើឱ្យភាពជោគជ័យរបស់យើងសម្រេចបាន។ យើងគោរព និងលើកទឹកចិត្ត គំនិត ភាពចម្រុះ និងវប្បធម៌របស់បុគ្គលិកយើង។

### អតិថិជន

យើងប្តេជ្ញាចិត្តចំពោះអតិថិជនរបស់យើង និងបង្កើតឧស្សាហកម្មស្តង់ដារ ក្នុងការផ្តល់សេវាកម្ម និងការចែកចាយ។

យើងទទួលយកភាពជាម្ចាស់ក្នុងការដោះស្រាយបញ្ហារបស់អតិថិជនរបស់យើង និងការចូលរួមក្នុងឱកាសថ្មីៗ។

### ឧត្តមភាព

យើងជឿជាក់លើការផ្តល់នូវឧត្តមភាពឥតខ្ចោះទៅលើអ្វីគ្រប់យ៉ាងដែលយើងធ្វើ។

### សុចរិតភាព

យើងត្រូវតែប្រកាន់ខ្ជាប់នូវការប្តេជ្ញាចិត្តរបស់យើងក្នុងការធ្វើសកម្មភាពប្រកបដោយក្រមសីលធម៌ និងសុចរិតភាពនៅក្នុងអ្វីដែលយើងធ្វើរាល់ថ្ងៃ។

### សុវត្ថិភាព

យើងជាក្រុមហ៊ុនដែលផ្តល់សុវត្ថិភាពខ្ពស់។ យើងទាំងអស់គ្នាមានការទទួលខុសត្រូវក្នុងការរក្សាខ្លួនរបស់យើង និងមិត្តរួមការងាររបស់យើងឱ្យមានសុវត្ថិភាព និងរាល់ការបំពេញការងារឱ្យអតិថិជនប្រកបដោយសុវត្ថិភាព។

### ការច្នៃប្រឌិត

ក្រុមហ៊ុនរបស់យើងមានភាពខុសគេដោយសារតែយើងប្រឈមខ្លួនឯង ដើម្បីស្វែងរកវិធីសាស្ត្រថ្មីក្នុងការចែកចាយជំនាញរបស់យើង តាមរយៈដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិតដែលអាចឲ្យអតិថិជនម្នាក់ៗអាចដឹងពីចក្ខុវិស័យរបស់ខ្លួន។

## សុចរិតភាពនូវអ្វីដែលយើងធ្វើ

នៅ ឌី ប៊ី ឌី យើងប្តេជ្ញាចិត្តធ្វើអ្វីដែលត្រឹមត្រូវនូវអ្វីដែលធ្វើទាំងអស់។ យើងជឿជាក់ថាការប្តេជ្ញាចិត្តចំពោះភាពស្មោះត្រង់បានធ្វើឱ្យក្រុមហ៊ុនរបស់យើងក្លាយជាអ្នកដឹកនាំឧស្សាហកម្ម និងនៅតែបន្តការរីកចម្រើនទៅមុខទៀត។ ក្រមសីលធម៌វិជ្ជាជីវៈ (ក្រម) បង្ហាញពីគុណតម្លៃវិជ្ជាជីវៈ សីលធម៌ ហិរញ្ញវត្ថុ និងសង្គមរបស់ក្រុមហ៊ុនយើង។ វាកំណត់នូវអ្វីដែលជាការរំពឹងទុករបស់និយោជិក របស់ ឌី ប៊ី ឌី និងគ្រប់ទីកន្លែងដែលយើងធ្វើជំនួញ។ ក្រមរបស់យើងតំណាងឱ្យការប្តេជ្ញាចិត្តរបស់យើងចំពោះអតិថិជន ម្ចាស់ភាគហ៊ុន ដៃគូ និងសហគមន៍ដែលយើងរស់នៅ និងធ្វើការ។

គុណតម្លៃស្នូលរបស់យើងគឺជាគ្រឹះសម្រាប់ក្រមនេះ។ ខាងក្រោមនេះគឺជាគោលការណ៍ណែនាំសម្រាប់ឥរិយាបទដែលយើងត្រូវតែអនុវត្តតាមៈ

- ឥរិយាបទខាងសីលធម៌គឺជាមូលដ្ឋានសម្រាប់អ្វីគ្រប់យ៉ាងដែលយើងធ្វើ។
- ឌី ប៊ី ឌី មានការប្តេជ្ញាចិត្តក្នុងការប្រព្រឹត្តចំពោះនិយោជិករបស់ខ្លួនដោយស្មើភាព និងផ្តល់ឱ្យយើងម្នាក់ៗនូវឱកាសសម្រាប់ការរីកចម្រើន និងលូតលាស់។
- ការធ្វើការងារជាក្រុម ការគោរពគ្នាទៅវិញទៅមក និងការជឿទុកចិត្តគ្នា និងការប្រាស្រ័យទាក់ទងគ្នាគឺជាគ្រឹះនៃវប្បធម៌របស់ ឌី ប៊ី ឌី។
- ការបំពេញតម្រូវការរបស់អតិថិជនមានសារៈសំខាន់បំផុត។
- យើងប្តេជ្ញាគោរពតាមច្បាប់ វិធាន និងបទបញ្ញារបស់រាជរដ្ឋាភិបាលកម្ពុជា។

## ឌី ប៊ី ឌី មួយ ក្រម មួយ

យើងទាំងអស់គ្នាមានកាតព្វកិច្ចអាន យល់ និងធ្វើតាមសីលធម៌វិជ្ជាជីវៈនេះ។ វាអនុវត្តចំពោះសហសេវិកទាំងអស់ វិស្វករមន្ត្រី និងនាយក រួមបញ្ចូលទាំងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់យើង និងក្រុមហ៊ុនបណ្តាក់ទុនរួមគ្នា ដែលមានចំណាប់អារម្មណ៍ភាគច្រើនទៅលើ ឌី ប៊ី ឌី ។ លើសពីនេះទៀត យើងរំពឹងថាអ្នកផ្គត់ផ្គង់ ភ្នាក់ងារ ដៃគូអាជីវកម្ម។

## ក្រុមហ៊ុនម៉ៅការ

ក្រុមហ៊ុនម៉ៅការបន្ត និងភាគីទីបីផ្សេងទៀតត្រូវដឹងហើយនឹងធ្វើតាមគោលការណ៍ស្រដៀងគ្នានៃស្តង់ដារសីលធម៌ទាំងនេះដូចដែលបានបញ្ជាក់នៅទីនេះ។ ការប្រើប្រាស់ក្រមរបស់យើងអនុញ្ញាតឱ្យយើងរក្សាកេរ្តិ៍ឈ្មោះក្នុងការធ្វើធុរកិច្ចតាមរបៀបត្រឹមត្រូវ។

ចុងបញ្ចប់ យើងម្នាក់ៗត្រូវតែៈ

- គោរពតាមក្រមនេះ
- មិនត្រូវជួយអ្នកដទៃក្នុងការរំលោភច្បាប់នេះ
- បញ្ចប់វគ្គបណ្តុះបណ្តាលស្តីពីក្រមសីលធម៌ និងការរៀនសូត្រ ឱ្យបានទាន់ពេលវេលា។

អ្នកត្រូវទទួលខុសត្រូវក្នុងការអាន និងយល់នូវក្រមនេះ និងរំពឹងថាមិនមានការរំលោភបំពាន។ ការរំលោភក្រមនេះនឹងបណ្តាលឱ្យមានវិធានការដោះស្រាយ។

## យើងពឹងផ្អែកទៅលើការគោរពរបស់បុគ្គលិករបស់យើង

## ការប្តេជ្ញាចិត្តរបស់យើងចំពោះការធ្វើពិពិធកម្ម

ឌី ប៊ី ឌី ប្តេជ្ញាចិត្តក្នុងការជម្រុញកន្លែងធ្វើការដែលយើងទាំងអស់គ្នាបង្កើតឡើងដោយសេចក្តីថ្លៃថ្នូរ និងការគោរព។ យើងជឿជាក់ថាភាពខុសគ្នារវាងប្រវត្តិ បទពិសោធន៍ និងទស្សនៈវិស័យរបស់យើងផ្តល់ឱ្យក្រុមហ៊ុនរបស់យើងមានភាពខ្លាំងដែលយើងត្រូវការដើម្បីដឹកនាំទីផ្សារ និងឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់យើងចំពោះការធ្វើពិពិធកម្ម។ យើងទាំងអស់គ្នាមានទំនួលខុសត្រូវក្នុងការប្រព្រឹត្តចំពោះសហសេវិករបស់យើង ក៏ដូចជាអ្នកដាក់ពាក្យសុំការងារ ដោយការគោរព និងដោយមិនរើសអើង។

ឌី ប៊ី ឌី ផ្តល់នូវឱកាសការស្មើៗគ្នាសម្រាប់បេក្ខជនទាំងអស់។ នេះផ្តល់ឱ្យយើងម្នាក់ៗនូវការគិតពិចារណាស្មើៗគ្នាសម្រាប់ការងារដោយមិនគិតពីប្រវត្តិ។ ការរក្សាកន្លែងធ្វើការប្រកបដោយការគោរពក៏មានន័យថាយើងមិនបានចូលរួម ឬអត់ធ្មត់នឹងការរំខានយាយីណាមួយឡើយ។ ដើម្បីឱ្យកាន់តែច្បាស់ "ការរំខានយាយី" គឺជាសកម្មភាពដែលបង្កើត ឬស្វែងរកការបង្កើតអរិភាព ការបំភិតបំភ័យ ឬការបំពាននៅក្នុងបរិយាកាស។ ការរំខានយាយីអាចរួមមានប៉ុន្តែមិនកំណត់ត្រឹម៖

- ពាក្យសម្តី (អនុសាសន៍ សំណូមពរ កំប្លែង ឬស្នើសុំក្នុងការរួមភេទ)
- រូបភាព (ការគូររូប រូបថត ឬវីដេអូ)
- អាកប្បកិរិយារាងកាយ (រូបរាងគួរឲ្យចង់សើចឬការប៉ះដែលមិនពេញចិត្ត)។

## រក្សាទីកន្លែងការងាររបស់យើងឱ្យមានសុវត្ថិភាព

សុវត្ថិភាពគឺជាគុណតម្លៃស្នូល ឌី ប៊ី ឌី និងសុវត្ថិភាព របស់បុគ្គលិក ទ្រព្យសម្បត្តិ រាងកាយ និងបរិស្ថានដែលយើងធ្វើប្រតិបត្តិការគឺជាការទទួលខុសត្រូវរួមគ្នារបស់និយោជិក ឌី ប៊ី ឌី ម្នាក់ៗ។ យើងម្នាក់ៗមានទំនួលខុសត្រូវខាងសីលធម៌ និងច្បាប់ តាមរយៈការអនុវត្តតាមច្បាប់ និងបទបញ្ញត្តិដែលត្រូវអនុវត្ត ក៏ដូចជាតម្រូវការផ្ទៃក្នុងរបស់យើងដែលទាក់ទងទៅនឹងសុវត្ថិភាព សុខភាព និងបរិស្ថាននៃការងារដែលយើងធ្វើ និងកន្លែងដែលយើងគ្រប់គង។

## ដឹកនាំដោយសមធម៌

ការគ្រប់គ្រងរបស់យើងបម្រើឱ្យធនធាន និងតម្រូវដល់ការធ្វើធុរកិច្ច។ ដោយហេតុផលនេះអ្នកគ្រប់គ្រងមានទំនួលខុសត្រូវបន្ថែមនៅពេលនិយាយអំពីការលើកស្ទួយក្រុមរបស់យើង។ ពួកគេត្រូវបានគេរំពឹងថានឹងលើកកម្ពស់បរិយាកាសការងារជាវិជ្ជ ដែលបុគ្គលិកទាំងអស់ត្រូវបានគេគោរពដោយសេចក្តីថ្លៃថ្នូរ និងការគោរព និងមានអារម្មណ៍ងាយស្រួលក្នុងការលើកឡើងនូវកង្វល់ដែលមាន។ អ្នកគ្រប់គ្រងក៏ត្រូវខិតខំផងដែរ ដើម្បីបង្កើតវប្បធម៌នៃការអនុវត្ត។ នេះអាចត្រូវបានធ្វើដោយផ្អែកលើ៖

- ដើរតួជាគំរូសម្រាប់ការអនុវត្តក្រម។
- ជំរុញបរិយាកាសលើកទឹកចិត្តឱ្យមានការពិភាក្សាបើកចំហរអំពីកង្វល់ផ្នែកច្បាប់ និងកង្វល់ក្រមសីលធម៌
- ការពារឱ្យបានតឹងរឹងនូវការរំលោភបំពានទៅលើក្រម គោលការណ៍ក្រុមហ៊ុន ឬច្បាប់របស់យើង។

## ឌី ប៊ី ឌី ពឹងផ្អែកទៅលើភាពស្មោះត្រង់របស់យើង

## ជៀសវាងទំនាស់ផលប្រយោជន៍

យើងម្នាក់ៗមានចំណែកផ្ទាល់ខ្លួនក្នុងការធ្វើសកម្មភាពដើម្បីផលប្រយោជន៍ល្អបំផុតរបស់ ឌី បី ឌី ។ ដើម្បីធានាបាននូវភាពជោគជ័យជាបន្តរបស់យើង វាជាការសំខាន់ណាស់ដែលយើងត្រូវចៀសវាងទំនាស់ផលប្រយោជន៍មិនថា ជាក់ស្តែង សក្តានុពល ឬការយល់ឃើញ។ "ទំនាស់ផលប្រយោជន៍" កើតឡើងនៅពេលយើងប្រើជំហររបស់យើងជា ឌី បី ឌី ឬព័ត៌មានដែលយើងទទួលបានក្នុងកំឡុងពេលដែលយើងកំពុងធ្វើការងារ តាមរបៀបមួយដែលអាចបង្កើតឱ្យមានទំនាស់រវាងផលប្រយោជន៍ផ្ទាល់ខ្លួន និងផលប្រយោជន៍របស់ក្រុមហ៊ុន ឬអតិថិជនរបស់យើង។

## អំណោយធុរកិច្ច និងការកំសាន្ត

ការទទួលយក ឬការផ្តល់អំណោយម្តងម្កាល ជាអាហារ ឬការកំសាន្ត ជាមួយដៃគូអាជីវកម្មត្រូវបានអនុញ្ញាតក្នុងកាលៈទេសៈខ្លះ។ ទោះយ៉ាងណាក៏ដោយ យើងត្រូវតែធ្វើសកម្មភាពឱ្យស្របតាមតម្លៃស្នូលរបស់ក្រុមយើង ច្បាប់ផ្សេងៗដែលគ្រប់គ្រងសកម្មភាពរបស់យើង និងតម្រូវការរបស់កិច្ចសន្យា។ អំណោយណាមួយដែលអាចបង្កើតជាកាតព្វកិច្ច ឬមានឥទ្ធិពលលើទំនាក់ទំនងអាជីវកម្មមិនគួរផ្តល់ឱ្យ ឬទទួលយកឡើយ។ សម្រាប់ហេតុផលនេះយើងអាចផ្តល់ជូន ឬទទួលយកអំណោយជាអាហារ ឬការកម្សាន្តស្របតាមច្បាប់ដែលអាចអនុវត្តបាន។

យើងមិនត្រូវផ្តល់ឱ្យ ឬទទួលយកនូវការគួរសមទាំងនេះទេ ប្រសិនបើ៖

- វាខុសច្បាប់នៅក្នុងច្បាប់ ឬបទបញ្ញត្តិដែលអាចអនុវត្តបាន
- វាគឺទម្រង់មួយដែលអង្គភាពអាចចូលរួមក្នុងលទ្ធកម្មសកម្ម។
- វាគឺជាផ្នែកមួយនៃកិច្ចព្រមព្រៀងដែលត្រូវធ្វើ ឬទទួលយកអ្វីត្រលប់មកវិញ។
- វាជាសាច់ប្រាក់ ឬសាច់ប្រាក់សមមូល ដូចជាកាត ឬ វិញ្ញាបនបត្រ ប្រាក់កម្ចី មូលបត្រកម្មសិទ្ធិ។ល។
- វាអាចត្រូវបានបកស្រាយថាជាការសូកសំណូក ឬការសងត្រលប់មកវិញ។
- វាអាចនឹងសមហេតុផលដែលត្រូវបានបកស្រាយថាជារង្វាន់សម្រាប់ការអនុគ្រោះ ការគិតពិចារណាជាក់ស្តែង ឬការយល់ឃើញ ឬការបង្កើតកាតព្វកិច្ចលើភាគីម្ខាងទៀត។

## ការការពារទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន និងទិន្នន័យសម្ងាត់

យើងបានខិតខំជាខ្លាំង ដើម្បីទទួលបានទ្រព្យសម្បត្តិដ៏មានតម្លៃរបស់យើង ទាំងទ្រព្យសម្បត្តិរូបវន្ត និងអរូបី។ ទ្រព្យសម្បត្តិរូបវន្តរបស់ ឌី បី ឌី រួមមានអាគារ គ្រឿងបរិក្ខារ យានយន្ត បរិក្ខារ ប្រព័ន្ធកំព្យូទ័រ ធនធាន និងការកត់ត្រា។ យើងទទួលខុសត្រូវក្នុងការការពារទ្រព្យសម្បត្តិទាំងនោះពីការបាត់បង់ ការខូចខាត ការប្រើប្រាស់មិនត្រឹមត្រូវ ការលួច និងការខ្ជះខ្ជាយ។ យើងអាចធ្វើដូច្នេះបាន លុះត្រាតែមានការប្រើធនធានរបស់ក្រុមហ៊ុនដោយប្រាជ្ញា និងសម្រាប់តែគោលបំណងអាជីវកម្មប៉ុណ្ណោះ។ វាក៏សំខាន់ផងដែរ ក្នុងការការពារទ្រព្យសម្បត្តិអរូបីរបស់យើងដូចជាកេរ្តិ៍ឈ្មោះ និងសុច្ចន្ទៈរបស់យើងនៅក្នុងសហគមន៍ដែលយើងធ្វើប្រតិបត្តិការ។ ទ្រព្យសម្បត្តិទាំងនេះក៏រួមបញ្ចូលព័ត៌មានសម្ងាត់របស់យើងផងដែរ ដូចជា ផែនការអាជីវកម្ម កម្មសិទ្ធិបញ្ញា សំណើ ការឌីសាញ បច្ចេកទេសច្នៃប្រឌិត ការបង្កើតប៉ាតង់ ព័ត៌មានហិរញ្ញវត្ថុ បញ្ជីអតិថិជន និងព័ត៌មានផ្សេងទៀត ដែលយើងបានកែច្នៃ ដែលជាផ្នែកមួយនៃការងាររបស់យើងសម្រាប់ ឌី បី ឌី។

យើងក៏មានកាតព្វកិច្ចការពារទិន្នន័យបុគ្គលិកស្របតាមការអនុវត្តច្បាប់។ គ្មាននរណាម្នាក់អាចទទួលបាន កំណត់ត្រាបុគ្គលិកនាពេលបច្ចុប្បន្ន ឬអតីត ដូចជាប្រាក់ឈ្នួល ការធានារ៉ាប់រង ឯកសារអត្ថប្រយោជន៍ និងការធ្វើការ ដោយគ្មានការអនុញ្ញាតត្រឹមត្រូវ។

## ការប្រើប្រាស់ប្រព័ន្ធកុំព្យូទ័ររបស់ក្រុមហ៊ុន

ដូចគ្នាទៅនឹងកាតព្វកិច្ចការពារទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន យើងក៏មានកាតព្វកិច្ចប្រើប្រាស់ធនធានកំព្យូទ័រ បណ្តាញអ៊ីនធឺណែត និងប្រព័ន្ធអ៊ីម៉ែលប្រកបដោយទំនួលខុសត្រូវ និងសុវត្ថិភាព។ ធនធានទាំងនេះត្រូវបាន ផ្តល់ជូន សម្រាប់គោលបំណងអាជីវកម្ម និងត្រូវបានបម្រុងទុកសម្រាប់ប្រើក្នុងធុរកិច្ច។

## ទីផ្សារពឹងផ្អែកលើភាពស្មោះត្រង់របស់យើង

## ទទួលបានអាជីវកម្មដោយភាពស្មោះត្រង់

ដើម្បីបម្រើដៃគូអាជីវកម្មរបស់យើងឱ្យអស់ពីសមត្ថភាព យើងត្រូវមានភាពស្មោះត្រង់ជានិច្ចអំពីអ្វីដែល ឌី ប៊ី ឌី អាចនឹងសម្រេចបាន និងមិនអាចសម្រេចបាន។ រាល់ពេលដែលយើងពិភាក្សាអំពីសមត្ថភាពរបស់យើង លិខិតបញ្ជាក់ គុណវុឌ្ឍិ និងប្រវត្តិសាជីវកម្ម ដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរក្តី យើងត្រូវតែប្រាកដជាមនុស្សរាប់អាន និង ត្រឹមត្រូវ។

## ការប្រកួតប្រជែងដោយស្មើភាព

ដោយសារ ឌី ប៊ី ឌី ប្រកួតប្រជែងដោយផ្អែកលើគុណភាពនៃផលិតផល និងសេវាកម្ម យើងប្តេជ្ញាលើកកម្ពស់ ការប្រកួតប្រជែងដោយយុត្តិធម៌គ្រប់ពេល។

## ជៀសវាងការអនុវត្តអំពើពុករលួយ

ឌី ប៊ី ឌី មានមោទនភាពចំពោះការងារដែលខ្លួនធ្វើនៅទូទាំងប្រទេស។ យើងជឿជាក់ថាសមត្ថភាពរបស់យើង ក្នុងការបន្តពង្រឹងទំនាក់ទំនងការងារល្អជាមួយក្រុមហ៊ុន សហគមន៍ និងរដ្ឋាភិបាល ទូទាំងប្រទេស គឺពឹងផ្អែកលើការ ធ្វើសកម្មភាពប្រកបដោយក្រមសីលធម៌នៅក្នុងការធ្វើជំនួញរបស់យើង។ នេះមានន័យថាយើងមិនដែលផ្តល់ឱ្យ ឬទទួល យកការទូទាត់មិនត្រឹមត្រូវតាមទម្រង់ណាមួយឡើយ។ ស្រដៀងគ្នានេះដែរ យើងមិនត្រូវផ្តល់ឬសងប្រាក់ត្រឡប់មក វិញដែលជាការត្រឡប់មកវិញនូវប្រាក់ដែលបានបង់រួចហើយ (ឬដោយសារតែត្រូវបង់) ជារង្វាន់សម្រាប់ការរៀបចំ ឬ ជម្រុញការរៀបចំអាជីវកម្ម។ យើងមិនអាចរក្សាទុកភាគីទីបី ឬចូលរួមការបណ្តាក់ទុនរួមគ្នា ឬសមាគមអាជីវកម្មផ្សេង ទៀត ដែលបានចូលរួមក្នុងសកម្មភាពណាមួយដែលយើងត្រូវបានហាមឃាត់មិនឱ្យចូលរួមនៅក្នុងអាជីកម្មយើងឡើយ។

## ភាគហ៊ុនិក ដៃគូអាជីវកម្ម និងអតិថិជន ពឹងផ្អែកលើឧត្តមភាពរបស់យើង

## ការផ្តល់ផលិតផល និងសេវាកម្មដែលមានគុណភាព

មូលដ្ឋានគ្រឹះនៃកេរ្តិ៍ឈ្មោះរបស់ ឌី ប៊ី ឌី គឺគុណភាពខ្ពស់នៃផលិតផល និងសេវាកម្មដែលយើងផ្តល់ជូន។ ដើម្បី រក្សាស្តង់ដាររបស់យើងឱ្យបានខ្ពស់ យើងម្នាក់ៗត្រូវតែអនុវត្តតាមនីតិវិធីត្រួតពិនិត្យគុណភាពទាំងអស់ និងអនុវត្តតាម កិច្ចសន្យាជាក់លាក់គ្រប់ពេលវេលា។

## ការផ្ដល់អាជ្ញាប័ណ្ណ

យើងទទួលខុសត្រូវក្នុងការរក្សាអាជ្ញាប័ណ្ណសមស្រប។ ក្រុមហ៊ុនរបស់យើងប្ដេជ្ញាបង្ហាញសេវាកម្មវិជ្ជាជីវៈតែនៅក្នុងយុត្តាធិការដែលយើងទទួលបានការអនុញ្ញាត ធ្វើដូច្នេះលើកលែងតែមានការលើកលែងដោយច្បាប់ដែលអាចអនុវត្តបាន។

## កំណត់ត្រាគណនេយ្យត្រឹមត្រូវ

យើងម្នាក់ៗត្រូវបំពេញការងាររបស់យើង ដើម្បីធ្វើឱ្យប្រាកដថាឯកសារហិរញ្ញវត្ថុដែលក្រុមហ៊ុនរបស់យើងបង្ហាញជូនសាធារណជនមានភាពត្រឹមត្រូវ និងស្មោះត្រង់។ ព័ត៌មានដែលយើងកត់ត្រាផ្ដល់នូវទស្សនៈត្រឹមត្រូវនៃប្រតិបត្តិការរបស់យើង និងអនុញ្ញាតឱ្យក្រុមហ៊ុនរបស់យើងធ្វើការសម្រេចចិត្តអាជីវកម្មដែលមានព័ត៌មានល្អ។ ដូច្នេះរាល់ព័ត៌មានទាំងអស់ដែលយើងបញ្ចូនទៅក្នុងកំណត់ត្រាក្រុមហ៊ុនត្រូវតែជាព័ត៌មានជាក់លាក់ ត្រឹមត្រូវ និងពេញលេញ។

## ការរក្សាកំណត់ត្រា

ការរក្សាកំណត់ត្រារបស់យើងឱ្យមានសណ្ដាប់ធ្នាប់ជួយឱ្យយើងបង្កើតទំនុកចិត្តជាមួយអតិថិជន និយ័តករ និងភាគហ៊ុនិក។ ការប្ដេជ្ញាចិត្តនេះអនុវត្តទាំងឯកសារជាលាយលក្ខណ៍អក្សរ និងអេឡិចត្រូនិក រួមទាំង សារអេឡិចត្រូនិក និងរូបភាព។ សរុបសេចក្ដីមកយើងត្រូវយកចិត្តទុកដាក់លើរាល់កំណត់ត្រាដែលយើងបង្កើត ទទួលបាន ឬរក្សាដើម្បីបំពេញការងាររបស់យើង។ ការគ្រប់គ្រងកំណត់ត្រាទាំងនេះប្រកបដោយប្រសិទ្ធភាពអនុញ្ញាតឱ្យយើងធានាថាវាអាចរកបាននៅពេលដែលមានតម្រូវការចាំបាច់។

## សវនកម្ម និងការស៊ើបអង្កេត

ក្នុងអំឡុងពេលនៃការងាររបស់អ្នក ក្រុមហ៊ុន ឬអតិថិជន អាចស្នើសុំឱ្យអ្នកចូលរួមក្នុងការធ្វើសវនកម្ម ឬការស៊ើបអង្កេតរបស់ ឌី ប៊ី ឌី ឬនិយោជិកជាក់លាក់។

## សុចរិតភាពហិរញ្ញវត្ថុ

## ការការពារការលាងលុយកខ្វក់

ឌី ប៊ី ឌី ប្ដេជ្ញាជួយក្នុងការប្រយុទ្ធប្រឆាំងនឹងការលាងលុយកខ្វក់ទូទាំងពិភពលោក។ "ការលាងលុយកខ្វក់" គឺជាដំណើរការដែលមនុស្សម្នាក់ ឬក្រុមមនុស្សព្យាយាមលាក់បាំងមូលនិធិខុសច្បាប់ ឬការប៉ុនប៉ងដើម្បីធ្វើឱ្យប្រភពនៃមូលនិធិខុសច្បាប់របស់ពួកគេមើលទៅស្របច្បាប់។ ដើម្បីកុំឱ្យ ឌី ប៊ី ឌី ចូលរួមក្នុងការប្រព្រឹត្តខុសដោយចេតនានេះ យើងគួរឧស្សាហ៍យកចិត្តទុកដាក់ចំពោះអតិថិជន អ្នកផ្គត់ផ្គង់ ភ្នាក់ងារអន្តរការី និងដៃគូរអាជីវកម្មដទៃទៀតដែលមានបំណងធ្វើអាជីវកម្មជាមួយក្រុមហ៊ុនរបស់យើង។

សហគមន៍របស់យើងពឹងផ្អែកលើភាពស្មោះត្រង់ និងការច្នៃប្រឌិតរបស់យើង។

## និរន្តរភាពបរិស្ថាន

ក្នុងនាមជាពលរដ្ឋសាជីវកម្មល្អ យើងអនុវត្តតាមច្បាប់ បទប្បញ្ញត្តិ និងបរិស្ថានទាំងអស់ដែលមានប្រសិទ្ធភាព នៅគ្រប់ទីកន្លែងដែលយើងធ្វើធុរកិច្ច។ ដល់ទីបញ្ចប់នេះ យើងខិតខំឥតឈប់ឈរដើម្បីបង្កើនការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាពនៅក្នុងកន្លែងធ្វើការរបស់យើង និងកាត់បន្ថយស្នាមដានបរិស្ថាន។

**ខ.ការផ្សព្វផ្សាយក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច**

ក្រមសីលធម៌របស់ ឌី ប៊ី ឌី ត្រូវបានបង្ហាញដល់ក្រុមប្រឹក្សាភិបាល បុគ្គលិកជាន់ខ្ពស់ និងបុគ្គលិកទាំងអស់ក៏ដូចជាសាធារណជនផងដែរ។ ជាធម្មតា ក្រុមហ៊ុនធ្វើបទបង្ហាញដល់បុគ្គលិក តាមរយៈការបណ្តុះបណ្តាលផ្ទៃក្នុង និងការប្រជុំ និងជាសាធារណៈ ដោយផ្សព្វផ្សាយនៅលើគេហទំព័ររបស់ក្រុមហ៊ុន។

**គ. យន្តការ និងនីតិវិធីតាមដានការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច**

គិតត្រឹមឆ្នាំ២០២២ ក្រុមហ៊ុនបានកំណត់យន្តការសម្រាប់ការតាមដាន ដោយមានរៀបចំជាគណៈកម្មាធិការត្រួតពិនិត្យការអនុវត្ត ដោយបានរាយការណ៍ផ្ទាល់ទៅគណៈគ្រប់គ្រង ដើម្បីស៊ើបអង្កេត និងចាត់វិធានការតាមផ្លូវច្បាប់។

**ឃ. ប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ**

**១. គោលនយោបាយសម្រាប់គ្រប់គ្រងប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ**

ឌី ប៊ី ឌី បានរៀបចំគោលនយោបាយស្តីពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ ដែលកំពុងពិភាក្សាដោយក្រុមប្រឹក្សាភិបាល។ គោលនយោបាយនេះបានកំណត់នូវបុគ្គលដែលជាភាគីជាប់ពាក់ព័ន្ធ ទំហំប្រតិបត្តិការ និងនីតិវិធីសម្រាប់អនុវត្តប្រតិបត្តិជាមួយភាគីជាប់ពាក់ព័ន្ធបានយ៉ាងច្បាស់លាស់។

| ល.រ | ភាគីជាប់ពាក់ព័ន្ធ | គោលនយោបាយ |
|---|---|---|
| ១ | ក្រុមហ៊ុនហូលឌីង | ក្រុមហ៊ុនមិនមានក្រុមហ៊ុនហូលឌីង |
| ២ | កិច្ចព្រមព្រៀងវិនិយោគចម្រុះ | ក្រុមហ៊ុនមាននូវគោលការណ៍ដាច់ដោយឡែកដើម្បីគ្រប់គ្រងគម្រោងវិនិយោគរបស់ក្រុមហ៊ុន |
| ៣ | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | ក្រុមហ៊ុនមិនមានក្រុមហ៊ុនបុត្រសម្ព័ន្ធ |
| ៤ | ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន និងច្រើនលើសលប់ | មាន |
| ៥ | អភិបាល និងសមាជិកគ្រួសារផ្ទាល់របស់អភិបាល | មាន |
| ៦ | បុគ្គលិក និងសមាជិកគ្រួសារផ្ទាល់របស់បុគ្គលិក | មាន |

**២. ប្រតិបត្តិការសំខាន់ៗជាមួយភាគីជាប់ពាក់ព័ន្ធ**

សម្រាប់ឆ្នាំ២០២២ ឌី ប៊ី ឌី មិនមានប្រតិបត្តិការសំខាន់ៗជាមួយភាគីជាប់ពាក់ព័ន្ធទេ លើកលែងតែប្រតិបត្តិដែលមានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២២ នៃរបាយប្រចាំឆ្នាំនេះ។

## ផ្នែកទី៤៖ ការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង និងការធ្វើសវនកម្ម

### ក. សេចក្ដីសង្ខេបអំពីគោលនយោបាយគ្រប់គ្រងហានិភ័យ

អាជីវកម្ម ឬស្ថានភាពហិរញ្ញវត្ថុរបស់ ឌី ប៊ី ឌី អាចរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយកត្តាហានិភ័យជាច្រើន។ អាស្រ័យហេតុនេះ ក្រុមហ៊ុនបានកំពុងរៀបចំគោលនយោបាយស្ដីពីការគ្រប់គ្រងហានិភ័យដោយបានកំណត់នូវចំណាត់ការជាវិធានការកាត់បន្ថយហានិភ័យ ដូចខាងក្រោម៖

#### ១. ហានិភ័យនៃការប៉ាន់ស្មានតម្លៃទាប

គម្រោងភាគច្រើនដែល ឌី ប៊ី ឌី ទទួលបានត្រូវបានណែនាំតាមរយៈការចូលរួមដេញថ្លៃ។ ហានិភ័យអាចនឹងកើតឡើងមាននៅពេលដែល ឌី ប៊ី ឌី ដេញថ្លៃគម្រោង បានដាក់តម្លៃប៉ាន់ស្មានទាបពេកទៅលើសម្ភារៈ ឬកម្លាំងពល-កម្ម។ កត្តាជាច្រើនដែលអាចនាំឱ្យមានការប៉ាន់ស្មានតម្លៃទាប រួមមាន ថ្លៃដើមពលកម្មដែលមិនអាចដឹងមុន ពេលវេលាកំហុសក្នុងគំនូសព្រាង ភាពខុសគ្នានៃលក្ខណៈបច្ចេកទេស ការប្រែប្រួលនៃតម្លៃវត្ថុធាតុដើម និងការផ្លាស់ប្ដូរវិសាលភាពការងារ។ ការប៉ាន់ស្មានតម្លៃទាបជាងតម្លៃជាក់ស្ដែងនៃគម្រោង អាចផ្ដល់ផលប៉ះពាល់អវិជ្ជមានដល់ប្រាក់ចំណេញ។

**វិធានការកាត់បន្ថយ៖**

ឌី ប៊ី ឌី បានបង្កើតស្ដង់ដារ និងគោលការណ៍ណែនាំយ៉ាងក្បោះក្បាយសម្រាប់រាល់ការដេញថ្លៃគម្រោង ដែលរួមមានបីដំណាក់កាល៖ (១) ការស្ទង់មតិដែលដឹកនាំដោយក្រុមស្ទង់មតិ (២) ការប៉ាន់ស្មាន និង (៣)សុពលភាពដែលត្រូវបានត្រួតពិនិត្យដោយអ្នកដេញថ្លៃដែលទទួលបានការអនុញ្ញាត។ ដំណើរការត្រួតពិនិត្យការដេញថ្លៃ ត្រូវបានធ្វើឡើងដោយអ្នកជំនាញរបស់ក្រុមហ៊ុន ក្នុងនោះរួមមាន ក្រុមអ្នកជំនាញផ្នែកច្បាប់ និងអ្នកជំនាញបច្ចេកទេស ដែលត្រួតពិនិត្យឡើងវិញនូវគំនូសព្រាង និងលក្ខណៈបច្ចេកទេស ក៏ដូចជាត្រួតពិនិត្យការអនុវត្តនៅនឹងកន្លែងរបស់គម្រោងនីមួយៗ។

#### ២.ហានិភ័យនៃកង្វះខាតសម្ភារៈ និងការប្រែប្រួលតម្លៃ

ឌី ប៊ី ឌី ពឹងផ្អែកយ៉ាងខ្លាំងទៅលើការផ្គត់ផ្គង់ និងផលិតផលដែលទទួលបានពីទីផ្សារបរទេសដោយសារតែកង្វះខាតនៅកម្ពុជា។ ជាឧទាហរណ៍ជាក់ស្ដែង ផលិតផលដែលប្រើប្រាស់ក្នុងអាជីវកម្ម ឌី ប៊ី ឌី គឺដែកថែប និងបេតុង ដែលក្រុមហ៊ុនបាននាំចូលពីទីផ្សារថៃ ចិន និងវៀតណាម ភាគច្រើន។ ជាធម្មតា តម្លៃប្រែប្រួលចំពោះផលិតផលទាំងនេះគឺប្រែប្រួលពី ៣% ទៅ ៥% ក្នុងមួយឆ្នាំ។ តម្លៃ និងវត្តមានរបស់ផលិតផលជារួម អាចរងផលប៉ះពាល់ដោយកត្តាជាច្រើន ដូចជា តម្រូវការទីផ្សារ និងស្ថានភាពសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក ការប្រែប្រួលអាកាសធាតុ តម្លៃប្រេងឥន្ធនៈ និងស្ថានភាពនយោបាយជាដើម។

ដោយសារលក្ខណៈនៃអាជីវកម្មរបស់ខ្លួន ឌី ប៊ី ឌី ត្រូវបានតម្រូវឱ្យដាក់ឯកសារដេញថ្លៃលើគម្រោងនានា និងចុះកិច្ចសន្យាផ្អែកលើតម្លៃដេញថ្លៃ។ ឌី ប៊ី ឌី ដាក់តម្លៃដេញថ្លៃគម្រោងដោយផ្អែកលើការប៉ាន់ស្មានដ៏ល្អបំផុតរបស់ខ្លួនរួមបញ្ចូលទាំងការប៉ាន់ស្មានថ្លៃដើមនៃការផ្គត់ផ្គង់។ ប្រសិនបើ ថ្លៃដើមនៃការផ្គត់ផ្គង់កើនឡើងបន្ទាប់ពីការដេញថ្លៃត្រូវបានទទួលយក ឌី ប៊ី ឌី មិនអាចស្នើថ្លៃដើមបន្ថែមទៅអតិថិជនបានទេ ហើយក្រុមហ៊ុនអាចនឹងគ្មានជម្រើសណាមួយក្រៅពីទិញមុខទំនិញនៅក្នុងតម្លៃថ្លៃដែលជាហេតុនាំឱ្យប្រាក់ចំណេញធ្លាក់ចុះ។ ហានិភ័យក៏អាចកើតមានផងដែរ នៅពេលដែលការផ្គត់ផ្គង់ចាំបាច់សម្រាប់គម្រោង ត្រូវពន្យារពេល ឬមិនមានជាបណ្ដោះអាសន្ន ដែលបណ្ដាលឱ្យរយៈពេល

បញ្ចប់គម្រោងត្រូវបានពន្យារពេល និងថ្លៃដើមគម្រោងកើតឡើង។ រាល់ការកើនឡើងនៃថ្លៃដើមផ្គត់ផ្គង់ ឬការពន្យារពេលក្នុងការទទួលការផ្គត់ផ្គង់ អាចជះឥទ្ធិពលអវិជ្ជមានដល់អាជីវកម្ម និងផលចំណេញរបស់ក្រុមហ៊ុន។

**វិធានការកាត់បន្ថយ៖**

ឌី ប៊ី ឌី រក្សាទំនាក់ទំនងយ៉ាងល្អជាមួយអ្នកផ្គត់ផ្គង់នានា និងមាននីតិវិធី ដើម្បីកាត់បន្ថយហានិភ័យទាក់ទងនឹងការប្រែប្រួលនៃតម្លៃផ្គត់ផ្គង់។ នីតិវិធីសំខាន់គឺជាការចរចារតម្លៃជាមុនជាមួយនឹងអ្នកផ្គត់ផ្គង់ ដូច្នេះតម្លៃផ្គត់ផ្គង់ ត្រូវបានកំណត់ក្នុងកំឡុងពេលនៃគម្រោង។ ជាផ្នែកមួយនៃដំណើរការចរចារ ឌី ប៊ី ឌី បានរួមបញ្ចូលតម្រូវការផ្គត់ផ្គង់នៃគម្រោងដែលកំពុងដំណើរការរបស់ខ្លួនភាពច្រើន ដើម្បីទទួលបានការបញ្ចុះតម្លៃយ៉ាងច្រើន និងបន្ថែមចំនុចខ្លាំងលើការចរចាររបស់ខ្លួន។ លើសនេះទៀត ឌី ប៊ី ឌី ព្យាយាមរកការផ្គត់ផ្គង់ចាំបាច់បំផុតមុនពេលចាប់ផ្តើមគម្រោង ដើម្បីកាត់បន្ថយទាំងការប្រែប្រួលតម្លៃ និងហានិភ័យនៃការព្យារពេលផ្គត់ផ្គង់។

ទោះបីជា ឌី ប៊ី ឌី ត្រូវបានចុះកិច្ចសន្យាក្នុងតម្លៃជាមួយរយៈពេលសម្រាប់គម្រោងដែលបានដេញថ្លៃក៏ដោយក៏ ឌី ប៊ី ឌី អាចចរចារឡើងវិញជាមួយម្ចាស់គម្រោងទៅលើពេលវេលា និងតម្លៃថ្មី ប្រសិនបើព្រឹត្តិការណ៍ទីផ្សារណាមួយកើតមានឡើងដែលហួសពីដែនគ្រប់គ្រងរបស់ ឌី ប៊ី ឌី។

**៣. ហានិភ័យពីការប្រកួតប្រជែង**

ដោយសារវិស័យសំណង់រឹងមាំ និងមានការរីកចម្រើន ចំនួនក្រុមហ៊ុនសំណង់ទាំងបរទេស និងក្នុងស្រុកមានការកើនឡើងយ៉ាងឆាប់រហ័ស។ ឌី ប៊ី ឌី កំពុងប្រឈមមុខនឹងការប្រកួតប្រជែងកាន់តែខ្លាំងឡើងក្នុងដំណើរការដេញថ្លៃសម្រាប់គម្រោងរបស់ខ្លួន។ ដៃគូប្រកួតប្រជែងនានាដែលមានដើមទុនច្រើន កំពុងបញ្ចុះតម្លៃក្នុងការដេញថ្លៃដើម្បីទទួលបានចំណែកទីផ្សារ។ កត្តានេះហើយដែលធ្វើឱ្យ ឌី ប៊ី ឌី ត្រូវបង្ខំចិត្តបញ្ចុះតម្លៃក្នុងការដេញថ្លៃដើម្បីទទួលបានគម្រោង។ បរិយាកាសប្រកួតប្រជែងនៅក្នុងវិស័យសំណង់កម្ពុជា អាចជះឥទ្ធិពលមិនល្អដល់ប្រាក់ចំណេញរបស់ក្រុមហ៊ុនដោយសារហានិភ័យនៃការបាត់បង់ការដេញថ្លៃ ឬការកាត់បន្ថយប្រាក់ចំណេញលើគម្រោងដែល ឌី ប៊ី ឌី ត្រូវបញ្ចុះតម្លៃដេញថ្លៃ។

**វិធានការកាត់បន្ថយ៖**

ដោយសារបទពិសោធន៍ដ៏ទូលំទូលាយនៅក្នុងវិស័យសំណង់កម្ពុជា ឌី ប៊ី ឌី អាចជ្រើសរើសគម្រោងដើម្បីដេញថ្លៃបានស្របតាមជំនាញរបស់ក្រុមហ៊ុន។ កត្តានេះអនុញ្ញាតឱ្យ ឌី ប៊ី ឌី គ្រប់គ្រងថ្លៃដើមគម្រោង និងដាក់តម្លៃដេញថ្លៃសមរម្យ ដើម្បីឱ្យក្រុមហ៊ុននៅតែទទួលបានផលចំណេញ។ លើសពីនេះទៀតកេរ្តិ៍ឈ្មោះដ៏រឹងមាំ និងបទពិសោធន៍ជាង ២៥ឆ្នាំ ឈ្នះការដេញថ្លៃគម្រោង ទោះបីជាការដេញថ្លៃមិនទាបពេកជាងក្រុមហ៊ុនដទៃទៀតក៏ដោយ។

**ខ. សេចក្តីសង្ខេបអំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង**

ឌី ប៊ី ឌី បានត្រៀមខ្លួនរួចរាល់ក្នុងការដំណើរការមុខងារសវនកម្មផ្ទៃក្នុងរបស់ខ្លួននៅឆ្នាំ២០២២។ នៅក្រោមវិសាលភាពនៃសវនកម្ម ការត្រួតពិនិត្យផ្ទៃក្នុងត្រូវបានអនុវត្តសម្រាប់ឆ្នាំ២០២២ ដែលរួមទាំងការត្រួតពិនិត្យលើសកម្មភាពហិរញ្ញវត្ថុ អនុលោមភាពនៃច្បាប់ និងបទប្បញ្ញត្តិ គោលការណ៍ និងគោលនយោបាយនានារបស់ក្រុមហ៊ុន។ ការធ្វើសវនកម្មផ្ទៃក្នុងដែលគ្រប់ដណ្តប់ដល់មុខងារការត្រួតពិនិត្យផ្ទៃក្នុង ត្រូវអនុវត្តដោយបុគ្គលទទួលបន្ទុកសវនកម្មផ្ទៃក្នុងដែលរាយការណ៍លទ្ធផលការងារដោយផ្ទាល់ទៅគណៈកម្មាធិការសវនកម្ម ដើម្បីគាំទ្រដល់ប្រតិបត្តិការសម្រាប់ផ្នែក

នេះប្រកបដោយប្រសិទ្ធភាព និងជានាឯករាជ្យចេញពីការគ្រប់គ្រងប្រតិបត្តិការរបស់ក្រុមហ៊ុន។ មួយផ្នែកនៃមុខងារសវនកម្មផ្ទៃក្នុងគឺការអនុវត្តគោលនយោបាយស្តីពីសវនកម្មផ្ទៃក្នុងដែលក្រុមហ៊ុនបានអនុម័តសម្រាប់ការអនុវត្តនៅក្នុងក្រុមហ៊ុន ដោយកំណត់នូវការការពារបីស្រទាប់ពីគណៈគ្រប់គ្រង សវនករផ្ទៃក្នុង និងក្រុមប្រឹក្សាភិបាល។ ការបង្កើតជាយន្តការការពារដល់ការប្រើប្រាស់ ធនធានសមស្របទៅនឹងគោលដៅក្រុមហ៊ុនដែលបានដាក់ចេញ។ បន្ថែមពីនេះ សវនករឯករាជ្យបានពិនិត្យ និងលើកបញ្ហាមួយចំនួនទាក់ទងនឹងសវនកម្មផ្ទៃក្នុង ដែលបញ្ហាសំខាន់ៗមួយចំនួននេះត្រូវបានពិភាក្សាជាមួយថ្នាក់ដឹកនាំ និងក្រុមប្រឹក្សាភិបាល ហើយត្រូវបានទទួលយក និងកែលម្អជាបណ្តើរៗដោយក្រុមហ៊ុនក្នុងការគ្រប់គ្រងប្រព័ន្ធផ្ទៃក្នុងរបស់ខ្លួន។

## គ. ការធ្វើសវនកម្ម

### ១. សវនកម្មផ្ទៃក្នុង

អង្គភាពសវនកម្មផ្ទៃក្នុងស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់គណៈកម្មាធិការសវនកម្ម។ ការទទួលខុសត្រូវរបស់សវនកម្មផ្ទៃក្នុងរួមមាន ការបង្កើតផែនការសវនកម្ម និងការត្រួតពិនិត្យសវនកម្មផ្ទៃក្នុងរបស់ដំណើរការអាជីវកម្មសំខាន់ៗរបស់ក្រុមហ៊ុន ដូចខាងក្រោម៖

- បង្ហាញពីការវាយតម្លៃដែលមានតុល្យភាព និងអាចយល់បានអំពីការអនុវត្ត ស្ថានភាព និងការរំពឹងទុករបស់ក្រុមហ៊ុន
- រាយការណ៍អំពីដំណើរការអាជីវកម្មរបស់ក្រុមហ៊ុនដោយលើកឡើងបញ្ហាដែលអាចកើតមាន
- ធានាភាពរឹងមាំនូវប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដើម្បីរក្សាផលប្រយោជន៍របស់ភាគហ៊ុនិក និងការវិនិយោគរបស់ភាគីពាក់ព័ន្ធ និងទ្រព្យសកម្មរបស់ក្រុមហ៊ុន។
- ស៊ើបអង្កេតដើម្បីវាយតម្លៃពីភាពសមស្រប និងប្រសិទ្ធភាពនៃអភិបាលកិច្ច ប្រតិបត្តិការ និងប្រព័ន្ធព័ត៌មានដោយរាប់បញ្ចូលទាំងការរក្សាការពារទ្រព្យសកម្ម និងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិ
- ផ្តល់ឱ្យគណៈកម្មាធិការសវនកម្ម និងបុគ្គលិកជាន់ខ្ពស់នូវរបាយការណ៍ប្រចាំឆ្នាំពាក់ព័ន្ធនឹងការអនុវត្តផែនការ និងយុទ្ធសាស្ត្រសវនកម្ម
- និងភារកិច្ចដែលកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ការតែងតាំងតំណែងជាសវនករផ្ទៃក្នុង៖**

| ល.រ. | ឈ្មោះ | កាលបរិច្ឆេទតែងតាំង |
|---|---|---|
| ១ | អ៊ុក វល័ក្ខ | ០១ វិច្ឆិកា ២០២២ |

### ២.សវនកម្មខាងក្រៅ

| ល.រ | ឈ្មោះក្រុមហ៊ុន | កាលបរិច្ឆេទជ្រើសតាំង | តម្លៃសេវាសវនកម្ម (ដុល្លាអាមេរិក) | តម្លៃសេវា មិនមែនសវនកម្ម |
|---|---|---|---|---|
| ១ | Grant Thornton (Cambodia) Limited | ០៩ ឧសភា ២០២២ | ២៦.៥០០ | មិនមាន |

## ផ្នែកទី៥៖ ភាគីពាក់ព័ន្ធ

### ក. គោលនយោបាយ និងសកម្មភាពទាក់ទងនឹងចំណុចដូចខាងក្រោម៖

| ល.រ | ខ្លឹមសារ | គោលនយោបាយ* | សកម្មភាព** |
|---|---|---|---|
| ១ | សុខុមាលភាពរបស់អតិថិជន | មិនមាន | អនុលោមតាមក្រមសីលធម៌ កិច្ចសន្យា គោលការណ៍របស់ក្រុមហ៊ុន |
| ២ | ការជ្រើសរើសអ្នកផ្គត់ផ្គង់/អ្នកម៉ៅការ | មិនមាន | |
| ៣ | ការគ្រប់គ្រង និងការការពារនិយោជិក | មិនមាន | |
| ៤ | ការគាំពារបរិស្ថាន | មិនមាន | |
| ៥ | អន្តរកម្មជាមួយសហគមន៍ | មិនមាន | |
| ៦ | ការការពារសិទ្ធិរបស់ម្ចាស់បំណុល | មិនមាន | |
| ៧ | កម្មវិធីប្រឆាំងអំពើពុករលួយ | មិនមាន | |

**ក្រុមហ៊ុនមិនមានគោលនយោបាយដាច់ដោយឡែកសម្រាប់អនុវត្តចំពោះភាគីជាប់ពាក់ព័ន្ធនោះទេ ប៉ុន្តែសិទ្ធិរបស់ភាគីពាក់ព័ន្ធត្រូវបានការពារដោយកិច្ចសន្យា និងគោលការណ៍ផ្ទៃក្នុងនានារបស់ក្រុមហ៊ុន។*

***នៅឆ្នាំ២០២២ ឌី ប៊ី ឌី បានខិតខំយកចិត្តទុកដាក់លើការគិតគូរដល់បុគ្គលិក សហគមន៍ និងការពារដល់សុខមាលភាពរបស់អតិថិជនយើងជានិច្ច។*

### ខ. ទំនួលខុសត្រូវសង្គម

ឌី ប៊ី ឌី បានផ្តល់ឱកាសដល់និស្សិតដកស្រង់បទពិសោធន៍ការងារសម្រាប់ការចុះកម្មសិក្សានៅក្រុមហ៊ុនផ្ទាល់ក្នុងឆ្នាំ២០២២។

| ឈ្មោះអ្នកទទួលផលប្រយោជន៍ | ទំហំបរិច្ចាគ | គោលបំណង |
|---|---|---|
| និស្សិត | N/A | ផ្តល់កម្មវិធីកម្មសិក្សាដើម្បីទទួលបានចំណេះដឹង និងបទពិសោធន៍ |

## ផ្នែកទី៦៖ ការបង្ហាញព័ត៌មាន និងតម្លាភាព

### ក. ព័ត៌មាននៅក្នុងរបាយការណ៍ប្រចាំឆ្នាំ

| ល.រ | ព័ត៌មាន | មាន/គ្មានបង្ហាញ |
|---|---|---|
| ១ | ចក្ខុវិស័យ/បេសកកម្ម/គោលដៅអាជីវកម្ម | មាន |
| ២ | សូចនាករហិរញ្ញវត្ថុ | មាន |
| ៣ | សូចនាករមិនមែនហិរញ្ញវត្ថុ | មាន |
| ៤ | កត្តាហានិភ័យសំខាន់ៗ | មាន |
| ៥ | គោលនយោបាយភាគលាភ | មាន |
| ៦ | ជីវប្រវត្តិរបស់អភិបាល | មាន |
| ៧ | ការបណ្តុះបណ្តាលសម្រាប់អភិបាល | មាន |
| ៨ | ចំនួនកិច្ចប្រជុំក្រុមប្រឹក្សាភិបាល | មាន |
| ៩ | វត្តមានរបស់អភិបាលក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល | មាន |
| ១០ | លាភការ ឬប្រាក់បំណាច់សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ | មាន |

### ខ. យន្តការនៃការបង្ហាញព័ត៌មាន ដោយរៀបរាប់ពីមធ្យោបាយ នីតិវិធី និងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន

ឌី ប៊ី ឌី កំពុងប្រើប្រាស់វិធីសាស្រ្តបង្ហាញព័ត៌មានតាមរយៈផ្សារមូលបត្រកម្ពុជា (CSX) គេហទំព័រ និង Facebook Page របស់ក្រុមហ៊ុន។ ការបង្ហាញទាំងនេះរួមមានព័ត៌មានទាន់ពេល ព័ត៌មានតាមកាលកំណត់ និងព័ត៌មានស្ម័គ្រចិត្ត។ បុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មានរបស់ ឌី ប៊ី ឌី គឺលោកស្រី លឹម មុយលី ដែលជាអភិបាល នាយកប្រតិបត្តិ និងប្រធានផ្នែកហិរញ្ញវត្ថុ។

### គ. ទំនាក់ទំនងជាមួយវិនិយោគិន

#### ១. យន្តការ និងនីតិវិធីនៃការទំនាក់ទំនងជាមួយវិនិយោគិន

វិនិយោគិនរបស់ ឌី ប៊ី ឌី អាចទាក់ទងទៅកាន់ ឌី ប៊ី ឌី ដូចខាងក្រោម៖

- អាស័យដ្ឋាន ដីឡូត៍ ៦៨ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រទេសកម្ពុជា
- អ៊ីម៉ែល៖ services@abdengineering.com
- លេខទូរសព្ទ៖ (+៨៥៥) ០៧៨ ៧០០ ៥៩៨

#### ២. សេចក្តីសង្ខេបអំពីទំនាក់ទំនងជាមួយនឹងវិនិយោគិនក្នុងរយៈពេល ១ (មួយ)ឆ្នាំចុងក្រោយ

នៅក្នុងឆ្នាំ២០២២ ឌី ប៊ី ឌី បានធ្វើការទំនាក់ទំនងជាមួយវិនិយោគិនតាមរយៈកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក ដែលធ្វើឡើងតាមរយៈប្រព័ន្ធអនឡាញ (Zoom)។

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

# និង

# របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច

## ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក

ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

# មាតិកា

| | ទំព័រ |
|---|---|
| **របាយការណ៍របស់ក្រុមប្រឹក្សាភិបាល** | ១-៣ |
| **របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច** | |
| របាយការណ៍របស់សវនកររងករាជ្យ | ៤-៨ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ៩-១០ |
| របាយការណ៍ចំណូលលម្អិត | ១១ |
| របាយការណ៍បម្រែបម្រួលមូលធន | ១២ |
| របាយការណ៍លំហូរសាច់ប្រាក់ | ១៣-១៤ |
| កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ | ១៥-៥២ |

DBD ENGINEERING



# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល សូមដាក់ជូននូវរបាយការណ៍របស់ខ្លួនព្រមជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ហៅកាត់ថា ("ក្រុមហ៊ុន") គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ("ការិយបរិច្ឆេទ")។

## អំពីក្រុមហ៊ុន

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតបានបង្កើតឡើងក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៩៨ ជាមួយការចុះបញ្ជីពាណិជ្ជកម្មលេខ ០០០០៤០២៩ ដែលបានចេញផ្សាយដោយក្រសួងពាណិជ្ជកម្ម ("MOC")។ ដោយអនុលោមតាមអនុស្សរណៈ និងលក្ខន្តិកៈ ("MAA") ដំណើរការអាជីវកម្មរបស់ក្រុមហ៊ុន គឺមានរយៈពេល ៩៩ឆ្នាំ គិតចាប់ផ្តើមពីកាលបរិច្ឆេទចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២១ ក្រុមហ៊ុនបានចុះបញ្ជីដោយជោគជ័យនៅក្នុងទីផ្សារកំណើននៃផ្សារមូលបត្រកម្ពុជា ("CSX")។ ចំនួនហ៊ុនថ្មីដែលបានបោះផ្សាយមានចំនួន ៦.៤៦១.៥៣៨ ហ៊ុនជាមួយតម្លៃចារិក ១.០០០ រៀល (០.២៥ ដុល្លារអាមេរិក) ក្នុងមួយហ៊ុន ក្នុងតម្លៃលក់ចេញ ២.៣៨០ រៀល (០.៥៨ ដុល្លារអាមេរិក) ក្នុងមួយហ៊ុន។ ក្រុមហ៊ុនបានទទួលចំណូលពីការបោះផ្សាយលក់ភាគហ៊ុនជាសាធារណៈលើកដំបូង ("IPO") ក្នុងសមតុល្យ ៣.៧៧៣.៥៣៩ ដុល្លារអាមេរិក ជាលទ្ធផលក្នុងបុព្វលាភភាគហ៊ុនចំនួន ២.១៥៨.១៥៤ ដុល្លារអាមេរិក (៨.៧៧៩.៣៧០.០០០ រៀល)។ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលមិនទាន់ធ្វើការអនុម័តទៅលើការធ្វើវិសោធនកម្មលើអនុស្សរណៈ និងលក្ខន្តិកៈរបស់ក្រុមហ៊ុន ដែលទាក់ទងនឹងការបង្កើនដើមទុនពី IPOនោះទេ។

ការិយាល័យចុះបញ្ជី និងទីតាំងអាជីវកម្មចម្បងរបស់ក្រុមហ៊ុនមានទីតាំងស្ថិតនៅដីឡូតិ៍លេខ៦៨ ផ្លូវ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ ប្រអប់សំបុត្រលេខ ១៧៨ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុនមាននិយោជិតចំនួន ១.១១២ នាក់ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១៖ មាននិយោជិតចំនួន ៩៦៦ នាក់)។

## សកម្មភាពអាជីវកម្មចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺធ្វើប្រតិបត្តិការជាអ្នកម៉ៅការផ្នែកមេកានិក និងអគ្គិសនី អ្នកម៉ៅការប្រព័ន្ធទឹក និងពន្លត់អគ្គីភ័យ ប្រព័ន្ធម៉ាស៊ីនត្រជាក់ក្នុងបន្ទប់ HVAC និងអ្នកម៉ៅការថែទាំអគារផ្សេងៗ។ ពុំមានការផ្លាស់ប្តូរលើសកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុនក្នុងអំឡុងការិយបរិច្ឆេទនេះឡើយ។

## លទ្ធផល និងភាគលាភ

លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងស្ថានភាពប្រតិបត្តិការរបស់ក្រុមហ៊ុនគិតត្រឹមកាលបរិច្ឆេទនេះ ត្រូវបានកំណត់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលអមមកជាមួយ។

នៅថ្ងៃទី២ ខែឧសភា ឆ្នាំ២០២២ ក្រុមប្រឹក្សាភិបាលបានអនុម័តលើការបែងចែកភាគលាភជាសាច់ប្រាក់ចំនួន ២០៨.១២៨ ដុល្លារអាមេរិក (៨៤៦.៤៦១.៤៧៨ រៀល) ដើម្បីធ្វើការបែងចែកដល់ភាគហ៊ុនិកថ្នាក់ "ក" ក្នុងតម្លៃ ១៣១ រៀលក្នុងមួយហ៊ុន។ ការទូទាត់ភាគលាភជាសាច់ប្រាក់ត្រូវបានធ្វើឡើងនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២ សម្រាប់ការកត់ត្រារបស់ភាគហ៊ុនិកក្នុងកាលបរិច្ឆេទគិតត្រឹមថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២។

## ក្រុមប្រឹក្សាភិបាល

សមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុននៅក្នុងអំឡុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះមានដូចខាងក្រោម៖

| ឈ្មោះ | មុខតំណែង | កាលបរិច្ឆេទនៃការតែងតាំង |
|---|---|---|
| លោក នាង វិធី | ប្រធានក្រុមប្រឹក្សាភិបាល | ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ |
| លោកស្រី លឹម មុយលី | អភិបាល | ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ |
| លោក ថៃ វ៉ាន់ថា | អភិបាល | ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០ |
| លោក ហ៊ុយ វ៉ាថារ៉ូ | អភិបាលឯករាជ្យ | ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០ |
| លោក Rami Bashir Asad Sharaf | អភិបាលមិនប្រតិបត្តិ | ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ |

## សវនករ

របាយការណ៍ហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុនស្នងការគណនេយ្យ ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត។

## ភាគកម្មរបស់អភិបាលនៅក្នុងក្រុមហ៊ុន

យោងតាមលក្ខន្តិកៈប្រតិបត្តិការរបស់ក្រុមហ៊ុន ភាគកម្មរបស់អភិបាលកាន់តំណែងនាចុងការិយបរិច្ឆេទ ជាភាគហ៊ុនធម្មតារបស់ក្រុមហ៊ុន និងសាជីវកម្មពាក់ព័ន្ធក្នុងអំឡុងការិយបរិច្ឆេទត្រូវមានដូចខាងក្រោម៖

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | %នៃម្ចាស់កម្មសិទ្ធិ | ចំនួនភាគហ៊ុន | %នៃម្ចាស់កម្មសិទ្ធិ | ចំនួនភាគហ៊ុន |
| លោក នាង វិធី | ៤៥,៥០% | ៨.៤០០.០០០ | ៤៥,៥០% | ៨.៤០០.០០០ |
| លោកស្រី លឹម មុយលី | ១៩,៥០% | ៣.៦០០.០០០ | ១៩,៥០% | ៣.៦០០.០០០ |
| | ៦៥,០០% | ១២.០០០.០០០ | ៦៥,០០% | ១២.០០០.០០០ |

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល មានទំនួលខុសត្រូវក្នុងការអះអាងបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវជាសារវន្តអំពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលតម្រូវឱ្យ៖

(ក) អនុម័តនូវគោលនយោបាយគណនេយ្យឱ្យបានសមស្របដែលអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា "CIFRSs" ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានប្រកបដោយភាពសមហេតុផល និងប្រុងប្រយ័ត្ន ហើយអនុវត្តគោលនយោបាយទាំងនេះឱ្យមានសង្គតិភាព

DBD ENGINEERING



(ខ) អនុលោមតាមតម្រូវការលាតត្រដាងនៃស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ឬប្រសិនបើមានការប្រាសចាកណាមួយពីតម្រូវការទាំងនោះ ក្នុងការបង្ហាញនូវភាពពិត និងត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថាការប្រាសចាកទាំងនេះ ត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណឱ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

(គ) រក្សាទុកកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព

(ឃ) រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែក្នុងករណីមិនអាចសន្មតថា ក្រុមហ៊ុននឹងបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួន នាពេលអនាគតបន្តទៀតបាន និង

(ង) គ្រប់គ្រង និងដឹកនាំក្រុមហ៊ុនឱ្យមានប្រសិទ្ធភាព ចូលរួមលើរាល់សេចក្តីសម្រេចចិត្តសំខាន់ៗទាំងអស់ដែលប៉ះពាល់ដល់ប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថារាល់ការសម្រេចចិត្ត និង/ឬ សេចក្តីណែនាំនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាល ក៏ជាអ្នកទទួលខុសត្រូវក្នុងការថែរក្សាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ហើយក៏ត្រូវចាត់វិធានការឱ្យសមស្របដើម្បីទប់ស្កាត់ និងរកឱ្យឃើញការក្លែងបន្លំ និងភាពមិនប្រក្រតីផ្សេងៗ។

ក្រុមប្រឹក្សាភិបាលសូមបញ្ជាក់ថា ក្រុមហ៊ុនបានអនុវត្តតាមលក្ខខណ្ឌតម្រូវចាំបាច់នានាដូចដែលបានបញ្ជាក់ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

**សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល**

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល អមជាមួយរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ របាយការណ៍ចំណូលលម្អិត របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ រួមជាមួយនឹងកំណត់សម្គាល់នានា ត្រូវបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវជាសារវន្ត ពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ដែលអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

ជំនួសឱ្យក្រុមប្រឹក្សាភិបាល៖

**លោក នាង រិទ្ធី**
**ប្រធានក្រុមប្រឹក្សាភិបាល**

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣



DBD Engineering Plc. #68, St.598, SK. Phnom Penh Thmey, K. Sensok, Phnom Penh, CAMBODIA
Tel: (855)78 700 598, E-mail: services@dbdengineering.com, www.dbdengineering.com

# របាយការណ៍របស់សវនករឯករាជ្យ

**ហ្គ្រេន សនថុន (ខេមបូឌា) លីមីតធីត**
ជាន់ទី២០ អាគារកាណាឌីយ៉ា
៣១៥ ផ្លូវព្រះអង្គឌួង
កែងមហាវិថីព្រះមុនីវង្ស
សង្កាត់វត្តភ្នំ. ខណ្ឌដូនពេញ
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
**លេខទូរស័ព្ទ +៨៥៥ ៩៦៦ ៥២០**
www.grantthornton.com.kh

**ជូនចំពោះភាគហ៊ុននិករបស់**
**ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក**

## មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក (ហៅកាត់ថា "ក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ព្រមទាំងរបាយការណ៍ចំណូលលម្អិត របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងសេចក្ដីសង្ខេបគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗ។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់មកជាមួយបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវជាសារវន្តពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRSs")។

## មូលដ្ឋាននៃការបញ្ចេញមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ("CISAs")។ ការទទួលខុសត្រូវរបស់យើងខ្ញុំស្ថិតក្រោមស្តង់ដារទាំងនោះ គឺត្រូវបានរៀបរាប់បន្ថែមនៅក្នុងផ្នែកការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ។ យើងខ្ញុំមានឯករាជ្យភាពពីក្រុមហ៊ុនដោយអនុលោមតាមក្រុមប្រឹក្សាស្តង់ដារវិជ្ជាជីវៈគណនេយ្យអន្តរជាតិ ក្រមសីលធម៌របស់គណនេយ្យករជំនាញ (រួមទាំងស្តង់ដារឯករាជ្យអន្តរជាតិ) ("IESBA Code") រួមជាមួយនឹងតម្រូវការក្រមសីលធម៌ ដែលពាក់ព័ន្ធទៅនឹងការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញការទទួលខុសត្រូវទៅតាមតម្រូវការក្រមសីលធម៌ទាំងនោះ និង IESBA Code។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្ម ដែលយើងខ្ញុំទទួលបាន គឺគ្រប់គ្រាន់ និងសមស្របដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

## បញ្ហាសវនកម្មសំខាន់ៗ

បញ្ហាសវនកម្មសំខាន់ៗ គឺជាបញ្ហាទាំងឡាយណាដែលកើតមាននៅក្នុងការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈរបស់យើងខ្ញុំដែលមានសារៈសំខាន់បំផុតនៅក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់យើងខ្ញុំសម្រាប់ការិយបរិច្ឆេទបច្ចុប្បន្ន។ បញ្ហាទាំងនេះត្រូវបានដោះស្រាយក្នុងបរិបទនៃការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុទាំងមូល និងក្នុងការបញ្ចេញមតិយោបល់សវនកម្មរបស់យើងខ្ញុំ ហើយយើងខ្ញុំមិនធ្វើការបញ្ចេញមតិយោបល់ដាច់ដោយឡែកទាក់ទងនឹងបញ្ហាទាំងនេះឡើយ។

Grant Thornton

ខាងក្រោមនេះ គឺជាបញ្ហាសវនកម្មសំខាន់ៗ ដែលបានកំណត់អត្តសញ្ញាណក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន៖

| បញ្ហាសវនកម្មសំខាន់ៗ | វិធីសាស្ត្រដែលសវនករយើងខ្ញុំបានកំណត់នូវបញ្ហាសវនកម្មសំខាន់ៗ |
|---|---|
| **ចំណូល និងការទទួលស្គាល់ថ្លៃដើមសម្រាប់ការសាងសង់ និងសេវាកម្មថែទាំ និងទំនិញបានលក់**<br><br>ចំណូល និងការទទួលស្គាល់ថ្លៃដើមសម្រាប់ការសាងសង់ និងសេវាកម្មថែទាំ និងទំនិញបានលក់ គឺត្រូវបានទទួលស្គាល់ដោយអនុលោមជាមួយគោលនយោបាយគណនេយ្យ និងការប៉ាន់ស្មានការសន្មត និងការវិនិច្ឆ័យសំខាន់ៗ ដូចដែលបានបកស្រាយលម្អិតនៅក្នុងកំណត់សម្គាល់ ៤.១២ និង៥ ទៅលើរបាយការណ៍ហិរញ្ញវត្ថុនានា។<br><br>យើងខ្ញុំផ្ដោតសំខាន់ទៅលើការវិនិច្ឆ័យ និងការប៉ាន់ស្មានសំខាន់ៗរបស់គណៈគ្រប់គ្រងត្រូវបានរួមបញ្ចូលទៅក្នុងការកំណត់ដូចខាងក្រោម៖<br><br>(i) តម្លៃប្រតិបត្តិការលើកិច្ចសន្យាជាមួយអតិថិជនដែលរួមបញ្ចូលទាំងធាតុផ្សំហិរញ្ញវត្ថុសំខាន់ៗ<br><br>(ii) កាលបរិច្ឆេទដែលចំណូលតាមកិច្ចសន្យាគួរតែត្រូវបានទទួលស្គាល់។<br><br>(iii) តម្លៃសមស្របក្នុងការផ្ដល់សេវាកម្មដែលពាក់ព័ន្ធ និងការបែងចែកតម្លៃតបស្នងដែលបានទទួល ឬត្រូវទទួលបានពីកាតព្វកិច្ចអនុវត្ត និង<br><br>(iv) វិសាលភាពនៃថ្លៃដើមកិច្ចសន្យាដែលបានកើតឡើងរហូតដល់កាលបរិច្ឆេទនោះ។ | ក្នុងការផ្ដោតលើការដោះស្រាយបញ្ហាសំខាន់ៗទាំងនេះ យើងខ្ញុំបានអនុវត្តនូវនីតិវិធីផ្សេងៗដូចខាងក្រោម៖<br><br>(i) រយៈពេលប្រើប្រាស់ និងលក្ខខណ្ឌដែលបានកំណត់នៅក្នុងកិច្ចសន្យាជាមួយអតិថិជន និងអ្នកម៉ៅការបន្ត/អ្នកផ្គត់ផ្គង់ ដើម្បីកំណត់នូវកិច្ចសន្យាសំខាន់ៗដាច់ដោយឡែក និងបានវាយតម្លៃទំនាក់ទំនងរវាងចំណូល និងថ្លៃដើមដែលបានទទួលស្គាល់<br><br>(ii) បានវាយតម្លៃពីភាពសមស្រប និងភាពស៊ីតស្តេរនៃការសន្មតសំខាន់ៗដែលបានប្រើប្រាស់ដោយគណៈគ្រប់គ្រងដើម្បីកំណត់តម្លៃប្រតិបត្តិការនៃកិច្ចសន្យាជាមួយអតិថិជនដោយរួមបញ្ចូលទាំងធាតុផ្សំហិរញ្ញវត្ថុសំខាន់ៗ តម្លៃសមស្របនៃសេវាកម្មដើម្បីផ្ដល់ជូន និងជាមូលដ្ឋាននៃការបែងចែកតម្លៃតបស្នងបានទទួល និង/ឬត្រូវទទួលបានពីសេវាកម្មនីមួយៗ និង<br><br>(iii) បានវាយតម្លៃលើចំណាយជាក់ស្តែងដែលបានកើតឡើង និងចំណាយបង្គរ ដោយពិនិត្យលើភស្តុតាងដែលមានដូចជាការធ្វើកិច្ចសន្យាដំណើរការក្នុងការទាមទារសំណងរបស់អ្នកម៉ៅការ និងការចេញវិក្កយបត្ររបស់អ្នកផ្គត់ផ្គង់ក្នុងអំឡុងការិយបរិច្ឆេទ និង/ឬការិយបរិច្ឆេទបន្តបន្ទាប់។ |

Grant Thornton

## ព័ត៌មានផ្សេងៗ

គណៈគ្រប់គ្រង មានទំនួលខុសត្រូវទាំងស្រុងទៅលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗទាំងនោះ រួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ប៉ុន្តែមិនរួមបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ ដែលទទួលបានមុនកាលបរិច្ឆេទនៃរបាយការណ៍របស់សវនករនេះ និងរបាយការណ៍ប្រចាំឆ្នាំ ដែលបានរំពឹងទុកថានឹងត្រូវបានរៀបចំរួចរាល់សម្រាប់យើងខ្ញុំបន្ទាប់ពីកាលបរិច្ឆេទនោះ។

មតិយោបល់របស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់ទៅលើព័ត៌មានផ្សេងៗទេ ហើយយើងខ្ញុំមិនផ្តល់ការធានា ឬសេចក្តីសន្និដ្ឋានក្នុងទម្រង់បែបណាមួយឡើយ។

ភ្ជាប់ជាមួយការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន យើងខ្ញុំមានទំនួលខុសត្រូវក្នុងការអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានវិសមភាពជាសារវន្តជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ ឬទេ ឬចំណេះដឹងរបស់យើងខ្ញុំដែលទទួលបានពីការធ្វើសវនកម្ម ថាតើព័ត៌មានទាំងនោះអាចមានកំហុសឆ្គងជាសារវន្តដែរឬទេ។

ប្រសិនបើ ផ្អែកតាមការងារដែលយើងខ្ញុំបានអនុវត្ត យើងខ្ញុំសន្មតថាមានកំហុសជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗទាំងនេះ យើងខ្ញុំតម្រូវឱ្យរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំមិនមានអ្វីត្រូវរាយការណ៍នៅក្នុងករណីនេះឡើយ។

នៅពេលយើងខ្ញុំបានអានរបាយការណ៍ប្រចាំឆ្នាំរួច ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្ត យើងខ្ញុំតម្រូវឱ្យធ្វើការប្រាស្រ័យទាក់ទងបញ្ហានេះទៅកាន់ក្រុមប្រឹក្សាភិបាល ហើយធ្វើការឆ្លើយតបទៅនឹងបញ្ហានោះដោយអនុលោមតាមតម្រូវការរបស់ CISA ៧២០ (បានកែតម្រូវ)។

## ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងលើរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងរបស់ក្រុមហ៊ុន ជាអ្នកទទួលខុសត្រូវចំពោះការរៀបចំ និងការបង្ហាញទិដ្ឋភាពពិត និងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងទទួលខុសត្រូវដូចគ្នាផងដែរ ចំពោះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ពុំឱ្យមានកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងមានទំនួលខុសត្រូវលើការវាយតម្លៃទៅលើសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការបន្តប្រតិបត្តិការ ដោយផ្អែកលើមូលដ្ឋាននិរន្តរភាព ការលាតត្រដាង ប្រសិនជាមានបញ្ហាទាក់ទងនឹងនិរន្តរភាព និងការប្រើប្រាស់និរន្តរភាពជាមូលដ្ឋានគណនេយ្យ លុះត្រាតែគណៈគ្រប់គ្រងមានគោលបំណងរំសាយក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬក៏គ្មានជម្រើសផ្សេង ប៉ុន្តែចាំបាច់ត្រូវធ្វើ។

Grant Thornton

## ការទទួលខុសត្រូវរបស់សវនករនៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដ៏សមហេតុផលថាតើរបាយការណ៍ហិរញ្ញវត្ថុទាំងមូលពុំមានលក្ខណៈខុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង ក្នុងការបញ្ចេញមតិយោបល់លើរបាយការណ៍របស់សវនករ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាអះអាងកម្រិតខ្ពស់ ប៉ុន្តែវាមិនបានធានាថាការធ្វើសវនកម្មដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិរបស់កម្ពុជា នឹងតែងតែរកឃើញកំហុសខុសឆ្គងជាសារវន្ត នៅពេលវាកើតឡើងនោះទេ។ ការរាយការណ៍ខុសអាចកើតមានឡើងពីការក្លែងបន្លំ ឬកំហុសឆ្គងដែលអាចចាត់ទុកថាជាសារវន្ត នៅពេលដែលកំហុសមួយ ឬកំហុសរួមគ្នាបានធ្វើឱ្យប៉ះពាល់ដល់សេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃជាការធ្វើសវនកម្មដោយយោងទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវវិជ្ជាជីវៈវិនិច្ឆ័យ និងរក្សាមជ្ឈធាតុនិយមប្រកបដោយវិជ្ជាជីវៈទៅលើការធ្វើសវនកម្ម។ យើងខ្ញុំក៏៖

- កំណត់អត្តសញ្ញាណ និងវាយតម្លៃនូវហានិភ័យនៃការរាយការណ៍ខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុថាតើវាកើតឡើងពីការក្លែងបន្លំ ឬកំហុសឆ្គងដោយអចេតនា រៀបចំ និងអនុវត្តនីតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ រួមទាំងការប្រមូលយកភស្តុតាងសវនកម្មឱ្យបានគ្រប់គ្រាន់ និងសមស្របដើម្បីជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញដោយការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ គឺធំជាងកំហុសឆ្គងដោយអចេតនាដោយសារតែការក្លែងបន្លំរួមបញ្ចូលទាំងការរួមគំនិតការក្លែងបន្លំដោយចេតនា ការលុបចោលដោយចេតនា ការបង្ហាញខុស ឬការល្មើសទៅលើការត្រួតពិនិត្យផ្ទៃក្នុង។

- ធ្វើការស្វែងយល់អំពីការគ្រប់គ្រងផ្ទៃក្នុង ដែលទាក់ទងទៅនឹងការធ្វើសវនកម្ម ដើម្បីបង្កើតនូវនីតិវិធីសវនកម្មដែលសមស្របទៅនឹងកាលៈទេសៈ ប៉ុន្តែមិនមែនជាគោលបំណងក្នុងការបង្ហាញនូវមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុននោះទេ។

- ធ្វើការវាយតម្លៃភាពសមស្របលើគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃគណនេយ្យប៉ាន់ស្មាន ក៏ដូចជាការលាតត្រដាងនានាដែលធ្វើឡើងដោយគណៈគ្រប់គ្រង។

- សន្និដ្ឋានដ៏សមស្របមួយទៅលើការប្រើប្រាស់របស់គណៈគ្រប់គ្រងលើមូលដ្ឋាននិរន្តរភាពគណនេយ្យ ផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ថាតើភាពមិនប្រាកដប្រជាជាសារវន្តបានកើតឡើងទាក់ទិននឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលធ្វើឱ្យមានមន្ទិលសង្ស័យខ្លាំងទៅលើលទ្ធភាពក្នុងការបន្តនិរន្តរភាពរបស់ក្រុមហ៊ុន។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា ភាពមិនប្រាកដប្រជាជាសារវន្តនឹងកើតមានឡើង យើងខ្ញុំតម្រូវឱ្យធ្វើការលាតត្រដាងព័ត៌មានចាំបាច់ ដើម្បីទាញការយកចិត្តទុកដាក់នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំទៅនឹងការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬក៏ប្រសិនបើការលាតត្រដាងនោះមិនគ្រប់គ្រាន់ នោះមតិយោបល់មិនត្រឹមត្រូវ នឹងត្រូវបានផ្តល់។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបានគិតត្រឹមថ្ងៃនៃការចេញរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ ទោះបីយ៉ាងណាក៏ដោយ ស្ថានភាព ឬក៏ព្រឹត្តិការណ៍នាពេលអនាគតអាចបណ្តាលឱ្យក្រុមហ៊ុនមិនអាចបន្តប្រតិបត្តិការជានិរន្តរភាពបាន។

- វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងមាតិការបស់របាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងការលាតត្រដាងនានា ថាតើរបាយការណ៍ហិរញ្ញវត្ថុបង្ហាញនូវប្រតិបត្តិការ និងព្រឹត្តិការណ៍នានាដើម្បីបង្ហាញនូវភាពត្រឹមត្រូវសមស្របរបស់វា។

Grant Thornton

យើងខ្ញុំប្រាស្រ័យទាក់ទងជាមួយនឹងគណៈគ្រប់គ្រងទៅលើបញ្ហាផ្សេងៗ ការរៀបចំវិសាលភាព និងពេលវេលាក្នុងការធ្វើសវនកម្ម និងរបកគំហើញសវនកម្មសំខាន់ៗ រួមបញ្ចូលទាំងកង្វះខាតសំខាន់ៗមួយចំនួនទៅលើការគ្រប់គ្រងផ្ទៃក្នុងដែលយើងខ្ញុំបានរកឃើញអំឡុងពេលធ្វើសវនកម្ម។

យើងខ្ញុំក៏ផ្តល់ជូនគណៈគ្រប់គ្រង នូវសេចក្តីថ្លែងការណ៍មួយដែលយើងខ្ញុំបានអនុវត្តទៅតាមតម្រូវការក្រមសីលធម៌ដែលទាក់ទងនឹងឯករាជ្យភាព ហើយយើងខ្ញុំធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងគណៈគ្រប់គ្រងនូវបញ្ហាទាំងអស់ដែលនឹងគិតថាសមហេតុផលទៅលើឯករាជ្យភាពរបស់យើងខ្ញុំ និងការការពារដែលអាចមាន។

បញ្ហានានាដែលយើងខ្ញុំបានជម្រាបជូនគណៈគ្រប់គ្រង យើងខ្ញុំកំណត់ទៅលើបញ្ហាណាដែលមានសារៈសំខាន់បំផុតនៅក្នុងការធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទនាពេលបច្ចុប្បន្ន ហើយបញ្ហាទាំងនោះត្រូវកំណត់ថាជា បញ្ហាសវនកម្មសំខាន់ៗ។ យើងខ្ញុំពណ៌នាពីបញ្ហាទាំងនេះនៅក្នុងរបាយការណ៍សវនកររបស់យើងខ្ញុំ លើកលែងតែច្បាប់ ឬបទប្បញ្ញត្តិរាំងស្ទះដល់ការលាតត្រដាងជាសាធារណៈ ឬនៅក្នុងកាលៈទេសៈចាំបាច់ណាមួយ យើងខ្ញុំអាចកំណត់ថាបញ្ហានោះ មិនគួរត្រូវបានពណ៌នានៅក្នុងរបាយការណ៍របស់យើងខ្ញុំទេ ព្រោះផលប៉ះពាល់ជាអវិជ្ជមាននឹងត្រូវបានរំពឹងទុកដោយសមហេតុផលថាវាលើសពីផលប្រយោជន៍ជាសាធារណៈ ដែលកើតចេញពីបញ្ហានោះ។

Grant Thornton

ព្រះរាជាណាចក្រកម្ពុជា
គ្រេនថនថុន (ខេមបូឌា) លីមីធីត
GRANT THORNTON (CAMBODIA) LIMITED
រាជធានីភ្នំពេញ

**គ្រេនថន សនថុន (ខេមបូឌា) លីមីធីត**
គណនេយ្យករជំនាញ
សវនករប្រតិស្រុតចុះបញ្ជី

**Ronald C. Almera**
នាយកសវនករជំនាញ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

| | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| **ទ្រព្យសកម្ម** | | | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | | | |
| ទ្រព្យសម្បត្តិ និងបរិក្ខារ -សុទ្ធ | ៦ | ៤.១០៣.៧៣៨ | ១៦.៨៩៥.០៨៩ | ២.៦៤៣.០៦២ | ១០.៧៦៧.៨៣៥ |
| ទ្រព្យសកម្មអរូបី -សុទ្ធ | ៧ | ៤៣.៧៤៥ | ១៨០.០៩៨ | ៣៣.៩៨៦ | ១៣៨.៤៥៩ |
| សិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម -សុទ្ធ | ៨ | - | - | ៣២.៧៤៥ | ១៣៣.៤០៣ |
| ទ្រព្យសកម្មរយៈពេលវែងផ្សេងៗ | ៩ | ២០.១០០ | ៨២.៧៥២ | ២០.០៥០ | ៨១.៦៨៤ |
| **ទ្រព្យសកម្មរយៈពេលវែងសរុប** | | **៤.១៦៧.៥៨៣** | **១៧.១៥៧.៩៣៩** | **២.៧២៩.៨៤៣** | **១១.១២១.៣៨១** |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | | | |
| ទ្រព្យសកម្មកិច្ចសន្យា | ១៥ | ៤.៣៣៨.៧៧២ | ១៧.៨៦២.៧២៤ | ៣.៧៩១.៣៦៦ | ១៥.៤៤៦.០២៥ |
| សមតុល្យដែលភាគហ៊ុនិកជំពាក់ | ២៦ | ១៣៦.២៧០ | ៥៦១.០២៤ | ១៣៤.៤២១ | ៥៤៧.៦៣១ |
| សន្និធិ | ១៣ | ១.២៧៤.១៣២ | ៥.២៤៥.៦០១ | ២.១៦៧.២៥៨ | ៨.៨២៩.៤០៩ |
| គណនីពាណិជ្ជត្រូវទទួល | ១២ | ៣.១៦៥.៧៧៣ | ១៣.០៣៣.៤៨៧ | ៦.២៧៣.០៥៧ | ២៥.៥៥៦.៤៣៤ |
| ប្រាក់តម្កល់ធានា | ១១ | ៥៩០.០៨០ | ២.៤២៩.៣៥៩ | ៦៥.០០០ | ២៦៤.៨១០ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១០ | ២១.៤៦៤ | ៨៨.៣៦៧ | ២២៥.១១៩ | ៩១៧.១៣៥ |
| ទ្រព្យសកម្មរយៈពេលខ្លីផ្សេងៗ | ១៤ | ១.០៦២.២៣៧ | ៤.៣៧៣.២៣០ | ៩៤៦.៩៦២ | ៣.៨៥៧.៩២៣ |
| **ទ្រព្យសកម្មរយៈពេលខ្លីសរុប** | | **១០.៥៨៨.៧២៨** | **៤៣.៥៩៣.៧៩២** | **១៣.៦០៣.១៨៣** | **៥៥.៤១៩.៣៦៧** |
| **ទ្រព្យសកម្មសរុប** | | **១៤.៧៥៦.៣១១** | **៦០.៧៥១.៧៣១** | **១៦.៣៣៣.០២៦** | **៦៦.៥៤០.៧៤៨** |
| **មូលធន** | | | | | |
| ដើមទុន | ១៦ | ៤.៦១៥.៣៨៥ | ១៨.៧៩៦.៦៨៧ | ៤.៦១៥.៣៨៥ | ១៨.៧៩៦.៦៨៧ |
| បុព្វលាភដើមទុន | ១៦.១ | ២.១៥៨.១៥៤ | ៨.៧៧៩.៣៧០ | ២.១៥៨.១៥៤ | ៨.៧៧៩.៣៧០ |
| ប្រាក់ចំណេញរក្សាទុក | | ៨៨១.៣៩០ | ៣.៧១៨.៩៦៨ | ២.២៨១.៦៦៤ | ៩.៤៤១.៨៨៧ |
| ការប្តូររូបិយប័ណ្ណបម្រុងទុក | | - | ២២០.៣១៦ | - | (១២៧.០៤៧) |
| **មូលធនសរុប** | | **៧.៦៥៤.៩២៩** | **៣១.៥១៥.៣៤១** | **៩.០៥៥.២០៣** | **៣៦.៨៩០.៨៩៧** |
| **បំណុល** | | | | | |
| **បំណុលរយៈពេលវែង** | | | | | |
| ប្រាក់កម្ចី - ដកចេញនូវចំណែករយៈពេលខ្លី | ១៧ | ៥៩៩.៨៦៣ | ២.៤៦៩.៦៣៦ | ៨១១.៣២០ | ៣.៣០៥.៣១៨ |
| បំណុលភតិសន្យា- ដកចេញនូវចំណែករយៈពេលខ្លី | ៨ | - | - | - | - |
| **បំណុលរយៈពេលវែងសរុប** | | **៥៩៩.៨៦៣** | **២.៤៦៩.៦៣៦** | **៨១១.៣២០** | **៣.៣០៥.៣១៨** |

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (ត)

| | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| **បំណុលរយៈពេលខ្លី** | | | | | |
| ប្រាក់កម្ចី | ១៧ | ៨៩៣.៧៨៣ | ៣.៦៧៩.៧០៥ | ២.៥១៩.០១១ | ១០.២៦២.៤៥១ |
| គណទានវិបារូបន៍ | ១៨ | ២.៤១០.៩៨៤ | ៩.៩២៦.០២០ | ១.៨៧១.១១២ | ៧.៦២២.៩១០ |
| គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ | ១៩ | ១.០៨០.២៤៤ | ៤.៤៤៧.៣៦៥ | ១.៨៣១.២១៥ | ៧.៤៦០.៣៧០ |
| បំណុលភតិសន្យា | ៨ | - | - | ៤៨.៥០៩ | ១៩៧.៦២៦ |
| បំណុលកិច្ចសន្យា | ១៥ | ២.១០៥.២៥៤ | ៨.៦៦៧.៣៣១ | ១៦១.៨៨០ | ៦៥៩.៤៩៩ |
| បំណុលពន្ធលើប្រាក់ចំណូលបច្ចុប្បន្ន | ២៥.៣ | ១១.២៥៤ | ៤៦.៣៣៣ | ៣៤.៧៧៦ | ១៤១.៦៧៧ |
| **បំណុលរយៈពេលខ្លីសរុប** | | **៦.៥០១.៥១៩** | **២៦.៧៦៦.៧៥៤** | **៦.៤៦៦.៥០៣** | **២៦.៣៤៤.៥៣៣** |
| **បំណុលសរុប** | | **៧.១០១.៣៨២** | **២៩.២៣៦.៣៩០** | **៧.២៧៧.៨២៣** | **២៩.៦៤៩.៨៥១** |
| **មូលធន និងបំណុលសរុប** | | **១៤.៧៥៦.៣១១** | **៦០.៧៥១.៧៣១** | **១៦.៣៣៣.០២៦** | **៦៦.៥៤០.៧៤៨** |

# របាយការណ៍ចំណូលលម្អិត

| | កំណត់សម្គាល់ | សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
|---|---|---|---|---|---|
| ចំណូល | ២០ | ១៤.៣១៦.៧៨៣ | ៥៨.៥១២.៦៩២ | ១៧.៩៦៤.២២៨ | ៧៣.០៧៨.៤៨០ |
| ថ្លៃដើមសេវាកម្ម និងទំនិញបានលក់ | ២១ | (១៣.៦០៤.០៥៧) | (៥៥.៥៩៩.៧៨១) | (១៥.៤០៩.៤១០) | (៦២.៦៨៥.៤៨០) |
| **ចំណេញដុល** | | **៧១២.៧២៦** | **២.៩១២.៩១១** | **២.៥៥៤.៨១៨** | **១០.៣៩៣.០០០** |
| ចំណូលផ្សេងៗ - សុទ្ធ | ២៣ | ៧.៣១៧ | ២៩.៩០៥ | ២៨.០៦៣ | ១១៤.១៦០ |
| ចំណាយប្រតិបត្តិការ | ២២ | (១.៥៥៧.៥៨៧) | (៦.៣៦៥.៨៥៨) | (១.៤៨៣.៥៧៥) | (៦.០៣៥.១៨៣) |
| ចំណាយហិរញ្ញវត្ថុ | ២៤ | (៣៥៤.៦០២) | (១.៤៤៩.២៥៨) | (៥០៦.៨៧០) | (២.០៦១.៩៤៧) |
| **(ខាត)/ចំណេញមុនបង់ពន្ធ** | | **(១.១៩២.១៤៦)** | **(៤.៨៧២.៣០០)** | **៥៩២.៤៣៦** | **២.៤១០.០៣០** |
| ចំណាយពន្ធលើប្រាក់ចំណូល | ២៥.១ | - | - | (១៧៩.៧៥៤) | (៧៣១.២៣៩) |
| **(ខាត)/ចំណេញក្នុងការិយបរិច្ឆេទ** | | **(១.១៩២.១៤៦)** | **(៤.៨៧២.៣០០)** | **៤១២.៦៨២** | **១.៦៧៨.៧៩១** |
| ចំណូលលម្អិតផ្សេងៗ - | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | **៣៤៧.៣៦៣** | - | **១៦៦.៣១៨** |
| **(ខាត) /ចំណូលលម្អិតសរុបក្នុងការិយបរិច្ឆេទ** | | **(១.១៩២.១៤៦)** | **(៤.៥២៤.៩៣៧)** | **៤១២.៦៨២** | **១.៨៤៥.១០៩** |

(ខាត)/ចំណេញក្នុងមួយសន្លឹកហ៊ុន ដែលត្រូវបានបែងចែកទៅឱ្យភាគហ៊ុនិករបស់ក្រុមហ៊ុនក្នុងអំឡុងការិយបរិច្ឆេទមានដូចខាងក្រោម៖

| | | | | | |
|---|---|---|---|---|---|
| (ខាត)/ចំណេញមូលដ្ឋានក្នុងមួយភាគហ៊ុន | **២៩** | (0,0៦) | (0,២៥) | 0,0៣ | 0,១២ |
| (ខាត)/ចំណេញថយចុះក្នុងមួយភាគហ៊ុន | **២៩** | (0,0៦) | (0,២៥) | 0,0៣ | 0,១២ |

# របាយការណ៍បម្រែបម្រួលមូលធន

| | កំណត់សម្គាល់ | ដើមទុន ដុល្លារអាមេរិក | ដើមទុន ពាន់រៀល (កំណត់សម្គាល់ ៤.២) | បុព្វលាភដើមទុន ដុល្លារអាមេរិក | បុព្វលាភដើមទុន ពាន់រៀល (កំណត់សម្គាល់ ៤.២) | ប្រាក់ចំណេញរក្សាទុក ដុល្លារអាមេរិក | ប្រាក់ចំណេញរក្សាទុក ពាន់រៀល (កំណត់សម្គាល់ ៤.២) | ការប្តូររូបិយប័ណ្ណបម្រុងទុក ពាន់រៀល (កំណត់សម្គាល់ ៤.២) | សរុប ដុល្លារអាមេរិក | សរុប ពាន់រៀល (កំណត់សម្គាល់ ៤.២) |
|---|---|---|---|---|---|---|---|---|---|---|
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | | ៤.៦១៥.៣៨៥ | ១៨.៧៩៦.៦៨៧ | ២.១៥៨.១៥៤ | ៨.៧៧៩.៣៧០ | ២.២៨១.៦៦៤ | ៩.៤៤១.៨៨៧ | (១២៧.០៤៧) | ៩.០៥៥.២០៣ | ៣៦.៨៩០.៨៩៧ |
| ខាតក្នុងការិយបរិច្ឆេទ | | - | - | - | - | (១.១៩២.១៤៦) | (៤.៨៧២.៣០០) | - | (១.១៩២.១៤៦) | (៤.៨៧២.៣០០) |
| ភាគលាភដែលបានបង់ | ១៦.២ | - | - | - | - | (២០៨.១២៨) | (៨៥០.៦១៩) | - | (២០៨.១២៨) | (៨៥០.៦១៩) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | - | - | - | - | ៣៤៧.៣៦៣ | - | ៣៤៧.៣៦៣ |
| **សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | **៤.៦១៥.៣៨៥** | **១៨.៧៩៦.៦៨៧** | **២.១៥៨.១៥៤** | **៨.៧៧៩.៣៧០** | **៨៨១.៣៩០** | **៣.៧១៨.៩៦៨** | **២២០.៣១៦** | **៧.៦៥៤.៩២៩** | **៣១.៥១៥.៣៤១** |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២១ | | ៣.០០០.០០០ | ១២.២២៥.៣០១ | - | - | ១.៨៦៨.៩៨២ | ៧.៧៦៣.០៩៦ | (២៩៣.៣៦៥) | ៤.៨៦៨.៩៨២ | ១៩.៦៩៥.០៣២ |
| ការបន្ថែមដើមទុន | ១៦.១ | ១.៦១៥.៣៨៥ | ៦.៥៧១.៣៨៦ | ២.១៥៨.១៥៤ | ៨.៧៧៩.៣៧០ | - | - | - | ៣.៧៧៣.៥៣៩ | ១៥.៣៥០.៧៥៦ |
| ចំណេញក្នុងការិយបរិច្ឆេទ | | - | - | - | - | ៤១២.៦៨២ | ១.៦៧៨.៧៩១ | - | ៤១២.៦៨២ | ១.៦៧៨.៧៩១ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | - | - | - | - | ១៦៦.៣១៨ | - | ១៦៦.៣១៨ |
| សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ៤.៦១៥.៣៨៥ | ១៨.៧៩៦.៦៨៧ | ២.១៥៨.១៥៤ | ៨.៧៧៩.៣៧០ | ២.២៨១.៦៦៤ | ៩.៤៤១.៨៨៧ | (១២៧.០៤៧) | ៩.០៥៥.២០៣ | ៣៦.៨៩០.៨៩៧ |

# របាយការណ៍លំហូរសាច់ប្រាក់

| | | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| **សកម្មភាពប្រតិបត្តិការ** | | | | | |
| (ខាត)/ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល | | (១.១៩២.១៤៦) | (៤.៨៧២.៣០០) | ៥៩២.៤៣៦ | ២.៤១០.០៣០ |
| **និយ័តកម្មសម្រាប់៖** | | | | | |
| រំលស់លើទ្រព្យសកម្មរូបី និងរំលស់ លើទ្រព្យសកម្មអរូបី | ៦ ៧ និង ៨ | **១៨៩.៨៣៦** | **៧៧៥.៨៦១** | ១៧៨.៩១៦ | ៧២៧.៨៣១ |
| ចំណាយហិរញ្ញវត្ថុ | ២៤ | **៣៥៤.៦០២** | **១.៤៤៩.២៥៨** | ៥០៦.៨៧០ | ២.០៦១.៩៤៧ |
| ចំណូលការប្រាក់ | ២៣ | **(៣.៦០២)** | **(១៤.៧២១)** | (៧.៣២០) | (២៩.៧៧៨) |
| ចំណេញពីការប្តូររូបិយប័ណ្ណបរទេស | ២៣ | **(៤.១៥១)** | **(១៦.៩៦៥)** | (៣.៣៧៣) | (១៣.៧២១) |
| ខាតលើការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | ២៣ | **៤៣៨** | **១.៧៩១** | ១.៨២០ | ៧.៤០៤ |
| (ខាត)ប្រតិបត្តិការ/ចំណេញមុនបម្រែបម្រួលទុនបង្វិល | | **(៦៥៥.០២៣)** | **(២.៦៧៧.០៧៦)** | ១.២៦៩.៣៤៩ | ៥.១៦៣.៧១៣ |
| **បម្រែបម្រួលទុនបង្វិល** | | | | | |
| **បម្រែបម្រួលសុទ្ធក្នុង៖** | | | | | |
| ទ្រព្យសកម្មកិច្ចសន្យា | | **(៥៤៧.៤០៦)** | **(២.២៣៧.២៤៨)** | (៦៤០.៥៣៦) | (២.៦០៥.៧០០) |
| ទ្រព្យសកម្មរយៈពេលខ្លីផ្សេងៗ | | **(១១១.១២៣)** | **(៤៥៤.១៦០)** | (៤៨៦.១១៣) | (១.៩៧៧.៥០៦) |
| សមតុល្យដែលភាគហ៊ុនិកជំពាក់ | | **(១.៨៤៩)** | **(៧.៥៥៧)** | (១៣៤.៤២១) | (៥៤៦.៨២៩) |
| សន្និធិ - សុទ្ធ | | **៨៩៣.១២៦** | **៣.៦៥០.២០៦** | (៥៣៣.៤៤២) | (២.១៧០.០៤២) |
| ប្រាក់តម្កល់ធានា | | **(៥២៥.០៨០)** | **(២.១៤៦.០០២)** | ១៤៥.៥៤៥ | ៥៩២.០៧៧ |
| គណនីពាណិជ្ជត្រូវទទួល | | **៣.១០៧.២៨៤** | **១២.៦៩៩.៤៧០** | (៤.៧៨៥.៨៣៨) | (១៩.៤៦៨.៧៨៩) |
| ទ្រព្យសកម្មរយៈពេលវែងផ្សេងៗ | | **(៥០)** | **(២០៤)** | ៣៩.០០០ | ១៥៨.៦៥២ |
| ឥណទានវិបារូបន៍ | | **៥៣៩.៨៧២** | **២.២០៦.៤៥៧** | ១៤៦.៥២០ | ៥៩៦.០៤៣ |
| គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ | | **(៦៩៧.០៧១)** | **(២.៨៤៨.៩២៨)** | ១.១៣៤.០៤៧ | ៤.៦១៣.៣០៣ |
| បំណុលកិច្ចសន្យា | | **១.៩៤៣.៣៧៤** | **៧.៩៤២.៥៧០** | (២៤៦.០៧៣) | (១.០០១.០២៥) |
| សមតុល្យដែលជំពាក់ភាគហ៊ុនិក | | - | - | (៥.៦៤២) | (២២.៩៥២) |
| **សាច់ប្រាក់បានពី/(បានប្រើក្នុង)សកម្មភាពប្រតិបត្តិការ** | | **៣.៩៤៦.០៥៤** | **១៦.១២៧.៥២៨** | (៤.០៩៧.៦០៣) | (១៦.៦៦៩.០៥៥) |
| ការប្រាក់បានទទួល | | **៣.៦០២** | **១៤.៧២១** | ៧.៣២០ | ២៩.៧៧៨ |
| ពន្ធលើប្រាក់ចំណូលដែលបានបង់ | ២៥.៣ | **(៧៧.៤២២)** | **(៣១៦.៤២៤)** | (១៧២.៩៤៣) | (៧០៣.៥៣២) |
| **សាច់ប្រាក់សុទ្ធបានពី/(បានប្រើក្នុង)សកម្មភាពប្រតិបត្តិការ** | | **៣.៨៧២.២៣៤** | **១៥.៨២៥.៨២៥** | (៤.២៦៣.២២៧) | (១៧.៣៤២.៨០៩) |
| **សកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ និងទ្រព្យសកម្មអរូបី | ៦ និង ៧ | **(១.៦២៧.៩៦៥)** | **(៦.៦៥៣.៤៩៣)** | (១៨២.៨០៦) | (៧៤៣.៦៥៥) |
| សាច់ប្រាក់បានពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | ៦ និង ៧ | - | - | ១៥០ | ៦១០ |
| **សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ** | | **(១.៦២៧.៩៦៥)** | **(៦.៦៥៣.៤៩៣)** | (១៨២.៦៥៦) | (៧៤៣.០៤៥) |

# របាយការណ៍លំហូរសាច់ប្រាក់(ត)

| | | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| **សកម្មភាពហិរញ្ញវត្ថុ** | | | | | |
| ការបន្ថែមដើមទុន | ១៦.១ | - | - | ៣.៧៧៣.៥៣៩ | ១៥.៣៥០.៧៥៧ |
| ការទូទាត់ភាគលាភ | ១៦.២ | (២០៨.១២៨) | (៨៥០.៦១៩) | - | - |
| ការទូទាត់សងបំណុលភតិសន្យា | ៨ | (៥០.៤០០) | (២០៥.៩៨៥) | (៦៧.២០១) | (២៧៣.៣៧៤) |
| ការទូទាត់សងប្រាក់កម្ចី | ១៧ | (៥.៦៨៧.៩១៩) | (២៣.២៤៦.៥២៥) | (៧.៣០៥.៥២១) | (២៩.៧១៨.៨៥៩) |
| ប្រាក់កម្ចី | ១៧ | ៣.៨៥១.២៣៤ | ១៥.៧៣៩.៩៩៣ | ៨.៤៨៦.៨២១ | ៣៤.៥២៤.៣៨៨ |
| ការទូទាត់ការប្រាក់ | ១៧ | (៣៥២.៧១១) | (១.៤៤១.៥២៩) | (៤៩៩.៧៦០) | (២.០៣៣.០២៣) |
| **សាច់ប្រាក់សុទ្ធ (បានប្រើក្នុង)/បានពីសកម្មភាពហិរញ្ញវត្ថុ** | | (២.៤៤៧.៩២៤) | (១០.០០៤.៦៦៥) | ៤.៣៨៧.៨៧៨ | ១៧.៨៤៩.៨៨៩ |
| **បម្រែបម្រួលសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធក្នុងការិយបរិច្ឆេទ** | | (២០៣.៦៥៥) | (៨៣២.៣៣៣) | (៥៨.០០៥) | (២៣៥.៩៦១) |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមគ្រា | | ២២៥.១១៩ | ៩១៧.១៣៥ | ២៨៣.១២៤ | ១.១៤៥.២៣៧ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | ៣.៥៦៥ | - | ៧.៨៦៣ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងគ្រា** | ១០ | ២១.៤៦៤ | ៨៨.៣៦៧ | ២២៥.១១៩ | ៩១៧.១៣៥ |

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

## ១. ព័ត៌មានទូទៅអំពីក្រុមហ៊ុន

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក (ហៅកាត់ថា"ក្រុមហ៊ុន") ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតបានបង្កើតឡើងក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៩៨ ជាមួយការចុះបញ្ជីពាណិជ្ជកម្មលេខ ០០០០៤០២៩ ដែលបានចេញផ្សាយដោយក្រសួងពាណិជ្ជកម្ម ("MOC")។ ដោយអនុលោមតាមអនុស្សរណៈ និងលក្ខន្តិកៈ ដំណើរការអាជីវកម្មរបស់ក្រុមហ៊ុន គឺរយៈពេល ៩៩ឆ្នាំ គិតចាប់ផ្តើមពីកាលបរិច្ឆេទចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យចុះបញ្ជី និងទីតាំងអាជីវកម្មចម្បងរបស់ក្រុមហ៊ុនមានទីតាំងស្ថិតនៅដីឡូត៍លេខ៦៨ ផ្លូវ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ ប្រអប់សំបុត្រលេខ ១៧៨ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺធ្វើប្រតិបត្តិការជាអ្នកម៉ៅការផ្នែកមេកានិក និងអគ្គិសនី អ្នកម៉ៅការប្រព័ន្ធទឹក និងពន្លត់អគ្គីភ័យ ប្រព័ន្ធម៉ាស៊ីនត្រជាក់ក្នុងបន្ទប់ HVAC និងអ្នកម៉ៅការថែទាំអាគារផ្សេងៗ។

នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២១ ក្រុមហ៊ុនបានចុះបញ្ជីដោយជោគជ័យនៅក្នុងទីផ្សារកំណើននៃផ្សារមូលបត្រកម្ពុជា ("CSX")។ ចំនួនហ៊ុនថ្មីដែលបានបោះផ្សាយមានចំនួន ៦.៤៦១.៥៣៨ ហ៊ុនជាមួយតម្លៃចារឹក ១.០០០ រៀល (០.២៥ ដុល្លារអាមេរិក) ក្នុងមួយហ៊ុន ក្នុងតម្លៃលក់ចេញ ២.៣៨០ រៀល (០.៥៨ ដុល្លារអាមេរិក) ក្នុងមួយហ៊ុន។ ក្រុមហ៊ុនបានទទួលចំណូលពីការបោះផ្សាយលក់ភាគហ៊ុនជាសាធារណៈលើកដំបូង ("IPO") ក្នុងសមតុល្យ ៣.៧៧៣.៥៣៩ ដុល្លារអាមេរិក ជាលទ្ធផលក្នុងបុព្វលាភភាគហ៊ុនចំនួន ២.១៥៨.១៥៤ ដុល្លារអាមេរិក (៨.៧៧៩.៣៧០.០០០ រៀល)។ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលមិនទាន់ធ្វើការអនុម័តទៅលើការធ្វើវិសោធនកម្មលើអនុស្សរណៈ និងលក្ខន្តិកៈរបស់ក្រុមហ៊ុន ដែលទាក់ទងនឹងការបង្កើនដើមទុនពី IPO ឡើយ។

ក្រុមហ៊ុនមាននិយោជិតចំនួន ១.១១២ នាក់ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១៖ មាននិយោជិតចំនួន ៩៦៦ នាក់)។

## ២. មូលដ្ឋាននៃការរៀបចំ និងរបាយការណ៍ដែលអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា

របាយការណ៍ហិរញ្ញវត្ថុទាំងនេះ ត្រូវបានរៀបចំដោយអនុលោមតាមស្តង់ដារស្តីពីរបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRSs")។

និយ័តករគណនេយ្យ និងសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា បានចេញប្រកាស (សារាចរ) លេខ ០៦៨-សហវ ប្រ.ក ចុះនៅថ្ងៃទី៨ ខែមករា ឆ្នាំ២០០៩ ដែលបានចេញផ្សាយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា លើការអនុវត្តស្តង់ដារស្តីពីរបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុនៃកម្ពុជា បានសម្រេចឱ្យអនុវត្តពេញលេញទៅលើស្តង់ដារស្តីពីរបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ("IFRS") ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាភិបាលគណនេយ្យអន្តរជាតិ ("IASB") ដោយមិនមានការកែប្រែឡើយ។ ស្តង់ដារនេះត្រូវបានគេហៅថាស្តង់ដារស្តីពីរបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ។

## ៣. ស្តង់ដារថ្មី ឬវិសោធនកម្មស្តង់ដារ និងការបកស្រាយ

### ៣.១ ស្តង់ដារ វិសោធនកម្ម និងការបកស្រាយទៅលើស្តង់ដារដែលមានស្រាប់ដែលមិនទាន់មានប្រសិទ្ធភាព និងមិនទាន់បានអនុវត្តជាមុនដោយក្រុមហ៊ុន

នាកាលបរិច្ឆេទនៃសេចក្តីអនុម័តទៅលើរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ស្តង់ដារថ្មីមួយចំនួន ប៉ុន្តែមិនទាន់មានប្រសិទ្ធភាព ស្តង់ដារ និងវិសោធនកម្មស្តង់ដារដែលមានស្រាប់ និងការបកស្រាយដែលត្រូវបានចេញផ្សាយដោយ IASB។

ស្តង់ដារផ្សេងៗ និងវិសោធនកម្មដែលមិនទាន់មានប្រសិទ្ធភាពនៅឡើយ និងមិនទាន់បានអនុវត្តជាមុនដោយក្រុមហ៊ុនរួមមាន៖

- CIFRS ១៧ កិច្ចសន្យាធានារ៉ាប់រង
- វិសោធនកម្មទៅលើ CIFRS ១៧ 'កិច្ចសន្យាធានារ៉ាប់រង' (វិសោធនកម្មទៅលើ CIFRS ១៧ និងCIFRS ៤)
- ការធ្វើចំណាត់ថ្នាក់លើបំណុលរយៈពេលខ្លី ឬរយៈពេលវែង (វិសោធនកម្មទៅលើ CIAS ១)
- ការលាតត្រដាងគោលនយោបាយគណនេយ្យ (វិសោធនកម្មទៅលើ CIAS ១ និងការអនុវត្តរបាយការណ៍ IFRS ២)
- ពន្ធពន្យារទាក់ទងនឹងទ្រព្យសកម្ម និងបំណុល ដែលកើតឡើងពីប្រត្តិបត្តិការតែមួយ (វិសោធនកម្មទៅលើ CIAS ១២)
- ការលាតត្រដាងគោលនយោបាយគណនេយ្យ (វិសោធនកម្មទៅលើ CIAS ១)
- និយមន័យគណនេយ្យប៉ាន់ស្មាន (វិសោធនកម្មទៅលើ CIAS ៨)

ការធ្វើវិសោធនកម្មទាំងនេះ មិនបានរំពឹងថានឹងមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនក្នុងអំឡុងការអនុវត្តដំបូងនេះទេ ហេតុដូចនេះហើយការលាតត្រដាងមិនត្រូវបានធ្វើឡើងឡើយ។

## ៤. សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ

### ៤.១ មូលដ្ឋាននៃការរៀបចំ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលបានបង្ហាញជាដុល្លារអាមេរិក ("USD") ត្រូវបានរៀបចំក្រោមមូលដ្ឋានថ្លៃដើមប្រវត្តិសាស្ត្រ និងបានរៀបចំឡើងដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

### ៤.២ រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណក្នុងការបង្ហាញ

រូបិយវត្ថុជាតិនៃព្រះរាជាណាចក្រកម្ពុជា គឺខ្មែររៀល ("KHR")។ ប៉ុន្តែដោយសារក្រុមហ៊ុនមានប្រតិបត្តិការអាជីវកម្ម និងការរក្សាកំណត់ត្រាគណនេយ្យបឋមជាប្រាក់ដុល្លារអាមេរិក គណៈគ្រប់គ្រងបានកំណត់យកប្រាក់ដុល្លារអាមេរិក ជារូបិយប័ណ្ណរបស់ក្រុមហ៊ុនសម្រាប់គោលបំណងក្នុងការវាស់វែង និងបង្ហាញ ព្រោះវាបានឆ្លុះបញ្ចាំងពីសារៈសំខាន់នៃសេដ្ឋកិច្ចក្រោមព្រឹត្តិការណ៍ និងស្ថានការណ៍របស់ក្រុមហ៊ុន។

ប្រតិបត្តិការជារូបិយប័ណ្ណបរទេស ក្រៅពីប្រាក់ដុល្លារអាមេរិក គឺត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ក្នុងអត្រាប្តូរប្រាក់តាមកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ទ្រព្យសកម្ម និងបំណុលជារូបិយវត្ថុ ដែលកំណត់ដោយរូបិយប័ណ្ណក្រៅពីប្រាក់ដុល្លារអាមេរិកនាកាលបរិច្ឆេទនៃរបាយការណ៍ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក តាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ភាពលម្អៀងនៃអត្រាប្តូរប្រាក់ដែលកើតឡើងពីការប្តូររូបិយប័ណ្ណ គឺត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិតផ្សេងៗ។

ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិក ទៅជាខ្មែររៀលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានដាក់បញ្ចូលទាំងស្រុងដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ និងត្រូវបានធ្វើឡើងដោយប្រើប្រាស់អត្រាប្តូរប្រាក់ជាផ្លូវការ ដូចដែលបានបង្ហាញជាខ្មែររៀលក្នុង ១ ដុល្លារអាមេរិកដូចដែលបានចេញផ្សាយដោយ ធនាគារជាតិ នៃ កម្ពុជា ("NBC")៖

| | ឆ្នាំ២០២២ | ឆ្នាំ២០២១ |
|---|---|---|
| អត្រាមធ្យម* (១២ ខែ) | **៤.០៨៧** | ៤.០៦៨ |
| អត្រាចុងគ្រា | **៤.១១៧** | ៤.០៧៤ |

*សមតុល្យគិតជាមធ្យម ត្រូវបានកំណត់ដោយប្រើប្រាស់អត្រាប្រចាំថ្ងៃរបស់ធនាគារជាតិ នៃ កម្ពុជា ក្នុងអំឡុងការិយបរិច្ឆេទនោះ។

ការប្តូររូបិយប័ណ្ណទាំងនេះមិនត្រូវបានធ្វើសវនកម្មទេ ហើយមិនត្រូវបានបកស្រាយថាជាតំណាងនៃប្រាក់ដុល្លារអាមេរិក ដែលត្រូវបាន ឬអាចនឹងត្រូវបាន ឬអាចប្តូរទៅជាប្រាក់រៀលតាមអត្រាដែលបានបង្ហាញនេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតទេ។

## ៤.៣ ឧបករណ៍ហិរញ្ញវត្ថុ

**ការទទួលស្គាល់ និងការឈប់ទទួលស្គាល់**

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានទទួលស្គាល់នៅពេលដែលក្រុមហ៊ុនបានក្លាយទៅជាភាគីកិច្ចសន្យាសំវិធានធននៃឧបករណ៍ហិរញ្ញវត្ថុ។

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានឈប់ទទួលស្គាល់នៅពេលដែលសិទ្ធិទទួលបានពីលំហូរសាច់ប្រាក់តាមកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុនោះផុតកំណត់ ឬនៅពេលហានិភ័យ និងតម្លៃតបស្នងពីកម្មសិទ្ធិនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានផ្ទេរចេញ។

បំណុលហិរញ្ញវត្ថុ ត្រូវបានឈប់ទទួលស្គាល់នៅពេលដែលកាតព្វកិច្ច កិច្ចសន្យាបានបញ្ចប់ បានលុបចោល ឬផុតកាលកំណត់។

**ការធ្វើចំណាត់ថ្នាក់ និងការវាស់វែងដំបូងនៃទ្រព្យសកម្មហិរញ្ញវត្ថុ**

ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ ត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្របដែលបានធ្វើការកែតម្រូវលើថ្លៃដើមប្រតិបត្តិការ (ប្រសិនបើអាចអនុវត្តបាន)។

ទ្រព្យសកម្មហិរញ្ញវត្ថុ ក្រៅពីការកំណត់ និងមានប្រសិទ្ធភាពដែលជាឧបករណ៍ការពារហានិភ័យ ត្រូវបានចាត់ថ្នាក់តាមប្រភេទដូចខាងក្រោម៖

- ថ្លៃដើមបានរំលស់
- តម្លៃសមស្របតាមរយៈចំណេញ ឬខាត (FVTPL) ឬ
- តម្លៃសមស្របតាមរយៈចំណូលលម្អិតផ្សេងៗ (FVOCI)។

ការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុនេះ បានកំណត់ដូចខាងក្រោម៖

- គំរូអាជីវកម្មរបស់អង្គភាពសម្រាប់គ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និង
- លក្ខណៈនៃលំហូរសាច់ប្រាក់តាមកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុ។

រាល់ចំណូល និងចំណាយដែលទាក់ទងទៅនឹងទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានទទួលស្គាល់ក្នុងគណនីចំណេញ ឬខាត ត្រូវបានបង្ហាញនៅក្នុងចំណូលការប្រាក់ ឬចំណាយការប្រាក់។

### ការវាស់វែងជាបន្តបន្ទាប់នៃទ្រព្យសកម្មហិរញ្ញវត្ថុ

#### ទ្រព្យសកម្មហិរញ្ញវត្ថុតាមថ្លៃដើមបានរំលស់

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាស់វែងតាមថ្លៃដើមបានរំលស់ប្រសិនបើទ្រព្យសកម្មមានលក្ខខណ្ឌដូចខាងក្រោម (និងមិនត្រូវបានកំណត់ជា FVTPL)៖

- វាត្រូវបានធ្វើឡើងតាមគំរូអាជីវកម្មដែលមានគោលបំណងដើម្បីកាន់កាប់ទ្រព្យសកម្មហិរញ្ញវត្ថុ និងប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា និង
- លក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុផ្តល់នូវលំហូរសាច់ប្រាក់ដែលជាការទូទាត់ប្រាក់ដើម និងការប្រាក់ទៅលើសមតុល្យដើមដែលនៅសល់។

បន្ទាប់ពីការទទួលស្គាល់ដំបូង ទ្រព្យសកម្មហិរញ្ញវត្ថុទាំងនេះ ត្រូវបានវាស់វែងតាមថ្លៃដើមបានរំលស់ដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ ការធ្វើអប្បហារ នឹងមិនត្រូវបានធ្វើឡើងឡើយ ប្រសិនបើផលប៉ះពាល់វាជាអសារវន្ត។ សាច់ប្រាក់ និងសាច់ប្រាក់សមមូលគណនីពាណិជ្ជត្រូវទទួល ប្រាក់តម្កល់ធានា និងទ្រព្យសកម្មរយៈពេលវែងផ្សេងៗរបស់ក្រុមហ៊ុន ត្រូវបានស្ថិតនៅក្នុងចំណាត់ថ្នាក់ប្រភេទនៃឧបករណ៍ហិរញ្ញវត្ថុនេះ។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានវាស់វែងតាមថ្លៃដើមបានរំលស់ មានសាច់ប្រាក់ និងសាច់ប្រាក់សមមូល គណនីពាណិជ្ជត្រូវទទួល ប្រាក់តម្កល់ធានា សមតុល្យដែលភាគហ៊ុនិកជំពាក់ និងទ្រព្យសកម្មរយៈពេលវែងផ្សេងៗ។

គណនីពាណិជ្ជត្រូវទទួល គឺជាគណនីមិនមានការប្រាក់ ហើយជាធម្មតាត្រូវបានទូទាត់ក្នុងរយៈពេលមួយខែបន្ទាប់ពីការចេញវិក្កយបត្រនៅរៀងរាល់ចុងខែរហូតដល់គម្រោងមួយត្រូវបានបញ្ចប់។

### ទ្រព្យសកម្មហិរញ្ញវត្ថុនៃតម្លៃសមស្របតាមរយៈគណនីចំណេញ ឬខាត (FVTPL)

ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានរក្សាក្នុងគំរូអាជីវកម្ម ក្រៅពី "កាន់កាប់សម្រាប់ការប្រមូល" ឬ "កាន់កាប់សម្រាប់ការប្រមូល និងលក់" និងទ្រព្យសកម្មហិរញ្ញវត្ថុ ដែលលំហូរសាច់ប្រាក់តាមកិច្ចសន្យាមិនត្រូវបានទូទាត់ជាប្រាក់ដើម និងការប្រាក់ គឺត្រូវបានគណនាតាមតម្លៃសមស្របតាមរយៈគណនីចំណេញ ឬខាត។ ពុំមានឧបករណ៍ហិរញ្ញវត្ថុណាមួយរបស់ក្រុមហ៊ុន ស្ថិតនៅក្នុងប្រភេទនៃចំណាត់ថ្នាក់នេះទេ។

### ទ្រព្យសកម្មហិរញ្ញវត្ថុនៃតម្លៃសមស្របតាមរយៈចំណូលលម្អិតផ្សេងៗ (FVOCI)

ក្រុមហ៊ុនកត់ត្រាទ្រព្យសកម្មហិរញ្ញវត្ថុទៅតាម FVOCI ប្រសិនបើទ្រព្យសកម្មនោះ មានលក្ខណៈដូចខាងក្រោម៖

- ទ្រព្យសកម្មនោះត្រូវបានកាន់កាប់នៅក្នុងគំរូអាជីវកម្មក្នុងគោលបំណងកាន់កាប់ដើម្បីប្រមូលលំហូរសាច់ប្រាក់ដែលពាក់ព័ន្ធ និងលក់
- លក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុ ផ្ដល់ការកើនឡើងនូវលំហូរសាច់ប្រាក់ ចំពោះតែការទូទាត់សងនៃប្រាក់ដើម និងការប្រាក់ទៅលើសមតុល្យដើមដែលនៅសល់។

ចំណេញ ឬខាត បានទទួលស្គាល់នៅក្នុងចំណូលលម្អិតផ្សេងៗនឹងត្រូវបានកែសម្រួលឡើងវិញនៅពេលមានការឈប់ទទួលស្គាល់នៃទ្រព្យសកម្មទាំងនោះ។ ពុំមានឧបករណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនណាមួយត្រូវបានចាត់ចូលនៅក្នុងចំណាត់ថ្នាក់នេះទេ។

### ឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ

ឱនភាពនៃ CIFRS ៩ តម្រូវឱ្យប្រើប្រាស់ព័ត៌មាននៅពេលខាងមុខដើម្បីទទួលស្គាល់ការខាតបង់ឥណទានដែលរំពឹងទុក- 'ការខាតបង់ឥណទានដែលរំពឹងទុកគំរូ ("ECL")' ។ ក្រុមហ៊ុនពិចារណាលើព័ត៌មានយ៉ាងទូលំទូលាយ នៅពេលវាយតម្លៃហានិភ័យឥណទាន និងវាស់វែងការខាតបង់ឥណទានដែលរំពឹងទុក រួមទាំងព្រឹត្តិការណ៍ពីមុន បច្ចុប្បន្ន និងការព្យាករណ៍ដ៏សមហេតុផល និងអាចជឿជាក់បាន ដែលប៉ះពាល់ដល់លទ្ធភាពពីការប្រមូលនៃលំហូរសាច់ប្រាក់ដែលបានរំពឹងទុកនាពេលអនាគតនៃឧបករណ៍ហិរញ្ញវត្ថុទាំងនោះ។

ដើម្បីអនុវត្តវិធីសាស្ត្ររំពឹងទុកនេះ បង្ករឱ្យមានភាពខុសគ្នារវាង៖

- ឧបករណ៍ហិរញ្ញវត្ថុដែលមិនបានធ្លាក់ចុះតម្លៃយ៉ាងខ្លាំងនៅក្នុងគុណភាពឥណទាន ចាប់តាំងពីថ្ងៃកត់ត្រាដំបូង ឬដែលមានហានិភ័យឥណទានទាប ("ដំណាក់កាលទី ១") និង
- ឧបករណ៍ហិរញ្ញវត្ថុដែលបានធ្លាក់ចុះយ៉ាងខ្លាំងនៅក្នុងគុណភាពឥណទាន ចាប់តាំងពីថ្ងៃកត់ត្រាដំបូង និងមានហានិភ័យឥណទានខ្ពស់ ("ដំណាក់កាលទី ២")។

"ដំណាក់កាលទី៣" គ្របដណ្តប់លើទ្រព្យសកម្មហិរញ្ញវត្ថុដែលមានភស្តុតាងជាក់ស្តែងទាក់ទងនឹងឱនភាពនាកាលបរិច្ឆេទនៃរបាយការណ៍។ ទោះបីជាយ៉ាងណាក៏ដោយ ពុំមានទ្រព្យសកម្មហិរញ្ញវត្ថុរបស់ក្រុមហ៊ុនណាមួយត្រូវបានចាត់ចូលក្នុងចំណាត់ថ្នាក់នេះឡើយ។

"ECL សម្រាប់រយៈពេល ១២ខែ" ត្រូវបានទទួលស្គាល់សម្រាប់ដំណាក់កាលទី១ ហើយ "ECL សម្រាប់ពេញមួយអាយុកាល" ត្រូវបានទទួលស្គាល់សម្រាប់ដំណាក់កាលទី២។

ការវាស់វែងលើការខាតបង់ឥណទានដែលបានរំពឹងទុក ត្រូវបានកំណត់ដោយការប៉ាន់ស្មានតាមប្រូបាប៊ីលីតេមធ្យមលើការខាតបង់ឥណទានលើអាយុកាលនៃឧបករណ៍ហិរញ្ញវត្ថុដែលបានរំពឹងទុក។

### គណនីពាណិជ្ជ និងគណនីត្រូវទទួលផ្សេងៗ និងទ្រព្យសកម្មកិច្ចសន្យា

ក្រុមហ៊ុនប្រើវិធីសាស្ត្រសាមញ្ញមួយក្នុងការកត់ត្រាលើគណនីពាណិជ្ជ និងគណនីត្រូវទទួលផ្សេងៗ ព្រមទាំងទ្រព្យកម្មកិច្ចសន្យា និងកត់ត្រាការខាតបង់សំវិធានធនជា ECL សម្រាប់ពេញមួយអាយុកាល។ គណនីទាំងនេះ គឺជាកង្វះខាតដែលបានរំពឹងទុកនៅក្នុងលំហូរសាច់ប្រាក់តាមកិច្ចសន្យា ដោយពិចារណាលើសក្តានុពលនៃការខកខានលើចំណុចណាមួយក្នុងអំឡុងពេលនៃអាយុកាលរបស់ឧបករណ៍ហិរញ្ញវត្ថុ។ ក្រុមហ៊ុនប្រើប្រាស់បទពិសោធន៍ប្រវត្តិសាស្ត្រ និងសូចនាករខាងក្រៅរបស់ខ្លួន ដើម្បីគណនាការខាតបង់ឥណទានដែលរំពឹងទុក ដោយប្រើប្រាស់អត្រាការខាតបង់ជាប្រវត្តិសាស្ត្រ។

### ការធ្វើចំណាត់ថ្នាក់ និងការវាស់វែងនៃបំណុលហិរញ្ញវត្ថុ

គណនេយ្យនៃបំណុលហិរញ្ញវត្ថុ គឺនៅដដែលបើប្រៀបធៀប CIFRS ៩ ទៅនឹង CIAS ៣៩ ហើយបំណុលហរិញ្ញវត្ថុរបស់ក្រុមហ៊ុន មិនត្រូវបានប៉ះពាល់ដោយការអនុវត្ត CIFRS ៩ ទេ។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីភាពពេញលេញ គោលនយោបាយគណនេយ្យត្រូវបានលាតត្រដាងដូចខាងក្រោម។

បំណុលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួមមាន ប្រាក់កម្ចី ឥណទានវិបារូបន៍ បំណុលភតិសន្យា សមតុល្យដែលជំពាក់ភាគីពាក់ព័ន្ធ និងគណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ។

បំណុលហិរញ្ញវត្ថុត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប និងដែលអាចអនុវត្តបាន ហើយត្រូវបានកែតម្រូវទៅតាមថ្លៃដើមប្រតិបត្តិការ លុះត្រាតែក្រុមហ៊ុនបានកំណត់នូវបំណុលហិរញ្ញវត្ថុក្នុងតម្លៃសមស្របតាមគណនីចំណេញ ឬខាត។

បន្ទាប់មក បំណុលហិរញ្ញវត្ថុត្រូវបានវាស់វែងតាមថ្លៃដើមបានរំលស់ដោយប្រើប្រាស់វិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាពលើកលែងសម្រាប់ឧបករណ៍និស្សន្ទ និងបំណុលហិរញ្ញវត្ថុដែលបានកំណត់តាម FVTPL ដែលត្រូវបានយោងជាបន្តបន្ទាប់តាមតម្លៃសមស្របជាមួយគណនីចំណេញ ឬខាត បានទទួលស្គាល់ក្នុងរបាយការណ៍ចំណូលលម្អិត (ក្រៅពីឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទដែលបានកំណត់ និងមានប្រសិទ្ធភាពជាឧបករណ៍ការពារហានិភ័យ)។

រាល់ចំណាយការប្រាក់ដែលពាក់ព័ន្ធ និងប្រសិនបើអនុវត្តបាននូវការផ្លាស់ប្តូរតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ ដែលបានរាយការណ៍នៅក្នុងរបាយការណ៍ចំណូលលម្អិត ត្រូវបានបញ្ចូលទៅក្នុងគណនីចំណាយហិរញ្ញវត្ថុ ឬចំណូលហិរញ្ញវត្ថុ។

### ៤.៤. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់មានក្នុងដៃ និងសមតុល្យក្នុងធនាគារផ្សេងៗ ដែលងាយស្រួលក្នុងការបំប្លែងជាសាច់ប្រាក់ជាក់លាក់ ដែលប្រឈមនឹងហានិភ័យនៃការផ្លាស់ប្តូរតម្លៃតិច។

### ៤.៥. មូលធន ទុនបម្រុង និងប្រាក់ចំណេញរក្សាទុក

ដើមទុនតំណាងឱ្យតម្លៃចារឹករបស់ភាគហ៊ុនត្រូវបានបោះផ្សាយ។ ចំណេញរក្សាទុក រួមមានចំណេញ ឬខាតនាពេលបច្ចុប្បន្ន និងចាស់ទាំងអស់។

### ៤.៦. សំវិធានធន បំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុ

សំវិធានធនត្រូវបានទទួលស្គាល់នៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចស្របច្បាប់ ឬកាតព្វកិច្ច ដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងមក វាអាចទៅរួចដែលក្រុមហ៊ុនតម្រូវឱ្យមានប្រភពលំហូរចេញនៃអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច និងសមតុល្យអាចត្រូវបានប៉ាន់ស្មានយ៉ាងត្រឹមត្រូវ។ ការកំណត់ពេលវេលា ឬសមតុល្យនៃលំហូរចេញនៅតែអាចមានភាពមិនច្បាស់លាស់។ កាតព្វកិច្ចបច្ចុប្បន្ន កើតឡើងពីកិច្ចសន្យាផ្លូវច្បាប់ ឬកិច្ចព្រមព្រៀងដែលជាលទ្ធផលពីព្រឹត្តិការណ៍កន្លងមក ជាឧទាហរណ៍ ធានារ៉ាប់រងក្នុងការផ្គត់ផ្គង់ផលិតផល ជម្លោះផ្លូវច្បាប់ ឬកិច្ចសន្យាស្មុគស្មាញ។

សំវិធានធន ត្រូវបានវាស់វែងតាមការចំណាយដែលបានប៉ាន់ស្មានទុកដែលតម្រូវឱ្យធ្វើការទូទាត់នូវកាតព្វកិច្ចបច្ចុប្បន្ន ដោយយោងទៅលើភស្តុតាងដែលអាចជឿទុកចិត្តបានបំផុតនាកាលបរិច្ឆេទនៃរបាយការណ៍ រួមបញ្ចូលទាំងហានិភ័យ និងភាពមិនច្បាស់លាស់ដែលទាក់ទងនឹងកាតព្វកិច្ចបច្ចុប្បន្ន។ នៅពេលដែលមានកាតព្វកិច្ចស្រដៀងគ្នាមួយចំនួន ដែលនឹងតម្រូវឱ្យមានលំហូរចេញនៃសាច់ប្រាក់ក្នុងការទូទាត់ត្រូវបានកំណត់តាមរយៈការពិចារណាទៅលើចំណាត់ថ្នាក់នៃកាតព្វកិច្ចទាំងមូល។ សំវិធានធន ត្រូវបានធ្វើអប្បហារឱ្យស្មើទៅនឹងតម្លៃបច្ចុប្បន្ន ប្រសិនបើតម្លៃនោះមានភាពជាសារវន្ត។

រាល់សំណងដែលក្រុមហ៊ុនជឿជាក់ថានឹងប្រមូលបានពីតតិយជនដែលទាក់ទងទៅនឹងកាតព្វកិច្ច ត្រូវបានទទួលស្គាល់ជាទ្រព្យសកម្មដាច់ដោយឡែក។ ទោះជាយ៉ាងណា ទ្រព្យសកម្មនេះអាចនឹងមិនលើសពីសមតុល្យនៃសំវិធានធនដែលពាក់ព័ន្ធ។ រាល់សំវិធានធន ត្រូវបានត្រួតពិនិត្យឡើងវិញនារាល់កាលបរិច្ឆេទនៃរបាយការណ៍ និងបានកែតម្រូវដើម្បីឆ្លុះបញ្ចាំងពីការប៉ាន់ស្មានបច្ចុប្បន្នដែលត្រឹមត្រូវបំផុត។

ក្នុងករណីទាំងនោះ នៅពេលដែលលំហូរចេញនៃធនធានសេដ្ឋកិច្ចដែលអាចកើតមាន ដែលជាលទ្ធផលនៃកាតព្វកិច្ចបច្ចុប្បន្នត្រូវបានចាត់ទុកថាមិនសមស្រប ឬមិនអាចនឹងកើតមាន នោះបំណុលមិនត្រូវបានទទួលស្គាល់ឡើយ។

លំហូរចូលនៃអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចដែលអាចហូរចូលទៅក្នុងក្រុមហ៊ុន ដែលមិនគ្រប់លក្ខខណ្ឌក្នុងការទទួលស្គាល់ទ្រព្យសកម្មត្រូវបានចាត់ទុកជាទ្រព្យសកម្មយថាហេតុ។

### ៤.៧. ការកាត់កង

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានកាត់កង ហើយសមតុល្យសុទ្ធបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនៅពេល និងនៅពេលដែលក្រុមហ៊ុនមានសិទ្ធិក្នុងការអនុវត្តតាមផ្លូវច្បាប់ ដើម្បីធ្វើការកាត់កង និងមានបំណងក្នុងការទូទាត់លើមូលដ្ឋានសុទ្ធ ឬដើម្បីទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។ ចំណូល និងចំណាយ ត្រូវបានបង្ហាញតាមមូលដ្ឋានសុទ្ធ លុះត្រាតែត្រូវបានអនុញ្ញាតក្រោមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ឬសម្រាប់ចំណេញ និងខាតដែលកើតឡើងពីប្រតិបត្តិការស្រដៀងគ្នា។

### ៤.៨. ទ្រព្យសម្បត្តិ និងបរិក្ខារ

សមាសធាតុរបស់ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកំណត់តាមថ្លៃដើមដកចេញរំលស់បង្គរ និងឱនភាពតម្លៃបង្គរប្រសិនបើមាន។ នៅពេលសមាសធាតុរបស់ទ្រព្យសម្បត្តិ និងបរិក្ខារ រួមមានធាតុផ្សំសំខាន់ៗ ដែលមានអាយុកាលប្រើប្រាស់ខុសៗគ្នា ធាតុផ្សំទាំងនោះ ត្រូវបានកត់ត្រាជាសមាសធាតុរបស់គណនីទ្រព្យសម្បត្តិ និងបរិក្ខារដាច់ដោយឡែកពីគ្នា។

ថ្លៃដើមនៃសមាសធាតុទ្រព្យសម្បត្តិ និងបរិក្ខារ រួមមានតម្លៃទិញចូល និងរាល់ថ្លៃដើមដែលពាក់ព័ន្ធដោយផ្ទាល់ទាំងអស់ក្នុងការនាំយកទ្រព្យសកម្មទៅកាន់លក្ខខណ្ឌការងារ និងទីតាំងតាមការកំណត់ដែលបានគ្រោងទុក។

ចំណាយបន្តបន្ទាប់ ត្រូវបានរួមបញ្ចូលនៅក្នុងសមតុល្យយោងរបស់ទ្រព្យសកម្ម ឬបានទទួលស្គាល់ជាទ្រព្យសកម្មដាច់ដោយឡែក នៅពេលចំណាយត្រូវបានកើតឡើង ហើយវាទំនងបានផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតទាក់ទងនឹងទ្រព្យសកម្មដែលនឹងមានលំហូរទៅក្រុមហ៊ុន និងថ្លៃដើមទ្រព្យសកម្ម ត្រូវបានអាចធ្វើការវាស់វែងដោយជឿទុកចិត្តបាន។ សមតុល្យយោងនៃផ្នែកណាមួយដែលត្រូវបានជំនួស ត្រូវបានឈប់ទទួលស្គាល់។ ចំណាយលើសេវាកម្មប្រចាំថ្ងៃនៃទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានទទួលស្គាល់ក្នុងគណនីចំណេញ ឬខាត ដែលបានកើតឡើង។ ថ្លៃដើម ក៏រួមមានការប៉ាន់ស្មានដំបូងនៃការរុះរើ និងដកហូតទ្រព្យសកម្ម និងការរៀបចំទីតាំងឡើងវិញទៅតាមទីតាំងដែលក្រុមហ៊ុនត្រូវមានកាតព្វកិច្ចទទួល នៅពេលដែលទ្រព្យសកម្មត្រូវបានទទួល ប្រសិនបើអាចអនុវត្តបាន។

រំលស់ត្រូវបានគណនា ដើម្បីលុបចោលនូវថ្លៃដើមនៃសមាសធាតុរបស់ទ្រព្យសម្បត្តិ និងបរិក្ខារ ដែលមានតម្លៃសំណល់ តាមវិធីសាស្ត្រថេរ លើអាយុកាលប្រើប្រាស់ដែលបានប៉ាន់ស្មានទុក មានដូចខាងក្រោមៈ

| | អាយុកាលប្រើប្រាស់ដែលបានប៉ាន់ស្មានទុក |
|---|---|
| ម៉ាស៊ីន | ២ឆ្នាំ ទៅ ៥ឆ្នាំ |
| យានយន្ត | ៣ឆ្នាំ ទៅ ៥ឆ្នាំ |
| បរិក្ខារការិយាល័យ | ២ឆ្នាំ ទៅ ៤ឆ្នាំ |
| គ្រឿងសង្ហារឹម | ២ឆ្នាំ ទៅ ៣ឆ្នាំ |
| ការកែលម្អដី | ២ឆ្នាំ ទៅ ៣ឆ្នាំ |
| សិទ្ធប្រើប្រាស់លើទ្រព្យសកម្ម | ១០ឆ្នាំ |

ពុំមានអាយុកាលប្រើប្រាស់ដីអាចត្រូវបានកំណត់ទេ ហើយសមតុល្យយោងដែលបានពាក់ព័ន្ធមិនត្រូវបានរំលស់ឡើយ។

នាចុងការិយបរិច្ឆេទនៃរបាយការណ៍ សមតុល្យយោងនៃសមាសធាតុរបស់ទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានវាយតម្លៃលើឱនភាពតម្លៃ នៅពេលដែលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈ បង្ហាញថាសមតុល្យយោងរបស់វាប្រហែលមិនអាចប្រមូលមកវិញបានទេ។ ការបន្ថយតម្លៃ ត្រូវបានធ្វើឡើងប្រសិនបើសមតុល្យយោងលើសពីសមតុល្យដែលអាចប្រមូលមកវិញបាន។

ទ្រព្យសកម្មដែលកំពុងសាងសង់ត្រូវបានកំណត់តាមថ្លៃដើម។ ថ្លៃដើមនេះ រាប់បញ្ចូលទាំងថ្លៃដើមនៃការសាងសង់ទ្រព្យសម្បត្តិ និងបរិក្ខារ ការចំណាយលើប្រាក់កម្ចីដោយផ្ទាល់ដែលត្រូវបានបែងចែកលើទ្រព្យសកម្មនោះក្នុងអំឡុងពេលសាងសង់ និងការចំណាយផ្សេងទៀតដោយផ្ទាល់។ ទ្រព្យសកម្មដែលកំពុងសាងសង់មិនត្រូវបានរំលស់ទេ រហូតដល់ពេលដែលទ្រព្យសកម្មដែលពាក់ព័ន្ធត្រូវបានបញ្ចប់ និងរួចរាល់សម្រាប់ការប្រើប្រាស់ប្រតិបត្តិការ។

ចំណេញ ឬខាត កើតឡើងពីការដល់អាយុកាលប្រើប្រាស់ ឬការលក់ចេញនូវសមាសធាតុរបស់ទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានកំណត់ថាជាភាពខុសគ្នារវាងសាច់ប្រាក់លក់ចេញសុទ្ធ និងសមតុល្យយោងនៃទ្រព្យសកម្ម ហើយត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលនាកាលបរិច្ឆេទដែលដល់អាយុកាលផុតកំណត់ ឬលក់ចេញទ្រព្យទាំងនោះ។

ទ្រព្យសម្បត្តិ និងបរិក្ខារបានរំលស់ពេញលេញ ត្រូវបានរក្សាទុកក្នុងរបាយការណ៍ហិរញ្ញវត្ថុរហូតដល់ពេលវាត្រូវបានលក់ចេញ ឬលុបចោល។

តម្លៃសំណល់ អាយុកាលប្រើប្រាស់ និងវិធីសាស្ត្ររំលស់ ត្រូវបានត្រួតពិនិត្យឡើងវិញនាចុងការិយបរិច្ឆេទនៃរបាយការណ៍នីមួយៗ ដើម្បីធានាថាសមតុល្យ វិធីសាស្ត្រ និងរយៈពេលរំលស់គឺស្របជាមួយការប៉ាន់ស្មានកន្លងមក និងគំរូដែលបានរំពឹងទុកក្នុងការប្រើប្រាស់អត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនាពេលអនាគតដែលបានបញ្ចូលទៅក្នុងសមាសធាតុរបស់ទ្រព្យសម្បត្តិ និងបរិក្ខារ។ ប្រសិនបើការរំពឹងទុកខុសគ្នាពីការប៉ាន់ស្មានកន្លងមកនោះ ការផ្លាស់ប្តូរត្រូវបានកត់ត្រាជាការផ្លាស់ប្តូរនៅក្នុងគណនេយ្យប៉ាន់ស្មាន។

សមតុល្យយោងរបស់សមាសធាតុរបស់ទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានឈប់ទទួលស្គាល់លើការលក់ចេញ ឬនៅពេលមិនមានអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនាពេលអនាគត ដែលត្រូវបានរំពឹងទុកពីការប្រើប្រាស់ និងការលក់ចេញរបស់វា។ ភាពខុសគ្នារវាងចំណូលពីការលក់ចេញសុទ្ធ និងសមតុល្យយោង ប្រសិនបើមាន ហើយសមតុល្យយោងត្រូវបានកត់ត្រាក្នុងគណនីចំណេញ ឬខាត។

### ៤.៩. ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី តំណាងឱ្យកម្មវិធីកុំព្យូទ័រដែលត្រូវបានកំណត់តាមថ្លៃដើមដករំលស់បង្គរ និងឱនភាពតម្លៃ។ ថ្លៃដើមប្រវត្តិសាស្ត្រ រួមបញ្ចូលការចំណាយដែលពាក់ព័ន្ធដោយផ្ទាល់ក្នុងការនាំយកកម្មវិធីកុំព្យូទ័រដែលមានបំណងក្នុងការប្រើប្រាស់។ កម្មវិធីកុំព្យូទ័រមិនត្រូវបានរំលសើ មុនពេលដែលបានរៀបចំរួចរាល់សម្រាប់ការប្រើប្រាស់។

### ៤.១០. ការធ្វើតេស្តឱនភាពតម្លៃនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ដើម្បីធ្វើការវាយតម្លៃឱនភាព ទ្រព្យសកម្មត្រូវបានចាត់ជាក្រុមក្នុងកម្រិតទាបបំផុត ដែលមានលំហូរសាច់ប្រាក់ឯករាជ្យមួយផ្នែកធំ (ឯកតាបង្កើតសាច់ប្រាក់)។ ជាលទ្ធផលទ្រព្យសកម្មមួយចំនួនត្រូវបានធ្វើតេស្តឱនភាពដាច់ដោយឡែក និងមួយចំនួនទៀតបានធ្វើតេស្តជាកម្រិតឯកតាបង្កើតសាច់ប្រាក់។ ឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់សម្រាប់សមតុល្យដែលទ្រព្យសកម្ម ឬ ឯកតាបង្កើតសាច់ប្រាក់របស់សមតុល្យយោងលើសពីសមតុល្យដែលអាចប្រមូលមកវិញបាន ដែលតម្លៃខ្ពស់ណាមួយនៃតម្លៃសមស្របតិចជាងថ្លៃដើមក្នុងការលក់ និងតម្លៃប្រើប្រាស់។

ដើម្បីកំណត់តម្លៃប្រើប្រាស់ គណៈគ្រប់គ្រងប៉ាន់ស្មានលំហូរសាច់ប្រាក់នាពេលអនាគតដែលបានរំពឹងទុកពីឯកតាបង្កើតសាច់ប្រាក់នីមួយៗ និងកំណត់អត្រាការប្រាក់ដែលសមរម្យ ដើម្បីគណនាតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ទាំងនោះ។ ទិន្នន័យដែលបានប្រើសម្រាប់នីតិវិធីក្នុងការធ្វើតេស្តភាពឱនភាពត្រូវបានភ្ជាប់ដោយផ្ទាល់ទៅនឹងថវិកាដែលបានអនុម័តចុងក្រោយបំផុតរបស់ក្រុមហ៊ុន ដោយបានកែតម្រូវតាមភាពចាំបាច់ ដែលមិនរាប់បញ្ចូលផលប៉ះពាល់នៃការរៀបចំឡើងវិញនាពេលអនាគត និងការពង្រឹងទ្រព្យសកម្ម។ កត្តាអប្បហារ ត្រូវបានកំណត់ជាឯកតាបង្កើតសាច់ប្រាក់ដាច់ដោយឡែកនីមួយៗ និងឆ្លុះបញ្ចាំងពីទម្រង់ហានិភ័យតាមការវាយតម្លៃដោយគណៈគ្រប់គ្រង។

### ៤.១១. ភតិសន្យា

#### ក្រុមហ៊ុនក្នុងនាមជាភតិកៈ

ភតិសន្យាត្រូវបានកំណត់ជា "កិច្ចសន្យា ឬជាផ្នែកនៃកិច្ចសន្យា" ដែលបង្ហាញពីសិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម (មូលដ្ឋានទ្រព្យសកម្ម) ក្នុងអំឡុងពេលនៃការផ្លាស់ប្តូរនៃតម្លៃតបស្នង។

ដើម្បីអនុវត្តនិយមន័យនេះ ក្រុមហ៊ុនត្រូវធ្វើការវាយតម្លៃថាតើកិច្ចសន្យាឆ្លើយតបនឹងការវាយតម្លៃសំខាន់ៗទាំងបី ថាតើ៖

១). កិច្ចសន្យាដែលរួមមានទ្រព្យសកម្មជាក់លាក់ ដែលបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងកិច្ចសន្យា ឬបញ្ជាក់ដោយប្រយោលដែលបានកំណត់ចាប់ពីពេលដែលទ្រព្យសកម្មនោះបានរៀបចំរួចសម្រាប់ក្រុមហ៊ុនអាចប្រើប្រាស់បាន។
២). ក្រុមហ៊ុនមានសិទ្ធិទទួលបានអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចទាំងស្រុងពីការប្រើប្រាស់ទ្រព្យសកម្មដែលបានកំណត់ ក្នុងអំឡុងការិយបរិច្ឆេទនៃការប្រើប្រាស់ ដោយពិចារណាលើសិទ្ធិរបស់ខ្លួនក្នុងវិសាលភាពដែលបានកំណត់ក្នុងកិច្ចសន្យា។
៣). ក្រុមហ៊ុនមានសិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម ដែលបានកំណត់នៅក្នុងអំឡុងការិយបរិច្ឆេទនៃការប្រើប្រាស់។ ក្រុមហ៊ុនវាយតម្លៃថាតើក្រុមហ៊ុនមានសិទ្ធិ "របៀបណា និងសម្រាប់គោលបំណងអ្វី" ដែលទ្រព្យសកម្មត្រូវបានប្រើប្រាស់ក្នុងអំឡុងការិយបរិច្ឆេទនៃការប្រើប្រាស់។

#### ការវាស់វែង និងការទទួលស្គាល់នៃភតិសន្យាក្នុងនាមជាភតិកៈ

នាកាលបរិច្ឆេទចាប់ផ្តើមនៃភតិសន្យា ក្រុមហ៊ុនកត់ត្រាសិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម និងបំណុលភតិសន្យានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ សិទ្ធិប្រើប្រាស់លើទ្រព្យសកម្មត្រូវបានវាស់វែងតាមថ្លៃដើម ដែលត្រូវបានបង្កើតឡើងតាមរយៈការវាស់វែងដំបូងលើបំណុលភតិសន្យា ចំណាយផ្ទាល់ណាមួយដែលបានធ្វើឡើងដោយក្រុមហ៊ុន ការប៉ាន់ស្មានលើចំណាយណាមួយក្នុងការរុះរើ និងការដកហូតទ្រព្យសកម្មនាចុងកាលបរិច្ឆេទនៃភតិសន្យា ហើយរាល់ការទូទាត់លើភតិសន្យាបានធ្វើឡើងជាមុននាកាលបរិច្ឆេទចាប់ផ្តើមនៃភតិសន្យា (ដកចេញនូវរាល់អត្ថប្រយោជន៍ដែលទទួលបាន)។

ក្រុមហ៊ុនធ្វើការរំលស់លើសិទ្ធិប្រើប្រាស់លើទ្រព្យសកម្មតាមមូលដ្ឋានថេរ គិតចាប់ពីកាលបរិច្ឆេទចាប់ផ្តើមនៃភតិសន្យារហូតដល់មុនអាយុកាលប្រើប្រាស់ចុងក្រោយនៃសិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម ឬចុងកាលបរិច្ឆេទនៃភតិសន្យានោះ។ ក្រុមហ៊ុនក៏បានវាយតម្លៃសិទ្ធិប្រើប្រាស់លើទ្រព្យសកម្មសម្រាប់ឱនភាពនៃតម្លៃនៅពេលដែលមានសូចនាករណាមួយបានកើតឡើង។

នាកាលបរិច្ឆេទចាប់ផ្តើម ក្រុមហ៊ុនវាស់វែងបំណុលភតិសន្យាតាមតម្លៃបច្ចុប្បន្ននៃការទូទាត់ភតិសន្យាដែលមិនទាន់បានទូទាត់នាកាលបរិច្ឆេទនោះ ហើយធ្វើអប្បហារដោយប្រើប្រាស់អត្រាការប្រាក់ដែលបញ្ជាក់ក្នុងភតិសន្យា ប្រសិនបើអត្រានោះអាចយកមកប្រើប្រាស់បាន ឬការកើនឡើងអត្រាប្រាក់កម្ចីរបស់ក្រុមហ៊ុន។

ការទូទាត់ភតិសន្យាបានរួមបញ្ចូលទៅក្នុងការវាស់វែងបំណុលភតិសន្យា ដែលត្រូវបានធ្វើឡើងតាមការទូទាត់ថេរ (រាប់បញ្ចូលទាំងការទូទាត់ថេរ) ការទូទាត់អថេរផ្អែកលើសន្ទស្សន៍ ឬអត្រាការប្រាក់ សមតុល្យដែលបានរំពឹងថានឹងត្រូវធ្វើការទូទាត់ក្រោមការធានាតម្លៃសំណល់ និងការទូទាត់ដែលកើតឡើងពីជម្រើសជាក់លាក់ដ៏សមស្របដើម្បីធ្វើការអនុវត្ត។

បន្ទាប់ពីការវាស់វែងដំបូង បំណុលភតិសន្យានឹងត្រូវបានកាត់បន្ថយសម្រាប់ធ្វើការទូទាត់ និងបង្កើនការប្រាក់។ វាត្រូវបានវាស់វែងឡើងវិញដើម្បីឆ្លុះបញ្ចាំងពីការវាយតម្លៃឡើងវិញ ឬការកែតម្រូវ ឬប្រសិនបើមានការផ្លាស់ប្តូរលើការទូទាត់ថេរ។

នៅពេលដែលបំណុលភតិសន្យាត្រូវបានវាស់វែងឡើងវិញ ការកែតម្រូវមួយចំនួនដែលត្រូវបានឆ្លុះបញ្ចាំងពីសិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម ឬគណនីចំណេញ និងខាត ប្រសិនបើសិទ្ធិប្រើប្រាស់លើទ្រព្យសកម្មត្រូវបានថយចុះរហូតដល់សូន្យ។

ក្រុមហ៊ុនបានជ្រើសរើសយកគណនីភតិសន្យារយៈពេលខ្លី និងភតិសន្យារបស់ទ្រព្យសកម្មតម្លៃទាប ដោយប្រើប្រាស់ការអនុវត្តជាក់ស្តែង។ ជំនួសឱ្យការទទួលស្គាល់សិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម និងបំណុលភតិសន្យា ការទូទាត់ដែលទាក់ទងទៅនិងការទទួលស្គាល់ជាចំណាយនៅក្នុងរបាយការណ៍ចំណូលលម្អិតតាមមូលដ្ឋានថេរលើលក្ខខណ្ឌនៃភតិសន្យានោះ។

## ៤.១២. ការទទួលស្គាល់ចំណូល

ចំណូលត្រូវបានទទួលស្គាល់នៅពេលដែល ឬជាកាតព្វកិច្ចអនុវត្តនៅក្នុងកិច្ចសន្យាជាមួយអតិថិជនត្រូវបានបំពេញដោយពេញលេញ ជាឧទាហរណ៍ នៅពេលដែល "ការគ្រប់គ្រង" នៃទំនិញ ឬសេវាកម្មដែលស្ថិតនៅក្រោមមូលដ្ឋានកាតព្វកិច្ចអនុវត្តជាក់លាក់ ត្រូវបានផ្ទេរទៅឱ្យអតិថិជន។

កាតព្វកិច្ចអនុវត្ត គឺជាការសន្យានៃការផ្ទេរទំនិញ ឬសេវាកម្មដាច់ដោយឡែកមួយ (ឬបណ្តុំនៃទំនិញ ឬសេវាកម្មផ្សេងៗគ្នា ដែលមានលក្ខណៈដូចគ្នាយ៉ាងខ្លាំង និងមានលំនាំនៃការផ្ទេរដូចគ្នា) ទៅកាន់អតិថិជន ដែលបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងកិច្ចសន្យា និងបញ្ជាក់អត្ថន័យទៅតាមការអនុវត្តច្បាប់ទម្លាប់អាជីវកម្មរបស់ក្រុមហ៊ុន។

ដើម្បីកំណត់ថាតើត្រូវទទួលស្គាល់ចំណូល ក្រុមហ៊ុនអនុវត្តតាមនីតិវិធី ៥ ជំហានដូចខាងក្រោម៖

- ក. កំណត់អត្តសញ្ញាណកិច្ចសន្យាជាមួយអតិថិជន
- ខ. កំណត់អត្តសញ្ញាណកាតព្វកិច្ចអនុវត្តដាច់ដោយឡែកក្នុងកិច្ចសន្យា
- គ. កំណត់តម្លៃនៃប្រតិបត្តិការ
- ឃ. ការបែងចែកតម្លៃនៃប្រតិបត្តិការទៅតាមកាតព្វកិច្ចអនុវត្ត
- ង. ការទទួលស្គាល់ចំណូលនៅពេល /ជាកាតព្វកិច្ចអនុវត្តត្រូវបានបំពេញដោយពេញលេញ

ចំណូលត្រូវបានវាស់វែងតាមសមតុល្យនៃតម្លៃតបស្នង ដែលក្រុមហ៊ុនរំពឹងថានឹងទទួលបានក្នុងការដោះដូរការផ្ទេរទំនិញ ឬសេវាកម្មដែលបានសន្យាជូនអតិថិជន ដោយមិនរាប់បញ្ចូលសមតុល្យដែលបានប្រមូលមកវិញជំនួសឱ្យតតិយជន ដូចជាពន្ធលើការលក់ ឬពន្ធលើទំនិញ និងសេវាកម្ម។ ប្រសិនបើសមតុល្យនៃតម្លៃតបស្នង ប្រែប្រួលដោយសារតែការធ្វើអប្បហារ ការបង្វិលសងមកវិញ ការបង្វិលសង ឥណទាន ការលើកទឹកចិត្ត ការពិន័យ ឬសមាសធាតុស្រដៀងគ្នាផ្សេងទៀត ក្រុមហ៊ុនប៉ាន់ស្មានសមតុល្យនៃតម្លៃតបស្នងដែលវានឹងមានសិទ្ធិទទួលបានដោយផ្អែកលើតម្លៃដែលរំពឹងទុក ឬលទ្ធផលដែលសមរម្យបំផុត។ ប្រសិនបើកិច្ចសន្យាជាមួយអតិថិជនមានកាតព្វកិច្ចអនុវត្តច្រើនជាងមួយ សមតុល្យនៃតម្លៃតបស្នងត្រូវបានបែងចែកតាមកាតព្វកិច្ចអនុវត្តនីមួយៗដោយផ្អែកលើតម្លៃលក់ដាច់ដោយឡែកដែលទាក់ទងទៅនឹងទំនិញ ឬសេវាកម្មដែលបានសន្យាក្នុងកិច្ចសន្យា។

ការគ្រប់គ្រងលើទំនិញ ឬសេវាកម្មដែលបានសន្យា ដែលអាចត្រូវបានផ្ទេរក្នុងរយៈពេលលើសពេលវេលាកំណត់ ឬតាមពេលវេលាជាក់លាក់មួយ។ ការគ្រប់គ្រងលើទំនិញ ឬសេវាកម្មត្រូវបានផ្ទេរលើសពេលវេលាកំណត់ ហើយចំណូលត្រូវបានទទួលស្គាល់ក្នុងរយៈពេលលើសពេលវេលាកំណត់ប្រសិនបើ៖

- អតិថិជនទទួលបាន និងប្រើប្រាស់អត្ថប្រយោជន៍បានផ្តល់ដោយការអនុវត្តរបស់ក្រុមហ៊ុនក្នុងពេលដំណាលគ្នា នៅពេលដែលក្រុមហ៊ុនអនុវត្តប្រត្តិបតិការនោះ។
- ការអនុវត្តរបស់ក្រុមហ៊ុនក្នុងការបង្កើត ឬពង្រឹងទ្រព្យសកម្មដែលអតិថិជនគ្រប់គ្រង ជាទ្រព្យសកម្មត្រូវបានបង្កើត ឬពង្រឹងឬ
- ការអនុវត្តរបស់ក្រុមហ៊ុនមិនបានបង្កើតទ្រព្យសកម្មជាមួយនឹងការប្រើប្រាស់ជំនួសទេ ហើយក្រុមហ៊ុនមានសិទ្ធិអាចអនុវត្តបានក្នុងការទូទាត់សម្រាប់ការអនុវត្តដែលបានបញ្ចប់រហូតដល់កាលបរិច្ឆេទនោះ។

ចំណូលសម្រាប់កាតព្វកិច្ចអនុវត្ត ដែលមិនទាន់បញ្ចប់ដោយពេញលេញលើសពេលវេលាកំណត់ ត្រូវបានទទួលស្គាល់តាមពេលវេលាជាក់លាក់មួយនៅពេលដែលអតិថិជនទទួលបានការគ្រប់គ្រងលើទំនិញ ឬសេវាកម្មដែលបានសន្យា។

ក្រុមហ៊ុនទទួលស្គាល់ចំណូលពីសេវាកម្មសាងសង់លើសពេលវេលាកំណត់ ប្រសិនបើសេវាកម្មនេះបង្កើតទ្រព្យសកម្មដែលគ្មានការប្រើប្រាស់ជំនួសក្រុមហ៊ុន ហើយក្រុមហ៊ុនមានសិទ្ធិទទួលបានការទូទាត់ទៅលើការអនុវត្តប្រត្តិបតិការបានបញ្ចប់រហូតដល់កាលបរិច្ឆេទនោះ។ ចំណូលត្រូវបានទទួលស្គាល់ក្នុងការិយបរិច្ឆេទនៃកិច្ចសន្យា ដោយយោងទៅលើវឌ្ឍនភាពឆ្ពោះទៅរកការបញ្ចប់ដោយពេញលេញលើកាតព្វកិច្ចអនុវត្ត។

វឌ្ឍនភាពឆ្ពោះទៅរកការបញ្ចប់ដោយពេញលេញលើកាតព្វកិច្ចអនុវត្ត ត្រូវបានវាស់វែងដោយផ្អែកលើកិច្ចខិតខំប្រឹងប្រែង ឬធាតុចូលរបស់ក្រុមហ៊ុនចំពោះការបញ្ចប់ដោយពេញលេញលើកាតព្វកិច្ចអនុវត្ត (ឧទាហរណ៍ ដោយយោងទៅលើការចំណាយលើការអភិវឌ្ឍទ្រព្យសម្បត្តិដែលកើតឡើងរហូតមកដល់បច្ចុប្បន្នជាភាគរយនៃការចំណាយសរុបដែលបានប៉ាន់ស្មានលើការអភិវឌ្ឍនៃកិច្ចសន្យា)។

នៅពេលដែលចំណូលបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិត លើសពីវិក័យប័ត្រដែលចេញជូនអ្នកទិញ សមតុល្យត្រូវបានបង្ហាញជាទ្រព្យសកម្មកិច្ចសន្យា។ នៅពេលដែលវិក័យប័ត្រដែលចេញជូនអ្នកទិញ លើសពីចំណូលបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិត ហើយសមតុល្យត្រូវបានបង្ហាញជាបំណុលកិច្ចសន្យា។

ចំណូលពីការលក់ទំនិញ ត្រូវបានទទួលស្គាល់នៅពេលដែលទំនិញត្រូវបានប្រគល់ជូនអ្នកទិញរួចរាល់ ហើយសិទ្ធិនៃការគ្រប់គ្រងទ្រព្យសម្បត្តិក៏ត្រូវបានផ្ទេរទៅឱ្យអ្នកទិញ ។

### ចំណូលផ្សេងៗ

ចំណូលផ្សេងៗ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិតនាការិយបរិច្ឆេទដែលទទួលបាន។

## ៤.១៣. ការទទួលស្គាល់ចំណាយ

ចំណាយត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណូលលម្អិត នៅពេលដែលមានការថយចុះនៃអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនាពេលអនាគតដែលទាក់ទងនឹងការថយចុះទ្រព្យសកម្ម ឬការកើនឡើងនៃបំណុលដែលបានកើតឡើងអាចត្រូវបានវាស់វែងយ៉ាងត្រឹមត្រូវ។ ចំណាយ ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណូលលម្អិត៖

ក. នៅលើមូលដ្ឋានដែលទាក់ទងគ្នាដោយផ្ទាល់រវាងចំណាយដែលបានកើតឡើង និងចំណេញពីចំណូលលើសមាសធាតុជាក់លាក់នានា

ខ. នៅលើមូលដ្ឋាននីតិវិធីនៃការបែងចែកជាប្រព័ន្ធ និងភាពសមស្រប នៅពេលដែលអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចត្រូវបានរំពឹងទុកថានឹងកើតមានឡើងក្នុងការិយបរិច្ឆេទនៃគណនេយ្យមួយចំនួន និងទាក់ទងជាមួយចំណូលដែលអាចកំណត់បានយ៉ាងទូលំទូលាយ ឬកំណត់បានដោយប្រយោល

គ. ឬភ្លាមៗនៅពេលដែលការចំណាយមិនទទួលបានអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនាពេលអនាគត ឬនៅពេល និងក្នុងវិសាលភាពដែលអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនាពេលអនាគតមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ឬលែងមានលក្ខណៈគ្រប់គ្រាន់ជាទ្រព្យសកម្មសម្រាប់ការទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

ចំណាយនៅក្នុងរបាយការណ៍ចំណូលលម្អិត ត្រូវបានបង្ហាញដោយប្រើប្រាស់វិធីសាស្ត្រចំណាយមុខងារ។ ថ្លៃដើមសេវាកម្ម និងទំនិញបានលក់ តំណាងឲ្យចំណាយកម្លាំងពលកម្មដោយផ្ទាល់ សន្និធិ និងចំណាយលើសផ្សេងៗទៀតដែលទាក់ទងដោយផ្ទាល់ក្នុងការស្វែងរកប្រាក់ចំណូល។ ចំណាយប្រតិបត្តិការ គឺជាចំណាយដែលទាក់ទងនឹងចំណាយទូទៅ ចំណាយរដ្ឋបាល និងចំណាយលើសកម្មភាពអាជីវកម្មផ្សេងៗទៀតរបស់ក្រុមហ៊ុន។

## ៤.១៤. ពន្ធលើប្រាក់ចំណូល

ចំណាយពន្ធបានទទួលស្គាល់នៅក្នុងគណនីចំណេញ ឬខាត រួមមានផលបូកនៃពន្ធពន្យារ ហើយពន្ធបច្ចុប្បន្នមិនបានទទួលស្គាល់ក្នុងគណនីចំណូលលម្អិតផ្សេងៗ ឬទទួលស្គាល់ដោយផ្ទាល់ក្នុងគណនីមូលធនទេ។

ទ្រព្យសកម្មពន្ធលើប្រាក់ចំណូល និង/ឬបំណុលបច្ចុប្បន្ន រួមមានកាតព្វកិច្ច ឬការទាមទារពីអាជ្ញាធរសារពើពន្ធដែលទាក់ទងនឹងការិយបរិច្ឆេទនៃរបាយការណ៍បច្ចុប្បន្ន ឬពីពេលកន្លងមក ដែលមិនបានទូទាត់នាកាលបរិច្ឆេទនៃរបាយការណ៍នោះ។ ពន្ធបច្ចុប្បន្ន គឺជាបំណុលលើប្រាក់ចំណេញជាប់ពន្ធ ដែលខុសពីប្រាក់ចំណេញ ឬខាតក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ពន្ធពន្យារលើប្រាក់ចំណូល ត្រូវបានគណនាដោយប្រើប្រាស់វិធីសាស្ត្របំណុលលើភាពខុសគ្នាជាបណ្តោះអាសន្នរវាងសមតុល្យយោងរបស់ទ្រព្យសកម្ម និងបំណុល ព្រមទាំងមូលដ្ឋានពន្ធរបស់វា ដែលត្រូវបានរំពឹងថានឹងមានការកើនឡើង ឬថយចុះនៃប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត និងការខាតបង់ពន្ធដែលមិនបានប្រើប្រាស់ និងឥណទានពន្ធដែលមិនបានប្រើប្រាស់។

ទ្រព្យសកម្ម និងបំណុលពន្ធពន្យារ ត្រូវបានគណនាដោយមិនគិតអប្បហារ តាមអត្រាពន្ធដែលរំពឹងថានឹងអនុវត្តទៅតាមរយៈពេលការទទួលស្គាល់របស់ពួកគេ ដោយសារអត្រាពន្ធទាំងនោះត្រូវបានអនុម័ត ឬអនុម័តនាចុងការិយបរិច្ឆេទនៃរបាយការណ៍ ដោយធ្វើការពិចារណាដល់លទ្ធភាពដែលអាចកើតមានទាំងអស់នៃការពិនិត្យឡើងវិញដោយអាជ្ញាធរពន្ធដារ។

ទ្រព្យសកម្មពន្ធពន្យារ ត្រូវបានទទួលស្គាល់ដើម្បីពង្រីកវិសាលភាពដែលប្រហែលជាមានការខាតបង់ពន្ធ ឬភាពខុសគ្នាបណ្តោះអាសន្នដែលអាចកាត់កងបាន នឹងអាចប្រើប្រាស់បានធៀបនឹងប្រាក់ចំណូលជាប់ពន្ធនាពេលអនាគត។ ការវាយតម្លៃនេះ គឺផ្អែកលើការព្យាករណ៍របស់ក្រុមហ៊ុនទៅលើលទ្ធផលប្រតិបត្តិការនាពេលអនាគត ដែលបានកែតម្រូវលើប្រាក់ចំណូល និងចំណាយដែលមិនជាប់ពន្ធសំខាន់ៗ និងការកំណត់ជាក់លាក់លើការប្រើប្រាស់ខាតពន្ធ ឬឥណទានពន្ធដែលមិនបានប្រើប្រាស់។ បំណុលពន្ធពន្យារ តែងតែត្រូវបានទទួលស្គាល់ទាំងអស់។

ទ្រព្យសកម្ម និងបំណុលពន្ធពន្យារ អាចកាត់កងបានតែនៅពេលក្រុមហ៊ុនមានសិទ្ធិ និងគោលបំណងក្នុងការទូទាត់ពន្ធបច្ចុប្បន្នលើទ្រព្យសកម្ម និងបំណុលពីអាជ្ញាធរពន្ធដារតែមួយ។

សមតុល្យយោងនៃទ្រព្យសកម្មពន្ធពន្យារ ត្រូវបានត្រួតពិនិត្យឡើងវិញនាកាលបរិច្ឆេទនៃរបាយការណ៍នីមួយៗ និងត្រូវបានកែតម្រូវជាចាំបាច់ដើម្បីឆ្លុះបញ្ចាំងពីការវាយតម្លៃបច្ចុប្បន្ននៃប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត។

ការផ្លាស់ប្តូរទ្រព្យសកម្មពន្ធពន្យារ ឬបំណុលពន្ធពន្យារត្រូវបានទទួលស្គាល់ជាផ្នែកនៃពន្ធលើប្រាក់ចំណូល ឬចំណាយនៅក្នុងគណនីចំណេញ ឬខាត លើកលែងតែនៅពេលដែលពន្ធទាំងនោះ មានការទាក់ទងនឹងសមាធាតុដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិតផ្សេងៗ (ដូចជាការវាយតម្លៃដី) ឬដោយផ្ទាល់នៅក្នុងគណនីមូលធន ក្នុងករណីណាមួយទាក់ទងនឹងពន្ធពន្យារ ក៏ត្រូវទទួលស្គាល់នៅក្នុងគណនីចំណូលលម្អិតផ្សេងៗ ឬគណនីមូលធន។

### ៤.១៥. ភាគីពាក់ព័ន្ធ

ភាគីពាក់ព័ន្ធ គឺជាបុគ្គល ឬអង្គភាពដែលមានទំនាក់ទំនងជាមួយក្រុមហ៊ុន។ ប្រតិបត្តិការរបស់ភាគីពាក់ព័ន្ធ គឺជាការផ្ទេរធនធាន សេវាកម្ម ឬកាតព្វកិច្ចរវាងក្រុមហ៊ុន និងភាគីពាក់ព័ន្ធរបស់ខ្លួនទោះបីជាបានគិតថ្លៃ ឬមិនបានគិតថ្លៃ។ បន្ថែមពីនេះទៀត៖

(១). បុគ្គល ឬមនុស្សដែលជិតស្និទ្ធ ជាមួយបុគ្គលនៃគ្រួសារនោះ គឺមានការពាក់ព័ន្ធជាមួយក្រុមហ៊ុន ប្រសិនបើបុគ្គលនោះ៖
- ក មានសិទ្ធិគ្រប់គ្រង ឬចូលរួមក្នុងការគ្រប់គ្រងលើក្រុមហ៊ុន
- ខ មានឥទ្ធិពលខ្លាំងលើក្រុមហ៊ុន ឬ
- គ គឺជាសមាជិកនៃគណៈគ្រប់គ្រងសំខាន់ៗរបស់ក្រុមហ៊ុន។

(២). អង្គភាពដែលចាត់ចូលជាភាគីពាក់ព័ន្ធរបស់ក្រុមហ៊ុន ប្រសិនបើស្ថិតក្នុងលក្ខខណ្ឌដូចខាងក្រោម៖
- ក ក្រុមហ៊ុន គឺជាសមាជិកនៃសម្ព័ន្ធក្រុមហ៊ុនតែមួយ
- ខ អង្គភាពមួយដែលជាការចូលរួម ឬការបណ្តាក់ទុនរួមគ្នានៃអង្គភាពផ្សេងទៀត
- គ អង្គភាពទាំងពីរធ្វើការបណ្តាក់ទុនរួមលើភាគីទីបីដូចគ្នា
- ឃ អង្គភាពមួយ គឺជាភាគហ៊ុនរួមនៃអង្គភាពភាគីទីបី និងអង្គភាពផ្សេងទៀតគឺជាអង្គភាពរួមបញ្ចូលគ្នានៃភាគីទីបី
- ង អង្គភាព គឺជាគម្រោងអត្ថប្រយោជន៍ក្រោយការងារសម្រាប់អត្ថប្រយោជន៍របស់និយោជិតនៅក្នុងក្រុមហ៊ុន
- ច អង្គភាពត្រូវបានគ្រប់គ្រង ឬគ្រប់គ្រងរួមគ្នាដោយបុគ្គលដែលបានបញ្ជាក់នៅក្នុង (ក) ខាងលើ
- ឆ បុគ្គលដែលបានកំណត់អត្តសញ្ញាណនៅក្នុង (ក.១) ខាងលើមានឥទ្ធិពលគួរឱ្យកត់សម្គាល់លើអង្គភាព ឬជាសមាជិកនៃគណៈគ្រប់គ្រងសំខាន់ៗ ដែលកំពុងកាន់កាប់ក្រុមហ៊ុន ឬអង្គភាព ឬ
- ជ អង្គភាព ឬសមាជិកនៃសម្ព័ន្ធ ដែលជាផ្នែកមួយផ្តល់នូវសេវាកម្មគ្រប់គ្រងសំខាន់ៗដល់ក្រុមហ៊ុន។

## ៥. ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យគណនេយ្យសំខាន់ៗ

ក្នុងការអនុវត្តគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុន តម្រូវឱ្យគណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យ ប៉ាន់ស្មាន និងការសន្មតអំពីសមតុល្យយោងនៃទ្រព្យសកម្ម និងបំណុលដែលមិនមានការបង្ហាញពីប្រភពផ្សេងដែលច្បាស់លាស់ឡើយ។ ការប៉ាន់ស្មាន និងការសន្មតដែលពាក់ព័ន្ធគឺផ្អែកលើបទពិសោធន៍ដែលធ្លាប់មានពីមុន និងកត្តាផ្សេងទៀតដែលត្រូវបានគេចាត់ទុកថាសមស្រប។ លទ្ធផលជាក់ស្តែងអាចខុសគ្នាពីការប៉ាន់ស្មានទាំងនេះ។

ការប៉ាន់ស្មាន និងការសន្មតត្រូវបានត្រួតពិនិត្យមូលដ្ឋាននិរន្តរភាព។ ការកែសម្រួលការប៉ាន់ស្មានគណនេយ្យត្រូវបានទទួលស្គាល់ក្នុងអំឡុងពេលដែលការប៉ាន់ស្មានត្រូវបានកែសម្រួល ប្រសិនបើការកែសម្រួលនេះប៉ះពាល់តែក្នុងអំឡុងពេលនោះ ឬក៏ក្នុងអំឡុងពេលកែតម្រូវ និងអំឡុងពេលនាពេលអនាគត ប្រសិនបើការកែតម្រូវនេះប៉ះពាល់ទាំងពេលបច្ចុប្បន្ន និងពេលអនាគត។

### ក. ការប៉ាន់ស្មាន និងការសន្មតគណនេយ្យសំខាន់ៗ

ខាងក្រោមនេះ គឺជាការសន្មតសំខាន់ៗទាក់ទងនឹងអនាគត និងប្រភពសំខាន់ៗផ្សេងទៀតនៃការប៉ាន់ស្មានមិនច្បាស់លាស់នាចុងការិយបរិច្ឆេទនៃរបាយការណ៍នីមួយៗ ដែលមានហានិភ័យគួរឱ្យកត់សម្គាល់ក្នុងការបង្កឱ្យមានការកែតម្រូវជាសារវន្តទៅលើសមតុល្យយោងនៃទ្រព្យសកម្ម និងបំណុលនៅក្នុងការិយបរិច្ឆេទបន្ទាប់។

#### ចំណូលកិច្ចសន្យា

សមតុល្យនៃចំណូលកិច្ចសន្យាដែលបានទទួលស្គាល់ និងគណនីត្រូវទទួលដែលបានពាក់ព័ន្ធ ដែលឆ្លុះបញ្ចាំងពីការប៉ាន់ស្មានដ៏ល្អបំផុតរបស់គណៈគ្រប់គ្រងលើលទ្ធផល និងដំណាក់កាលនៃការបញ្ចប់កិច្ចសន្យា។ ចំណូលកិច្ចសន្យានេះ រាប់បញ្ចូលទាំងការវាយតម្លៃលើប្រាក់ចំណេញនៃកិច្ចសន្យាសាងសង់ដែលកំពុងបន្ត និងការរាំងស្ទះពីមុន។ ចំពោះកិច្ចសន្យាដែលស្មុគស្មាញជាងនេះ ជាពិសេសការចំណាយដើម្បីបញ្ចប់ និងប្រាក់ចំណេញនៃកិច្ចសន្យា គឺស្ថិតក្រោមការប៉ាន់ស្មានមិនច្បាស់លាស់ដែលគួរឱ្យកត់សម្គាល់។

### ការប៉ាន់ស្មានការខាតបង់សំវិធានធនលើការខាតបង់ឥណទានដែលបានរំពឹងទុក

ក្រុមហ៊ុនវាស់វែងលើការខាតបង់ឥណទានដែលបានរំពឹងទុកនៃឧបករណ៍ហិរញ្ញវត្ថុតាមរយៈការឆ្លុះបញ្ចាំងពីសមតុល្យដែលមានភាពមិនលម្អៀង និងប្រូបាប៊ីលីតេជាមធ្យមដែលត្រូវបានកំណត់តាមរយៈការវាយតម្លៃក្នុងកម្រិតនៃលទ្ធផលដែលអាចកើតមាន តម្លៃ និងព័ត៌មានអំពីព្រឹត្តិការណ៍កន្លងមក លក្ខខណ្ឌបច្ចុប្បន្ន និងការព្យាករណ៍ពីលក្ខខណ្ឌផ្នែកសេដ្ឋកិច្ចនាពេលអនាគត។ នៅពេលដែលធ្វើការវាស់វែង ECL ក្រុមហ៊ុនប្រើប្រាស់ព័ត៌មាននាពេលអនាគតដែលសមស្រប និងជឿជាក់បាន ដោយផ្អែកលើការសន្មតពីបម្រែបម្រួលនាពេលអនាគតនៃភាពខុសគ្នាលើកត្តាជំរុញសេដ្ឋកិច្ច ហើយដំណើរការទាំងនេះនឹងប៉ះពាល់គ្នាទៅវិញទៅមកដោយរបៀបណា។

### ការប៉ាន់ស្មានតម្លៃសន្និធិសុទ្ធដែលអាចសម្រេចបាន

តម្លៃសន្និធិសុទ្ធដែលអាចសម្រេចបាន តំណាងឱ្យតម្លៃលក់សន្និធិដែលបានប៉ាន់ស្មាន ដកចំណាយនៃការបញ្ចប់បានប៉ាន់ស្មានទាំងអស់ និងការចំណាយចាំបាច់ដើម្បីធ្វើការលក់។ ក្រុមហ៊ុនកំណត់តម្លៃលក់បានប៉ាន់ស្មាន ដោយផ្អែកលើប្រតិបត្តិការលក់បច្ចុប្បន្ននៃទំនិញស្រដៀងគ្នាជាមួយនឹងការកែតម្រូវដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរនៅក្នុងលក្ខខណ្ឌផ្នែកសេដ្ឋកិច្ចចាប់តាំងពីកាលបរិច្ឆេទដែលប្រតិបត្តិការណាមួយបានកើតឡើង។

ក្រុមហ៊ុនកត់ត្រាសំវិធានធនលើចំណាយលើសពីតម្លៃសន្និធិសុទ្ធដែលអាចសម្រេចបាន។ ខណៈពេលដែលក្រុមហ៊ុនជឿជាក់ថាការប៉ាន់ស្មានមានភាពសមហេតុផល និងសមស្រប នៅក្នុងបទពិសោធន៍ជាក់ស្តែងខុសៗគ្នាគួរឱ្យកត់សម្គាល់ ឬការផ្លាស់ប្តូរសំខាន់ៗក្នុងការប៉ាន់ស្មានដែលអាចប៉ះពាល់ជាសារវន្តដល់គណនីចំណេញ ឬខាត និងគណនីមូលធន។

### អាយុកាលប្រើប្រាស់នៃទ្រព្យសកម្មដែលបានរំលស់

អាយុកាលប្រើប្រាស់នៃទ្រព្យសកម្មរបស់ក្រុមហ៊ុន ដែលមានអាយុកាលច្បាស់លាស់ ត្រូវបានប៉ាន់ស្មានដោយផ្អែកលើរយៈពេលលើសកាលកំណត់ដែលទ្រព្យសកម្មត្រូវបានរំពឹងថារួចរាល់ដែលអាចប្រើប្រាស់បាន។ អាយុកាលប្រើប្រាស់នៃទ្រព្យសម្បត្តិ និងបរិក្ខាររបស់ក្រុមហ៊ុន និងទ្រព្យសកម្មអរូបីដែលបានប៉ាន់ស្មាន ត្រូវបានត្រួតពិនិត្យជាប្រចាំ និងត្រូវបានធ្វើបច្ចុប្បន្នភាព ប្រសិនបើការរំពឹងទុកខុសពីការប៉ាន់ស្មានពីមុន ដោយសារតែទ្រព្យសកម្មបានបែកបាក់ ភាពហួសសម័យផ្នែកបច្ចេកទេស ឬពាណិជ្ជកម្ម និងច្បាប់ ឬដែនកំណត់ផ្សេងទៀតលើការប្រើប្រាស់ទ្រព្យសកម្មរបស់ក្រុមហ៊ុន។

លើសពីនេះទៀត ការប៉ាន់ស្មាននៃអាយុកាលប្រើប្រាស់ គឺផ្អែកលើការវាយតម្លៃរួមរបស់ក្រុមហ៊ុនលើការអនុវត្តផ្នែកឧស្សាហកម្ម ការវាយតម្លៃបច្ចេកទេសផ្ទៃក្នុង និងបទពិសោធន៍លើទ្រព្យសកម្មដែលស្រដៀងគ្នា។ ទោះយ៉ាងណាក៏ដោយ វាអាចទៅរួចដែលលទ្ធផលនៃប្រតិបត្តិការនាពេលអនាគតអាចត្រូវបានប៉ះពាល់យ៉ាងខ្លាំងជាសារវន្ត ដោយការផ្លាស់ប្តូរក្នុងការប៉ាន់ស្មានដែលនាំមកនូវកត្តាប្រែប្រួលដែលបានរៀបរាប់ខាងលើ។ សមតុល្យ និងកាលបរិច្ឆេទនៃការចំណាយដែលបានកត់ត្រាសម្រាប់រយៈពេលណាមួយ នឹងត្រូវបានប៉ះពាល់ដោយការផ្លាស់ប្តូរនៅក្នុងកត្តា និងកាលៈទេសៈទាំងនេះ។ ការកាត់បន្ថយអាយុកាលប្រើប្រាស់នៃទ្រព្យសម្បត្តិ និងបរិក្ខារ និងទ្រព្យសកម្មអរូបីដែលបានប៉ាន់ស្មាន នឹងបង្កើនការចំណាយប្រតិបត្តិការដែលបានទទួលស្គាល់ និងកាត់បន្ថយទ្រព្យសកម្មរយៈពេលវែង។

### ភតិសន្យា - ការប៉ាន់ស្មាននៃការកើនឡើងអត្រាប្រាក់កម្ចី

ក្រុមហ៊ុនមិនអាចកំណត់បាននូវអត្រាការប្រាក់ដែលបញ្ជាក់នៅក្នុងភតិសន្យាឡើយ ហេតុដូចនេះក្រុមហ៊ុនប្រើប្រាស់ការកើនឡើងអត្រាប្រាក់កម្ចី (IBR) ដើម្បីវាស់វែងបំណុលភតិសន្យា។ IBR គឺជាអត្រាការប្រាក់ដែលក្រុមហ៊ុន ត្រូវចំណាយដើម្បីខ្ចីក្នុងលក្ខខណ្ឌស្រដៀងគ្នា ហើយមានការធានាប្រហាក់ប្រហែលគ្នា មូលនិធិចាំបាច់ដើម្បីទទួលបានទ្រព្យសកម្មដែលមានតម្លៃប្រហាក់ប្រហែលទៅនឹងសិទ្ធិប្រើប្រាស់លើទ្រព្យសកម្មក្នុងបរិស្ថានសេដ្ឋកិច្ចស្រដៀងគ្នា។ ក្រុមហ៊ុន ប៉ាន់ស្មាន IBR ដោយប្រើប្រាស់អត្រាការប្រាក់ខ្ចីជាមធ្យមនៅប្រទេសកម្ពុជា។

### ការប៉ាន់ស្មានថ្លៃដើមនៃសិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម

ការកំណត់ថ្លៃដើមនៃសិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម រួមបញ្ចូលទាំងសមតុល្យនៃបំណុលភតិសន្យាដែលបានទទួលស្គាល់ និងចំណាយដែលបានប៉ាន់ស្មានទុកថានឹងកើតមានឡើងក្នុងការរុះរើ ឬដកហូតនូវមូលដ្ឋានទ្រព្យសកម្ម ឬការរៀបចំឡើងវិញតាមលក្ខខណ្ឌតម្រូវក្នុងកិច្ចសន្យា។

### ឱនភាពនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ក្រុមហ៊ុន ធ្វើការអនុវត្តលើការត្រួតពិនិត្យឱនភាពនៃតម្លៃ នៅពេលដែលមានសូចនាករបង្ហាញពីឱនភាពនៃតម្លៃជាក់ស្តែង។

ការកំណត់លើតម្លៃដែលអាចប្រមូលមកវិញបានរបស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងទ្រព្យសកម្មអរូបី ដែលតម្រូវឱ្យមានការកំណត់នូវលំហូរសាច់ប្រាក់នាពេលអនាគតដែលរំពឹងថា នឹងទទួលបានពីការបន្តប្រើប្រាស់ និងការបែងចែកលើកចុងក្រោយនៃទ្រព្យសកម្មទាំងនោះ ដែលតម្រូវឱ្យក្រុមហ៊ុនធ្វើការប៉ាន់ស្មាន និងសន្មត ដែលអាចប៉ះពាល់ជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច។ ព្រឹត្តិការណ៍នាពេលអនាគត អាចបណ្តាលឱ្យក្រុមហ៊ុនសន្និដ្ឋានថាទ្រព្យសម្បត្តិ និងបរិក្ខារ និងទ្រព្យសកម្មអរូបី ត្រូវមានឱនភាពនៃតម្លៃ។ រាល់ឱនភាពនៃតម្លៃ អាចមានផលប៉ះពាល់អវិជ្ជមានជាសារវន្តលើស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលនៃប្រតិបត្តិការ។

ការរៀបចំលំហូរសាច់ប្រាក់នាពេលអនាគតដែលបានរំពឹងទុក ទាក់ទងនឹងការវិនិច្ឆ័យ និងការប៉ាន់ស្មានសំខាន់ៗ។ ខណៈពេលដែលក្រុមហ៊ុនជឿជាក់ថាការសន្មតគឺសមស្រប និងសមហេតុផល ហើយការផ្លាស់ប្តូរសំខាន់ៗក្នុងការសន្មតដែលអាចប៉ះពាល់ជាសារវន្តក្នុងការវាយតម្លៃលើតម្លៃដែលអាចប្រមូលមកវិញបាន និងអាចបណ្តាលឲ្យមានបន្ទុកលើឱនភាពនៃតម្លៃបន្ថែមនាពេលអនាគត។

## ខ. ការវិនិច្ឆ័យគណនេយ្យសំខាន់ៗ

ខាងក្រោមនេះ គឺជាការវិនិច្ឆ័យសំខាន់ៗ ក្រៅពីការប៉ាន់ស្មានដែលពាក់ព័ន្ធទាំងនេះ គណៈគ្រប់គ្រងបានដំណើរការក្នុងការអនុវត្តគោលនយោបាយគណនេយ្យរបស់អង្គភាព ហើយវាមានផលប៉ះពាល់ខ្លាំងបំផុតលើសមតុល្យដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច។

### ការទទួលស្គាល់នៃចំណូលកិច្ចសន្យា

ការទទួលស្គាល់នៃកិច្ចសន្យាសាងសង់ តម្រូវឲ្យមានការវិនិច្ឆ័យយ៉ាងម៉ត់ចត់ ក្នុងការកំណត់ទិសដៅការងារជាក់ស្តែង និងការចំណាយនានាដែលបានប៉ាន់ស្មានដើម្បីបញ្ចប់ការងារនោះ។

### ការកំណត់រយៈពេលក្នុងការបញ្ចប់ដោយពេញលេញនូវកាតព្វកិច្ចអនុវត្ត

ក្រុមហ៊ុនបានវាយតម្លៃកិច្ចសន្យាទាំងនោះជាមួយអតិថិជនដែលមានកាតព្វកិច្ចអនុវត្តច្រើនជាងមួយ ហើយចំណូលកើតឡើងពីលក្ខណៈសម្បត្តិគ្រប់គ្រាន់ពីការទទួលស្គាល់រយៈពេលលើសពេលវេលាកំណត់ ការបញ្ចប់ដោយពេញលេញនៃកាតព្វកិច្ចអនុវត្ត ត្រូវបានផ្អែកលើរបាយការណ៍នៃការបញ្ចប់សេវាកម្មដែលបានសន្យាក្នុងកិច្ចសន្យា។

ទន្ទឹមនឹងនេះដែរ នៅពេលដែលមានកាតព្វកិច្ចអនុវត្តតែមួយ ចំណូលដែលកើតឡើងពីលក្ខណៈសម្បត្តិគ្រប់គ្រាន់ពីការទទួលស្គាល់តាមពេលវេលាជាក់លាក់មួយ នៅពេលសិទ្ធិក្នុងការគ្រប់គ្រងសន្និធិត្រូវបានផ្ទេរជូនអតិថិជន។

### ការកំណត់តម្លៃប្រតិបត្តិការ និងសមតុល្យដែលបានបែងចែកលើកាតព្វកិច្ចអនុវត្ត

ក្រុមហ៊ុនពិចារណាលើលក្ខខណ្ឌនៃកិច្ចសន្យា និងការអនុវត្តអាជីវកម្មតាមច្បាប់ទម្លាប់របស់ខ្លួន ដើម្បីកំណត់តម្លៃប្រតិបត្តិការ។ តម្លៃប្រតិបត្តិការ គឺជាសមតុល្យនៃតម្លៃតបស្នងដែលក្រុមហ៊ុនរំពឹងថានឹងមានសិទ្ធិទទួលបានពីការដោះដូរសេវាកម្មដែលត្រូវបានអនុវត្ត និងការផ្ទេរសិទ្ធិក្នុងការគ្រប់គ្រងលើសន្និធិទៅឲ្យអតិថិជន។

ក្រុមហ៊ុនបានវាយតម្លៃលើកិច្ចសន្យាជាមួយអតិថិជនដែលមានកាតព្វកិច្ចអនុវត្តច្រើនជាងមួយ ហើយចំណូលដែលកើតឡើងពីកិច្ចព្រមព្រៀងដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការទទួលស្គាល់លើសពេលវេលាកំណត់ បានផ្អែកលើរបាយការណ៍នៃការបញ្ចប់សេវាកម្មដែលបានអនុវត្ត។ ក្រុមហ៊ុនបែងចែកតម្លៃប្រតិបត្តិការទៅតាមកាតព្វកិច្ចអនុវត្ត និងទទួលស្គាល់ចំណូលតាមពេលវេលា។

ចំណូលប្រតិបត្តិការ ដែលមានកាតព្វកិច្ចអនុវត្តតែមួយ ក្រុមហ៊ុនបានវាយតម្លៃថាចំណូលដែលកើតឡើងពីកិច្ចព្រមព្រៀង ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ទទួលស្គាល់តាមពេលវេលាជាក់ណាមួយ ដោយផ្អែកលើការផ្ទេរសិទ្ធិក្នុងការគ្រប់គ្រង។ សិទ្ធិក្នុងការគ្រប់គ្រងសន្និធិសំដៅដល់ លទ្ធភាពក្នុងការគ្រប់គ្រងការប្រើប្រាស់ដោយផ្ទាល់ និងការទទួលបានអត្ថប្រយោជន៍ដែលនៅសល់ពីការប្រើប្រាស់ទ្រព្យសកម្មនោះ។ ក្រុមហ៊ុនបែងចែកតម្លៃប្រតិបត្តិការលើកាតព្វកិច្ចអនុវត្តតែមួយ និងទទួលស្គាល់ចំណូលតាមពេលវេលាណាមួយ។

### ការកំណត់សមតុល្យថ្លៃដើមកិច្ចសន្យា

ក្រុមហ៊ុនបានវាយតម្លៃលើការកើនឡើងនៃថ្លៃដើមក្នុងការធ្វើកិច្ចសន្យាជាមួយអតិថិជន ដែលមានដូចជាកម្រៃជើងសាលើការលក់ដែលបានទូទាត់ គឺជាចំណាយកើតឡើងក្នុងក្រុមហ៊ុន ដែលនឹងមិនកើតឡើងប្រសិនបើកិច្ចសន្យាមិនត្រូវបានធ្វើឡើង និងគួរតែត្រូវបានទទួលស្គាល់ជាទ្រព្យសកម្ម។

### ភតិសន្យា

ការវាយតម្លៃថាតើការរៀបចំមានរួមបញ្ចូលនូវភតិសន្យា ត្រូវបានផ្អែកលើសមាសធាតុរបស់វា។ ការរៀបចំគឺ ឬមានរួមបញ្ចូលនូវភតិសន្យានៅពេលដែលបានបំពេញលើការរៀបចំ អាស្រ័យទៅលើទ្រព្យសកម្មជាក់លាក់ ឬទ្រព្យសកម្មនានា និងការរៀបចំដែលបង្ហាញពីសិទ្ធិប្រើប្រាស់លើទ្រព្យសកម្មនោះ។

### ភតិសន្យាលើទ្រព្យសកម្មដែលមានតម្លៃទាប

ក្នុងការវាយតម្លៃថាភតិសន្យាមានតម្លៃទាប ឬទេ គណៈគ្រប់គ្រងពិចារណាលើខ្លឹមសារមូលដ្ឋានសេដ្ឋកិច្ចរបស់ទ្រព្យសកម្មទាំងស្រុង។

### អត្រាអប្បហារដែលបានប្រើប្រាស់ក្នុងការកំណត់សមតុល្យយោងនៃបំណុលភតិសន្យារបស់ក្រុមហ៊ុន

បំណុលភតិសន្យារបស់ក្រុមហ៊ុន ត្រូវបានធ្វើអប្បហារក្នុងអត្រាដែលបានកំណត់តាមរយៈការយោងទៅតាមទីផ្សារនាចុងការិយបរិច្ឆេទនៃរបាយការណ៍ ដូចដែលបានបកស្រាយដោយ GDT។ ការវិនិច្ឆ័យសំខាន់ៗ ត្រូវបានតម្រូវនៅពេលដែលកំណត់ពីប្រភេទនៃអត្រាការប្រាក់កម្ចី ដែលត្រូវបានរួមបញ្ចូលនៅក្នុងចំនួនប្រជាជនដែលអត្រាអប្បហារត្រូវបានយកមកប្រើប្រាស់។

### រំលស់លើសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម

រំលស់លើទ្រព្យសកម្មភតិសន្យា ត្រូវបានគណនាដោយប្រើប្រាស់វិធីសាស្ត្រថេរដើម្បីបែងចែកថ្លៃដើមដកតម្លៃសំណល់លើអាយុកាលប្រើប្រាស់ដែលបានប៉ាន់ស្មានទុកដែលតិចជាងរវាងរយៈពេលជួលដែលនៅសល់ និងអាយុកាលទ្រព្យសកម្មដែលបានរំពឹងទុក។

### ចំណាយពន្ធលើប្រាក់ចំណូល

ក្រុមហ៊ុននឹងទទួលស្គាល់បំណុល សម្រាប់ចំណាយពន្ធដែលបានរំពឹងទុក ដោយផ្អែកលើការប៉ាន់ស្មានថាតើពន្ធនោះត្រូវបានឆ្លងកាត់ការបកស្រាយបច្ចុប្បន្នរបស់គណៈគ្រប់គ្រងទៅលើបទប្បញ្ញត្តិពន្ធមួយចំនួនដែលមានការផ្លាស់ប្តូរជាប្រចាំ។ ការកំណត់ចុងក្រោយទៅលើចំណាយពន្ធដែលត្រូវធ្វើឡើងតាមការត្រួតពិនិត្យដោយអគ្គនាយកដ្ឋានពន្ធដារ។

នៅពេលដែលលទ្ធផលពន្ធចុងក្រោយដែលបានពីបង្ហាញបញ្ហាទាំងនេះ ដែលមានភាពខុសគ្នាពីសមតុល្យដែលត្រូវបានទទួលស្គាល់ដំបូង ភាពខុសគ្នាទាំងនេះនឹងប៉ះពាល់ដល់សំវិធានធនពន្ធក្នុងការិយបរិច្ឆេទដែលការកំណត់ត្រូវបានធ្វើឡើង។

### ការទទួលស្គាល់ទ្រព្យសកម្មពន្ធពន្យារ

វិសាលភាពនៃទ្រព្យសកម្មពន្ធពន្យារ អាចត្រូវបានគេទទួលស្គាល់ ដោយផ្អែកលើការវាយតម្លៃនៃប្រូបាប៊ីលីតេលើប្រាក់ចំណូលជាប់ពន្ធនាពេលអនាគតនឹងអាចប្រើប្រាស់បាន ធៀបទៅនឹងភាពខុសគ្នាបណ្តោះអាសន្នដែលអាចកាត់កងបាន និងខាតពន្ធយោងទៅមុខដែលអាចប្រើប្រាស់។ លើសពីនេះទៀត ការវិនិច្ឆ័យសំខាន់ៗត្រូវតម្រូវឱ្យមានការវាយតម្លៃលើផលប៉ះពាល់នៃច្បាប់ណាមួយ ឬដែនកំណត់ផ្អែកសេដ្ឋកិច្ច ឬភាពមិនច្បាស់លាស់នៅក្នុងយុត្តាធិការពន្ធផ្សេងៗ។

(ទំព័រនេះត្រូវទុកឲ្យចន្លោះទទេដោយចេតនា)

## ៦. ទ្រព្យសម្បត្តិ និងបរិក្ខារ

| | ដីកម្មសិទ្ធ<br>ដុល្លារអាមេរិក | គ្រឿងម៉ាស៊ីន<br>ដុល្លារអាមេរិក | យានយន្ត<br>ដុល្លារអាមេរិក | បរិក្ខារ<br>ការិយាល័យ<br>ដុល្លារអាមេរិក | គ្រឿងសង្ហារឹម<br>ដុល្លារអាមេរិក | ការកែលម្អដី<br>ដុល្លារអាមេរិក | ការងារកំពុង<br>ដំណើរការ<br>ដុល្លារអាមេរិក | ដុល្លារអាមេរិក | សរុប<br>ពាន់រៀល<br>(កំណត់សម្គាល់ ៤.២) |
|---|---|---|---|---|---|---|---|---|---|
| **សមតុល្យយោងដុល** | | | | | | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | ២.១៦៧.៦២០ | ៦៥២.៩៤០ | ៥៧៣.៤០៩ | ៦៦.៤៣៣ | ៨.៩០៩ | ៥២.១៦៦ | ៦០.៨០១ | ៣.៥៨២.២៧៨ | ១៤.៥៩៤.២០១ |
| បន្ថែម | - | ៩៣.៥២៥ | - | ៦.២៤០ | - | - | ១.៥១៣.៣៩១ | ១.៦១៣.១៥៦ | ៦.៥៩២.៩៦៩ |
| ការលក់ចេញ | - | (១៣.២០៥) | - | (៤.០៤៣) | | - | - | (១៧.២៤៨) | (៧០.៤៩៤) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | ២០១.៩១៤ |
| **សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **២.១៦៧.៦២០** | **៧៣៣.២៦០** | **៥៧៣.៤០៩** | **៦៨.៦៣០** | **៨.៩០៩** | **៥២.១៦៦** | **១.៥៧៤.១៩២** | **៥.១៧៨.១៨៦** | **២១.៣១៨.៥៩០** |
| **រំលស់បង្គរ** | | | | | | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | - | ៣៩២.០៧០ | ៤៨២.៧២១ | ៥១.០០៧ | ៨.២០២ | ៥.២១៧ | - | ៩៣៩.២១៦ | ៣.៨២៦.៣៦៦ |
| រំលស់ | - | ១០៧.៥៤៦ | ២៣.១៣៨ | ១០.៣៥៧ | ៥៦៧ | ១០.៤៣៣ | - | ១៥២.០៤២ | ៦២១.៣៩៤ |
| ការលក់ចេញ | - | (១២.៩៤៦) | - | (៣.៨៦៤) | - | - | - | (១៦.៨១០) | (៦៨.៧០២) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | ៤៤.៤៤៣ |
| **សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **-** | **៤៨៦.៦៧០** | **៥០៥.៨៥៩** | **៥៧.៥០០** | **៨.៧៦៨** | **១៥.៦៥០** | **-** | **១.០៧៤.៤៤៨** | **៤.៤២៣.៥០១** |
| **សមតុល្យយោងគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **២.១៦៧.៦២០** | **២៤៦.៥៩០** | **៦៧.៥៥០** | **១១.១៣០** | **១៤១** | **៣៦.៥១៦** | **១.៥៧៤.១៩២** | **៤.១០៣.៧៣៨** | **១៦.៨៩៥.០៨៩** |

## ៦. ទ្រព្យសម្បត្តិ និងបរិក្ខារ (ត)

| | ដីកម្មសិទ្ធ ដុល្លារអាមេរិក | គ្រឿងម៉ាស៊ីន ដុល្លារអាមេរិក | យានយន្ត ដុល្លារអាមេរិក | បរិក្ខារការិយាល័យ ដុល្លារអាមេរិក | គ្រឿងសង្ហារឹម ដុល្លារអាមេរិក | ការកែលម្អដី ដុល្លារអាមេរិក | ការងារកំពុងដំណើរការ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
|---|---|---|---|---|---|---|---|---|---|
| សមតុល្យយោងដុល | | | | | | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា | | | | | | | | | |
| ឆ្នាំ២០២១ | ២.១៦៧.៦២០ | ៥៥០.៦០២ | ៥៧៣.២៦៨ | ៦១.៣៧៦ | ៨.៦៥៣ | - | ៥២.១៦៥ | ៣.៤១៣.៦៨៤ | ១៣.៨០៨.៣៥២ |
| បន្ថែម | - | ១១៣.៤៤១ | ៤៩០ | ៧.៨១៧ | ២៥៧ | - | ៦០.៨០១ | ១៨២.៨០៦ | ៧៤៣.៦៥៥ |
| ផ្ទេរចេញ | - | - | - | - | - | ៥២.១៦៥ | (៥២.១៦៥) | - | - |
| ការលក់ចេញ | - | (១១.១០២) | (៣៥០) | (២.៧៦០) | - | - | - | (១៤.២១២) | (៥៧.៨១៤) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | ១០០.០០៨ |
| សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | ២.១៦៧.៦២០ | ៦៥២.៩៤១ | ៥៧៣.៤០៨ | ៦៦.៤៣៣ | ៨.៩១០ | ៥២.១៦៥ | ៦០.៨០១ | ៣.៥៨២.២៧៨ | ១៤.៥៩៤.២០១ |
| រំលស់បង្គរ | | | | | | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា | | | | | | | | | |
| ឆ្នាំ២០២១ | - | ២៩៥.៨៧៨ | ៤៦៥.៨៥៦ | ៤៤.៩២៨ | ៧.០០៧ | - | - | ៨១៣.៦៦៩ | ៣.២៩១.២៩១ |
| រំលស់ | - | ១០៥.៤៧៨ | ១៧.០៨១ | ៨.៨១៨ | ១.១៩៥ | ៥.២១៧ | - | ១៣៧.៧៨៩ | ៥៦០.៥២៦ |
| ការលក់ចេញ | - | (៩.២៨៦) | (២១៧) | (២.៧៣៩) | - | - | - | (១២.២៤២) | (៤៩.៨០០) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | ២៤.៣៤៩ |
| សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | - | ៣៩២.០៧០ | ៤៨២.៧២០ | ៥១.០០៧ | ៨.២០២ | ៥.២១៧ | - | ៩៣៩.២១៦ | ៣.៨២៦.៣៦៦ |
| សមតុល្យយោងគិតត្រឹមថ្ងៃទី៣១ ខែធ្នូ | | | | | | | | | |
| ឆ្នាំ២០២១ | ២.១៦៧.៦២០ | ២៦០.៨៧១ | ៩០.៦៨៨ | ១៥.៤២៦ | ៧០៨ | ៤៦.៩៤៨ | ៦០.៨០១ | ២.៦៤៣.០៦២ | ១០.៧៦៧.៨៣៥ |

## ៦. ទ្រព្យសម្បត្តិ និងបរិក្ខារ(ត)

នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ ក្រុមហ៊ុនបានចុះកិច្ចសន្យាឥណទាន ជាមួយធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ ("ABA") ក្នុងសមតុល្យ ១.៦៩០.០០០ ដុល្លារអាមេរិក មានអត្រាការប្រាក់ ៨% ក្នុងមួយឆ្នាំ ជាមួយនឹងការទូទាត់សងត្រឡប់រយៈពេល ៧២ខែ គិតចាប់ពីកាលបរិច្ឆេទដែលឥណទានមានប្រសិទ្ធភាព។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ប្រាក់ដើមនៃឥណទានដែលនៅសល់មានសមតុល្យ ១.៣៨៤.០១៦ ដុល្លារអាមេរិក។ ឥណទាននេះត្រូវបានដាក់ធានាដោយដីឡូត៍ចំនួនពីរប្លង់ដែលមានទំហំសរុបចំនួន ១០.៣២២ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនបត្របញ្ជាក់កម្មសិទ្ធិលេខ ១២១២០១០៣-០៤៩៥ និង ១២១២០១០៣-០៤៩៦ ដោយមានប្លង់លេខ ៤៩៥ និង៤៩៦ មានទីតាំងស្ថិតនៅភូមិស្វាយចេក សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ត្រូវបានកត់ត្រាជាទ្រព្យសម្បត្តិ និងបរិក្ខាររបស់ក្រុមហ៊ុន ជាដីកម្មសិទ្ធិមានតម្លៃ ២.១៦៧.៦២០ ដុល្លារអាមេរិក។ ប័ណ្ណកម្មសិទ្ធិដីទាំងនេះ ត្រូវបានចុះបញ្ជីក្រោមឈ្មោះរបស់លោក នាង វិធី និងលោកស្រី លឹម មុយលី ដែលជាតំណាងឱ្យក្រុមហ៊ុន។ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២២ ប័ណ្ណកម្មសិទ្ធិត្រូវបានផ្ទេរទៅជាឈ្មោះក្រុមហ៊ុនវិញ ហើយបានបញ្ចូលទៅក្នុងវិញ្ញាបនបត្រអចលនទ្រព្យតែមួយ មានប័ណ្ណកម្មសិទ្ធិលេខ ២១២០១០៣-១២៩៨។

ក្រុមហ៊ុនបានទូទាត់រួចរាល់ទៅលើបំណុលដែលនៅសល់ទាក់ទងទៅនឹងការទិញដីឡូត៍ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ។

## ៧. ទ្រព្យសកម្មអរូបី - សុទ្ធ

| | ឆ្នាំ២០២២ | | ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| **សមតុល្យយោងដុល** | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា | **៤២.៨៤៥** | **១៧៤.៥៥១** | ៤២.៨៤៥ | ១៧៣.៣០៨ |
| បន្ថែម | **១៤.៨០៩** | **៦០.៩៦៥** | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | **-** | **២២៧** | - | ១.២៤៣ |
| **សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ** | **៥៧.៦៥៤** | **២៣៥.៧៤៣** | ៤២.៨៤៥ | ១៧៤.៥៥១ |
| **រំលស់បង្គរ** | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា | **៨.៨៥៩** | **៣៦.០៩២** | ៥.៣៨៩ | ២១.៧៩៨ |
| រំលស់ | **៥.០៥០** | **២០.៥៧៣** | ៣.៤៧០ | ១៤.១១៦ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | **-** | **(១.០២០)** | - | ១៧៨ |
| **សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ** | **១៣.៩០៩** | **៥៥.៦៤៥** | ៨.៨៥៩ | ៣៦.០៩២ |
| **សមតុល្យយោងគិតត្រឹមថ្ងៃទី៣១ ខែធ្នូ** | **៤៣.៧៤៥** | **១៨០.០៩៨** | ៣៣.៩៨៦ | ១៣៨.៤៥៩ |

## ៨. សិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម - សុទ្ធ និងបំណុលភតិសន្យា

*ក្រុមហ៊ុនក្នុងនាមជាភតិកៈ*

ក្រុមហ៊ុនមានកិច្ចសន្យាភតិសន្យា ទៅលើអគារដែលជាទីតាំងការិយាល័យរបស់ខ្លួនសម្រាប់រយៈពេលដប់ឆ្នាំ ជាកិច្ចសន្យាដែលមិនអាចលុបចោលបាន ជាមួយនឹងមិនមានជម្រើសក្នុងការបន្តភតិសន្យាបន្ទាប់ពីកិច្ចសន្យាចាស់ត្រូវបានបញ្ចប់។ កិច្ចសន្យានេះមិនរឹតត្បិតទៅលើក្រុមហ៊ុនក្នុងការចាត់ចែង និងការជួលបន្តលើទ្រព្យសកម្មនេះឡើយ។

សមតុល្យយោងនៃសិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម បានទទួលស្គាល់ និងបម្រែបម្រួលក្នុងអំឡុងការិយបរិច្ឆេទមានដូចខាងក្រោម៖

| | | **ឆ្នាំ២០២២** | | ឆ្នាំ២០២១ |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | ដុល្លារអាមេរិក | ពាន់រៀល |
| | | **(កំណត់សម្គាល់ ៤.២)** | | (កំណត់សម្គាល់ ៤.២) |
| **សមតុល្យយោងដុល** | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា | **៣៩២.៩៤១** | **១.៦០០.៨៤២** | ៣៩២.៩៤១ | ១.៥៨៩.៤៤៦ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | **១៦.៨៩៦** | - | ១១.៣៩៦ |
| **សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ** | **៣៩២.៩៤១** | **១.៦១៧.៧៣៨** | ៣៩២.៩៤១ | ១.៦០០.៨៤២ |
| **រំលស់បង្គរ** | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា | **៣៦០.១៩៦** | **១.៤៦៧.៤៣៩** | ៣២២.៥៣៩ | ១.៣០៤.៦៧០ |
| រំលស់ | **៣២.៧៤៥** | **១៣៣.៨២៩** | ៣៧.៦៥៧ | ១៥៣.១៨៩ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | **១៦.៤៧០** | - | ៩.៥៨០ |
| **សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ** | **៣៩២.៩៤១** | **១.៦១៧.៧៣៨** | ៣៦០.១៩៦ | ១.៤៦៧.៤៣៩ |
| **សមតុល្យយោងគិតត្រឹមថ្ងៃទី៣១ ខែធ្នូ** | - | - | ៣២.៧៤៥ | ១៣៣.៤០៣ |

រយៈពេលភតិសន្យាលើអគារការិយាល័យសម្រាប់រយៈពេលដប់ឆ្នាំដែលមិនអាចលុបចោលបានផុតកំណត់នៅខែតុលា ឆ្នាំ២០២២ ហើយក្រុមហ៊ុនបានចុះកិច្ចព្រមព្រៀងលើភតិសន្យាថ្មីសម្រាប់រយៈពេលប្រាំខែបន្ត។ ការផុតកំណត់នៃរយៈពេលភតិសន្យាថ្មីនេះស្របពេលជាមួយនឹងការរំពឹងទុកនៃការបញ្ចប់ការសាងសង់ការិយាល័យកណ្តាលរបស់ខ្លួននៅខែកុម្ភៈ ឆ្នាំ២០២៣។ ភតិសន្យារយៈពេលខ្លីនេះ ត្រូវបានកត់ត្រាក្នុងការប្រើប្រាស់លក្ខខណ្ឌជាក់ស្តែង ហើយការទូទាត់ដែលទាក់ទងនឹងភតិសន្យានេះ ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងរបាយការណ៍ចំណូលលម្អិតនៅលើមូលដ្ឋានថេរលើរយៈពេលភតិសន្យា។

បំណុលភតិសន្យា ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដូចខាងក្រោម៖

| | | **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | ដុល្លារអាមេរិក | ពាន់រៀល |
| | | **(កំណត់សម្គាល់ ៤.២)** | | (កំណត់សម្គាល់ ៤.២) |
| រយៈពេលខ្លី | - | - | ៤៨.៥០៩ | ១៩៧.៦២៦ |
| រយៈពេលវែង | - | - | - | - |
| | - | - | ៤៨.៥០៩ | ១៩៧.៦២៦ |

តារាងខាងក្រោមត្រូវបានបង្ហាញអំពីសមតុល្យយោងនៃបំណុលភតិសន្យា និងបម្រែបម្រួលក្នុងអំឡុងការិយបរិច្ឆេទដូចខាងក្រោម៖

| | **ឆ្នាំ២០២២** | | ឆ្នាំ២០២១ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | ដុល្លារអាមេរិក | ពាន់រៀល |
| | | **(កំណត់សម្គាល់ ៤.២)** | | (កំណត់សម្គាល់ ៤.២) |
| **នាថ្ងៃទី១ ខែមករា** | **៤៨.៥០៩** | **១៩៧.៦២៦** | ១០៨.៦០០ | ៤៣៩.២៨៧ |
| ការកើនឡើងនៃការប្រាក់ | **១.៨៩១** | **៧.៧២៩** | ៧.១១០ | ២៨.៩២៣ |
| ការទូទាត់សង | **(៥០.៤០០)** | **(២០៥.៩៨៥)** | (៦៧.២០១) | (២៧៣.៣៧៤) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | **-** | **៦៣០** | - | ២.៧៩០ |
| **នាថ្ងៃទី៣១ ខែធ្នូ** | **-** | **-** | ៤៨.៥០៩ | ១៩៧.៦២៦ |

## ៨.១. ការផ្ទៀងផ្ទាត់លើបំណុលដែលកើតឡើងពីសកម្មភាពហិរញ្ញវត្ថុ

ការប្រែប្រួលលើបំណុលរបស់ក្រុមហ៊ុន ដែលកើតឡើងពីសកម្មភាពហិរញ្ញវត្ថុអាចត្រូវបានចាត់ថ្នាក់ដូចខាងក្រោម៖

| | **ថ្ងៃទី១ ខែមករា ឆ្នាំ២០២២** | **សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | | **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | |
|---|---|---|---|---|---|---|
| | | **ដកចេញ** | **ការទូទាត់សង** | **មិនមែនលំហូរសាច់ប្រាក់** | | |
| | **ដុល្លារអាមេរិក** | **ដុល្លារអាមេរិក** | **ដុល្លារអាមេរិក** | **ដុល្លារអាមេរិក** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| | | | | | | **(កំណត់សម្គាល់ ៤.២)** |
| **បំណុលភតិសន្យា** | **៤៨.៥០៩** | **-** | **(៥០.៤០០)** | **១.៨៩១** | **-** | **-** |

| | នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២១ | សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | | នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|---|---|
| | | ដកចេញ | ការទូទាត់សង | មិនមែនលំហូរសាច់ប្រាក់ | | |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល |
| | | | | | | (កំណត់សម្គាល់ ៤.២) |
| បំណុលភតិសន្យា | ១០៨.៦០០ | - | (៦៧.២០១) | ៧.១១០ | ៤៨.៥០៩ | ១៩៧.៦២៦ |

បំណុលភតិសន្យាទាក់ទងនឹងតម្លៃបច្ចុប្បន្ននៃការទូទាត់ភតិសន្យាដែលមិនត្រូវបានបង់នាកាលបរិច្ឆេទចាប់ផ្តើម ត្រូវធ្វើអប្បហារដោយប្រើអត្រាការប្រាក់ដែលបង្កប់នៅក្នុងភតិសន្យា ឬប្រសិនបើអត្រានោះមិនអាចកំណត់បានភ្លាមៗនោះត្រូវប្រើអត្រាកម្ចីបន្ថែមរបស់អ្នកជួល។ អត្រាការប្រាក់ក្រោមបំណុលជួលគឺ ៩.២៦% ដែលជាអត្រាកម្ចីបន្ថែមរបស់ក្រុមហ៊ុន។

### ៨.២. ការទូទាត់ភតិសន្យាអប្បបរមានាពេលអនាគត

ព័ត៌មានលម្អិតនៃការទូទាត់ភតិសន្យាអប្បបរមានាពេលអនាគត ដែលទាក់ទងនឹងការជួលការិយាល័យត្រូវបានសង្ខេបដូចខាងក្រោម៖

| | ការទូទាត់ភតិសន្យាអប្បបរមាតាមកាលកំណត់ | | | |
|---|---|---|---|---|
| | ក្នុងអំឡុងពេលមួយឆ្នាំ | ១ ទៅ២ ឆ្នាំ | សរុប | |
| | | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | | | |
| **ការទូទាត់ភតិសន្យា** | - | - | - | - |
| **បន្ទុកហិរញ្ញវត្ថុ** | - | - | - | - |
| **តម្លៃបច្ចុប្បន្នសុទ្ធ** | - | - | - | - |

| | ការទូទាត់ភតិសន្យាអប្បបរមាតាមកាលកំណត់ | | | |
|---|---|---|---|---|
| | ក្នុងអំឡុងពេលមួយឆ្នាំ | ១ ទៅ២ ឆ្នាំ | សរុប | |
| | | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | | | |
| បំណុលភតិសន្យា | ៥០.៤០០ | - | ៥០.៤០០ | ២០៥.៣៣០ |
| សេវាហិរញ្ញវត្ថុ | (១.៨៩១) | - | (១.៨៩១) | (៧.៧០៤) |
| តម្លៃបច្ចុប្បន្នសុទ្ធ | ៤៨.៥០៩ | - | ៤៨.៥០៩ | ១៩៧.៦២៦ |

### ៩. ទ្រព្យសកម្មរយៈពេលវែងផ្សេងៗ

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| ប្រាក់តម្កល់ដែលបានបង់ | **២០.១០០** | **៨២.៧៥២** | ២០.០៥០ | ៨១.៦៨៤ |

### ១០. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| សាច់ប្រាក់ក្នុងធនាគារ | **១៧.២៧៧** | **៧១.១២៩** | ២១៨.៦០៣ | ៨៩០.៥៨៩ |
| សាច់ប្រាក់ក្នុងដៃ | **៤.១៨៧** | **១៧.២៣៨** | ៦.៥១៦ | ២៦.៥៤៦ |
| | **២១.៤៦៤** | **៨៨.៣៦៧** | ២២៥.១១៩ | ៩១៧.១៣៥ |

## ១១. ប្រាក់តម្កល់ធានា

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (កំណត់សម្គាល់ ៤.២) | | (កំណត់សម្គាល់ ៤.២) |
| ប្រាក់តម្កល់ធានាលើឥណទានហ្សាស៊ីលីធី | **៥៩០.០៨០** | **២.៤២៩.៣៥៩** | ៦៥.០០០ | ២៦៤.៨១០ |

ប្រាក់តម្កល់ធានាមានកាលកំណត់រយៈពេល ១២ ខែ ត្រូវបានប្រើប្រាស់ជាការធានាសុវត្ថិភាពលើឥណទានហ្សាស៊ីលីធីដែលបានផ្តល់ជូនក្រុមហ៊ុន ដែលទទួលបានការប្រាក់ ៦% ក្នុងមួយឆ្នាំ។ ប្រាក់តម្កល់ធានាទាំងនេះ ត្រូវបានដាក់តម្កល់ជាមួយធនាគារវឌ្ឍនៈអាស៊ីចំកាត់ (“ABA”) និង ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី។

## ១២. គណនីពាណិជ្ជត្រូវទទួល

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (កំណត់សម្គាល់ ៤.២) | | (កំណត់សម្គាល់ ៤.២) |
| គណនីពាណិជ្ជត្រូវទទួល | **១.៣៣៥.៣៤១** | **៥.៤៩៧.៥៩៩** | ៤.៥១០.៦៦៦ | ១៨.៣៧៦.៤៥៣ |
| គណនីត្រូវទទួលរក្សាទុក | **១.៨៣០.៤៣២** | **៧.៥៣៥.៨៨៨** | ១.៧៦២.៣៩១ | ៧.១៧៩.៩៨១ |
| | **៣.១៦៥.៧៧៣** | **១៣.០៣៣.៤៨៧** | ៦.២៧៣.០៥៧ | ២៥.៥៥៦.៤៣៤ |

## ១៣. សន្និធិ - សុទ្ធ

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (កំណត់សម្គាល់ ៤.២) | | (កំណត់សម្គាល់ ៤.២) |
| ម៉ាស៊ីនកម្តៅ ខ្យល់ និងសម្ភារគ្រឿងម៉ាស៊ីនត្រជាក់ | **១.២៧៤.១៣២** | **៥.២៤៥.៦០១** | ២.១៦៧.២៥៨ | ៨.៨២៩.៤០៩ |

គិតត្រឹមខែធ្នូ ឆ្នាំ២០២២ សន្និធិសរុបចំនួន ៧.៨៣៤.៦៩០ ដុល្លារអាមេរិក (គិតត្រឹមខែធ្នូ ឆ្នាំ២០២១៖ ៩.៥៦៩.០៤៤ ដុល្លារអាមេរិក) ត្រូវបានរួមបញ្ចូលក្នុងថ្លៃដើមសេវាកម្ម និងទំនិញដែលបានលក់។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ គណៈគ្រប់គ្រងជឿជាក់ថាការចំណាយលើសន្និធិរបស់ក្រុមហ៊ុនលើសពីតម្លៃសុទ្ធដែលអាចសម្រេចបាន អាស្រ័យហេតុនេះ ពុំមានសំវិធានធនត្រូវបានទទួលស្គាល់ទេ។

## ១៤. ទ្រព្យសកម្មរយៈពេលខ្លីផ្សេងៗ

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (កំណត់សម្គាល់ ៤.២) | | (កំណត់សម្គាល់ ៤.២) |
| ការទូទាត់បង់មុនទៅអ្នកផ្គត់ផ្គង់ | ៨១៩.៩៩៧ | ៣.៣៧៥.៩២៨ | ៦៣០.៥០៦ | ២.៥៦៨.៦៨១ |
| គណនីត្រូវទទួលពីនិយោជិត | ២១៥.៨០១ | ៨៨៨.៤៥៣ | ៣១២.២៣៣ | ១.២៧២.០៣៧ |
| ឥណទានអាករលើតម្លៃបន្ថែមយោងទៅមុខ | ២២.៨១៥ | ៩៣.៩២៩ | - | - |
| សម្ភារប្រើប្រាស់បាន | ៣.៦២៤ | ១៤.៩២០ | ៤៥២ | ១.៨៤២ |
| បុរេប្រទានប្រាក់បៀវត្ស | - | - | ៣.៧៧១ | ១៥.៣៦៣ |
| | ១.០៦២.២៣៧ | ៤.៣៧៣.២៣០ | ៩៤៦.៩៦២ | ៣.៨៥៧.៩២៣ |

## ១៥. ទ្រព្យសកម្មកិច្ចសន្យា / បំណុលកិច្ចសន្យា

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (កំណត់សម្គាល់ ៤.២) | | (កំណត់សម្គាល់ ៤.២) |
| ទ្រព្យសកម្មកិច្ចសន្យា | ៤.៣៣៨.៧៧២ | ១៧.៨៦២.៧២៤ | ៣.៧៩១.៣៦៦ | ១៥.៤៤៦.០២៥ |
| បំណុលកិច្ចសន្យា | ២.១០៥.២៥៤ | ៨.៦៦៧.៣៣១ | ១៦១.៨៨០ | ៦៥៩.៤៩៩ |

ទ្រព្យសកម្មកិច្ចសន្យាតំណាងឱ្យ សិទ្ធិរបស់ក្រុមហ៊ុនលើតម្លៃតបស្នងសម្រាប់ការងារដែលបានបញ្ចប់នៃកិច្ចសន្យាសាងសង់ ប៉ុន្តែមិនទាន់បានចេញវិក្កយបត្រនៅកាលបរិច្ឆេទនៃរបាយការណ៍។ ជាធម្មតាវិក្កយបត្រនឹងត្រូវបានចេញក្នុងរយៈពេល ៣០ថ្ងៃ ហើយការទូទាត់ត្រូវបានគេរំពឹងទុកបានទទួលក្នុងរយៈពេល ៦០ ថ្ងៃ។

បំណុលកិច្ចសន្យាជា តម្លៃតបស្នងដែលបានទទួលជាមុនពីអតិថិជនសម្រាប់កិច្ចសន្យាសាងសង់ ដែលប្រាក់ចំណូលត្រូវបានគេទទួលស្គាល់ក្នុងរយៈពេលលើសពេលវេលាកំណត់ក្នុងអំឡុងពេលសាងសង់អចលនទ្រព្យ។ បំណុលកិច្ចសន្យាត្រូវបានគេរំពឹងថា នឹងត្រូវបានទទួលស្គាល់ជាចំណូលនៅពេលបញ្ចប់ការសាងសង់ដែលបានព្រមព្រៀងជាក់លាក់។

ការផ្លាស់ប្តូរសំខាន់ៗលើបំណុលកិច្ចសន្យាក្នុងអំឡុងការិយបរិច្ឆេទមានដូចខាងក្រោម៖

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (កំណត់សម្គាល់ ៤.២) | | (កំណត់សម្គាល់ ៤.២) |
| បំណុលកិច្ចសន្យានៅដើមការិយបរិច្ឆេទដែលបាន ទទួលស្គាល់ជាចំណូល | ៦៤៧.៦៤៤ | ២.៦៦៦.៣៥០ | ៣៩៦.០៩០ | ១.៦១១.២៩៤ |

## ១៦. ដើមទុន

ភាគហ៊ុនដែលបានអនុម័តឱ្យចេញផ្សាយត្រូវបានចែកជា ២ចំណាត់ថ្នាក់របស់ក្រុមហ៊ុនដូចខាងក្រោម៖

| | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|---|---|
| | ចំនួនភាគហ៊ុន | | សមតុល្យ | ចំនួនភាគហ៊ុន | | សមតុល្យ |
| | | ដុល្លារអាមេរិក | ពាន់រៀល | | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (កំណត់សម្គាល់ ២.៣) | | | (កំណត់សម្គាល់ ២.៣) |
| ថ្នាក់ ក មានតម្លៃចារឹក ០.២៥ ដុល្លារអាមេរិកក្នុងមួយភាគហ៊ុន | **១០.០០០.០០០** | **២.៥០០.០០០** | **១០.០០០.០០០** | ១០.០០០.០០០ | ២.៥០០.០០០ | ១០.០០០.០០០ |
| ថ្នាក់ ខ មានតម្លៃចារឹក ០.២៥ ដុល្លារអាមេរិកក្នុងមួយភាគហ៊ុន | **២០.០០០.០០០** | **៥.០០០.០០០** | **២០.០០០.០០០** | ២០.០០០.០០០ | ៥.០០០.០០០ | ២០.០០០.០០០ |
| | **៣០.០០០.០០០** | **៧.៥០០.០០០** | **៣០.០០០.០០០** | ៣០.០០០.០០០ | ៧.៥០០.០០០ | ៣០.០០០.០០០ |

បម្រែបម្រួលដើមទុនដែលបានទូទាត់រួចរាល់មានដូចខាងក្រោម៖

| | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|---|---|
| | ចំនួនភាគហ៊ុន | | សមតុល្យ | ចំនួនភាគហ៊ុន | | សមតុល្យ |
| | | ដុល្លារអាមេរិក | ពាន់រៀល | | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (កំណត់សម្គាល់ ២.៣) | | | (កំណត់សម្គាល់ ២.៣) |
| គិតត្រឹមដើមការិយបរិច្ឆេទ | **១៨.៤៦១.៥៣៨** | **៤.៦១៥.៣៨៥** | **១៨.៧៩៦.៦៨៧** | ១២.០០០.០០០ | ៣.០០០.០០០ | ១២.២២៥.៣០១ |
| ការបន្ថែមដើមទុន | - | - | - | ៦.៤៦១.៥៣៨ | ១.៦១៥.៣៨៥ | ៦.៥៧១.៣៨៦ |
| **គិតត្រឹមចុងការិយបរិច្ឆេទ** | **១៨.៤៦១.៥៣៨** | **៤.៦១៥.៣៨៥** | **១៨.៧៩៦.៦៨៧** | ១៨.៤៦១.៥៣៨ | ៤.៦១៥.៣៨៥ | ១៨.៧៩៦.៦៨៧ |

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងឆ្នាំ២០២១ ព័ត៌មានលម្អិតអំពីការកាន់កាប់ភាគហ៊ុនមានដូចខាងក្រោម៖

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (កំណត់សម្គាល់ ៤.២) | | (កំណត់សម្គាល់ ៤.២) |
| លោក នាង វិធី | **២.១០០.០០០** | **៨.៥៥៦.០០១** | ២.១០០.០០០ | ៨.៥៥៦.០០១ |
| លោកស្រី លឹម មុយលី | **៩០០.០០០** | **៣.៦៦៩.៣០០** | ៩០០.០០០ | ៣.៦៦៩.៣០០ |
| ភាគហ៊ុនិកជាសាធារណៈជន | **១.៦១៥.៣៨៥** | **៦.៥៧១.៣៨៦** | ១.៦១៥.៣៨៥ | ៦.៥៧១.៣៨៦ |
| | **៤.៦១៥.៣៨៥** | **១៨.៧៩៦.៦៨៧** | ៤.៦១៥.៣៨៥ | ១៨.៧៩៦.៦៨៧ |

### ១៦.១ បុព្វលាភដើមទុន

នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២១ ក្រុមហ៊ុនបានចុះបញ្ជីដោយជោគជ័យនៅក្នុងផ្សារមូលបត្រកម្ពុជា ("CSX")។ ចំនួនហ៊ុនថ្មីដែលបានបោះផ្សាយមានចំនួន ៦.៤៦១.៥៣៨ ហ៊ុន ជាមួយតម្លៃចារឹក ១០០០ រៀល (០.២៥ ដុល្លារអាមេរិក) ក្នុងមួយហ៊ុន ក្នុងតម្លៃលក់ចេញ ២.៣៨០ រៀល (០.៥៨ ដុល្លារអាមេរិក) ក្នុងមួយហ៊ុន។ ក្រុមហ៊ុនបានទទួលប្រាក់ពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ ចំនួន ៣.៧៧៣.៥៣៩ ដុល្លារអាមេរិក ដែលបណ្តាលឱ្យមានបុព្វលាភភាគហ៊ុនចំនួន ២.១៥៨.១៥៤ ដុល្លារអាមេរិក (៨.៧៧៩.៣៧០.០០០ រៀល)។

### ១៦.២ ភាគលាភ

នៅថ្ងៃទី២ ខែឧសភា ឆ្នាំ២០២២ ក្រុមប្រឹក្សាភិបាល បានអនុម័តភាគលាភជាសាច់ប្រាក់ចំនួន ២០៨.១២៨ ដុល្លារអាមេរិក (៨៤៦.៤៦១.៤៧៨ រៀល) ដើម្បីចែកចាយដល់ភាគហ៊ុនិកថ្នាក់ "ក" ក្នុងតម្លៃ ១៣១ រៀលក្នុងមួយហ៊ុន។ ការទូទាត់ភាគលាភជាសាច់ប្រាក់ត្រូវបានធ្វើឡើងនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២ សម្រាប់កាលបរិច្ឆេទកត់ត្រារបស់ភាគហ៊ុនិកគិតត្រឹមថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២។

## ១៧. ប្រាក់កម្ចី

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (កំណត់សម្គាល់ ៤.២) | | (កំណត់សម្គាល់ ៤.២) |
| ប្រាក់កម្ចីរយៈពេលវែង | **៥៩៩.៨៦៣** | **២.៤៦៩.៦៣៦** | ៨១១.៣២០ | ៣.៣០៥.៣១៨ |
| ប្រាក់កម្ចីរយៈពេលខ្លី | **៨៩៣.៧៨៣** | **៣.៦៧៩.៧០៥** | ២.៥១៩.០១១ | ១០.២៦២.៤៥១ |
| | **១.៤៩៣.៦៤៦** | **៦.១៤៩.៣៤១** | ៣.៣៣០.៣៣១ | ១៣.៥៦៧.៧៦៩ |

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (កំណត់សម្គាល់ ៤.២) | | (កំណត់សម្គាល់ ៤.២) |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា | **៣.៣៣០.៣៣១** | **១៣.៥៦៧.៧៦៩** | ២.១៤៩.០៣១ | ៨.៦៩២.៨៣០ |
| បន្ថែម | **៣.៨៥១.២៣៤** | **១៥.៧៣៩.៩៩៣** | ៨.៤៨៦.៨២១ | ៣៤.៥២៤.៣៨៨ |
| ការទូទាត់សង | **(៥.៦៨៧.៩១៩)** | **(២៣.២៤៦.៥២៥)** | (៧.៣០៥.៥២១) | (២៩.៧១៨.៨៥៩) |
| បន្ទុកការប្រាក់ | **៣៥២.៧១១** | **១.៤៤១.៥២៩** | ៤៩៩.៧៦០ | ២.០៣៣.០២៣ |
| ការប្រាក់ដែលបានបង់ | **(៣៥២.៧១១)** | **(១.៤៤១.៥២៩)** | (៤៩៩.៧៦០) | (២.០៣៣.០២៣) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | **-** | **៨៨.១០៤** | - | ៦៩.៤១០ |
| **សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ** | **១.៤៩៣.៦៤៦** | **៦.១៤៩.៣៤១** | ៣.៣៣០.៣៣១ | ១៣.៥៦៧.៧៦៩ |

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (កំណត់សម្គាល់ ៤.២) | | (កំណត់សម្គាល់ ៤.២) |
| **តាមកាលបរិច្ឆេទកំណត់៖** | | | | |
| ក្នុងអំឡុងពេល១ឆ្នាំ | **៨៩៣.៧៨៣** | **៣.៦៧៩.៧០៥** | ២.៥១៩.០១១ | ១០.២៦២.៤៥១ |
| ពី២ ទៅ ៥ ឆ្នាំ | **៥៩៩.៨៦៣** | **២.៤៦៩.៦៣៦** | ៨១១.៣២០ | ៣.៣០៥.៣១៨ |
| | **១.៤៩៣.៦៤៦** | **៦.១៤៩.៣៤១** | ៣.៣៣០.៣៣១ | ១៣.៥៦៧.៧៦៩ |
| **តាមការធានា៖** | | | | |
| កម្ចីដែលមានទ្រព្យបញ្ចាំ | **១.៤៩៣.៦៤៦** | **៦.១៤៩.៣៤១** | ២.៧៥៤.៤៥០ | ១១.២២១.៦២៩ |
| កម្ចីដែលគ្មានទ្រព្យបញ្ចាំ | **-** | **-** | ៥៧៥.៨៨១ | ២.៣៤៦.១៤០ |
| | **១.៤៩៣.៦៤៦** | **៦.១៤៩.៣៤១** | ៣.៣៣០.៣៣១ | ១៣.៥៦៧.៧៦៩ |
| **តាមប្រភេទរូបិយប័ណ្ណ៖** | | | | |
| ដុល្លារអាមេរិក | **១.៤៩៣.៦៤៦** | **៦.១៤៩.៣៤១** | ៣.៣៣០.៣៣១ | ១៣.៥៦៧.៧៦៩ |
| ខ្មែររៀល | **-** | **-** | - | - |
| | **១.៤៩៣.៦៤៦** | **៦.១៤៩.៣៤១** | ៣.៣៣០.៣៣១ | ១៣.៥៦៧.៧៦៩ |

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| **តាមទំនាក់ទំនង៖** | | | | |
| មិនមែនជាភាគីពាក់ព័ន្ធ | **១.៤៩៣.៦៤៦** | **៦.១៤៩.៣៤១** | ៣.៣៣០.៣៣១ | ១៣.៥៦៧.៧៦៩ |
| ភាគីពាក់ព័ន្ធ | - | - | - | - |
| | **១.៤៩៣.៦៤៦** | **៦.១៤៩.៣៤១** | ៣.៣៣០.៣៣១ | ១៣.៥៦៧.៧៦៩ |
| **តាមអត្រាការប្រាក់ (ក្នុង១ឆ្នាំ)** | | | | |
| លក្ខខណ្ឌឥណទាន | | ៧,៥% to ៨ % | | ៧% to ៩ % |

លក្ខខណ្ឌឥណទានហ្វាស៊ីលីធី ជាមួយធនាគារវឌ្ឍនៈអាស៊ីចំកាត់ មានអត្រាការប្រាក់ ៧,៥%ក្នុងមួយឆ្នាំ និងត្រូវបានធានាដោយការបញ្ចាំដីឡូត៍របស់ក្រុមហ៊ុនដែលបានកត់ត្រាជាដីកម្មសិទ្ធិក្រោមគណនីទ្រព្យសម្បត្តិ និងបរិក្ខារ ដែលមានតម្លៃ ២.១៦៧.៦២០ ដុល្លារអាមេរិក។ កិច្ចព្រមព្រៀង ត្រូវបានធ្វើឡើងនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៩ ដែលមានសមតុល្យកំណត់ចំនួន ១.៦៩០.០០០ ដុល្លារអាមេរិក និងត្រូវបានធ្វើឡើងវិញថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២ ដែលមានសមតុល្យកំណត់ចំនួន ១.១០០.០០០ ដុល្លារអាមេរិក និងត្រូវទូទាត់ក្នុងរយៈពេល ៤៤ ខែគិតចាប់ពីកាលបរិច្ឆេទនៃកិច្ចព្រមព្រៀង។

ឥណទានមានកាលកំណត់ ជាមួយធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ("J.Trust") មានអត្រាការប្រាក់ ៨%ក្នុងមួយឆ្នាំ ត្រូវបានធានាដោយទ្រព្យសម្បត្តិរបស់ម្ចាស់ភាគហ៊ុន និងគណៈគ្រប់គ្រងសំខាន់ៗ។ កិច្ចព្រមព្រៀងត្រូវបានធ្វើឡើងវិញថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលមានសមតុល្យកំណត់ចំនួន ៦០០.០០០ ដុល្លារអាមេរិក និងមានកាលបរិច្ឆេទកំណត់នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២។ ក្នុងអំឡុងឆ្នាំបច្ចុប្បន្ននេះឥណទានហិរញ្ញប្បទានពាណិជ្ជ ត្រូវបានរៀបចំឡើងវិញសម្រាប់ឆ្នាំថ្មីដោយស្វ័យប្រវត្តិ។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ សមតុល្យឥណទានហ្វាស៊ីលីធីដែលនៅសល់ជាមួយធនាគារ ABA មានសមតុល្យចំនួន ៨៩៣.៦៤៦ ដុល្លារអាមេរិក និង J Trust មានសមតុល្យចំនួន ៦០០.០០០ ដុល្លារអាមេរិក។

## ១៨. ឥណទានវិបារូបន៍

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| ធនាគារវឌ្ឍនៈអាស៊ីចំកាត់ | **១.៧២៦.៩៧៣** | **៧.១០៩.៩៥០** | ១.២១៨.៨៥៤ | ៤.៩៦៥.៦១១ |
| ធនាគារជីប ម៉ុង ខមមើសល បែ៊ង ម.ក | **៣៥៣.៨៥៨** | **១.៤៥៦.៨៣៥** | ៣៨៣.៧៩៨ | ១.៥៦៣.៥៩៣ |
| ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ | **៣៣០.១៥២** | **១.៣៥៩.២៣៥** | ២៦៨.៤៦០ | ១.០៩៣.៧០៦ |
| | **២.៤១០.៩៨៤** | **៩.៩២៦.០២០** | ១.៨៧១.១១២ | ៧.៦២២.៩១០ |

ឥណទានវិបារូបន៍ជាមួយធនាគារវឌ្ឍនៈអាស៊ីចំកាត់ មានអត្រាការប្រាក់ ៧.៥%ក្នុងមួយឆ្នាំ និងត្រូវបានធានាដោយដាក់ទ្រព្យសម្បត្តិរបស់ភាគហ៊ុនិក និងគណៈគ្រប់គ្រងសំខាន់ៗ។ កិច្ចព្រមព្រៀងត្រូវបានធ្វើឡើងវិញនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២ ដែលមានសមតុល្យកំណត់ចំនួន ១.៨០០.០០០ ដុល្លារអាមេរិក និងត្រូវទូទាត់ក្នុងរយៈពេល ១២ខែគិតចាប់ពីកាលបរិច្ឆេទនៃកិច្ចព្រមព្រៀង។

ឥណទានវិបារូបន៍ជាមួយធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ មានអត្រាការប្រាក់ ៨%ក្នុងមួយឆ្នាំ ដែលត្រូវបានធានាដោយទ្រព្យសម្បត្តិរបស់ភាគហ៊ុនិក និងគណៈគ្រប់គ្រងសំខាន់ៗ។ កិច្ចព្រមព្រៀងត្រូវបានធ្វើឡើងវិញថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលមានសមតុល្យកំណត់ចំនួន ៦០០.០០០ ដុល្លារអាមេរិក និងមានកាលបរិច្ឆេទកំណត់នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២។ ក្នុងអំឡុងឆ្នាំបច្ចុប្បន្ននេះឥណទានវិបារូបន៍ ត្រូវបានរៀបចំឡើងវិញសម្រាប់ឆ្នាំថ្មីដោយស្វ័យប្រវត្តិ។

ឥណទានវិបារូបន៍ជាមួយធនាគារជីបម៉ុង មានអត្រាការប្រាក់ ៩%ក្នុងមួយឆ្នាំ និងមិនមានទ្រព្យធានាឡើយ។ កិច្ចព្រមព្រៀងត្រូវបានធ្វើឡើងវិញនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២២ ដែលមានសមតុល្យកំណត់ចំនួន ៤០០.០០០ ដុល្លារអាមេរិក និងមានកាលបរិច្ឆេទផុតកំណត់នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៣។ ក្នុងអំឡុងឆ្នាំបច្ចុប្បន្ននេះ ឥណទានវិបារូបន៍ ត្រូវបានរៀបចំឡើងវិញសម្រាប់ឆ្នាំថ្មីដោយស្វ័យប្រវត្តិ។

## ១៩. គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| គណនីត្រូវសង | **៨៤២.១១៥** | **៣.៤៦៦.៩៨៧** | ៦៦៨.៦៧៧ | ២.៧២៤.១៩០ |
| ចំណាយរក្សាទុកដែលត្រូវបង់ | **១៣៦.៨៧៧** | **៥៦៣.៥២៣** | ៣១.៦២៥ | ១២៨.៨៤០ |
| ពន្ធផ្សេងៗត្រូវបង់ | **៥៦.៧១៨** | **២៣៣.៥០៩** | ២៧៥.៩២៣ | ១.១២៤.១១១ |
| ចំណាយបង្គរ | **៤១.៦៤១** | **១៧១.៤៣៦** | ៦៦៦.០៦៨ | ២.៧១៣.៥៦១ |
| ប្រាក់បៀវត្សត្រូវបង់ | - | - | ១៨១.០៨២ | ៧៣៧.៧២៨ |
| បំណុលរយៈពេលខ្លីផ្សេងៗ | **២.៨៩៣** | **១១.៩១០** | ៧.៨៤០ | ៣១.៩៤០ |
| | **១.០៨០.២៤៤** | **៤.៤៤៧.៣៦៥** | ១.៨៣១.២១៥ | ៧.៤៦០.៣៧០ |

ការរក្សាទុកដែលត្រូវសង ទាក់ទងទៅនឹងសមតុល្យដែលក្រុមហ៊ុនកាន់កាប់ និងជំពាក់ទៅអ្នកម៉ៅការបន្តរបស់ខ្លួន។ ក្រុមហ៊ុននឹងបញ្ចេញ ៥០% នៃការរក្សាទុកដែលត្រូវសងនៅពេលដែលកិច្ចសន្យាត្រូវបានបញ្ចប់ និង ៥០% ទៀតរហូតដល់ចុងបញ្ចប់នៃរយៈពេលធានាដែលជាធម្មតាមានចន្លោះចាប់ពី៣០ ទៅ១៨០ ថ្ងៃ។

## ២០. ចំណូល

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| សេវាកម្មសាងសង់ និងថែទាំ | **១៤.២៥៩.៩៨៥** | **៥៨.២៨០.៥៥៩** | ១៧.៥៦៦.៧៩០ | ៧១.៤៦១.៧០២ |
| ទំនិញដែលបានលក់ | **៥៦.៧៩៨** | **២៣២.១៣៣** | ៣៩៧.៤៣៨ | ១.៦១៦.៧៧៨ |
| | **១៤.៣១៦.៧៨៣** | **៥៨.៥១២.៦៩២** | ១៧.៩៦៤.២២៨ | ៧៣.០៧៨.៤៨០ |

## ២១. ថ្លៃដើមទំនិញ និងសេវាកម្មដែលបានលក់

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| ថ្លៃដើមសេវាកម្មសាងសង់ និងសេវាកម្មថែទាំ | ១៣.៥៥២.៤៥២ | ៥៥.៣៨៨.៨៧១ | ១៥.០២៦.០០៦ | ៦១.១២៥.៧៩៣ |
| ថ្លៃដើមទំនិញដែលបានលក់ | ៥១.៦០៥ | ២១០.៩១០ | ៣៨៣.៤០៤ | ១.៥៥៩.៦៨៧ |
| | ១៣.៦០៤.០៥៧ | ៥៥.៥៩៩.៧៨១ | ១៥.៤០៩.៤១០ | ៦២.៦៨៥.៤៨០ |

## ២២. ចំណាយប្រតិបត្តិការ

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| ចំណាយបុគ្គលិក | ៦៥២.០២៣ | ២.៦៦៤.៨១៨ | ៥០៦.២៧៦ | ២.០៥៩.៥៣១ |
| ពន្ធផ្សេងៗ | ២២២.៩១០ | ៩១១.០៣៣ | ១៧៧.២៧១ | ៧២១.១៣៨ |
| សេវាធនាគារ | ១២០.០៣៥ | ៤៩០.៥៨៣ | ១១៣.៧៧០ | ៤៦២.៨១៦ |
| សេវាវិជ្ជាជីវៈ | ១០៨.៣៦៤ | ៤៤២.៨៨៤ | ២៥៨.៣៧៧ | ១.០៥១.០៧៨ |
| សម្ភារការិយាល័យ និងសម្ភារផ្គត់ផ្គង់ការិយាល័យ | ៨៧.៤៦៧ | ៣៥៧.៤៧៨ | ១១៥.៦៥០ | ៤៧០.៤៦៤ |
| រំលស់ | ៨២.២៩០ | ៣៣៦.៣១៩ | ៧៣.៤៣៧ | ២៩៨.៧៤២ |
| ធានារ៉ាប់រង | ៦៩.៨៧០ | ២៨៥.៥៥៩ | ៦៥.២១០ | ២៦៥.២៧៤ |
| ការជួល | ៥២.៥៩១ | ២១៤.៩៣៩ | ១៧.២៣៨ | ៧០.១២៤ |
| ទឹកភ្លើង | ៣៣.៩៤៧ | ១៣៨.៧៤១ | ៧០.៥៩៦ | ២៨៧.១៨៥ |
| ជួសជុល និងថែទាំ | ៣២.២៤៣ | ១៣១.៧៧៧ | ៤៦.៤៦៥ | ១៨៩.០២០ |
| ទំនាក់ទំនង | ៧.៧៣៨ | ៣១.៦២៥ | ៨.៦១៥ | ៣៥.០៤៦ |
| ការកម្សាន្ត | ៤.៧៦៥ | ១៩.៤៧៥ | ៧.១៥៣ | ២៩.០៩៨ |
| ការកែតម្រូវលើសន្និធិ | - | - | ៥.៦៨៦ | ២៣.១៣១ |
| ផ្សេងៗ | ៨៣.៣៤៤ | ៣៤០.៦២៧ | ១៧.៨៣១ | ៧២.៥៣៦ |
| | ១.៥៥៧.៥៨៧ | ៦.៣៦៥.៨៥៨ | ១.៤៨៣.៥៧៥ | ៦.០៣៥.១៨៣ |

## ២៣. ចំណូលផ្សេងៗ - សុទ្ធ

| | សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| ចំណូលការប្រាក់ | ៣.៦០២ | ១៤.៧២១ | ៧.៣២០ | ២៩.៧៧៨ |
| ចំណេញពីការប្តូររូបិយប័ណ្ណបរទេស | ៤.១៥១ | ១៦.៩៦៥ | ៣.៣៧៣ | ១៣.៧២១ |
| ខាតពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | (៤៣៨) | (១.៧៩១) | (១.៨២០) | (៧.៤០៤) |
| ចំណូលផ្សេងៗ | ២ | ៩ | ១៩.១៩០ | ៧៨.០៦៥ |
| | ៧.៣១៧ | ២៩.៩០៥ | ២៨.០៦៣ | ១១៤.១៦០ |

## ២៤. ចំណាយហិរញ្ញវត្ថុ

| | សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| ការប្រាក់លើប្រាក់កម្ចី | ៣៥២.៧១១ | ១.៤៤១.៥៣០ | ៤៩៩.៧៦០ | ២.០៣៣.០២៤ |
| ការប្រាក់លើបំណុលភតិសន្យា | ១.៨៩១ | ៧.៧២៨ | ៧.១១០ | ២៨.៩២៣ |
| | ៣៥៤.៦០២ | ១.៤៤៩.២៥៨ | ៥០៦.៨៧០ | ២.០៦១.៩៤៧ |

## ២៥. ពន្ធលើប្រាក់ចំណូល

អនុលោមតាមច្បាប់ពន្ធរបស់កម្ពុជា ក្រុមហ៊ុនមានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណូលដោយកំណត់យកចំនួនមួយណាខ្ពស់ជាងរវាងពន្ធលើប្រាក់ចំណូល ("TOI") តាមអត្រា ២០% ឬពន្ធអប្បបរមា ("MT") តាមអត្រា ១% នៃចំណូលជាប់ពន្ធប្រចាំឆ្នាំរួមបញ្ចូលពន្ធទាំងអស់ លើកលែងតែអាករលើតម្លៃបន្ថែម។ ពន្ធអប្បបរមា គឺត្រូវតែបង់ដោយមិនគិតពីស្ថានភាពចំណេញ ឬខាតរបស់អ្នកជាប់ពន្ធឡើយ។

នៅខែឧសភា ឆ្នាំ២០២២ ក្រុមហ៊ុនបានទទួលលិខិតអនុម័តពីអគ្គនាយកដ្ឋានពន្ធដារ ("GDT") សម្រាប់ការលើកទឹកចិត្តផ្នែកពន្ធដែលបានផ្តល់ឱ្យក្រុមហ៊ុនដែលបានចុះបញ្ជីភាគហ៊ុនរបស់ពួកគេ ឬចេញមូលបត្របំណុលនៅលើ ផ្សារមូលបត្រកម្ពុជា ។ ក្រុមហ៊ុនដែលបានចុះបញ្ជី និង ទទួលបានការកាត់បន្ថយ៥០%ទៅលើពន្ធលើប្រាក់ចំណូល សម្រាប់រយៈពេល៣ឆ្នាំគិតចាប់ពីថ្ងៃ បោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង។

ក្រុមហ៊ុនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការលើកលែង ពន្ធអប្បបរមាដោយសារ ក្រុមហ៊ុនជឿជាក់ថាខ្លួនបានរក្សាកំណត់ត្រាគណនេយ្យត្រឹមត្រូវ។

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| ចំណាយពន្ធលើប្រាក់ចំណូលបច្ចុប្បន្ន | - | - | ១៧៩.៧៥៤ | ៧៣១.២៣៩ |

## ២៥.១. ចំណាយពន្ធលើប្រាក់ចំណូល

ការផ្ទៀងផ្ទាត់រវាងគណនី (ខាត)/ចំណេញតាមគណនេយ្យមុនបង់ពន្ធលើប្រាក់ចំណូល និងពន្ធលើប្រាក់ចំណូលដែលបានប៉ាន់ស្មានទុកសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងឆ្នាំ២០២១ ត្រូវបានបង្ហាញដូចខាងក្រោម៖

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| (ខាត)/ចំណេញតាមគណនេយ្យមុនបង់ លើប្រាក់ចំណូល | (១.១៩២.១៤៦) | (៤.៨៧២.៣០០) | ៥៩២.៤៣៦ | ២.៤១០.០៣០ |
| **និយ័តកម្ម៖** | | | | |
| ភាពខុសគ្នាជាអចិន្ត្រៃយ៍ | ២១២.០៩០ | ៨៦៦.៨១៤ | (៣៥.៩៣៥) | (១៤៦.១៨៤) |
| ពន្ធអនុញ្ញាតដែលបានប្រើប្រាស់ | - | - | (៥៥៦.៥០១) | (២.២៦៣.៨៤៦) |
| ខាតជាប់ពន្ធដែលបានប៉ាន់ស្មាន | (៩៨០.០៥៦) | (៤.០០៥.៤៨៦) | - | - |
| ពន្ធលើប្រាក់ចំណូលដែលអាចអនុវត្តក្នុងអត្រា ២០% (ក) | - | - | - | - |
| អត្រាពន្ធអប្បបរមាក្នុងអត្រា ១%នៃចំណូល (ខ) | - | - | ១៧៩.៧៥៤ | ៧៣១.២៣៩ |
| ចំណាយពន្ធលើប្រាក់ចំណូលដែលបានប៉ាន់ស្មាន (តម្លៃមួយណាដែលខ្ពស់ជាងរវាង ក ឬ ខ) | - | - | ១៧៩.៧៥៤ | ៧៣១.២៣៩ |

ការប្រកាសពន្ធរបស់ក្រុមហ៊ុនត្រូវបានត្រួតពិនិត្យដោយអាជ្ញាធរពន្ធដារ។ ដោយសារតែការអនុវត្តច្បាប់ពន្ធដារ និងបទប្បញ្ញត្តិសម្រាប់ប្រតិបត្តិការជាច្រើនប្រភេទ គឺងាយនឹងមានការបកស្រាយផ្សេងៗគ្នា សមតុល្យដែលបានរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុអាចផ្លាស់ប្តូរនៅពេលក្រោយតាមការសម្រេចចុងក្រោយដោយអាជ្ញាធរពន្ធដារ។

## ២៥.២. ពន្ធយថាហេតុ

ប្រព័ន្ធពន្ធដារនៅព្រះរាជាណាចក្រកម្ពុជា ត្រូវបានបែងចែកជាច្រើនប្រភេទ និងបទប្បញ្ញត្តិមានការផ្លាស់ប្តូរញឹកញាប់ដែលជាធម្មតាពឹងផ្អែកលើការបកស្រាយ។ ជាញឹកញាប់ ការបកស្រាយខុសៗគ្នាជាច្រើន កើតមានឡើងក្នុងចំណោមអាជ្ញាធរពន្ធដារ និងយុត្តាធិការ។ ពន្ធដារ គឺជាកម្មវត្ថុនៃការពិនិត្យឡើងវិញ និងការសង្កេតដោយភ្នាក់ងារពន្ធដារផ្សេងៗជាច្រើន ដែលមានសមត្ថកិច្ចក្នុងការដាក់ពិន័យធ្ងន់ធ្ងរ និងពិន័យជាការប្រាក់។

កត្តាទាំងនេះហើយដែលអាចធ្វើឱ្យមានហានិភ័យពន្ធដារនៅក្នុងព្រះរាជាណាចក្រកម្ពុជាខ្លាំងជាងប្រទេសដទៃទៀត។ គណៈគ្រប់គ្រងជឿជាក់ថាខ្លួនបានបង់បំណុលពន្ធគ្រប់គ្រាន់ដោយផ្អែកលើការបកស្រាយបទប្បញ្ញត្តិពន្ធបច្ចុប្បន្ន។ ទោះបីជាយ៉ាងណាក៏ដោយ អាជ្ញាធរជាប់ពាក់ព័ន្ធអាចនឹងមានបំណកស្រាយខុសៗគ្នា ហើយផលប៉ះពាល់អាចមានលក្ខណៈជាសារវន្ត។

### ២៥.៣. បំណុលពន្ធលើប្រាក់ចំណូល

| | **សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៤.២)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| នាដើមគ្រា | **៣៤.៧៧៦** | **១៤១.៦៧៧** | ២៧.៩៦៥ | ១១៣.១១៨ |
| កត់ត្រាក្នុងអំឡុងការិយបរិច្ឆេទ | **-** | **-** | ១៧៩.៧៥៤ | ៧៣១.២៣៩ |
| ការកត់ត្រាបញ្ច្រាសដោយសារសំវិធានធនលើស | **៥៣.៩០០** | **២២០.២៩០** | | |
| ពន្ធលើប្រាក់ចំណូលដែលបានបង់ | **(៧៧.៤២២)** | **(៣១៦.៤២៤)** | (១៧២.៩៤៣) | (៧០៣.៥៣២) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | **-** | **៧៩១** | - | ៨៥២ |
| នាចុងគ្រា | **១១.២៥៤** | **៤៦.៣៣៣** | ៣៤.៧៧៦ | ១៤១.៦៧៧ |

## ២៦. សមតុល្យ និងប្រតិបត្តិការរបស់ភាគីពាក់ព័ន្ធ

សមតុល្យខាងក្រោម គឺជាសមតុល្យដែលនៅជំពាក់ភាគីពាក់ព័ន្ធៈ

| **ភាគពាក់ព័ន្ធ** | **ទំនាក់ទំនង** | **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|---|
| | | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៤.២)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| សមតុល្យដែលភាគហ៊ុនិកជំពាក់ | | | | | |
| លោក នាង វិធី | ភាគហ៊ុនិក | **១៣៦.២៧០** | **៥៦១.០២៤** | ១៣៤.៤២១ | ៥៤៧.៦៣១ |

សមតុល្យដែលភាគហ៊ុនិកជំពាក់ គឺមិនមានទ្រព្យធានា គ្មានការប្រាក់ និងមានការទូទាត់សងតាមតម្រូវការ។

ក្នុងអំឡុងការិយបរិច្ឆេទ ប្រតិបត្តិការដែលទាក់ទងជាមួយភាគហ៊ុនិកត្រូវបានកត់ត្រាដូចខាងក្រោមៈ

| | **សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៤.២)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| **ប្រតិបត្តិការ** | | | | |
| លោក នាង វិធី | | | | |
| ការទូទាត់ជំនួសឲ្យភាគហ៊ុនិក | **១០០.០០០** | **៤០៨.៧០០** | ៧៤៧.៨៧៩ | ៣.០៤២.៣៧២ |
| ការទូទាត់សងពីភាគហ៊ុនិក | **(៩៨.១៥១)** | **(៤០១.១៤៣)** | (៧០៥.៨៧៩) | (២.៨៧១.៥១៦) |
| ការទូទាត់ជំនួសឲ្យក្រុមហ៊ុន | **-** | **-** | (៣៣.៥៤៨) | (១៣៦.៤៧៣) |
| ការទូទាត់សងទៅភាគហ៊ុនិក | **-** | **-** | ១៣១.៦១១ | ៥៣៥.៣៩៤ |

## ២៧. ប្រតិបត្តិការជាមួយនឹងគណៈគ្រប់គ្រងសំខាន់ៗ

គណៈគ្រប់គ្រងសំខាន់ៗ ត្រូវបានកំណត់ថាជាបុគ្គលទាំងឡាយដែលមានសិទ្ធអំណាច និងមានទំនួលខុសត្រូវក្នុងការធ្វើផែនការ ដឹកនាំ និងគ្រប់គ្រងសកម្មភាព អាជីវកម្មរបស់ក្រុមហ៊ុនមិនថាដោយផ្ទាល់ ឬដោយប្រយោល។ គណៈគ្រប់គ្រងសំខាន់ៗរួមបញ្ចូលទាំងប្រធានក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន។

| | **សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៤.២)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| ប្រាក់បៀវត្ស និងអត្ថប្រយោជន៍ | **១៨៥.០៦៤** | **៧៥៦.៣៥៧** | ១៧១.១៥០ | ៦៩៦.២៣៨ |

## ២៨. កិច្ចសន្យា

នាកាលបរិច្ឆេទនៃរបាយការណ៍ ក្រុមហ៊ុនមានកិច្ចសន្យាភតិសន្យា ក្រោមលក្ខខណ្ឌការសន្យាដែលមិនអាចលុបចោលបានសម្រាប់ការជួលអគារអន្តេវាសិកដ្ឋានសម្រាប់បុគ្គលិករបស់ខ្លួន ក្រោមកិច្ចព្រមព្រៀងភតិសន្យាប្រតិបត្តិការ។

ព័ត៌មានលម្អិតនៃការទូទាត់ភតិសន្យាអប្បបរមានាពេលអនាគតដែលទាក់ទងនឹងការជួលអន្តេវាសិកដ្ឋានត្រូវបានសង្ខេបដូចខាងក្រោម៖

| | **សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៤.២)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| ក្នុងអំឡុងពេលមួយឆ្នាំ | **២២.០០០** | **៨៩.៩១៤** | ១១.៨៨០ | ៤៨.៣២៨ |

## ២៩. (ខាត)/ចំណេញក្នុងមួយហ៊ុន

(ខាត)/ចំណេញមូលដ្ឋានក្នុងមួយសន្លឹកហ៊ុន គឺត្រូវបានគណនាដោយការបែងចែកប្រាក់(ខាត)/ចំណេញឱ្យទៅអ្នកកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុន តាមចំនួនមធ្យមនៃសន្លឹកហ៊ុនធម្មតាដែលបានបោះផ្សាយក្នុងអំឡុងការិយបរិច្ឆេទជាបន្តបន្ទាប់ ដូចដែលបានបង្ហាញដូចខាងក្រោម៖

| | **សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៤.២)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| (ខាត)/ចំណេញដែលបែងចែកទៅឱ្យម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុន | **(១.១៩២.១៤៦)** | **(៤.៥២៤.៩៣៧)** | **៤១២.៦៨២** | ១.៨៤៥.១០៩ |
| ចំនួនភាគហ៊ុនមធ្យម | | **១៨.៤៦១.៥៣៨** | | ១៥.១៥៣.៨៤៦ |
| (ខាត)/ចំណេញមូលដ្ឋានក្នុងមួយសន្លឹកហ៊ុន | (០,០៦) | (០,២៥) | ០,០៣ | ០,១២ |
| (ខាត)/ចំណេញថយចុះក្នុងមួយសន្លឹកហ៊ុន | (០,០៦) | (០,២៥) | ០,០៣ | ០,១២ |

## ៣០. ការធ្វើចំណាត់ថ្នាក់នៅលើទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (កំណត់សម្គាល់ ៤.២) | | (កំណត់សម្គាល់ ៤.២) |
| **បំណុលហិរញ្ញវត្ថុបានវាស់វែងតាមថ្លៃដើមបានរំលស់** | | | | |
| ទ្រព្យសកម្មរយៈពេលវែងផ្សេងៗ | **២០.១០០** | **៨២.៧៥២** | ២០.០៥០ | ៨១.៦៨៤ |
| ប្រាក់តម្កល់ធានា | **៥៩០.០៨០** | **២.៤២៩.៣៥៩** | ៦៥.០០០ | ២៦៤.៨១០ |
| សមតុល្យដែលភាគហ៊ុនិកជំពាក់ | **១៣៦.២៧០** | **៥៦១.០២៤** | ១៣៤.៤២១ | ៥៤៧.៦៣១ |
| គណនីពាណិជ្ជដែលត្រូវទទួល | **៣.១៦៥.៧៧៣** | **១៣.០៣៣.៤៨៧** | ៦.២៧៣.០៥៧ | ២៥.៥៥៦.៤៣៤ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | **២១.៤៦៤** | **៨៨.៣៦៧** | ២២៥.១១៩ | ៩១៧.១៣៥ |
| **ទ្រព្យសកម្មហិរញ្ញវត្ថុសរុប** | **៣.៩៣៣.៦៨៧** | **១៦.១៩៤.៩៨៩** | ៦.៧១៧.៦៤៧ | ២៧.៣៦៧.៦៩៤ |

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (កំណត់សម្គាល់ ៤.២) | | (កំណត់សម្គាល់ ៤.២) |
| **បំណុលហិរញ្ញវត្ថុបានវាស់វែងតាមថ្លៃដើមបានរំលស់** | | | | |
| ប្រាក់កម្ចី | **១.៤៩៣.៦៤៦** | **៦.១៤៩.៣៤១** | ៣.៣៣០.៣៣១ | ១៣.៥៦៧.៧៦៩ |
| បំណុលភតិសន្យា | **-** | **-** | ៤៨.៥០៩ | ១៩៧.៦២៦ |
| ឥណទានវិបារូបន៍ | **២.៤១០.៩៨៤** | **៩.៩២៦.០២០** | ១.៨៧១.១១២ | ៧.៦២២.៩១០ |
| គណនីពានីជ្ជ និងគណនីត្រូវសងផ្សេងៗ* | **១.០២៣.៥២៦** | **៤.២១៣.៨៥៦** | ១.៥៥៥.២៩២ | ៦.៣៣៦.២៥៩ |
| សមតុល្យដែលជំពាក់ភាគហ៊ុនិក | **-** | **-** | - | - |
| **បំណុលហិរញ្ញវត្ថុសរុប** | **៤.៩២៨.១៥៦** | **២០.២៨៩.២១៧** | ៦.៨០៥.២៤៤ | ២៧.៧២៤.៥៦៤ |

** មិនរាប់បញ្ចូលពន្ធត្រូវបង់ផ្សេងៗ និងបុរេប្រទានពីអតិថិជន*

## ៣១. ព័ត៌មាននៃតម្លៃសមស្រប

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលបានវាស់វែងតាមតម្លៃសមស្របនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុត្រូវបានចាត់ជាបីកម្រិតក្រុមទៅតាមឋានានុក្រមនៃតម្លៃសមស្រប។ កម្រិតទាំងបី ត្រូវបានកំណត់ដោយផ្អែកលើការអង្កេតនៃធាតុចូលសំខាន់ៗក្នុងការវាស់វែងដូចខាងក្រោម៖

- កម្រិតទី១៖ តម្លៃដែលបានដកស្រង់ (មិនអាចកែប្រែបាន) នៅក្នុងទីផ្សារសកម្មរបស់ទ្រព្យសកម្ម និងបំណុលដូចគ្នា
- កម្រិតទី២៖ ធាតុចូលក្រៅពីតម្លៃដែលបានដកស្រង់ ដោយរួមបញ្ចូលនៅក្នុងកម្រិតទី១ ដែលអាចតាមដានបានទៅលើទ្រព្យសកម្ម ឬបំណុល មិនថាដោយផ្ទាល់ ឬដោយប្រយោល
- កម្រិតទី៣៖ ធាតុចូលមិនអាចតាមដានបានរបស់ទ្រព្យសកម្ម ឬបំណុល។

<u>វិធីសាស្ត្រ និងការសន្មតដែលបានប្រើប្រាស់ដើម្បីធ្វើការប៉ាន់ស្មានតម្លៃសមស្រប</u>
ឧបករណ៍ហិរញ្ញវត្ថុដែលមិនត្រូវបានយោងតាមតម្លៃសមស្រប ហើយសមតុល្យយោងនោះ ត្រូវបានសន្មតឱ្យប្រហាក់ប្រហែលនឹងតម្លៃសមស្របដ៏សមហេតុផល។

សមតុល្យយោងនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ ដូចជាគណនីពាណិជ្ជ និងគណនីត្រូវទទួលផ្សេងៗ ទ្រព្យសកម្មផ្សេងទៀត សមតុល្យដែលជំពាក់ភាគីពាក់ព័ន្ធ និងសមតុល្យដែលភាគីពាក់ព័ន្ធជំពាក់ និងគណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ ត្រូវបានសន្មតឱ្យប្រហាក់ប្រហែលនឹងតម្លៃសមស្របដ៏សមហេតុផល ដោយសារលក្ខណៈរយៈពេលខ្លីរបស់គណនីទាំងនេះ។

គិតត្រឹមចុងការិយបរិច្ឆេទ គណៈគ្រប់គ្រងពិចារណាថាតម្លៃសមស្របនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសន្មតឱ្យប្រហាក់ប្រហែលនឹងសមតុល្យយោងរបស់វា។

## ៣២. គោលនយោបាយ និងគោលបំណងនៃការគ្រប់គ្រងហានិភ័យ

*ហានិភ័យហិរញ្ញវត្ថុ*

ក្រុមហ៊ុន ត្រូវបានប្រឈមនឹងហានិភ័យហិរញ្ញវត្ថុដែលកើតឡើងពីប្រតិបត្តិការអាជីវកម្ម និងការប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុ។ គោលនយោបាយក្នុងការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដើម្បីធានាថា ក្រុមហ៊ុនមានធនធានគ្រប់គ្រាន់សម្រាប់ការអភិវឌ្ឍអាជីវកម្មរបស់ក្រុមហ៊ុន ខណៈពេលកំពុងគ្រប់គ្រងហានិភ័យឥណទាន ហានិភ័យហានិភ័យសាច់ប្រាក់ងាយស្រួល ហានិភ័យរូបិយប័ណ្ណ បរទេស និងហានិភ័យអត្រាការប្រាក់របស់ក្រុមហ៊ុន។ ក្រុមហ៊ុនធ្វើប្រតិបត្តិការតាមគោលនយោបាយ និងនីតិវិធីដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលដើម្បីធានាពីប្រសិទ្ធភាពលើដំណើរការគ្រប់គ្រងហានិភ័យ។

ផ្នែកសំខាន់ៗនៃហានិភ័យហិរញ្ញវត្ថុដែលក្រុមហ៊ុនបានប្រឈម និងគោលនយោបាយរបស់ខ្លួនទាក់ទងនឹងផ្នែកសំខាន់ៗនៃសកម្មភាពរតនាគារត្រូវបានកំណត់ដូចខាងក្រោម៖

### (ក). ហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាហានិភ័យនៃការខាតបង់ផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ប្រសិនបើអតិថិជន ឬសមភាគីនៃឧបករណ៍ហិរញ្ញវត្ថុខកខានមិនបានបំពេញកាតព្វកិច្ចតាមកិច្ចសន្យា។ វាជាគោលនយោបាយរបស់ក្រុមហ៊ុន ក្នុងការបញ្ចូលឧបករណ៍ហិរញ្ញវត្ថុជាមួយសមភាគីដែលទទួលបានឥណទាន។ ក្រុមហ៊ុនមិនរំពឹងថានឹងទទួលរងការខាត់បង់ឥណទានជាសារវន្តលើទ្រព្យសកម្មហិរញ្ញវត្ថុរបស់ខ្លួន ឬឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតនោះទេ។

ការផ្តោតសំខាន់ទៅលើហានិភ័យឥណទានកើតមាននៅពេលដែលការផ្លាស់ប្តូរកត្តាសេដ្ឋកិច្ច ឧស្សាហកម្ម និងភូមិសាស្ត្រជះឥទ្ធិពលដល់ក្រុមសមភាគីដែលមានហានិភ័យឥណទាន សរុបទាក់ទងនឹងហានិភ័យឥណទានសរុបរបស់ក្រុមហ៊ុន។ ប្រតិបត្តិការរបស់ក្រុមហ៊ុនត្រូវបានចូលរួមជាមួយសមភាគី ដែលគួរឱ្យកត់សម្គាល់ដោយកាត់បន្ថយការប្រមូលផ្តុំហានិភ័យឥណទាន។

កត្តាដែលបណ្តាលឱ្យក្រុមហ៊ុនអាចប្រឈមនឹងហានិភ័យឥណទានមានដូចខាងក្រោម៖

**គណនីពាណិជ្ជកម្មដែលត្រូវទទួល**
ក្រុមហ៊ុនបានអនុវត្តគំរូសាមញ្ញរបស់ CIFRS ៩ ក្នុងការទទួលស្គាល់ការខាតបង់ឥណទានដែលបានរំពឹងទុកពេញមួយជីវិតសម្រាប់គណនីពាណិជ្ជត្រូវទទួលទាំងអស់ ដោយសារធាតុទាំងនេះ មិនមានធាតុផ្សំហិរញ្ញប្បទានគួរឱ្យកត់សម្គាល់ឡើយ។

ក្នុងការវាស់ស្ទង់ការខាតបង់ឥណទានដែលបានរំពឹងទុក គណនីត្រូវទទួល ត្រូវបានវាយតម្លៃជាមូលដ្ឋានសមូហភាពនៅពេលដែលគណនីនោះមានលក្ខណៈហានិភ័យឥណទានរួមគ្នា។

អត្រានៃការខាតបង់ដែលបានរំពឹងទុក គឺផ្អែកទៅលើការខាតបង់ឥណទានប្រវត្តិសាស្ត្ររយៈពេល ៣ឆ្នាំកន្លងមក មុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ក៏ដូចជាការខាតបង់ឥណទានប្រវត្តិសាស្ត្រក្នុងអំឡុងការិយបរិច្ឆេទ។ អត្រាប្រវត្តិសាស្ត្រត្រូវបានកែតម្រូវ ដើម្បីឆ្លុះបញ្ចាំងពីកត្តាម៉ាក្រូសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន និងនាពេលខាងមុខ ដែលជះឥទ្ធិពលដល់សមត្ថភាពរបស់អតិថិជនក្នុងការទូទាត់ត្រឡប់វិញនូវសមតុល្យដែលនៅសល់។ ការប្រឈមនឹងហានិភ័យឥណទានរយៈពេលខ្លី ផលប៉ះពាល់នៃកត្តាម៉ាក្រូសេដ្ឋកិច្ច មិនត្រូវបានចាត់ទុកជាកត្តាគួរឱ្យកត់សម្គាល់នៅក្នុងការិយបរិច្ឆេទនៃរបាយការណ៍នោះទេ។

គណនីពាណិជ្ជត្រូវទទួល ត្រូវបានលុបចោល (ឧទាហរណ៍៖ បានឈប់ទទួលស្គាល់) នៅពេលដែលគ្មានការរំពឹងទុកដ៏សមហេតុផលណាមួយដែលអាចប្រមូលមកវិញបាន។ ការខកខានក្នុងការទូទាត់ក្នុងរយៈពេល ១៨០ ថ្ងៃ គិតចាប់ពីថ្ងៃចេញវិក័យបត្រ និងការខកខានមិនបានចូលរួមជាមួយក្រុមហ៊ុនទៅលើការទូទាត់ជំនួសក្នុងចំណោមមធ្យោបាយផ្សេងទៀត ត្រូវបានចាត់ទុកថាជាសូចនាករដែលមិនមានការរំពឹងទុកសមហេតុផល។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងឆ្នាំ២០២១ គណៈគ្រប់គ្រងមានទស្សនៈថាគណនីពាណិជ្ជត្រូវទទួល ត្រូវបានវាយតម្លៃថាមានហានិភ័យឥណទានទាបដែលអាចកំណត់ថាឱនភាពនៃតម្លៃ ត្រូវបានចាត់ទុកជាអសារវន្ត។

**សាច់ប្រាក់ និងសាច់ប្រាក់សមមូល**
ហានិភ័យឥណទានទៅលើសាច់ប្រាក់ និងសាច់ប្រាក់សមមូល និងប្រាក់តម្កល់រយៈពេលខ្លី ត្រូវបានចាត់ទុកថាមានហានិភ័យតិចតួច ដោយសារតែសមភាគី គឺជាធនាគារក្នុងស្រុកដែលមានកេរ្តិ៍ឈ្មោះ។

### (ខ). ហានិភ័យសាច់ប្រាក់ងាយស្រួល
ហានិភ័យសាច់ប្រាក់ងាយស្រួល គឺជាហានិភ័យដែលអង្គភាពប្រឈមនឹងការលំបាកក្នុងការប្រមូលថវិកា ដើម្បីបំពេញតាមកិច្ចព្រមព្រៀងដែលទាក់ទងនឹងឧបករណ៍ហិរញ្ញវត្ថុ។ ហានិភ័យសាច់ប្រាក់ងាយស្រួល អាចជាលទ្ធផលពីការអសមត្ថភាពរបស់ក្រុមហ៊ុនក្នុងលក់ចេញនូវទ្រព្យសកម្មហិរញ្ញវត្ថុឱ្យបានលឿនក្នុងតម្លៃដែលកៀកនឹងតម្លៃសមស្របរបស់វាបំផុត។ គោលនយោបាយរបស់ក្រុមហ៊ុន គឺដើម្បីត្រួតពិនិត្យជាប្រចាំនូវតម្រូវការសាច់ប្រាក់បច្ចុប្បន្ន និងសាច់ប្រាក់ងាយស្រួលដែលបានរំពឹងទុក ដើម្បីធានាឱ្យបានថា ក្រុមហ៊ុនអាចរក្សាសាច់ប្រាក់បម្រុងឱ្យបានគ្រប់គ្រាន់ដើម្បីបំពេញនូវតម្រូវការសាច់ប្រាក់រយៈពេលខ្លី និងរយៈពេលវែងរបស់ខ្លួនបាន។

ហានិភ័យសាច់ប្រាក់ងាយស្រួល ជាទូទៅកើតឡើងពីប្រាក់កម្ចី បំណុលភតិសន្យា ឥណទានវិបារូបន៍ គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ។

***ការវិភាគលើឧបករណ៍ហិរញ្ញវត្ថុតាមកាលកំណត់នៃកិច្ចសន្យា***

តារាងខាងក្រោមបង្ហាញនូវការវិភាគអំពី បំណុលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនតាមរយៈក្រុមនៃបំណុលដែលដល់អាយុកាលផុតកំណត់។ សមតុល្យជាសមតុល្យដុល និងមិនបានធ្វើអប្បហារ និងរួមបញ្ចូលទាំងការទូទាត់ការប្រាក់តាមកិច្ចសន្យា និងមិនរាប់បញ្ចូលនូវផលប៉ះពាល់នៃកិច្ចព្រមព្រៀងជាក់ស្តែង។

| | បច្ចុប្បន្ន ដុល្លារអាមេរិក | ច្រើនជាង ៣០ ថ្ងៃ ដុល្លារអាមេរិក | ច្រើនជាង ៩០ ថ្ងៃ ដុល្លារអាមេរិក | ច្រើនជាង ១ឆ្នាំ ដុល្លារអាមេរិក | លើសពី ៥ឆ្នាំ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|---|
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | | | | | |
| **បំណុលហិរញ្ញវត្ថុ** | | | | | | |
| ប្រាក់កម្ចី | **២៣.៥៣០** | **៣៧៧.០៤៧** | **៤៩៣.២០៦** | **៥៥៩.៨៦៣** | - | **១.៤៩៣.៦៤៦** |
| បំណុលភតិសន្យា* | - | - | - | - | - | - |
| ឥណទានវិបារូបន៍ | **២.៤១០.៩៨៤** | - | - | - | - | **២.៤១០.៩៨៤** |
| គណនីពាណិជ្ជ និងបំណុលផ្សេងៗ** | **១.០២៣.៥២៥** | - | - | - | - | **១.០២៣.៥២៥** |
| **បំណុលហិរញ្ញវត្ថុសរុប** | **៣.៤៥៨.០៣៩** | **៣៧៧.០៤៧** | **៤៩៣.២០៦** | **៥៥៩.៨៦៣** | - | **៤.៩២៨.១៥៥** |
| **សមមូលពាន់រៀល (កំណត់សម្គាល់ ៤.២)** | **១៤.២៣៦.៧៨៧** | **១.៥៥២.៣០២** | **២.០៣០.៥២៩** | **២.៤៦៩.៦៣៦** | - | **២០.២៨៩.២១៤** |

**មុនដកបន្ទុកហិរញ្ញវត្ថុ*
***មិនរួមបញ្ចូលពន្ធដែលត្រូវបង់ផ្សេងៗ និងបុរេប្រទានពីអតិថិជន*

| | បច្ចុប្បន្ន ដុល្លារអាមេរិក | ច្រើនជាង ៣០ ថ្ងៃ ដុល្លារអាមេរិក | ច្រើនជាង ៩០ ថ្ងៃ ដុល្លារអាមេរិក | ច្រើនជាង ១ឆ្នាំ ដុល្លារអាមេរិក | លើសពី ៥ឆ្នាំ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|---|
| នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | | | | | |
| បំណុលហិរញ្ញវត្ថុ | | | | | | |
| ប្រាក់កម្ចី | ៣៦៧.៧៣០ | ១.៧៤៣.៥២០ | ៤០៧.៧៦១ | ៨១១.៣២០ | - | ៣.៣៣០.៣៣១ |
| បំណុលភតិសន្យា* | ៥.៦០០ | ១៦.៨០០ | ២៨.០០០ | - | - | ៥០.៤០០ |
| ឥណទានវិបារូបន៍ | ១.៨៧១.១១២ | - | - | - | - | ១.៨៧១.១១២ |
| គណនីពាណិជ្ជ និងបំណុលផ្សេងៗ** | ១.៥៥៥.២៩២ | - | - | - | - | ១.៥៥៥.២៩២ |
| បំណុលហិរញ្ញវត្ថុសរុប | ៣.៧៩៩.៧៣៤ | ១.៧៦០.៣២០ | ៤៣៥.៧៦១ | ៨១១.៣២០ | - | ៦.៨០៧.១៣៥ |
| សមមូលពាន់រៀល (កំណត់សម្គាល់ ៤.២) | ១៥.៤៨០.១១៦ | ៧.១៧១.៥៤៤ | ១.៧៧៥.២៩០ | ៣.៣០៥.៣១៨ | - | ២៧.៧៣២.២៦៨ |

**មុនដកបន្ទុកហិរញ្ញប្បទាន*
***មិនរួមបញ្ចូលបំណុលពន្ធផ្សេងទៀត និងបុរេប្រទានពីអតិថិជន*

## (គ). ហានិភ័យរូបិយប័ណ្ណបរទេស

ហានិភ័យពីការប្តូររូបិយប័ណ្ណបរទេសរបស់ក្រុមហ៊ុនកើតឡើងពីប្រតិបត្តិការប្តូររូបិយប័ណ្ណបរទេស។

ក្នុងអំឡុងការិយបរិច្ឆេទ ការប្រឈមរបស់ក្រុមហ៊ុនទៅនឹងហានិភ័យនេះ គឺមានតិចតួចបំផុតដោយសារប្រតិបត្តិការភាគច្រើនរបស់ក្រុមហ៊ុនត្រូវបានធ្វើឡើងជាប្រាក់ដុល្លារអាមេរិក។

## (ឃ). ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់ គឺជាហានិភ័យដែលតម្លៃសមស្របនៃលំហូរសាច់ប្រាក់នាពេលអនាគតនៃឧបករណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុននឹងប្រែប្រួលដោយសារតែការផ្លាស់ប្តូរទីផ្សារអត្រាការប្រាក់។

ក្រុមហ៊ុនមិនប្រឈមនឹងហានិភ័យអត្រាការប្រាក់នោះទេ ដោយសារតែក្រុមហ៊ុនមិនមានអត្រាការប្រាក់អណ្តែតលើទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុឡើយ។

## ៣៣. ការគ្រប់គ្រងដើមទុន

គោលបំណងចម្បងនៃការគ្រប់គ្រងដើមទុនរបស់ក្រុមហ៊ុន ដើម្បីធានាថារក្សាបាននូវអនុបាតដើមទុនគ្រប់គ្រាន់ ដើម្បីគាំទ្រដល់អាជីវកម្មរបស់ក្រុមហ៊ុន និងបង្កើនតម្លៃជូនភាគហ៊ុនិកជាអតិបរមា។

ក្រុមហ៊ុន គ្រប់គ្រងរចនាសម្ព័ន្ធដើមទុនរបស់ខ្លួន និងធ្វើការកែសម្រួលនៃការផ្លាស់ប្តូរនៅក្នុងលក្ខខណ្ឌសេដ្ឋកិច្ច។ ដើម្បីរក្សា ឬកែសម្រួលរចនាសម្ព័ន្ធដើមទុន ហើយក្រុមហ៊ុន អាចកែសម្រួលភាគលាភដែលត្រូវបង់ជូនភាគហ៊ុនិក និងអនុម័តដើមទុនថ្មី។ ពុំមានការផ្លាស់ប្តូរណាមួយត្រូវបានធ្វើឡើងក្នុងគោលបំណង គោលនយោបាយ ឬដំណើរការនានាក្នុងការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ នេះទេ។

## ៣៤. ព្រឹត្តិការណ៍ក្រោយការិយបរិច្ឆេទរបាយការណ៍

ពុំមានការកែតម្រូវ ឬព្រឹត្តិការណ៍មិនបានកែតម្រូវសំខាន់ៗ ដែលបានកើតឡើងនៅចន្លោះចុងការិយបរិច្ឆេទនៃរបាយការណ៍ និងកាលបរិច្ឆេទនៃសេចក្តីអនុម័តឱ្យចេញផ្សាយរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ដែលតម្រូវឱ្យមានការកែតម្រូវ ឬលាតត្រដាងត្រូវធ្វើឡើងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះឡើយ។

## ៣៥. ការអនុម័តទៅលើរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ត្រូវបានអនុម័តឱ្យចេញផ្សាយដោយក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុននៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣។